ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

អប្សរសិក្សា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនឥតពូមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ កៅ-សុីម, អ្នកគ្រូតគ្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

បញ្ជីរឿង

ផ្នែកអក្សរសាស្ត្រ		ទំព័រ
លោកអាចារ្យ កៅ-សុីម	វិសុទ្ធម្មទេសនា-កណ្ឌទី ១៥	១
ស៊ៅកុអាចារ្យ-ឈឹម-សុំ	" " ១៦	១៤
ព្រះមហា សៅម-ឡុច	" " ១៧	២៩
លោក សុង់-ហង់រីហ្វាប	អំពីដំណើរជីវិតនៃសត្វល្អិតៗ	៣៦
អ្នកនាងញ៉ាំបេស្តាវិនិច្ឆ័យ កែវ-ហង្ស	ប្រជុំចំណូល (គាថាភាសា)	៤៨
អ្នកនាងកញ្ញាំវង្សាសារពេន្ទ (ខង់)	លោកនេយ្យ ភាសាភាសា (តមក)	៧៩
ឃុនឥតពូមន្ត្រី ញ៉ុក-ថែម	ពង្សាវតារប្រទេសចិន	១០៥
ផ្នែកសាសនា		
ដំណឹងអំពីក្រសួងធម្មការ	បញ្ជីរាយនាមមន្ត្រីសង្ឃនិងចៅអធិការ ដែលទើបតាំងឡើងថ្មី	១២៤
" "	បុណ្យបង្ហុះសីមានៅវត្តនាគ	១២៩
ឃុនឥតពូមន្ត្រី ញ៉ុក-ថែម	ប្រវត្តិសង្ខេបបច្ចុមសង្គាយនា(តមកទំនិងបន្ត)	១៣៣
" "	ប្រវត្តិព្រះមហាកច្ចាយនត្ថេរ	១៣៦
លោកអាចារ្យ ឈឹម-សុំ	ពុទ្ធឃោសប្បវត្តិ	១៤៣

ឆ្នាំទី ១៤ លេខ ១-២-៣ ប្រចាំខែឃ្លាំងវិយោរ- ហៅថ្ងៃយោរ- ១៩៤៣ ។

Kampuchaea Suriya
1943
n°. 2 à 12

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀមអក្សរសោភ្ស្តែ ចេះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកអក្សរសោភ្ស្តែ ឃុនឥន្ទមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា លោកអាចារ្យ កៅ-សុំម អ្នកគ្រូតគ្រា
សិស្សនៅសណ្ឋាគារលីដាន់ខ្ពស់

ECOLE FRANÇAISE D'EXTRÊME-ORIENT BIBLIOTHÈQUE

បញ្ជីរឿង

ផ្នែកអក្សរសោភ្ស្តែ		ទំព័រ
លោកអាចារ្យ កៅ-សុំម	វិវុឌ្ឍធម្មទេសនា ភាណ្ឌទី ១៩	១
ស៊ៅពុអាចារ្យ-ឈឹម-សុំ	" " ១៦	១៤
ព្រះមហា សោម-ឡុប	" " ១៧	២៩
លោក សង់-ហង់រីហ្សាប	អំពីដំណើរដីវិតនៃសត្វល្អិតខ្លះ	៣៦
អ្នកឧកញ៉ាចេស្តាវិន័យ កែវ-ហង្ស	ប្រដៅចិត្ត (ភាសាភាឡ)	៥៨
អ្នកឧកញ៉ាវង្សាសារពេទ្យ (ឧងរ៉ែ	លោកនេប្បៅ ភាសាភាឡ (ត្រមក)	៧៩
ឃុនឥន្ទមន្ត្រី ញ៉ុក-ថែម	ពង្សាវតារប្រទេសចិន	១០៥
ផ្នែកសាសនា		
ដំណឹងអំពីក្រសួងធម្មការ	បញ្ជីរាយនាមមន្ត្រីសង្ឃនិងចៅអធិការ ដែលទើបតាំងឡើងថ្មី	១២៤
" "	បុណ្យបញ្ចុះសីមានៅវត្តនាគ	១២៩
ឃុនឥន្ទមន្ត្រី ញ៉ុក-ថែម	ប្រវត្តិសង្ខេបបញ្ចូមសង្គាយនា(ត្រមកនិងចប់)	១៣៣
" "	ប្រវត្តិព្រះមហាកច្ចាយនត្ថេរ	១៣៦
លោកអាចារ្យ ឈឹម-សុំ	ពុទ្ធឃោសប្បវត្តិ	១៤៣

ឆ្នាំទី ១៤ លេខ ១-២-៣ ប្រចាំខែឃុំងអ៊ីយោ- ហ្ស្រ៊ីយោ- ម៉ាស្ស ១៩៤៣ ។

KAMBUJASURIYĀ

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Khoun Nibandhamantri Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Kao-Sim, surveillant général de l'Ecole Supérieur de Pāli.

TABLE DES MATIÈRES

Partie littéraire

		Pages
Vénérable Kao-Sim.....	Conférences-Radio : "Mittakathā"..	1
» Chim-Soum....	"Dhammādhammakathā".....	14
» Mahā Som-Loch	"Vipāttikathā".....	29
Jean-Henri Fabre.....	Vie des insectes.....	36
Oknha Chesdavinichay Kéo-Hang.....	Prâdaochet (poème).....	58
Feu l'Oknha Vongsâsârpejna Nong....	Lokaneyya, traduit en vers (suite)...	79
Khoun Nibandhamantri Nhok-Thèm...	Histoire de Chine.....	105

Partie religieuse

Informations du Ministère des Cultes.....	Liste des nomminations de nouveaux Chao-Atthikar.....	124
» «....	Fêtes religieuses de divers pagodes..	129
Khoun Nibandhamantri Nhok-Thèm....	Conciles bouddhiques antiques (suite et fin).....	133
» «....	Vie de Mahākaccāyana (un des grands disciples du Bouddha).....	117
Vénérable Chhim-Soum...	Vie de Buddhaghosa.....	143

15e année — Nos 1-2-3. Janvier-Février-Mars-1943
Abonnement; un an 10$00.

KAMPUCHEA SUBHA

ទីស្នាក់ការ ក្រសួងធម្មការ ព្រះពុទ្ធសាសនា

ទិវាពុទ្ធបូជា ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៩

លោកគ្រូអាចារ្យ កៅ សុំម

អ្នកគ្រូតន្ត្រីសិស្សសោភាមើជាន់ខ្ពស់

សំដែង កាលពីថ្ងៃសុក្រ ១៤ រោចខែដើមស្នួនឆ្នាំមមីចត្វាស័កពុទ្ធសាសនា ២៤៨៥

(១២ ឧសភា ១៩៤២)

ឧបត្ថម្ភកថា

ខ្ញុំសូមនមស្សការ ថ្វាយបង្គំព្រះរត្នត្រ័យ គឺព្រះពុទ្ធ ព្រះធម៌

អស់លោកសប្បុរសទាំងឡាយ ដែលប្រជុំស្តាប់ហើយនឹងប្រតិបត្តិឲ្យ
បានសមគួរតាមភូមិខ្លួនផង នឹងបានសម្រេចប្រយោជន៍សេចក្តីសុខចំរើន
ក្នុងលោកនេះ នឹងលោកខាងមុខ ដោយផលានិសង្សដែលបានប្រព្រឹត្ត
តែមត្រូវនេះ ។

មុននឹងសំដែងអំពីបទមិត្តកថានេះ សូមនាំយកពុទ្ធគាថាដែល
សំដែងអំពីបុគ្គលទៅខ្លាយអំពីគ្នា ๔ យ៉ាងមកឆ្លើយជាឧទ្ទេសហេតុសិន ដោយ
ពាក្យព្រះបាលីថា:

ឥមានិ ខោ តេ ភិក្ខវេ ចត្តារិ សប្បុរិសវិទ្ធកានិ

សេចក្តីថា: ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលនៅខ្លាយហើយសែន
ខ្លាយអំពីគ្នាមាន ๔ យ៉ាង:

๑- អាកាសនឹងផែនដី

๒- ត្រីយសមុទ្រខាងអាយនឹងត្រីយសមុទ្រខាងទាយ

๓- ទិសបូព៌ាខាងកើតនឹងទិសបស្ចិមខាងលិច

๔- ធម៌បុគ្គលសប្បុរសនឹងធម៌បុគ្គលអសប្បុរស ។

បណ្តាបុគ្គលទាំង ๔ យ៉ាង ដែលបានរៀបរាប់មកនេះ ជាបុគ្គលនៅ
ខ្លាយអំពីគ្នា ពុំដែលបានជួបប្រទះគ្នាដល់ម្តងសោះឡើយ ត្រូវទាំងពុំ
ដឹងសេចក្តីសុខទុក្ខ ឬដំណឹងធុរៈកិច្ចការគ្នាទៅវិញទៅមក ទំនងខ្លួនអំណារ
សេចក្តីរឹងរឿងអ្វីមួយផងគ្នាក៏គ្មានដែរ, ដូចពាក្យសុភាសិតដែលខ្ពស់ស្រឡះ

ជុតអំពីផែនដីតតមានចំណង់បង្អុរភ្លៀងឲ្យធ្លាក់ចុះមកលើផែនដី ហើយហូរ
ច្រោះបំផ្លាញផែនដីឲ្យដាច់ធ្លាក់ពុះទៅក្នុងមហាសមុទ្រ ឬខេ្មស្ងួន-ព្រៃត
នោះឡើយ ឯផែនដីក៏មិនអាចទ្រាំស្រែកប្តឹងទៅអាកាសថា: "នែ អា-
កាស! ឯងកុំបង្អុរភ្លៀងឲ្យធ្លាក់ចុះមកលើអញ ហើយហូរច្រោះនាំឲ្យអញ
ធ្លុះទៅក្នុងមហាសមុទ្រ ឬស្រែកប្តឹងថា អញរងាំណាស់ ត្រជាក់
ណាស់ ឯខេ្មស-ស្ងួន-ព្រៃត, ក្តៅជាតិ លាតស្លុងដាដែម ដែលអាស្រ័យនឹង
អញសោត ក៏លិចលង់ស្ងាប់អស់ហើយ ឯងឈប់កុំភ្លៀងមកដួច្នេះពុំបាន
ដែរ"; ពុំនោះសោត កាលបើផែនដីខ្លួលតំណៅព្រៃអាត្មាក្តៅបែកក្រ-
ហែងក្នុងរដូវខែប្រាំង ក៏មិនអាចអង្វរតអោកាស សូមឲ្យភ្លៀងធ្លាក់មក
ជួយការពារកំណៅព្រៃអាត្មាបានឡើយ យ៉ាងនេះបានឈ្មោះថាអាកាស
ធាតុផែនដីច្រើស្រ័យយកគ្នាជាមិត្តសំឡាញ់ឲ្យសមតាមសេចក្តីប្រាថ្នារបស់
ខ្លួនពុំកើត ។

ដែលថាគ្រឿយសមុទ្រខាងអាយនឹងគ្រឿយសមុទ្រខាងនាយ ជា
របស់នៅឆ្ងាយអំពីគ្នានោះ ក៏ដូចអាកាសធាតុផែនដីដែរ គឺថាធាតុប្រាប់
ដំណឹងទៅវិញទៅមករកគ្នាថា "គ្រឿយសមុទ្រខាងនេះ មានភ្នំធំតួច
ខ្ពស់ភប ដើមឈើលតាវល្លិធំតួចវែងខ្លីមានពណ៌សណ្ឋានខៃផ្សំគ្នាយ
យ៉ាងនេះ យ៉ាងនោះ ឬត្រីតូចធំសម្បុរនោះកេនអោះនេះប៉ុណ្ណោះ។ មានឯធំ

តួចដុះពេលជាដួរតាមមាត់សមុទ្រប៉ុណ្ណេះៗ រលកបក់បោកមកកន្ត ១ ថ្ងៃ ប៉ុណ្ណេះៗ" តុំបានន័យកន្ត្រាជាមិត្តសំឡាញ់ជាទីពឹងពាក់ក៏មិនកើត ។

ដែលថាទំនុបូពិខាងកើត ទីណាទំនុបូស្ថិមខាងលិច ជារបស់ទៅឆ្ងាយពីគ្នានោះ ក៏មិនជាអ្នកជានាជួយការអាថ្កុបាប់ដំណាំដ៏ចំពោះហេតុអ្វីមួយ ដែលកើតមានឡើងលើគ្នាបានដល់ខ្លួនឡើយ សូម្បីតែព្រះអាទិត្យ ព្រះចន្ទដែលរះឡើងអំពីទំនុបូពី។ ក៏តុំដែលថ្កុបាប់ទៅទំនុបូស្ថិមថា: "ព្រះអាទិត្យ ព្រះចន្ទរះឡើងហើយ ពីរសប៉ុណ្ណេះៗ ភ្លៅយ៉ាងនេះ ត្រជាក់យ៉ាងនេះ មានទំហំរំដីមួលប៉ុណ្ណេះៗ ខុកណាជាព្រះអាទិត្យព្រះចន្ទដើរទៅដល់ទំនុបូខាងលិចហើយ ទំនុបូស្ថិមក៏មិនដែលថ្កុបាប់ត្រឡប់ទៅទំនុបូខាងកើតថា ព្រះអាទិត្យព្រះចន្ទមកដល់តន្លែងខ្ញុំតែលប៉ុណ្ណេះហើយភ្លៅយ៉ាងនេះ ត្រជាក់យ៉ាងនេះ មានទំហំរំដីមួលប៉ុណ្ណេះៗ លិចបាត់ទៅតែលប៉ុណ្ណេះដែរ" ទីឆ្ងល់ស្រស់ស្រាយយកជាមិត្តសំឡាញ់ឲ្យជួយសម្រួចតិចណាមួយតុំបានឡើយ ។

ដែលថា ធម៌របស់សប្បុរស ខំឆ្ងល់ធម៌របស់អសប្បុរស ជាធម្មតាយ មិនគ្នានោះ គួរដែរថា: លោកដែលជាសប្បុរសអ្នកខាងថ្កុបាប្ញ ជាន ប្រកបដោយនូវចិត្តដ៏ ធ ឃ្លាំង មានសទ្ធាកន្ត្រះដួតកម្ចាត់ទីឆ្ងល់របស់កម្ម ដើម្បីហេតុដែលគួរះដួតាដែរ លោកមិនបានរះដួអំពើអាក្រក់ដោយ កាយ-វាចា-ចិត្តដែលជាអំពើនាំឲ្យមានទោសទុក្ខនានាលោកនេះ ខំឆ្ងល់បរលោក

ខាងមុខគឺនៃដែលចូលទៅសេពគប់សមាគមឲ្យច្រឡូកច្រឡំដោយពុំជាន់
អសប្បុរសនោះឡើយ ព្រោះថា ជនជាអសប្បុរសតែងប្រព្រឹត្តធ្វើអំពើ
អាក្រក់ដ៏មោះមុត លោកពុកដូចជាពស់វែកដែលមានពិសដ៏ខ្លាំងក្លា អាច
ចឹកបុគ្គលដទៃឥតត្រាប្រណីថានេះមនុស្សឬសត្វផងខាំងពួនឡើយ ក៏ឥតធ្វើ
សេចក្តីភ័យឲ្យកើតឡើង ដរាបដល់អន្តរាយដល់ជីវិតភ្លុំខាន ។

ហេតុនេះឯង ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងថា : "ច ន
ដ្ឋេ សំសគ្គំ ភ ជ សាធុ សមាភរេ" បុគ្គលត្រូវតែលះលែងកុំសេព
គប់សមាគមឲ្យច្រឡូកច្រឡំ ទើបពុំជាន់ជាអសប្បុរសនោះឡើយ ត្រូវចូល
ទៅសេពគប់សមាគមនឹងជនជាសប្បុរស យកជាមិត្តសំឡាញ់ ប្រកបខ្ជាប់
ប្រយោជន៍របស់ខ្លួនចុះ ទើបនាំខ្លួនឲ្យកើតសេចក្តីសុខ-ចំរើនគ្រប់ប្រការ ។

បើតាមសេចក្តីពិតនោះ ត្រូវតែសេពគប់នឹងមនុស្សដែលភ្ញាក់មិន
ហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេង ។ ដែលលោកអ្នកប្រាជ្ញតាំងឲ្យតែងកាន់
តាមសារសើរ គឺមនុស្សណាដែលប្រព្រឹត្តធ្វើអំពើដ៏លាមកអាក្រក់
ហើយមានគំនិតគិតឃើញភ័យ ដែលកើតមកអំពីសេចក្តីទុក្ខគាល់ក្រែល-
ឆាក, ទឹកដល់ផលរបស់សេចក្តីព្យាយាមខំប្រឹងនឹងប្រែនឹកដល់អាជីវៈ
របស់សេដ្ឋីគហបតី[1] ទឹកដល់អាហារដែលស្វែងរកមកចិញ្ចឹមជីវិត ទើប

---

១ ត្រូវការតែប្រាថ្នាភោគសម្បត្តិ, ចូលចិត្តរ្យើរិះខាងផ្លូវចញ្ចើម, តាំនចិត្តខ្ជាប់ខួនចំពោះទៅ
រកសិល្បសាស្ត្រ, ចូលចិត្តប្រកាន់មាំធ្វើការងារ, មានការងារធ្វើហើលស្រែចេរីចំនួត ។

តតគ្រាមដែកឬសង្ឃដែមខុន កើតទៅជាចំពោះមុខខុកជាផលប្រយោជន៍ត្រូវតាំងត្រឹមរំដែលគុណបុត្តបុរស ដែលលោកបានខំទុកបំរុងរក្សាជីវិតនឹងផ្សែត្រកូលយ៉ាងណា មិនត្រូវសេពគប់នឹងមនុស្សឆ្កួលប្រអូសដែលមានសន្តានចិត្តដ៏ហោគាបទេឬយ ត្រូវសេពគប់នឹងមនុស្សអ្នកមានប្បាយាមជាគូកនគ្នា នឹងត្រូវធ្វើចិត្តឲ្យកើតសេចក្តីសប្បាយជាទំរាំខ្លះ ទើបឈ្មោះហៅជាមនុស្សមានតំនិតជាសប្បុរស អ្នកធ្លាប់លោកមិនដែលសរសើរមនុស្សដ៏ក្រៀវក្រាំសំនងឡើយ ។

មិត្តកថា គួរសាធុជនទំនើសេចក្តីសាមគ្គីព្រមព្រៀងគ្នា កម់អានយកគ្នាជាមិត្តមេត្រី ដើម្បីចៀសចាកនឹងកំរោលអាក្រក់គ្រប់យ៉ាង ខុកជានៅស្រុកទេសនាយអំពីគ្នា ផ្សែងដោយជាតិនៅត្រកូល ទីលំនៅរបរកេស៊ុកដោយ ទោះមិនដែលបានជួយធ្លុះកិច្ចការគ្នាក៏ដោយ តែលាដែលរាប់បានទៅជាមួយគ្នា ឬបានជួបប្រទះគ្នាកន្លងមកណា ត្រូវធ្វើសេចក្តីល្អឲ្យប្រាកដ សមភាពជាមនុស្សជាតិមិនត្រូវសំដែងនិន្ទាប្តូរអំណាចគោនកាចដល់គ្នាឡើយ ។

គួរស្គាល់ឲ្យជាក់ច្បាស់ ចំពោះកំរោលរបស់ដែលមិនមែនជាមិត្តសំឡាញ់ ព្រោះមនុស្សមិនមែនជាមិត្តរមែងធ្វើសេចក្តីភ័យឲ្យកើតឡើងដល់ប្រុបុរសស្ទើរកន្លងពីតពាលោកនេះ ។ ឯកំរោលនោះគួរស្គាល់ថាបុគ្គលជាសត្រូវនឹងគ្នា កាលបើត្រឡប់ឃើញគ្នាកាលណា ក៏ចងចិញ្ចើម

បើកន្លែងសំឡក់សំឡឹងប្រឹងដំរឿងមុនធ្វើក្រញ៉ូវ មិនធ្លាស់ចក្តីត្រេកអរ
សារនឹងគ្នា មិនមើលឱ្យចំមុខប្រទះប៉ះក្នែកគ្នាឡើយ តែងដំរឿង
ឫកពាខឹងឃោរឃៅចំពោះគ្នាជាដរាប នេះជាដំណើរកិរិយារបស់បុគ្គល
មិនមែនជាមិត្ត ។ ដូចគ្នានឹងសត្វសុនខ តែងម្នាសត្វសុនខ តែយើញ
គ្នាវាហើយ តាំងដែលមានសេចក្តីសោមនស្សត្រេកអរពប់រកគ្នាវាខ
តែងសំដែងអាការកំហឹងប្រឹងបញ្ចេញក្បេញបន្លាញចង្កួមដម្រើងរំខំអំណាច
របស់វា នេះជាកិរិយារបស់សត្វឆ្កែ ។

ក៏កន្លងមិត្តហាយនៈ ការណ៍ដែលនាំឱ្យបែកមិត្តពីគ្នា នាំមិនឱ្យស្រ-
ឡាញ់ពប់រកគ្នានោះ លោកសំដែងថា :

សទ្ធាកិត្តិលាភសំសគ្គា អសមោសរណេន ច
ឯតេ ន មិត្តា ជីវន្តិ អភាវេ យាចនេន ច...

មិត្តសំឡាញ់ណាដែលរកវឿងធ្លុះធ្លៀលគ្នាទៅវិញទៅមកឥតអត់ធ្មត់
អធ្មស្រើយហួសប្រមាណ ១, មិត្តសំឡាញ់ណាដែលឃ្លាតឃ្លាបែកចាក
គ្នា ជាយូរហើរមិនបានជួបមុខគ្នា ១, មិត្តសំឡាញ់ណាដែលសូមរបស់អ្វី
ញឹកញយ កន្លងកាលដែលមិនគួរសូម ១, ហេតុទាំង ៣ យ៉ាងនេះកើតឡើង
ជាញឹកញយ មនុស្សទាំងឡាយតែងបែកចាក់ចាកគ្នា មិនបានជាមិត្ត
សំឡាញ់តយូរអង្វែងឡើយ ។ ហេតុនេះមនុស្សដែលបានយកគ្នាជាសម្ភន្ធ-
មិត្តមេត្រីហើយ គួរតែបង្ការចៀសវាងនូវហេតុដែលនាំឱ្យជាទំនាស់បែកចាក់មិត្ត

នោះចេញ ហើយត្រូវប្រព្រឹត្តតាន់ចរិយាការចងសម្ពន្ធមិត្តឲ្យបានយូរអង្វែងលែងបែកបាក់គ្នានោះៗ ទៅតាមលំនាំនៃពុទ្ធភាសិតថា:

ឥស្សា ឃោតិ ភ្លុណំ ភយេ ន ច ភយេ ចិរចិរំ
តាសេន យាចំ យាចេយ្យុំ ឯវំ មិត្តា ន ជីយ្យរេ ។

សេចក្តីថា មនុស្សដែលបានចងគ្នាជាមិត្តភក្តិចាន់ចិត្តស្រឡាញ់ពប់ភេគ្នាដោយមេត្រីហើយ មិនគួរតែឃ្លាតឆ្ងាយពីគ្នាឡើយ ឃ្លាតឆ្ងាយសឹមទៅម្តង ពាក្យចំនៀមថា «ស្រឡាញ់គុំទៅញឹកៗ កាលណាលើកសឹមទៅម្តងៗ»; មែនពិត តែថាមិនគួរចាំលាគ្នាឲ្យឃ្លាតឃ្លាឆ្ងាយពេកដែរ តោងតែឃ្លាតឆ្ងាយទៅមកគ្នាម្តងទើបគួរ បើសូមរបស់អ្វីដែលគួរសូម ត្រូវសូមគ្នាតាមកាលដែលគួរសូម យ៉ាងនេះបានឈ្មោះថា សម្ពន្ធមិត្តចងចិត្តមេត្រីល្អ ទើបមិនបែកបាក់គ្នាឡើយ ។

មួយទៀត, ការដែលសង្កេតកម្មលក្ខណៈរបស់មិត្តសំឡាញ់ឲ្យឃើញជាក់ច្បាស់ រួចសឹមសេពគប់ស្និទ្ធស្នាលយកជាគ្រឿងនោះ បានដោយកម្រពេកណាស់ មិនងាយនឹងស្គាល់បាន តែលោកបានពោលទុកថា:

អភិតោ បដិសោនោ ច យោ ច សុខេ ច ឯយោជតោ
ឯតេន ទាយវិទ្ធោ សោ ន្តិំ មិត្តេសុ គច្ឆតិ ។

មិត្តសំឡាញ់ណាហាមឃាត់គ្នាក្នុងកម្មមិនជាប្រយោជន៍ មិត្តសំឡាញ់ណាដឹកនាំគ្នាឲ្យប្រកបក្នុងកម្មជាប្រយោជន៍ មិត្តសំឡាញ់ណាមិន

លះបង់ចោលគ្នាក្នុងគ្រាដែលមានវិបត្តិ អាចជាគាជួយជ្រោងគ្នាឲ្យបានដំអល់នៅកងហានៈយសសក្តិស្មើមុខគ្នាដូចដើម មិត្តសំឡាញ់បែបនោះឯង បុគ្គលត្រូវយកធ្វើជាមិត្តសំឡាញ់ចុះ ដែលសោកអ្នកថ្កុំថ្កំណត់ថាជាមហាមិត្តដ៏ប្រសើរ ។

ជនណាដែលមិនមែនជាញាតិសាច់សាលោហិតរបស់ខ្លួនទេ តែគេបានប្រកបប្រយោជន៍ដ៏ល្អចំពោះខ្លួន គេបានរួបរួមសេចក្តីសុខទុក្ខជាមួយនឹងខ្លួន ជននោះឈ្មោះថាជាមិត្តទុកស្មើដោយញាតិសាច់សាលោហិតដៅពង្សរបស់ខ្លួនពិត, មិត្តណាមិនមានសេចក្តីឫស្សាច្រណែនគ្នាទេ គេចេះបីបាច់ថែរក្សាខ្លួនល្អ មិត្តនោះលោកឲ្យឈ្មោះថា ជាឪពុកម្តាយរបស់ខ្លួនពិត, ស្ត្រីណាជាមិត្តស្នេហាក្នុងផ្ទះអាចរំលត់សេចក្តីទុក្ខកង្វល់បាន ស្ត្រីនោះលោកឲ្យឈ្មោះថាកវយាសុខសួស្តី ។

កវយាកាចមានចិត្តប្រទុស្តក្សត់ចិត្តស្វាមីរបស់ខ្លួនក្តី មិត្តសំឡាញ់កាចមានចិត្តប្រទុស្តមិត្តផងគ្នាក្តី ខ្ញុំធំជាធំម្ចាស់ក្តី បុគ្គលជាសម្បុរសត្រូវចៀសវាងវៀរលែងឲ្យស្រឡះ កុំរៀសេពគប់យកជាគ្នា ទើបមានទុក្ខព្រួយលំបាកដល់ខ្លួនតុំមានឡើយ ដូចគ្នាទើបមនុស្សនៅកងផ្ទះ ដែលមានពស់វែកនៅកស្រែយាជាមួយផង ទើបមានតែសេចក្តីស្លាប់តែម្យ៉ាងប៉ុណ្ណោះកុំសង្ឃឹមឡើយ ។

ន័យខ្លះលោកថ្លែងសំដែងថា:

ន វិសន្តេ អមិត្តេសុ មិត្តេសុ ន វិសន្តេ
កទាចិ ករោតោ មិត្តោ សព្វទោសំ បកាសយេ ។

ប្តូរតួសាសប្បុរសមិនគប្បីស្និទ្ធស្នាលជាប់រកនឹងពួកជនដាអសប្បុរស ដែលមិនមែនជាមិត្តល្អ គឺមិត្តណាដែលប្រកាសប្រាប់ទោសពាំងពួងរបស់មិត្តដល់ជនដទៃក្នុងពេលដែលខឹង មិត្តនោះ បុគ្គលជាសប្បុរសមិនត្រូវស្និទ្ធស្នាលជាប់រកឡើយ ។

មិត្តសំឡាញ់ណាដែលមានប្រាជ្ញាល្អ ទោះបីខ្លួនដល់សេចក្តីព្រួយខ្លុកលំបាកដោយខ្លួនឯងយ៉ាងណា ក៏មិនគួរញែកប្រាប់មិត្ត មិនកុហកបញ្ឆោតប្រាប់មិត្តផង មិនមើលងាយមិត្ត មិត្តយ៉ាងនេះ បុគ្គលជាសប្បុរសគប្បីសេពគប់យកជាមិត្តស្និទ្ធស្នាលឲ្យមាំពាំពុះ នឹងបានសេចក្តីចំរើនប្រយោជន៍គ្រប់យ៉ាង ។

ន័យមួយទៀតថា: ការសេពគប់មិត្តដែលគួរនឹងសេពគប់មាន ១០ ពួក លោកពោលទុកថា:

ពុទ្ធា បច្ចេកពុទ្ធា ច អរហន្តា ពុទ្ធសាវកា
ហតាបិត្តកិលេសា ជាយកា ធម្មទេសកា
មិត្តំ ឧសភដ្ឋានំ លោកេ ឯតេតំ ជយញ្ញា ។

សេចក្តីថា បុគ្គលជាអ្នកក្រៃជ្រមានក្រែងក្រាំដ៏ខ្លួនខ្ពើយ តម្រេសេត
តប់ខ្លួនមិត្ត ๑๐ យ៉ាងគឺ ព្រះសម្ពុទ្ធជាម្ចាស់ ๑, ព្រះបច្ចេកពុទ្ធ ๑, ព្រះ
អរហន្តខាងឆ្ងាយ ๑, សាវ័ករបស់ព្រះសម្ពុទ្ធជាម្ចាស់ ๑, មាតា ๑,
បិតា ๑, ត្រកូលភាព្យ ๑, ចតុប្បស-ស្មី ๑, គាយកអ្នកឲ្យទាន ๑,
បុគ្គលអ្នកសំដែងធម៌ ๑, បុគ្គលទាំងនេះលោកហៅថា មហាមិត្តដ៏ប្រ-
សើរក្នុងលោក ។

ទេត្តិកាវត្ថុ តាវេយ្យ តេតវេទិញ្ច តាវេយ្យ
តាវេយ្យ តាវតកំ ហុំ តេសុ ទាសវិនេសុបិ
និទ្ទេភិតំ យថា សារំ បវត្តំ សុខទាយកំ ។

បុគ្គលគួរធ្វើខ្លួនតាមរបស់ខ្លួនឲ្យជាមិត្តមេត្រីផង គួរធ្វើខ្លួនតតវេទិតា
ធម៌ផង គួរធ្វើខ្លួនកិរិយាបូជាចំពោះមហាមិត្តទាំង ๑๐ ប៉ំពូកនេះឯង ផលា-
និសង្សដែលខ្លួនបានធ្វើបានបូជានោះ។ លោកខុតដូចជាកំណប់ទ្រព្យដ៏
មានខ្លឹម រាមដូចឲ្យដល់នូវសេចក្តីសុខចំរើន ទាំងនាលោកនេះទើដល់លោក
ខាងមុខដោយពិត ។

សតតំ ទុដ្ឋំ បិយំ មិត្តំ បុន សង្ខាតុមិច្ចតិ
សោ មច្ចុមុបកណ្ឋាតិ តន្តេ អស្សត្ថរី យថា ។

បុគ្គលក្រែងក្រាំខំនុកប៉ុនខ្លែងនឹងមិត្តសំឡាញ់ឯណា ហើយបែកប្រាស្ត-
ព័យអស់ពាក្យមួងហើយ នឹងយកវាជាមិត្តសំឡាញ់ទៀត (តាំងមិនឡើយ)

មិត្តសំឡាញ់នោះ ក៏ដឹងនាំខ្លួនឱ្យចូលទៅកាន់សេចក្តីស្លាប់ជាតិច្រើនដង ដូចគ្នានឹងគតិនៃមេសេរអស្សត្រៃ រមែងសម្លាប់មេរ៉ា (ជាចំខែម) ។

ក្នុងទីបំផុតនៃមិត្តកថានេះ សូមនាំយកព្រឹត្តិ ១ មកជាឧទាហរណ៍ដើម្បីនឹងសេចក្តីនៃមិត្តកថា ឱ្យយើញជាក់ច្បាស់ត្រង់មិត្តសំឡាញ់ដែលថាដឹកនាំឱ្យឃ្លានសេចក្តីសុខ - ចំរើន ជាបដិសន្ធិឡើងថ្នាក់ទៅជាមហាមិត្តដ៏ប្រសើរ ។

សេចក្តីថា: កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង សោយព្រះជាតិជាជោតិបាលមាណព ក្នុងសាសនាព្រះពុទ្ធខែងព្រះនាមកស្សបៈសម្មាសម្ពុទ្ធជាម្ចាស់ ។

គ្រានោះ មានយដិការស្នងឆ្នាំក៏ម្នាក់ជាមិត្តសំឡាញ់ បាននិយាយបបួលជោតិបាលមាណពឲ្យដល់ ឱ្យចូលទៅគាល់ព្រះពុទ្ធកស្សបជាព្រះអរហន្តសម្មាសម្ពុទ្ធ, ឯជោតិបាលមាណព ក៏ឃាត់យដិការស្នងឆ្នាំនោះឲ្យ: កុំឡើយសំឡាញ់ ចុះឯងចូលទៅគាល់ស្រមណ៍កំណោរនោះធ្វើអ្វី ប្រៃកុមិនត្រមៃទៅ តាលែយដិការស្នងឆ្នាំនោះពោលតបវិញសាកសួរតំរង់ដួតទីពីរ ដើរចូលទៅគាល់ព្រះពុទ្ធកស្សបតាលែបាន ហើយសូមឱ្យព្រះអង្គសំដែងធម៌ប្រោសជោតិបាលមាណពឲ្យដឿងជាក់ស្តែងពាយៈវាយចម្លែកថាវបស់ព្រះអង្គ ។

ឯដៅតំណាលមាណព ក៏លះបង់ឃាតសត្វលះទៅបួសក្នុងសំណាក់ព្រះសម្ងាសម្ពុទ្ធជាម្ចាស់ ។ ឃើញការសាន្តឆ្នាំដ៏នេះ មិនត្រឹមតែមានមិត្តសំឡាញ់ទើសដៅតំណាលមាណពជាឃាតសត្វដូចគ្នាទេ សូម្បីតែព្រះសម្ងាសម្ពុទ្ធទ្រង់ព្រះនាមគស្សប ព្រះអង្គក៏ទំនុកទុកចិត្តសំនួរសួរហាក់ដូចជាមិត្តសំឡាញ់ដែរ, ដូចគាលដែលគាត់មិនទៅផ្ទះទៅធ្វើការផ្សេង។ ទ្រង់ហ៊ានយាងទៅឃាតចាយអំពីឆ្នាំង យកសម្លអំពីភាជន៍ យកនំកុម្មាសអំពីកន្លែងទៅឆាន់ ។

ថ្ងៃក្រោយទ្រង់ចាត់ឲ្យភិក្ខុទាំងឡាយទៅរុះរើស្នាដែលប្រគល់ផ្ទះរបស់គាត់យកមកប្រគល់កុដិ របស់ព្រះអង្គ ដែលលេចភ្លឿង, ពុតជាផ្ទះនោះចាលទេ ឃើញការងារគ្រឿងប្រគល់ជារាបអស់ ៣ ខែ ប៉ុន្តែមិនលេចភ្លឿងទេ ។

ឃើញការស្ងប់ឆ្នាំងមានសេចក្តីសុខតាយសប្បាយចិត្ត ដែលកើតអំពីបីតិអស់កន្លះខែ ដោយសេចក្តីពេញចិត្តនឹកថា ព្រះពុទ្ធលោកស្ងួនស្ងាលនឹងអញ្ជើញតណាស់; មនុស្សដូចជាឃើញការសាន្តឆ្នាំដ៏នេះឯងឈ្មោះថាមហាមិត្តចិត្តត្រង់ ដឹកនាំសំឡាញ់ឲ្យបានសម្រេចប្រយោជន៍ដូចជាខ្លួនដែរ គួរសាធុជនទាំងឡាយចំដឹកនាំគ្នាឲ្យបានសម្រេចប្រយោជន៍ត្រង់យ៉ាងនេះ ។ ឯវំ សម្ពុតា ឧទ្ទេសា ។

ធម្មទេសនា ស្តេចតែងដាច់ក្បែរប៉ុណ្ណេះ ។

របស់ព្រះអាចារ្យ ឈឹម-ស៊ុម សទ្ធម្មប្បញ្ជោ

អាចារ្យបង្រៀនខេមាសាលាជាលិជាន់ខ្ពស់ កុំពេញ

សំដែងតាំងថ្ងៃសៅរ៍ ៨កើត ប្រមាសាធ មធ្យមត្ថាស័ក ព.ស. ២៤៨៥ (២០ ឆ្នាំង ១៩៤២)

ធម្មានុធម្មកថា

សំដែងតំណមិត្រមិនមិនពុល

ឯមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ភាវៈនេះសូមសំដែងអំពីធម្មិត្រ ធម្មិពុល នឹងអំណាយផលនៃធម្មិត្រ ធម្មិពុលនោះ តាមបទបាលីភ្នុកាសិតថា

ឯ ហិ ឯម្មោ អនម្មោ ច ឧភោ សមវិបាកិនោ

អនម្មោ និរយំ នេតិ ឯម្មោ បាបេតិ សុគតិ ។

ប្រែថា សត្វរៀនធ្វើយ ២ ប្រការគឺ ធម្ម: បានដល់ធម្មិត្រ ១ អធម្ម: បានដល់ធម្មិពុល ១ ឲ្យផលពុំខុសគ្នាទេ, ធម្មិពុលរមែងទាំសត្វទៅកាន់នរក, ធម្មិត្រវរមែងទាំសត្វទៅកាន់សុគតិ ។

បណ្តាភាសាទាំង ២ ម៉ាត់នេះ, សូមអធិប្បាយអំពីភាសាថាធម្មិត្រជាមុន ។ ធម្មិត្រចែកចេញជា ៣ ប្រការគឺ:

ប្បរិយត្តិធម៌ បានដល់ធម៌សម្រាប់សិក្សា សម្រាប់ស្តាប់គឺ ព្រះត្រៃបិដក ដែលចែកចេញជាព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ប្តូរហៅថា

ទវង្គសត្ថុសាសនៈ គាក្យប្រែនប្រដៅរបស់ព្រះសាស្តាប្រកបដោយអង្គ ៩ គឺៈ សុត្តៈ គេយ្យៈ, វេយ្យាករណៈ, គាថា, ឧទានៈ, ឥតិវុត្តកៈ ជាតកៈ, អព្ភូតធម្មៈ, វេទល្លៈ ។

បដិបត្តិធម៌ ធម៌សម្រាប់ប្រតិបត្តិតាម ចាន់ដល់អដ្ឋង្គិកមគ្គ ដែលជាផ្លូវនៃសេចក្តីប្រតិបត្តិប្រកបដោយអង្គ ៨ ប្រការគឺ សម្មាទិដ្ឋិ សេចក្តីយល់ត្រូវ ១, សម្មាសង្កប្បោ សេចក្តីតម្រិះត្រូវ ១, សម្មាវាចា ពាក្យត្រូវ ១, សម្មាកម្មន្តោ ការងារត្រូវ ១, សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ ១, សម្មាវាយាមោ សេចក្តីព្យាយាមត្រូវ ១, សម្មាសតិ ស្មារតីត្រូវ ១, សម្មាសមាធិ ចិត្តដំកល់ត្រូវ ១ ។

បដិវេធធម៌ ធម៌គឺការត្រាស់ដឹង ចាន់ដល់លោកុត្តរធម៌គឺមគ្គ ៤ មានសោតាបត្តិមគ្គជាដើម, ផល ៤ មានសោតាបត្តិផលជាដើម ។

ធម៌ត្រូវចាំង ៣ ផ្នែកនេះ ជាបច្ច័យឲ្យកំឡាំងត ។ គ្នា គឺបរិយត្តិធម៌ បើកុលបុត្រចាន់សិក្សា ចាន់ស្តាប់ដោយការយកចិត្តទុកដាក់ហើយ, ជាពន្លឺភ្លឺឆ្ងុំឲ្យយល់ច្បាស់នូវផ្លូវនៃសេចក្តីប្រតិបត្តិ ដែលហៅថា បដិបត្តិធម៌; កាលបើដំណើរកាយវាចាចិត្តប្រព្រឹត្តត្រង់ទៅតាមបដិបត្តិធម៌ហើយ, ជាហេតុឲ្យកើតសេចក្តីត្រាស់ដឹង គឺបដិវេធធម៌ជាលំដាប់ ។

បរិយត្តិធម៌ ១ មិនមែនឲ្យផលត្រឹមតែយល់ឮវប្រែតម្រេតប៉ុណ្ណោះទេ
បើកុលបុត្តសិក្សា ឬស្តាប់ឲ្យបានសេចក្តីចេះចាំជាច្រើនដរហើយ, ជាគុណ
មានអានុភាពអាចនាំផលប្រយោជន៍ច្រើន មកប្រគល់ដល់កុលបុត្តអ្នក
សិក្សា អ្នកស្តាប់នោះតាំងពីតូចបច្ចុប្បន្នរៀនទៅជាច្រើនដង; តែកុលបុត្តអ្នក
ទ្រទ្រង់បរិយត្តិធម៌ រមែងបានលាភសក្ការៈដោយងាយ, រមែងមានមិត្ត
ចាំងឡាយមូលមកពីរតែប់ទិស, រមែងបានសេចក្តីសុខសាន្តក្នុងចិត្ត
តតែ្តកហាយ,រមែងបង្កើតបុណ្យចាំងឡាយដែលផ្សាយទៅខាងមុខ-
លោក, លុះរំលែងខន្ធអំពីឥលោកនេះបានទៅកើតក្នុងឋានសួគ៌នៃលោក
ឬសម្រេចដល់ឋានសិរីមេក្ខតីព្រះនិព្វានជាច្រើនដង ។ អស់លោក
ចាំងឡាយប្រហែលជាបានឃើញដោយជាក់ស្តែងថា : បរិយត្តិធម៌ អាច
ជ្រាងស្តុយកុលបុត្តដែលទ្រទ្រង់ដោយហ្មត់ចត់ ឲ្យអណ្តែតផុតពីទីតាប
ទៅដំកល់លើដំណែងដ៏ខ្ពង់ខ្ពស់បាន, ដូចយ៉ាងកុលបុត្តរូបខ្លះ ដែលកើត
ក្នុងត្រកូលថោកទាបសោះទេ, ប៉ុន្តែបានសិក្សាបរិយត្តិធម៌ច្រើនផ្នែក, ធម៌
នោះអាចឈោងតាញ្រមូលយកបណ្តាជនដទៃអំពីទីតំបន់ផ្សេងៗឲ្យចូល
មកកាន់អានុភាពនោះឯងដោយសេចក្តីគោរព, ឲ្យចូលមកទទួលយ៉ាង
ខ្លាំងដាអ្នកស្តាប់ចង្អាប់កុលបុត្តនោះដោយស្មោះអស់ពីចិត្ត; ហេតុដូច្នោះ
បានជាមានសុភាសិតឆាសេចក្តីឧបមាលោកប្រៀបទុកមកថា

ស្បង្ហិដសេតុបុរ្សេរត្តុបុរ្សិ លូតលាស់ផុះផុលពីកន្លែងកំ
ផុតនៃនប្រថពីមិតគ្រាក់ កន្ទុងំតគ្រុកគ្រឹបកេសរ ។

នេះជាគួរឧបមាថា: មនុស្សជាតំគ្រប់គ្នា ទោះបើកើតកង្គែតកូល
ទាបតាបយ៉ាងណាក៏ដោយ ឲ្យតែចាំបរិយត្តិធម៌ដោយមុតមាំ តំប្រា-
កដជាខំឆ្លងបានជាខំនិយមពប់អាននៃជនាទុជនច្រើនគ្នា, ដូចជាផ្កាឈូក
ទុកណាជាដុះកង្គែកក់ពិតគ្រាក់មិនស្អាតយ៉ាងណាក៏ដោយ ឲ្យតែលូតចេញ
ផុតពីកក់មក ប្រាកដជាទទួលវាសនៃនមរជាតិដ៏ឆ្ងាយមានកន្ទុង, រេមម, ឃ្មុំ ជាដើម ដូច្នោះឯង ។ នេះគឺមតែកុលបុត្តដែលកើតកង្គែ
តកូលទាបតាបផង ម្តេចតង្គំបណ្តាជនស្រឡាញ់ប្តូរចិត្តគំនិត ផ្ញើអាយុ
ជីវិតដល់ម្ងុំរៅហើយ, ចាំបាច់និយាយថ្វីឡើយ ដល់កុលបុត្តដែល
កើតកង្គែតកូលខ្ពង់ខ្ពស់ស្រាប់ ។ បើប្រសិនជាមានកុលបុត្តរបស់មហា-
តែកូលណាមួយសំភ្ជាបរិយត្តិធម៌ឲ្យច្បាស់លាស់ប្រតិបត្តិតាមឲ្យត្រឹម
ត្រូវដល់ក៏រឹត ម្ងុំរសមបណ្តាជនស្រឡាញ់ស្ងាប់ចិត្តឥតរឹងរូសឡើយ
ហើយប្រហែលជាឥតមានមនុស្សគោលនៅឲ្យខើសខែងកង្គែស្រុកកង្គែ
ប្រទេសទេ ។

កង្គែឧបមាខាងដើមនេះ មានសេចក្តីសមគ្នានឹងរឿងនិទាន ដែល
ព្រះគន្ធរចនាចារ្យរៀបរៀងពុកមកថា: កាលព្រះសព្វញ្ញុបរមគ្រូជាម្ចាស់
បានគ្រាស់ហើយនូវធម៌ប្រកាសព្រះពុទ្ធសាសនា ទ្រង់ស្តេចទៅដល់

ឧត្តរកោសម្ពី ជារាជធានីនៃព្រះបាទឧទេន, មានឋានស័ក្តិក្នុងតម្រិះ
ខាងខ្ពង្គត្តក ដែលនាងសាមាវតីជាអគ្គមហេសីនៃព្រះបាទឧទេន បានប្រើ
ឲ្យទៅទិញផ្កា ចេញដំណើរទៅស្រាប់តែបានជួបប្រទះនឹងព្រះអង្គកំពុង
សំដែងធម៌ទេសនា នាងបានចូលទៅស្តាប់អស់វេលាជាច្រើន, បានចាំ
ជាក់គ្រប់បទល្មមសំដែងចប់គេតទៅទៀតកើត ទើបហួសទៅទិញផ្កា
យកមកជូននាងសាមាវតីជាខាងក្រោយ ដោយដំណើរយឺតយូរហួស
កាលវេលា ។ នាងសាមាវតីបន្ទោសថា ម្តេចហាង! សព្វដងហាងឯងទៅ
ទិញផ្កាត្រឡប់មកវិញភ្លាម។, ម្តងនេះជាប់ខាតខាងជាយកតិចអ្វី បានដា
យឺតយូរដល់ម្ល៉េះ ? នាងខ្ពង្គត្តក ដាក់បបថា: ខ្ញុំចេញដំណើរទៅ ជួនជា
បានជួបនឹងព្រះសម្មាសម្ពុទ្ធ កំពុងសំដែងធម៌ទេសនា; សេចក្តីធម៌អាថ
ភ័ព្រះព័ស្តាណាស់ គួរឲ្យចង់ស្តាប់; ខ្ញុំជាប់ស្តាប់ធម៌ទេសនាបានជាគាត់
ដំណើរយឺតយូរយ៉ាងនេះ, កុងរឿងនេះ សូមព្រះនាងអភ័យទោស ។
នាងសាមាវតីនឹងស្រីតាំង ៥០០ ឮដំណឹងដូច្នោះក៏ចង់ស្តាប់ដែរ, ប៉ុន្តែខាល់
ពេលតែងសុំព្រះរាជានុញ្ញាតចេញទៅស្តាប់ផងពុំបាន ទើបអញ្ជើញនាង
ខ្ពង្គត្តកឲ្យសំដែងធម៌ទេសនាឲ្យស្តាប់, បានរៀបចំគ្រឿងប្រដាប់គុបតែងដ៏
ធម្មាសនៈដ៏ខ្ពង់ខ្ពស់ ឲ្យនាងខ្ពង្គត្តកនោះឡើងអង្គុយសំដែងធម៌ទេសនា ។
កាលបើនាងសាមាវតី នឹងស្រីតាំង ៥០០ ស្តាប់បាន មានសេចក្តីជ្រះថ្លា,
ក៏ផ្តើនាងខ្ពង្គត្តកឲ្យជាអ្នកជា រួចខ្លួនអំពីនាទីជាទាស ហើយតាំងនាង

ខ្ញុំឆ្កួតឲ្យដាអាចារ្យសម្រាប់បង្រៀនធម៌ទីសំដែងធម៌ឲ្យស្តាប់, ចាន់ធ
ឬដាខាងខ្ញុំឆ្កួតដោយគ្រឿងសក្ការៈឬដាផ្សេង។ ច្រើនដាអនេក ។

រឿងនេះគួរឲ្យយល់ថា បរិយត្តិធម៌មានគុណអស្ចារ្យក្រៃពេក . អាច
ស្មើកុលបុត្តកុលធីតាអ្នកបេះចាំនោះឲ្យអណ្តែតឡើងកាន់ដំណែងដ៏ថ្កុំថ្កើង
ចំឡែកជាងធម៌ឯទៀត។ ។

ខាងខ្ញុំឆ្កួតដែលបេះសំដែងធម៌ក្តី ខាងសាមាតែនឹងស្រែចាំង ៥០០
ដែលចូលចិត្តស្តាប់ធម៌ក្តី ចាន់សម្រែចសោតាបត្តិផលខ្លះ សកទាគាមិ-
ផលខ្លះ អនាគាមិផលខ្លះ; លុះលែងដាតិអំពីអត្តភាពនេះទៅ ចាន់ទៅ
កើតកងសុគតិសួគ៌ទៅសោតចាំងអស់គ្នា ។

ហេតុដូច្នេះ ចាន់ដាព្រះដ៏ឈ្នះមារទ្រង់ត្រាស់សំដែងថា ជម្ងោ
ថាបេតិ ស្វាកតំ ធម៌ត្រូវ រមែងនាំសត្វទៅកាន់សុគតិ ។

ចប់ធម៌ត្រូវក្នុងផ្នែកទី ១ ។

ចំណែកខាងធម៌ខុសវិញសោត ក៏មាន ៣ ផ្នែកខន្ធឹមគ្នានឹងធម៌
ត្រូវនេះដែរ; គួរសម្តែងសំដាងឲ្យយល់ខ្ញុំដាងថា: ធម៌ខុសនោះគឺបរិយត្តិ-
អធម៌ ១ បដិបត្តិអធម៌ ១ បដិវេធអធម៌ ១ ។

បរិយត្តិអធម៌ ប្រែថា: ធម៌ខុសដែលជនពាលតែងសិក្សាតែង
ស្តាប់ ចាន់ដល់ធម៌ខុសដូចយ៉ាងមន្តអាគមជាដើម។ ដាខាងក្រៅដូចព្រះ-
សាសនា មានមន្តសណ្តំ, មន្តស្នេហ៍ធ្វើចិត្តមនុស្សឲ្យរវើរវាយ ខុសត្រឹត្យ

បវរណា, មន្តបដ៏ចំណែន, មន្តផ្ចប់ជាដើម ជាគួបដំបូកខ្ទង់ដ៏បរិយត្តិធម៌ ដែលសំដែងរួបមកហើយនេះ ។ ធម៌ខុសទាំងនេះមែនទាំងនាលដែលសិក្សាឲ្យសំយុងក្សាលចុះទៅតាន់នាក, សមដូចព្រះតថាគតថា: អាជញ្ញោ និរយំ នេតិ ដូច្នេះពិត ។

ចប់ធម៌ខុសក្នុងផ្នែកទី ១ ។

ធម៌ត្រូវកន្លែងផ្នែកទី ២ ហៅថាបដិបត្តិធម៌ ធម៌សម្រាប់ប្រតិបត្តិតាមគឺអដ្ឋង្គិកមគ្គទាំង ៨ ប្រការ មានសម្មាទិដ្ឋិជាដើមដូចបានសំដែងពីបឋមឈ្មោះគ្រប់ចំនួនរួបមកហើយ ។ អដ្ឋង្គិកមគ្គនេះ មានសេចក្តីច្បាស់ក្នុងសុត្តន្តបិដកខ្លះ អភិធម្មបិដកខ្លះ តំណាត់ឲ្យឈ្មោះថាសម្មត្តនិយតាធម៌ ប្រែថា "ធម៌ខៀងក្នុងផ្លូវត្រូវឬថាធម៌ច្បាស់ជាត្រូវ" ដែលជាគួបដំបូកខ្ទង់ធម៌ច្បាស់និយតាធម៌ ប្រែថា "ធម៌ខៀងក្នុងផ្លូវខុស ឬធម៌ច្បាស់ជាខុស" ដូចព្រះតថាគតដែលមានច្បាស់ដំបូកក្នុងបទនាតិកាអភិធម្មថា " សម្មត្តនិយតា ធម្មា មិច្ឆត្តនិយតា ធម្មា " ដូច្នេះជាដើម ។

បដិបត្តិធម៌ អដ្ឋង្គិកមគ្គទាំង ៨ ប្រការនេះ ជាបច្ច័យឲ្យកំឡាំងគ្នា បើបុរសបុគ្គលណាប្រតិបត្តិធ្វើសម្មាទិដ្ឋិសេចក្តីយល់ត្រូវឲ្យកើតឡើងបានហើយ ជាហេតុឲ្យកើតសម្មាសង្កប្បោ សេចក្តីត្រិះរិះត្រូវជាដើមតមកខៀត ជាលំដាប់ហូតដល់សម្មាសមាធិជាទីបំផុតពុំខាន ។

គន្ថនៃនៃសេចក្តីប្រតិបត្តិខាងដ ៨ ខ្នងនេះ ជាធម៌សម្រាប់ផ្តាច់ផ្តិលនូវគំនរនៃសេចក្តីទុក្ខ ហើយប្រមូលយកនូវសេចក្តីសុខមកប្រគល់ឲ្យ ជាអំណោយដ៏វិសេសជាងអំណោយនៃមនុស្ស ទេពតា មារ ព្រហ្មខាងពួង, សមដូចពុទ្ធភាសិតថា

ន តំ មាតា បិតា ករយិរ អញ្ញេ វា បន ញាតកា
សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ។

ប្រែថា ប្រយោជន៍គឺសេចក្តីសុខសេចក្តីចំរើន ដែលមាតាបិតាញាតិការធ្វើឲ្យសម្រេចដល់ខ្លួន ឬដល់ចង្អួនពុំបាន ព្រោះមានតែចិត្តដែលបុគ្គលផ្គងឡើងត្រូវ ហៅថាសម្មាទិដ្ឋិនេះ ទើបអាចធ្វើឲ្យសម្រេចបាន ឬធ្វើឲ្យសម្រេចវិសេសហួសពីនោះទៅទៀតក៏សឹងបាន ដោយឥតខ្វើសោះ ។

បណ្តាជនដែលស្រឡាញ់រាប់អានយើងខាងប៉ុន្មាន នោះបំផុតត្រឹមលោកអ្នកដ៏មានគុណគឺមាតាបិតាគ្រួសារជាដើមប៉ុណ្ណោះ, ប៉ុន្តែខ្លះជាមាតាបិតាដែលមានបុណ្យច្រើន ដូចមាតាបិតារបស់នាងវិសាខាជាដើមក៏អាចចែកផលប្រយោជន៍ឲ្យកូនបាន ត្រឹមតែសម្បត្តិដែលខ្លួនមានស្រាប់ប៉ុណ្ណោះ, ដែលនឹងក្រសោបយកសម្បត្តិក្នុងមហាទ្វីបខាង ៤ មកចែកឲ្យកូនផង នោះពុំបានជាដាច់ខាត ។ បើត្រឹមតែសម្បត្តិមនុស្សក្នុងមហាទ្វីបខាង ៤ មាតាបិតាប្រមូលយកមកចែកកូនពុំបានទៅហើយ, ពាក្យថា

ខំយាយថ្វាយដល់សម្បត្តិទេពតាក្នុងហានសូត្រ ។ មានតែចិត្តដែលបុគ្គលផ្គងទ្បើងត្រូវតែសម្មាទិដ្ឋិនេះ ទើបអាចប្រគល់សម្បត្តិមនុស្សក្នុងមហាទ្វីបទាំង ៤ ទីឆសម្បត្តិទេពតាក្នុងធតាមាវេរសូត្រ ៦ ជាន់ទីឆសម្បត្តិក្នុងព្រហ្មលោក ១៦ ជាន់ ព្រមទាំងលោកុត្តរសម្បត្តិ គឺមគ្គ ផល និព្វាន ឲ្យដល់ដនទាំងពួងបានជាច្រើនជ ។ ហេតុដូច្នេះ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា ជន្តោ ចាបេតិ សុគតឹ ធម៌ត្រូវរមែងញ៉ាំងសត្វឲ្យដល់ទ្បីវសុគតិ គឺធ្វើបណ្តាជនអ្នកប្រតិបត្តិឲ្យមានដំណើរល្អទៅខាងមុខ ។

ចប់ធម៌ត្រូវក្នុងផ្នែកទី ២ ។

ឯធម៌ខុសក្នុងផ្នែកទី ២ ហៅថាបដិបត្តិអធម៌ ដែលជាគូបដិបក្ខទីឆបដិបត្តិធម៌នោះ គឺមាន ៨ ប្រការដូចគ្នាដែរ គឺមិច្ឆាទិដ្ឋិ សេចក្តីយល់ខុស ១, មិច្ឆាសង្កប្បោ សេចក្តីត្រិះរិះខុស ១, មិច្ឆាវាចា វាចាខុស ១, មិច្ឆាកម្មន្តោ ការងារខុស ១, មិច្ឆាអាជីវោ ការចិញ្ចឹមជីវិតខុស ១, មិច្ឆាវាយាមោ សេចក្តីព្យាយាមខុស ១, មិច្ឆាសតិ ស្មារតីខុស ១, មិច្ឆាសមាធិ ចិត្តដំកល់ខុស ១, ធម៌ទាំង ៨ ប្រការនេះ មានសេចក្តីច្រើនជក្នុងសុត្តន្តបិដកខ្លះ អភិធម្មបិដកខ្លះ តំណត់ឲ្យឈ្មោះថា "មិច្ឆត្តនិយតាធម៌" ប្រែថា ធម៌ទៀងក្នុងផ្លូវខុស ឬថាធម៌ច្រើនជាខុស ។ បើមិច្ឆាទិដ្ឋិ សេចក្តីយល់ខុសមានហើយ ជាបច្ច័យឲ្យកើតធម៌ខុសមានមិច្ឆា-

សន្ដិបប្បាសេចក្ដីត្រែះរែះខុសជាដើម តែគ្នាជាលំដាប់ រហូតដល់មិច្ឆាសមាធិជាខ័ប់ជុត ។

មិច្ឆាទិដ្ឋិ សេចក្ដីយល់ខុសនោះ ចែកចេញជាប្រភេទយ៉ាងសរុបមាន ២ យ៉ាង; ចែកចេញយ៉ាងកណ្ដាលមាន ៣ ប្រការ ចែកចេញដោយពិស្ដារមាន ៦២ ប្រភេទ ។

ឥឡូវនេះ សូមចែកក្នុងប្រភេទយ៉ាងកណ្ដាលថា : សេចក្ដីយល់ខុសមាន ៣ ប្រការនោះគឺ អត្ថិកវាទិដ្ឋិ សេចក្ដីយល់ឃើញថា អំពើអាក្រក់ដែលគេសន្មតថាបាប ដូចយ៉ាងបៀតបៀនកំដៅអ្នកដទៃដោយការជាដើមក្ដី ប្រព្រឹត្តក្បត់ស្វាមីភរិយារបស់អ្នកដទៃជាដើមក្ដី, និយយកុហក ឆ្កែគោះ ចោកចោះ សឹកសៀត ញុះញង់ជាដើមក្ដី ដែលគេសន្មតថាបាបនោះខុសជាបុគ្គលបានធ្វើហើយ ក៏ហើយទៅទេ មិនជាបាបអ្វីទេ, ដូច្នេះ ១; អហេតុកទិដ្ឋិ សេចក្ដីយល់ឃើញថា គ្មានហេតុដែលនាំសត្វឲ្យសៅហ្មង ឬបរិសុទ្ធទេ សត្វទាំងឡាយ សៅហ្មងឯង។ បរិសុទ្ធឯង។ ដូច្នេះ ១, នត្ថិកទិដ្ឋិ សេចក្ដីយល់ឃើញថា ឲ្យទៅគ្មានផល បូជាគ្មានផល ឬយល់ថា កិច្ចដែលគេសន្មតថាបុណ្យ បើបុគ្គលណាបានធ្វើហើយ ក៏គ្រាន់តែឲ្យមនុស្សពាលសរសើរក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ, ដែលនឹងឲ្យផលទៅក្នុងលោកខាងមុខ ដូចសំដីដែលជនពាលថាបញ្ជារមកនោះពុំមានដោយដាច់ខាតដូច្នេះ ១ ។ ទិដ្ឋិទាំងបី ហៅនេះនឹងហៅថា ទុច្ច-

ទទិដ្ឋិ ដូច្នេះវិញក៏ចុះ តើសេចក្តីយល់ឃើញថា សត្វទាំងឡាយកាល
ទម្លាយកាយតែងកាយទៅហើយ សូន្យទេ វិនាសឈឹង ខាងមុខ អំពីសេចក្តី
ស្លាប់ទៅមិនមានអ្វីខ្លះទេ ។ បុគ្គលណាយល់ដូច្នេះហើយ ទោះមុនជា
លែងធ្វើបុណ្យ ព្រោះគិតថាមិនដឹងយកបុណ្យទៅប្រើការឯណា ហើយ
ឥតឮញើតនឹងអំពើបាប ព្រោះគិតឃើញថា បើធ្វើបាប ក៏បាប
ឥតតាមទៅផ្តន្ទាដល់ជាតិណាខ្លះដែរ ។ ឃោឋលយ៉ាងនេះពេញជា
ខ្ទុះខ្ទាំងណាស់! មានទោសច្រើនជាងគេបំផុត! សមដូចព្រះតថាគត
ព្រះសំដែងសម្តែងដែលឃើញច្បាស់ជាក់ក្នុងគម្ពីរអង្គុត្តរនិកាយឯកនិបាត ថា
ម្នាលភិក្ខុទាំងឡាយ, តថាគតស្គាល់ច្បាស់នូវអំពើដែលមានទោសច្រើន
ដូចមិច្ឆាទិដ្ឋិ មិនឃើញមានសោះ, មានតែមិច្ឆាទិដ្ឋិនេះឯង ដែលមាន
ទោសច្រើនជាងគេបំផុត ។ អម្បាលអនន្តរិយកម្មគឺការសម្លាប់មាតា
សម្លាប់បិតា សម្លាប់ព្រះអរហន្ត បំបែកសង្ឃ ទំលាក់ឈាមហាតព្រះ
តថាគតឲ្យកក្រើងឡើង ទាំង ៥ ប្រការនេះ ជាអំពើមានទោសច្រើនដល់
ម្ល៉ោះម្តេចក៏តុំពាន់ស្មើនឹងទោសនៃមិច្ឆាទិដ្ឋិនោះឡើយ ។ ព្រោះហេតុអ្វី?
ព្រោះតែអនន្តរិយកម្មមានទោសនាំឲ្យចុះនរកតំណាត់តែមួយកប្បប៉ុណ្ណោះ
ឯមិច្ឆាទិដ្ឋិនោះបើជាទិយតបុគ្គលខ្លះដូច្នេះហើយ មានទោសនាំឲ្យចុះ
នរកតំណាត់ជាប៉ុន្មានកប្បពុំបានឡើយ ។ មិច្ឆាទិដ្ឋិនេះគេថាធ្វើបុរស
បុគ្គលអ្នកបុគ្គលខ្លាប់ ឲ្យវិនាសក្តីយជាងសេចក្តីដួងរបស់មនុស្សនឹង

ទេពតាទាំងឡាយទាំងអស់ប្រមាណណាស់, សមដូចព្រះពុទ្ធដីកា ព្រះ
សាស្តាដាក់ត្រាស់អំពែនដ៏ថា

ឯសោ ឥសំ យន្តំ តយិត្ថ កោ ភ យន ហោតំ
មិច្ឆាបណិហិតំ ចិត្តំ ទាមិយោ ឧំ ឥតោ. ឆរេ ។

ចោរហើយទើរចោរ ជាបុគ្គលចាន់ចិត្តអាត្រក់ត្រៃលែងស្រាប់ ថែម
ទាំងមានសំមប់គំនុំគុំគ្នាទៅវិញទៅមកទៀត ពុំនោះសោតទេ បុគ្គលមាន
ពៀរ ហើយទើរបុគ្គលមានពៀរ ដែលភ្ជាប់ចងពំនាំទើរគ្នាជាយូរអង្វែង
មកហើយ បុគ្គលទាំងពីរពួកនេះ បានជួបប្រទះគ្នាហើយ រមែងធ្វើ
សេចក្តីវិនាសឲ្យកើតឡើងដល់គ្នាទើរគ្នាយ៉ាងខ្លាំង តើត្រូវចាក់គ្នាក៏ចាក់
កាប់គ្នាក៏កាប់ ចុំញ៉ាំគ្នាក៏ចុំញ៉ាំ ឬតែងធ្វើឲ្យអន្តរាយដោយទុក្ខផ្សេងៗ
គួរឲ្យមិនពុំខាន, ប៉ុន្តែនៅពុំទាន់ស្មើនឹងចិត្តដែលបុគ្គលដាក់ទុកនៅ
ឡើយទេ, តើសេចក្តីយល់ខុសដែលហៅថាមិច្ឆាវិទ្ធិនោះ អាចធ្វើបុគ្គល
អ្នកយល់ខុសនោះឲ្យវិនាសខ្លាំងត្រៃលែងជាងនោះទៅទៀត ព្រោះថា
បុគ្គលជាសត្រូវនឹងគ្នាទាំងពីរពួកនេះ ធ្វើសេចក្តីវិនាសឲ្យកើតឡើងតែម
តែមួយជាតិ ឬពីរជាតិប៉ុណ្ណោះ, ឯសេចក្តីយល់ខុស អាចធ្វើឲ្យវិនាស
ក្នុងបច្ចុប្បន្នជាតិនេះផង ឲ្យវិនាសទៅខាងអនាគតកំណត់ជាតិកំណើតថា
ប៉ុណ្ណោះប៉ុណ្ណោះពុំបានឯណោះទៀតផង តើថាបើស្ងាប់វិនាសតាំងជាតិនេះទៅ

ទៀតតែទៅតើតក្នុងនេះ, សមនឹងព្រះពុទ្ធគាសិត ដែលទ្រង់សំដែងថា អនេកម្មោ ឯវាយំ លោកិ ធម្មិកុសតែងនាំសត្វចុះនេះ ។

ចប់ធម្មិកុសក្នុងផ្នែកទី ២ ។

ឯធម្មិតែក្នុងផ្នែកទី ៣ ហៅថាបដិវេធធម៌ ធម៌គឺសេចក្តីត្រាស់ដឹងរបស់ព្រះអរិយបុគ្គលទាំងឡាយ ឬថាធម៌ដែលព្រះអរិយបុគ្គលទាំងឡាយបានត្រាស់ដឹងផ្ទាល់ខ្លួន ដោយបានប្រតិបត្តិតាមបដិបត្តិធម៌ត្រង់ត្រាន់ទាំង ៨ ថ្នាក់, គឺថាបុរសបុគ្គលដែលមាន សម្មាទិដ្ឋិ, សម្មាសង្កប្បោ, សម្មាវាចា, សម្មាកម្មន្តោ, សម្មាអាជីវោ, សម្មាវាយាមោ, សម្មាសតិ, សម្មាសមាធិ ហើយចំរើនវិបស្សនាបញ្ញាតទៅទៀត ក៏ធ្វើឲ្យបានត្រាស់ដឹងដាក់ឮស់ខ្លួនដល់បដិវេធធម៌ គឺមគ្គញ្ញាណ ៤ ផលញ្ញាណ ៤ ជាធម៌ល្អចំផុតថ្នាក់ ដែលហៅថាលោកុត្តរធម៌ដូច្នេះផងក៏បាន ព្រោះធម៌នេះមិនត្រឹមតែធ្វើសត្វឲ្យទៅកាន់សុគតិប៉ុណ្ណោះទេ តែងញុំាងសត្វឲ្យឆ្លងផុតចាកលោកទៀតផង ។

ត្រង់ភាក្យថាលោក។ នេះ បានសេចក្តីថាប្រទេសដែលប្រកបដោយសេចក្តីទោស ឬថាប្រទេសដែលត្រូវតែលិចអណ្តែត លិចអណ្តែតចែកចេញជាបីកន្លែងគឺ កាមលោក បានដល់ឋានទាំង ១១ ប្រភេទ ដែលសត្វនៅគាយតំណាន មនុស្សទាំងតាមាវចរសួគ៌ ៦ ជាន់ ១ រូបលោក បានដល់ឋានរូបព្រហ្ម ១៦ ជាន់ ១, អរូបលោក បានដល់ឋានអរូបព្រហ្ម ៤ ជាន់ ១ ។ ប្រទេសទាំងបីអន្លើនេះ ប្រកបដោយសេចក្តីទោសពាល់ពីក្រឹត្យបញ្ញា

ជនប្រុសស្រីជាមនុស្សជាតិ ដែលកើតមកកន្លងលោកតិហេតុមនុស្សនេះ
សុទ្ធតែត្រូវការប៉ះពាល់សេចក្តីវិនាសជាច្រើនប្រការគ្រប់គ្នា គឺអ្នកខ្វះកំពុងតែ
ទៅជាសុខ ស្រាប់តែវិនាសចាកញាតិ, អ្នកខ្វះកំពុងតែពាយពោយពួក
ញាតិស្រាប់តែវិនាសចាកទ្រព្យសម្បត្តិ អ្នកខ្វះខ្សត់តែនឹងសន្សំទ្រព្យ
សម្បត្តិបានបន្តិចបន្តួចស្រាប់តែវិនាសចាកសេចក្តីសុខ គឺត្រូវរងគ្រោះ
ដោយជម្ងឺឈឺចាប់ ដោយរាគាត់រគាប់ ដោយគេបណ្តាញបំបរ ដោយ
គេសង្កត់សង្កិន ឲ្យជាក់ជប់ខ្វប់ខ្វាចនៅក្រែមអំណាចគេក៏សឹងមាន ។
កាលបើយ៉ាងដូច្នេះ តើសេចក្តីសុខមាននៅត្រង់ណា ? សេចក្តីវិនាសប្តូ
ដណើរលើចអណ្តែតយ៉ាងនេះ រមែងមានជាធម្មតា កន្លងកន្លែងដែលសត្វ
កើត ហេតុដូច្នោះ ចានជាកន្លែងនោះឈ្មោះថាលោក ។ ដូច្នេះ ។ សេច-
ក្តីគ្រាស់ដឹង ដែលហៅថាបដិវេធធម៌របស់ក្រមអ្នកប្រាជ្ញ អាចស្ទួយខ្លួន
ឲ្យឆ្ងងផុតចាកលោកតាំងបីនេះទៅប្រតិស្ឋានកន្លងនូវនិព្វានដែលឥតមាន
សេចក្តីវិនាសបាន ចានជាហៅថា លោកុត្តរធម៌ដូច្នេះឯង ។ បដិវេធធម៌
នេះ ជាធម៌ត្រូវធម៌ល្អបណ្តាច់បណ្តាលកំពូលធម៌តាំងអស់ ។

ចប់ធម៌ត្រូវក្នុងផ្នែកទី ៣ ។

ចំណែកខាងធម៌ខុសក្នុងផ្នែកទីបី ហៅថាបដិវេធអធម៌ ចានដល់
សេចក្តីគ្រាស់ដឹងខុស ចេះខុស គឺសេចក្តីគ្រាស់ដឹងខាងការប្រកបខ្វួន
កន្លងលោក ធ្វើខ្លួនឯងនឹងនឹងជនតាំងពួងឲ្យរងគ្រោះរងវិនាស, ធម៌ខុស

ថ្នាក់នេះ ក៏កើតតគ្គាអំពីបដិបត្តិអនម្ចិកឆឌ្ឍាក់ទី៣ ពោះមកដែរ គឺបុរស
បុគ្គលបុថុជ្ជនណាដែលមានមិច្ឆាទិដ្ឋិសេចក្តីយល់ខុសហើយ ប្រាកដជាមាន
កំហុសតាមគ្នា រហូតដល់មិច្ឆាសមាធិ ការផ្តោតចិត្តសិប់នៅក្នុងអារម្មណ៍
ណាមួយខុសទៀត, បើមានការតាំងចិត្តខុសសិប់ហើយ មុខជានឹងកើត
បដិវេធអធម្ម គឺសេចក្តីត្រាស់ដឹងខុស ដែលជាគ្រឿងធ្វើឲ្យនូវនឹងសត្វ
តាំងពួងមិនឲ្យរើចេញពីលោកតាំងប៉ាន់ជាប្រាកដ ។ ម្យ៉ាងទៀតថា
មនុស្សដែលមានបដិវេធអធម្មនេះ តែងបង្កសេចក្តីវិនាសដែលមិនទាន់
កើតឲ្យកើតឡើង តែងបង្កើតសេចក្តីវិនាសដែលកើតមានស្រាប់ហើយ
ឲ្យវិនាសតែតែវិនាសតទៅទៀត, បុគ្គលនោះស្លាប់ទៅ ទៀងតែទៅកើត
ក្នុងនរកទៀត ។

បប់ធម៌ខុសក្នុងផ្នែកទី ៣ ។

ឯម្មាឧម្មកថា សង្ខេបេន សង្ខតា ការសំដែងអំពីធម៌ត្រូវ
ធម៌ខុសសន្តតថាបប់ដោយសង្ខេបប៉ុណ្ណោះ ។

សូមសំរែកស្តីកើតមានដល់ក្រុមសប្បុរសអ្នកស្តាប់ អ្នកប្រតិបត្តិ
តាមគាថាអស់គ្នា សព្វកាលវេលាជាដរាបទៅ ។

ព្រះមហាសោម-ទ្បុប ក្រុមជំនុំព្រះត្រៃបិដក

សំដែងនៅថ្ងៃសៅរ៍ ១៤ កើតខែភទ្របទ ឆ្នាំខាលចត្វាស័ក ពុទ្ធសករាជ ២៤៨៥

(៤ កញ្ញា ១៩៤២)

វិបត្តិកថា

ឧភោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

លំដាប់អំពីនមស្សការមក សូមស្រែងលើកយកវិបត្តិ ៦ ប្រការ ដែលព្រះបរមសាស្តាទ្រង់សំដែងទុក ដើម្បីនឹងផ្សាយចែកជូនដល់អស់លោកអ្នកសប្បុរសទាំងឡាយ ចាន់ជាដ ។

ក៏ពាក្យដែលហៅថា វិបត្តិ។ នេះ ប្រែថាវិនាសទៅ ថាប្រែប្រួលទៅមិនចាន់តាំងនឹងនៅដូចធម្មតា គឺថាវេស់ណាធ្លាប់មាន ត្រឡប់ទៅជាគ្មាន ធ្លាប់សុខត្រឡប់ទៅជាទុក្ខ ធ្លាប់ធំត្រឡប់ទៅជាតូច ធ្លាប់ខ្ពស់ត្រឡប់ទៅជាទាប ប៉ុណ្ណេះជាដើមហៅថាវិបត្តិ ។

ឯវិបត្តិទាំង ៦ ប្រការនោះគឺ គតិវិបត្តិ វិបត្តិគតិ ១ កាលវិបត្តិ វិបត្តិពេលវេលា ១ ទេសវិបត្តិ វិបត្តិស្រុកទេស ១ កុលវិបត្តិ វិបត្តិត្រកូល ១ ឧបធិវិបត្តិ វិបត្តិរាងកាយ ១ ទិដ្ឋិវិបត្តិ វិបត្តិទិដ្ឋិ ១ ។

ត្រង់គតិវិបត្តិនេះ ១ សេចក្តីអធិប្បាយថា បុរសបុគ្គលក្នុងលោកនេះកម្រមានគតិគឺដំណើរដែលទំនងត្រូវមរណកាលទៅវិញឲ្យជាន់ខ្ពស់ឬទុ

ស្រួលតេកណាស់ ព្រោះនៅក្នុងលោកមនុស្សយើងតែងតែឃើញសត្វដែលមានកាយក្លាយទៅតាមកម្មអាយុយូរមិនខ្លី តែងតែមានកាយធំ តូច ខ្លី វែង ខ្ពស់ ទាប ស្តើង ក្រាស់ ខ្មៅ ស ជាដើម ។

ចំណែកខាងនរក ប្រែត អសុរកាយ តាំងពីអស់លោក-អ្នកតាំងពីឋានតូចរហូតដល់ឋានធំ ក៏ពុំដែលបានឃើញជាក់ច្បាស់ដោយភ្នែកមនុស្សយើងដែរ ទោះបីយ៉ាងណាក៏ដោយ ក៏មានរឿងរ៉ាវនិទានច្រើនសន្ធឹកសន្ធាប់ ដែលព្រះពុទ្ធជាម្ចាស់ ព្រះអរហន្តទាំងឡាយ ព្រះបច្ចេកពុទ្ធ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ប្រទានទេសនាប្រាប់ដល់ពុទ្ធបរិស័ទ ដើម្បីឲ្យបានដឹងច្បាស់ ហើយមិនត្រូវធ្វើអំពើបាបដែលនាំឲ្យទៅកើតក្នុងនរកនោះឡើយ ។

ដូចនេះ ខ្ញុំសូមលើកយកតែពួកតិរច្ឆានមកសំដែង ព្រោះសត្វតិរច្ឆានទាំងនោះ ក៏ជាសត្វដែលមនុស្សយើងតែងតែឃើញច្បាស់ដោយភ្នែកជារៀងរាល់ថ្ងៃ ដូចជា ក្តាន់, ខ្លា, ខ្លែង, ខ្លាឃ្មុំ, ខ្លាឃ្មុំ, ក្តាន់, ជ្រូក, គោ, ក្របី, ដំរី, សេះ, ប៉ាណ្ដែ ជាដើម ជាសត្វបាកតាចបំផុត មិនស្គាល់ខុសត្រូវគុណសម្បត្តិ ឬបុណ្យបាបអ្វីឡើយ ហើយតាំងមិនមានចេតនាដឹងថាកន្លងព្រះពុទ្ធ ព្រះធម៌ ព្រះ

សិក្ខ ទំនិតនស័ណ្ឋាវនា ពាន់ចំណេះវិជ្ជាផ្លូវលោកផ្លូវធម៌ក៏ឥតបានចេះ
ដឹងបន្តិចបន្តួច ចំណែកខាងឯនាមឈ្មោះក៏ចាត់ពីកេះពីសា សព្វថ្ងៃនេះ
មនុស្សលោកច្រើនហៅមី ហៅគា ដោះប្រទេចផ្តាសាតាមទំនើងចិត្តឥត
មានខ្លាច នេះដោយអំណាចអំពើទុច្ចរិត ដែលខ្លួនប្រព្រឹត្តផ្ទេរពីឥឡូវប្តូរ
ជាតិមុនមកពាន់ជាប៉ុន្មាន ទើបផលកម្មនោះដឹកនាំឲ្យកើតជាតិក្នុង កម្ម
ដ៏បានរួចមកកើតជាមនុស្សវិញឡើយ នេះឯងហើយហៅថាតតិវិបត្តិ ។

ត្រង់កាលវិបត្តិទី២សេចក្តីអធិប្បាយថា ការវិបត្តិពេលវេលា ពេល
វេលាណាមានព្រះពុទ្ធត្រាស់ក្នុងលោក សំដែងធម៌ទេសនាប្រោសពួក
ពុទ្ធបរិស័ទនានា ជនពាន់នោះក៏កើតសទ្ធាជ្រះថ្លាបានសម្រេចមគ្គផលពុំ
អាចនឹងពណ៌នាបាន ចំណែកពួកជនដែលឥតកំព្រ ឥតសំណាងពាន់ប៉ុន្មាន
ក៏អាក់ខានមិនបានកើតទាន់ពេលវេលា ដែលព្រះពុទ្ធត្រាស់នោះឡើយ
ត្រឡប់ទៅកើតក្នុងអបាយភូមិ ឬក៏កើតក្នុងសុញ្ញកាលទៅវិញ គឺកាល
ដ៏សូន្យ គ្មានព្រះពុទ្ធ បច្ចេកពុទ្ធ ស្តេចចក្រ ពួកមនុស្សក្នុងពេលនោះ
លោកហៅថាកាលវិបត្តិ ។ ពុំនោះសោតទេ ដូចកាលពីដើមមុន ៤០ ឆ្នាំ
មកក្នុងកម្ពុជរដ្ឋយើងនេះ មិនសូវមានលោកអ្នកប្រាជ្ញណាចេះដឹងខាងផ្លូវ
ព្រះពុទ្ធសាសនានឹងពន្យល់ធម៌អាថិសក្ខាវិនិយ ពាន់ចំណេះវិជ្ជាទំនើបថ្មី
ក៏ពុំសូវមាន ម្ល៉ោះហើយមនុស្សក្នុងពេលនោះ ច្រើនខ្វាត់ខ្វាយចំណេះ
វិជ្ជា បើនិងចាត់តាមពេលវេលា ក៏ហៅថាវិបត្តិមួយដែរ តែឥឡូវកែជាការ

ចាន់ចំនុកបំរុងរៀបចំគ្រប់នាទីដំណែងឲ្យបានរៀបរយ មិនឲ្យមានឃ្លៀងឃ្លាត ពួកទេវមារដៅតិតិកានតែចាន់ចេះដឹងច្រើនគ្នា ជនអ្នកមានកំពូលមានសំណាង កើតមកច្រើនចាន់ជួបប្រទះនឹងពេលវេលាល្អ ជនណាដែលគ្មានកំពូលគ្មានសំណាងទេ ជនគោះច្រើនកើតមកជួបប្រទះនឹងពេលវេលាមិនល្អ ដួចចាន់ថ្ងៃនិរៀបរាប់មកពីខាងដើមមិនសូវចាន់សេចក្តីសុខសេចក្តីចំរើនទេរួយ នេះហើយហៅថាកាលវិបត្តិ ។

ត្រង់ទេសវិបត្តិទី ៣ នោះ សេចក្តីអធិប្បាយថា ស្រុកទេសណាដែលសូន្យចាកព្រះពុទ្ធសាសនាគឺគ្មានធម៌អាចិសិក្ខាវិន័យ ចាំងគ្មានបព្វជ្ជាប់សម្រាប់ផែនដី ដើម្បីនឹងចំក្លឹជនចាំងពួងឲ្យចាន់ចេះដឹងសេចក្តីចុះស្រុកស្រុកទេសនោះ ។ ហៅថាទេសវិបត្តិ ។

ពុំនោះសោតទេ ស្រុកទេសនោះ ។ មានព្រះពុទ្ធសាសនា ចរិយាបូណ្ណិត្រឹមត្រូវដោយល្អមឲ្យអ្នកផងប្រតិបត្តិមិនឲ្យលំអៀងឃ្លៀងឃ្លាតចាំងបព្វជ្ជាប់សម្រាប់ក្សត្រិយទេសជាតិ ក៏មានគ្រប់គ្រាន់ចាំងអស់ ប៉ុន្តែមកមានចំនាស់ដោយសេចក្តីអន្តរាយគឺកើតចំចាំងពាំងវល់ឬក៏កើតខុវិក្ខត្រអត់ចាយ ប្រជាជនចាំងឆ្ងាយចំផ្លែស្រែចំការក៏ពុំសូវចាន់ផលបរិបូណ៌ ចំណែកខាងពួកអ្នកមូលដ្ឋានភូមិស្រុកក៏ច្រើនតែខាតមិនចំណេញ ទើបុគ្គលណាជាចំរកជនជាន់ចាន់តិចច្រើន ក៏លំបាកព្រួយចិត្តនឹងថែទាំរក្សាគ្រប់ពេលវេលាជួនកាលពួកចោរវៀនាំគ្នាមកលួច ប្លន់ ឆក់ ប្រវ័ញ្ចដំណើរយកតតមាន

កំណាត់ ចើនដងនិយាយឲ្យឃើញជាក់ច្បាស់ច្បាកដដូចកម្ពុជរដ្ឋប្រទេសយើងនេះពីដើមមក អ្នកក្រែង អ្នកចំការ អ្នកស្រែ ច្រើនតួញាត្តែរពីរឿងចោរលួច ចោបួន ពួកចស្លែចាំងប្រុសស្រីក៏តេតទុក្ខព្រួយចិត្តគ្រប់ពេលវេលា ដោយសារកដការជួយការពារ ទើបចស្លែចាល់គ្នាចានសេចក្តីសុខស្រួល ។

ពុំនោះសោត ស្រុកទេសនោះ។ ពីដើមដ្ឋាប់ចានសេចក្តីសុះសប្បាយថ្កុំថ្កើងរុងរឿងហិកហាក់ លុះដល់គ្រាគ្រោយមកទទួលគ្រោះថ្នាក់ដោយសត្រូវមកបៀតបៀនធ្វើឲ្យវិនាសអន្តរាយ ជាចចាល់តែក្លាយទៅជាស្រុកដុនជាបវនទុក្ខវេទនាតែម្តង ជនដែលតេតមកដួចប្រទះនឹងសម័យស្រុកទេសបែបនោះឯង កំរែងចានសេចក្តីលំបាកវេទនាកម្រនឹងចានស្រាកស្រាន្តឡើយ នោះឯងហើយហៅថាទេសវិបត្តិ ។

តន់កុលវិបត្តិ ៤ សេចក្តីអធិប្បាយថា វិបត្តិតកូលក្នុងគ្រាពុទ្ធសម័យលោកចែកតកូលចាំងនោះទៅជា ៤ យ៉ាងគឺ ខត្តិយកុល តកូលក្សត្រិយ៍ ១ ព្រាហ្មណកុល តកូលព្រាហ្មណ៍ ១ វេស្សកុល តកូលអ្នកធ្វើស្រែចំការនឹងការលក់ដូរ ១ សុទ្ធកុល តកូលស៊ីឈ្នួល ១ ។

បណ្តា តកូលចាំង ៤ នោះ តកូលក្សត្រិយ៍ នឹង តកូលព្រាហ្មណ៍ ចាត់ថាជាតកូលខ្ពង់ខ្ពស់ប្រសើរ ឯជាតិព្រាហ្មណ៍នោះមិនសូវដឿព្រះពុទ្ធសាសនាទេ ច្រើនដឿតែលទ្ធិក្រៅព្រះពុទ្ធសាសនា ដូចសាសនា

ព្រហ្មជាដើម ព្រាហ្មណ៍ចូលចិត្តជាប់ជំពុតដោយយល់ថាព្រហ្មអាចបង្កើតដីទឹក ភ្លើង ឲ្យសត្វសត្វអាស្រ័យនៅបាន ហើយខាងបានប្រកាន់ថាជាតិព្រាហ្មណ៍ខាងប៉ុន្មានសុទ្ធតែកើតមកពីព្រះឧស្ហព្រហ្ម ជាតិក្សត្រិយ៍កើតមកពីខ្នងព្រហ្ម ជាតិវេស្សអ្នកស្រែចំការកើតមកពីស្មាដើងព្រហ្ម ជាតិសុទ្ធអ្នកស៊ីឈ្នួលកើតមកពីទ្វង់ដើងព្រហ្ម ជាតិសមណៈអ្នកបួសកើតមកពីជាន់ដើងព្រហ្ម ព្រោះហេតុនោះ បានជាពួកព្រាហ្មណ៍ច្រើនគោរពកប់អាន្តព្រហ្មជួបព្រះ ។

ចំណែកខាងត្រកូលដែលថោកទាបជាងគេបំផុតនោះគឺ ត្រកូលសុទ្ធអ្នកស៊ីឈ្នួល មានន័យថាខាងត្រកូលចណ្ឌាល ត្រកូលបក្កុសអ្នកបោសសម្រាមប៉ុណ្ណោះជាដើម ចាត់ថាថោកទាបជួបគ្នា ថោកទាបខាងឫកទាមារយោងខាងដើរឈរអង្គុយនិយាយស្តីគប់ឃាត់ ហើយច្រើនខ្ជាត់ខ្ជួយខ្ជាត្យសម្បត្តិមិនសូវបានបរិបូណ៌ត្រប់ត្រាន់ ខាងមិនសូវមានអាកប់អានជាមុខជាមាត់ឡើយ នេះហើយហៅថា កុលវិបត្តិ ។

ត្រង់ឧបធិវិបត្តិនិ ៥ សេចក្តីអធិប្បាយថា ជនចំពួកខ្លះកើតលោកនេះមានរូបកាយមិនបរិបូណ៌ ច្រើនតែវិបត្តិខ្លះអាតអាយតនៈឥន្ទ្រិយ មិនគេញជាប្រុសជាស្រីកើតវិកលវិការៈផ្សេង ។ ខ្លះទៅជាមនុស្សខ្ទើយ មនុស្សកេងពិរ មនុស្សត្រ ថ្ងង់ ខ្វាក់ ខ្វិន ក្រែងក្រង់ កំពិកកំតាត ក្រញ្ជក្រពិតអាក្រក់លាមកដូចគាប្លែកៗ ខ្លះកើតយ្លង់ ស្រែង ហឺតរេង កំបុតដើង

កំបុតដៃ កំបុតស្វាំតែម្យ៉ាក កំបុតច្រមុះ ប៉ុណ្ណោះជាដើម មនុស្សម្នាបែប
នេះលោកហៅថា បរិសេសកៈ មនុស្សខ្វះស្ពឹងបរិស័ទ គឺគ្មានបរិស័ទ
ណាចូលចិត្តស្រឡាញ់កប់អានឡើយ នេះហើយហៅថាឧបធិវិបត្តិ ។

តែងពិដ្ឋិវិបត្តិទី ៦ សេចក្តីអធិប្បាយថា ជនចំពួកខ្វះកន្លងលោកនេះ
ច្រើនច្រែតាំងតែជ្រុលខុសផ្លូវមិនត្រូវតាមច្បាប់ព្រះពុទ្ធដីកាបានជាតិឆ្ងាយ
ពេក ឆ្ងាយពេក ឆ្ងេងៗពេក ស្កាំៗពេក ឥតបានត្រូវលើផ្លូវល្អត្រង់
ណា ពិដ្ឋិនេះបើចាត់ចែកតាមបទមាតិកាលោកថ្លាប់ថាមានអង្គ ៨ គឺ មិច្ឆា-
ទិដ្ឋិ ១ មិច្ឆាសង្កប្បោ ១ មិច្ឆាវាចា ១ មិច្ឆាកម្មន្តោ ១ មិច្ឆាអាជីវោ ១
មិច្ឆាវាយាមោ ១ មិច្ឆាសតិ ១ មិច្ឆាសមាធិ ១ ។

សេចក្តីថា កាលបើគំនិតយល់ខុសហើយ ត្រិះរិះក៏ខុស កាលបើត្រិះ-
រិះខុសហើយ និយាយក៏ខុស កាលបើនិយាយខុសហើយ ធ្វើអំពើអ្វីក៏ខុស
កាលបើធ្វើអំពើអ្វីខុសហើយ ចិញ្ចឹមជីវិតក៏ខុស កាលបើចិញ្ចឹមជីវិតខុស
ហើយ ព្យាយាមក៏ខុស កាលបើព្យាយាមខុសហើយ សតិក៏ខុស កាល
បើសតិខុសហើយ សមាធិ ការដំកល់ចិត្តឲ្យនឹងនៅក្នុងអារម្មណ៍នោះៗ ក៏
ខុសទៀត សេចក្តីដូចបានរៀបរាប់មកប៉ុណ្ណោះជាដើម ហៅថាទិដ្ឋិវិបត្តិ ។

សំដែងមកអំពីរឿងវិបត្តិទាំង ៦ ប្រការ កំសន្មតិថាចប់ដោយ
សង្ខេប, សូមឲ្យព្រះពុទ្ធសាសនានឹងពុទ្ធបរិសទ្យអ្នកស្តាប់ធម៌បានសេចក្តី
ចំរើនសព្វៗ កាលរៀងទៅ ឯរំ សម្មន្តរតាមវោហារប៉ុណ្ណេះឯង ។

អំពីដំណើរជីវិតនៃពួកសត្វល្អិត ។

តាមសេចក្តីពិនិត្យរបស់អ្នកប្រាជ្ញធំជាតិបារាំងសែសម្នាក់

លោកអ្នកប្រាជ្ញនេះឈ្មោះ សង-ហង់រ៉ី-ហ្វាប្រ៍(Jean Henri Fabre) កើតក្នុងឆ្នាំ ១៨២៣ អនិច្ចកម្មក្នុងឆ្នាំ ១៩១៥ ។ លោកជាអ្នកប្រាជ្ញធំមួយ ដែលបានទុកសជីវិតរបស់លោក ក្នុងការពិនិត្យពីដំណើរជីវិតនៃសត្វល្អិត ។ ។ នៅគ្រាសន្លើបុណ្យអាយុរបស់លោកគំរប់ ១០០ ឆ្នាំ គេបានចាត់ចោះតុម្ពអស់ពាន់រឿនក៏ដោយ ដែលជាសេចក្តីពិនិត្យរបស់លោក ហើយមានសម្ងាញ់របស់លោកម្នាក់ បានតែងប្រវត្តិដ៏ថ្លៃថ្លា ប្រសើរនេះ ដែលធ្វើការងារដោយមិនប្រាថ្នាមាសប្រាក់ទេ តែជាប្រយោជន៍ដល់វិទ្យាសាស្ត្រពាន់ឆមូល ។ កាលលោកនៅជាកុមារនោះ លោកគោរធ្វើការជាកម្មករសម្រាប់ចិញ្ចឹមជីវិត ហើយគិតតែខាងសប្បាយរីករាយជាច្រើនប៉ុន្តែនៅគ្រាសន្លើនោះ លោកបានពិនិត្យពិចារណាមើលពួកសត្វល្អិត ។ ដែលមាននៅតែក្បែរខាងលោក ។ លុះលោកសិក្សាពិនិត្យសព្វគ្រប់ហើយ ទើបប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ សម្រេចហើយទើបបានធ្វើជាគ្រូបង្រៀនក្នុងឆ្នាំ ១៨៤២ ឬក្នុងពុទ្ធសករាជ ២៣៨៥ ដោយបានទទួលប្រាក់ត្រក្នុង ១ ឆ្នាំ ៧០ រៀល តែតមានប្រាក់ត្រប៉ុន្តែតិចផង ។ សេចក្តីស្រឡាញ់ការពិនិត្យនេះហើយ ដែលនាំឲ្យលោកខិតខំព្យាយាមស្វែងរកចំណេះចេះដឹង ដោយមិនកន្ទុលដល់បង់ចិញ្ចឹមជីវិតរបស់ខ្លួនប៉ុន្មានឡើយ

ដូចលោកបានសរសេរសំបុត្រមួយដល់បងលោកថា "វិទ្យាសាស្ត្រមែនមានសុទ្ធតែប៉ាំងអស់" លុះលោកប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាពីវ៉ាក់ រួចទើបប្រឡងយកសញ្ញាប័ត្រឧត្តមសិក្សាផ្នែកវិជ្ជាលេខនិងវិទ្យាសាស្ត្រហ្វីស៊ីក ។ តមកលោកមានគ្រួសារ ការចិញ្ចឹមជីវិតក៏លំបាកពន់ពេក (ដោយមិនបានដល់ប្រយោជន៍គ្រប់គ្រាន់) ។ គេបានចាត់បញ្ជូនលោកទៅនៅកោះកស៍ នៅខាងត្បូងមហានគរបាំងសែសដើម្បីបង្រៀនវិជ្ជាហ្វីស៊ីកនៅវិទ្យាល័យ ក្នុងទីក្រុងអាស័កស្យូ ។ លោកនៅទីនោះ ក្រៅពីការបង្រៀនលោកបានពិនិត្យសិក្សា អំពីព្រឹក្សជាតិនៅកោះកស៍ លោកនៅក្នុងកោះនេះជាវេលា ៤ ឆ្នាំ ។ កាលលោកត្រឡប់មកមហានគរបាំងសែសវិញ លោកប្រឡងយកសញ្ញាបត្រជាន់ខ្ពស់ ផ្នែកវិទ្យាសាស្ត្រធម្មជាតិជាប់ថ្នាក់ខ្ពស់ ព្រមទាំងសេចក្តីសរសើរជាអនេកប្រការ ។ លោកនេះមិនបានឈប់បង្ហើរ នៅត្រឹមកិត្តិយសនិងសញ្ញាប័ត្រដែលលោកបានទទួល លោកនៅខំធ្វើការពិនិត្យសិក្សាតទៅទៀត ហើយលោកជាប់ចិត្តបែរទៅខំសិក្សា អំពីដំណើរជីវិតនៃសត្វល្អិតៗដែលមិនទាន់មានគេចេះដឹងច្រើននៅឡើយក្នុងសម័យនោះ ។

ដល់មកក្នុងឆ្នាំ ១៨៥៥ លោកមានអាយុគ្រប់ ៣២ ឆ្នាំ បានរៀបការជាមួយនឹងកូនស្រីនាវរដ្ឋវិទ្យាសាស្ត្រ និយាយពីទម្រាំលំបាកធំរឿងនេះហើយដែលទាំងអ្នកច្បាស់ធំ ។ ដាកមកយកចិត្តទុកដាក់ខ្លាំង

លោក ។ ទុកជាយ៉ាងណាក៏ដោយលោកនៅតែធ្វើត្រកូលមួយ នៅ
ខែក្រុលំយកវិញ្ញាងជាវេលា ២០ ឆ្នាំ ។ នៅទណ្ដោះនោះ ការចំញ៉ែមត្រួសារ
របស់លោកលំបាកច្រើន ទើបលោកត្រូវតែទៅធ្វើការបន្ថែមទាងក្រៅ
ខែតផង តាមនេះកាងមិនឲ្យលោកសិក្សាខែ្មសាស្ត្ររបស់លោកតទៅ
ខែត ។ លោកបានចូលទៅក្រុងបារីសជាដំបូង ដើម្បីប្រឡងយក
សញ្ញាបត្រជុកគ្លាងនៃវិទ្យាសាស្ត្រធម្មជាតិ ។ ក្រោយដែលបានពិនិត្យ
យ៉ាងពិតប្រាកដហើយ ទើបគេតំណាត់ឲ្យភ្នាល់យ៉ាងខ្លាំមួយឲ្យលោក
ជាភ្នាល់ដែលអ្នកប្រាជ្ញត្រូវបាន ។ តាមពីនោះមក ទើបលោកមានសិស្ស
តណាចោមរោមគោរពបូជាលោក ។ គេបានបំពាក់មេដែយខ្សែស៊ីយ៉ង-
ដូណ្ដើរឲ្យលោក ហើយគេនាំលោកចូលតាល់ព្រះចៅកជាជាងជ ។
ឯខ្លួនលោកនៅតែស្ម័គ្រចិត្តទៅនៅកងចំណោមសត្វល្អិត។ ហើយនៅតី
បំផុតនៃជីវិតរបស់លោក។ ជាកខ្លួនថយទៅនៅស្រុកកែ្រស ។

ឯសៀវភៅរបស់លោកជាដំបូងហៅថា ទំរើកនៃជីវិតទន្លឹងខ្លួ
តំនៀមនៃសត្វល្អិត។ ជាសៀវភៅយ៉ាងសំខាន់ ១ ក្នុងប្រវត្តិការណ៍នៃ
វិទ្យាសាស្ត្ររបស់លោក ។ ដើម្បីបង្ហាញឲ្យយើញថ្លៃដែរបស់លោក
អ្នកប្រាជ្ញធំនេះ យើងសូមស្រង់យកសេចក្តីពិនិត្យខ្លះរបស់លោក ដែល
និយាយអំពីសត្វល្អិត ។ ចំពួកខ្លះមកតោលទុកក្នុងទំនេះ :

អំពីពីងពាងក្តាម

ដែលគេហៅឈ្មោះដូច្នេះ ព្រោះដងខ្លួនវាមានទ្រង់ទ្រាយដូចដងខ្លួនរបស់ក្តាម វាដើរថយក្រោយ ។ ខ្លួនដូចជាក្តាមដែរ ដើមមុខវាមានសណ្ឋានដូចក្តាម ហើយមាំមួនជាងដើមគ្រាយ ។ វាតែងទៅសម្ងំចាំនៅតណ្តាលចំណោមផ្កាឈើ ចាប់សត្វដែលជាអាហារចំណីរបស់វាជាតិសត្វល្អិត ។ ដែលវាចូលចិត្តជាងគេគឺសត្វឃ្មុំ វាតែងចាប់ឃ្មុំមិនឲ្យឃ្មុំកម្រើកកន្ទុយបាន ដ្បិតកន្ទុយឃ្មុំមានទ្រនិចគាចចិចវាឲ្យស្វាប់បាន លុះវាជញ្ជក់យកឈាមឃ្មុំអស់ហើយ ទើបវាទម្លាក់ខ្មោចឃ្មុំដែលស្វាប់ហើយចោលទៅ ។ តាមធម្មតា ពីងពាងតែងមានពោះធំជានិច្ច ដែលមានសរសៃមង់សម្រាប់ធ្វើសំបុករបស់វា ។ ពីងពាងប្រភេទនេះ មិនចូលចិត្តអាកាសត្រជាក់ទេ ទើបគេឃើញមានសត្វចំពូកនេះនៅតែក្នុងប្រទេសចាំងសៃសៀមតែប៉ុណ្ណោះ ហើយវាចូលចិត្តទៅនៅតែតន្លៃណាដែលសំបូរផ្កា ហើយពួកសត្វឃ្មុំតែងនាំគ្នាមកជញ្ជក់ជាតិផ្កា ។ ឯសរីរាង្គរបស់ពីងពាងប្រភេទនេះមានព័ណ៌សប្បាយភ្នែក ដើមវាជាកន្ទុយមួយៗ ព័ណ៌ស្ពឺកុលាប ហើយលើកន្ទុយធ្នឹងខ្លួនមានក្រឡាក្បាច់ចាក់ក្រហមចាស់ហើយនៅខាងៗ ដើមក្រចកមានក្រឡាសំណាញ់ស្តើងៗ មានព័ណ៌ខៀវដូចផ្លែខៀវ ។

ក្នុងរដូវដែលសត្វព័ទ្ធពាន់នេះមានពន្ធ ក៏តែងរើសរកទំនៅលើផ្ការ
ជាទីខួលខ្ពស់ៗ មានស្មឹកឈើស្ងាប់ខ្លះផង ឬស្មិតដោយកំដៅថ្ងៃ ទើប
ព័ទ្ធពាន់ក្តាមនេះខ្លើន ។ ចុះ ។ ហើយមានសរសៃទៅនឹងពោះរបស់ក
ក៏ធ្លើផ្ទៅកមួយមានព័ណ៌សសាអែម ។ កាលក៏មានពន្ធខ្លើន ទើប
មានជាតំរមួយចំនួនមាត់ផ្ទៅកយ៉ាងដិតស្និទ្ធ រួចក៏ចាញសរសៃមធ៌ាបើ
សរសៃព័ទ្ធពាន់លើពន្ធ ធ្វើជាបន្ទប់ខ្ចាតគូបសម្រាប់មេរ៉ា ដ្បិតទៅខាងក្រ
មានពន្ធនេះមានសេចក្តីនឿយហាត់ច្រើន ដោយហេតុពាយមន៌ធ្វើសំបុក
និងកន្លែងដែលរបស់ក៏ ហើយមេព័ទ្ធពាន់នេះ ក៏តែងរក្សាមិនឲ្យសត្វដទៃ
មកចៀតចៀនពន្ធក៏បាន ។ លុះដល់ដាច់ខែមេ៉ កំពូតពន្ធក៏អស់ត្រឹម
នេះ ដល់កំពូតក្បាស់ពន្ធតទៅ ខណៈនោះ មេព័ទ្ធពាន់មិនចេញព័ទ្ធ
កន្លែងទេ ពាំងមិនបរិភោគអាហារសោះឡើយ ហើយខ្លួនមេក៏ដិតនឹងដាច់
ខ្សល់ស្ងាប់ផង លុះតែកាលណាកូនគូប ។ និងចេញព័សំបុក ទើបមេក
ចេីកសំបុកឲ្យកូនគូប ។ ចេញមក ហើយទៅវេលា ៥ ដល់ ៦ ម៉ាងទ្បាយ
មេក៏បានរង៌ចាំមិនគំរើកខ្លួន មិនថាមានអ្វីមកប៉ះពាល់ដល់ខ្លួនក៏ រហូត
ដល់ខែស្រូវយេត ទើបកូនគូប ។ ចេញ (ពីសំបុកពន្ធ) ហើយ ខ្លើនចុះទៅ
រកផ្កាឈើដោយកំដៅថ្ងៃ ទើបកូនគូប ។ នាំគ្នាធ្វើមង៌ព័ង៌ពាង៌ កាល់ៗដង
តែង៌មានព័ង៌ពាង៌ ៣-៤ ចេញទៅចង៌មង៌ព្រមគ្នា ក៏តែងខ្លើនទៅខ្ពង់ខ្ពាក់

ខ្ទមខ្លាយសរសៃមនុស្សជាមួយ ហើយគេធ្វើឲ្យឆាសពេញ គេ
ឲ្យចូលតាមគុម្ពស្មៅចាត់អស់ទៅក៏មាន ។

អំពីសត្វរៃនឹងស្រមោច

កន្លែងស្ងួតត - រសៀលថ្ងៃត្រង់ជាក់ - ជារសៀលស្អុះស្អាប់ លុះដល់
រសៀល ទើបសត្វរៃទាំងគ្នាស្រែកច្រៀងគ្រហឹមអឺងកងជានិច្ច ទៅលើ
មែកនៃដើមឈើគួច ។ ដែលវាចោះសំបកឈើឲ្យប៉ោងចេញទឹកដមឬជ័រ
ទើបវាយកទន្ទិចជញ្ជក់ជ័រឬទឹកដមដែលហូរចេញមក ទឹកដមនេះហើយ
ដែលនាំឲ្យសត្វល្អិត ។ ជារច្រើន ដែលស្រែកទឹកដែរនោះមកចោមកោម
ជិត ក្នុងចំពួកសត្វអស់នេះ មានស្រមោចមកចូលផង ។ ស្រមោចវាទាំរៃ
តាមដើងឬតាមស្លាប រាវឡើងទៅលើខ្នងហើយទាំទន្ទិចរៃ ឯរៃក្រែវស្រ-
មោចបៀតបៀនខ្លាំង ក៏ភួតចេញពីកន្ទែងនោះលេចនោមផង ។ លុះ
៥-៦ អាទិត្យ រៃក៏ធ្លាក់ចុះពីចុងឈើខ្ពស់មកស្លាប់ទៅ ហើយថ្ងៃក៏កំដៅ
ខ្លោចរៃឲ្យស្ងួតទៅ ស្រមោចក៏មកទាំកាត់ជាចំរៀកល្អិតៗ ហើយជញ្ជូន
ទៅខ្ទុកធ្វើជាស្បៀងអាហារបស់វាតទៅថ្ងៃក្រោយ ។

អំពីសំឡេងរៃយំ

ដើមទ្រូងសត្វរៃគាតក្រោយមានដើងមុខក្រោយ នៅចំណែកខាង
ក្រោយមានអវយវៈមួយ មានសណ្ឋានជាកន្ត្រកតូចមួយកំណាត់ ខាង

ទ្វេនពាក់តង់លើកំណាត់ងាងស្តាំបន្តិច ។ គាលណាវាបន្ថើបអាយវាខេះ
ខ្លៀង ទើបគេសង្កេតយើញរណ្តៅខ្លងមួយទល់នឹងគាគងាងមុខ ដែល
មានអាយវាះស្តើងខន់មានតំណាំសឿនចាស់ ហើយនៅងាងគ្រាយរណ្តៅ
នេះមានសែកស្តើងដែរ ហើយមានតំណាគ្រប់ងាណាមានសណ្ឋានដូចជា
តពុះទឹកត្រែវពន្ធូថ្ងៃ ។ អាយវាះអស់នេះហើយ ដែលបង្កើតឲ្យមានសូរ
សារម្ងនខ្លៀង ។ គ្រង់កន្ទែងគោះទន្លឹងខ្លងជាប់គ្នាគោះមានន្តួចមួយ
ហើយមានជាផ្លូវបើលទៅកន្លែរណ្តៅខ្លងមួយទៀត កន្ទែងនេះហើយដែល
ជាគ្រឿងបង្កើតឲ្យមានសូរសំឡេងខ្លៀង គ្រង់នេះជាអាយវាះមួយដែរ។
តំណាស កោងខុលចេញក្រៅភ្លឹកភ្លក់ នៅងាងបុងសរសៃប្រសាទទ្វេ
ឲ្យញ៉ាវញ្ជាយតិបុតបោងជាន នេះហើយដែលធ្វើឲ្យកើតសូរសំឡេងកង
តែងហើយធ្វើឲ្យកង់តាំងតាញ៉ាវដែង ។

ប្រសិនបើអាកាសស្ងប់ហើយក្តៅដង សូរសំឡេងវៃយ៉ាងមានឃ្លាមាន
ល្បះល្អស្តាប់ កង១០នាទីយ៉ាងខ្លៀងម្តងហើយឈប់ម្តងហើយយ៉ាងនេះខ្លៀង
ដល់ទៅបុងបង្ហើយកាន់តែស្រែកខ្លាំងខ្លៀង ។ ហើយកាន់តែញាប់ណាស់
ដង ហើយតមកពី១០នាទីទើបបន្ថយសូរស្រែកឲ្យតិច ។ គាល់តែគោះវាលែង
បើកបិទតទៅទៀតទើបសម្រាក ។ រួចតមកសត្វវៃកើតាប់ផ្តើមស្រែកសាន
ខ្លៀងវិញ ដល់ទៅវេលាល្ងាចយប់ស្ងុះស្ងាប់ សូរស្រែកយ៉ាងនៃសត្វវៃតែង
តែមានជាខិច្ចដែរ តែសំឡេងយ៉ាងតិងៗ ជួរៗខ្លីៗ រៃងៗ ។ ម៉ាន្តប្រសិនបើ

មេឃខ្ញុំមិនបើឲ្យលក់ត្រដាក់បក់មកភ្ញាក់ឯសត្វនៃមិនដែលយំទេ ។ ចុះហេតុអ្វីទើបសត្វនៃវាយំដូច្នេះ អ្នកច្បាប់ដែលរុករកហេតុផលតាំងពីដើមរហូតមកដល់ឥឡូវនេះ ក៏ពុំមានអ្នកច្បាប់ណាមួយអធិប្បាយឲ្យដាក់ច្បាស់បានឡើយ ។

អំពីសេចក្តីមេត្តានៃសត្វកណ្តុបសេះ

តាមធម្មតា សត្វកណ្តុបសេះជាសត្វស្លូត តែងមានមេត្តចិត្តនឹងសត្វជនៃ គេមិនដែលឃើញកណ្តុបសេះ សំដែងអាការសាហាវដូចជាសត្វពីងពាងដែលកាច ។ ឧទាហរណ៍ ។ កណ្តុបសេះត្រប់ ។ តួ តែងចាប់ស៊ីរបស់ដែលនៅជិត ។ ខ្លួន ឥតចេញទៅរុករកកាសរួសញាតមិត្រជិតខាងឡើយ ប៉ុន្តែកាលណាមេវាមានពងនៅក្នុងពោះហើយមានផ្ទៃពោះចាស់ផង ។ ។ ណៈដែលមេកណ្តុបសេះជិតចេញពងតាមផ្លូវរបស់វា នេះហើយដែលកណ្តុបសេះត្រប់ ។ តួ ទៅជាសត្វកាច វាតែងបង្កិលក្បាលងាកឆ្វេងងាកស្តាំ វាតែងគន់នឹងសត្វជិតខាង វាយារដើងផ្លាត់ទៅខាង ។ ឲ្យចំដងខ្លួនរបស់សត្វជាសត្រូវ រួចវាលាដើង ។ លើកឡើងធាក់ច្រៃ ទៅគួសត្រូវវាជាច្រើនដើង ខាងសត្រូវវាក៏តបតគន់វាមកវិញដូចគ្នាដែរ ដល់ត្រូវបួសជាដំបូងទើបវាដកខ្លួនថយចេញទៅ ។ មានច្បាប់កាលការតគន់គ្នានេះមានដល់ស្លាប់ក៏មាន ហើយកណ្តុបដែលឈ្នះក៏ឆ្លើងស៊ីកន្ទុយដាំមុន ។ កណ្តុបសេះញី ក្រោយដែលបានរួមសេពមេថុនធំនឹងកណ្តុបសេះឈ្មោលរួចហើយ

នៅថ្ងៃនោះប្តូរថ្ងៃស្អែកទៀត ។ មេញីក៏ចាប់តួឈ្មោលហើយចោះកន្ទុយ ហើយក៏ស៊ុតតួឈ្មោលទាំងមូល លើកលែងតែស្លាបចេញ ។ មេកណ្តុបញី តែងធ្វើដូច្នេះទាំងតួឈ្មោលឯទៀត ។ ដែលវាបានរួមមេជុនកិច្ចជាមួយផង វាច្រែនធ្វើដូច្នេះនៅឧកាសថ្ងៃក្តៅខ្លាំង ។

អំពីសត្វដង្កូវនៅនឹងជើមឈើតូចៗ

មេគំហ៊ុលសតែងមានក្រឡាមួយ ។ នៅនឹងនោះវាតែងណែនក្រមៅថ្លា ហើយវាពងកើតជាដង្កូវម្យ៉ាងបំផ្លាញដើមឈើដែលវាចំនៅ ។ ដង្កូវមានពងនៅក្នុងវែងសេចតម្រង់ ឯស្នំដែលវាពងជាក់នោះមានតំណែងខ្ចប់ មុខសន្ធឹកម្ខាងទៀតទៅជារឹងស្វិត ហើយមានតែសរសៃទុនឯស្នំឈើ ។ ភួនដង្កូវស្អិតក៏នាំគ្នាស៊ីមុខសន្ធឹកខាងលើតាមផ្លូវដែលវាវារទៅតាល់តែនៅសល់តែពងសន្ធឹកទេ លុះវានាំគ្នាស៊ីសន្ធឹកឈើដើមតូចៗអស់ហើយ ទើបវានាំគ្នាទៅទីដទៃ លុះដល់ដង្កូវធំៗទើបសត្វដង្កូវអស់នេះប្រមូលគ្នាទៅនៅចុងមែកឈើ ដែលមានសន្ធឹកស៊ុមទុមល្មមជាទីជ្រកការពារគ្រាន់តែក្នុងដង្កូវធំជាវេលា ៣-៤ ខែ ។ ក្នុងខណៈវេលានេះ ពួកដង្កូវមិនចេញទៅណាទេ លុះដល់ខែមាឃ ទើបវានាំគ្នាចេញទៅស្វែងរកចំណីអាហារ ។ ខណៈនេះពួកសត្វដង្កូវអស់នេះ កំពុងឃ្លានខ្លាំងណាស់ ទើបវានាំគ្នាស៊ីស្នំឈើទាំងអស់ ដូច្នេះហើយបានជាដើមឈើតូចៗ ដែលវាចោមស៊ីស៊ើតែងតែមានសន្ធឹកឡើយ ។ លុះវានាំគ្នាស៊ីស្នំឈើកាន់តែរេចរៃ

ជិតអស់ហើយ ទើបវាន់គ្នាចេញពីដើមឈើនោះទៅ ។ ក្នុងខែស៊ូយេត ដង្កូវនេះក៏ចេញពីដើមឈើតូច ។ នោះហើយចុះមកដី ដើម្បីធ្វើសំបុកនៅ កណ្តាលស្មឹកឈើស្ងាប់ ។ ឯសត្វដង្កូវនេះ កាលណាវាវារមកលើស្បែក ដៃឬកេរបស់មនុស្សយើង វាធ្វើឲ្យមានស្នាមក្រហមហើយហើមធ្វើឲ្យឈឺ ចាប់ជាខ្លាំង ។ ដល់ ៥ ថ្ងៃតមក ទើបស្បែកដែលវាវារលស់តៅហើយ បែកស្រកា ។

អំពីសត្វឌីម៉ាល់

ក្នុងសំបុកឌីម៉ាល់មួយនោះមានស្រទាប់ ។ ចំនួន ១០ ស្រទាប់ដុតលើគ្នា រួមទាំងរន្ធតូច ។ ពាងអស់ ១១.៩០០ ។ នៅវៃដេសមច្រើនពុនរងាខ្លាំង សត្វឌីម៉ាល់ត្រូវបានធ្វើឲ្យស្លឹកសាច់ជាខ្លាំង ទើបគេមើលឃើញនៅខាងក្រោមសំបុក មានភ្នោចសត្វឌីម៉ាល់ជាចំនួនច្រើន ។ តែកាលណាមានសត្វឌីម៉ាល់មួយដិតដល់ជាច់ខ្យល់ស្ងាប់ ទើបមានសត្វឌីម៉ាលមួយទាំងើនមួយទៅ ជាក់គាតខាងក្រោមសំបុកដែលជាកន្លែងសម្រាប់ជាក់ភ្នោចពួកវា ។ គេបានពិនិត្យឃើញសត្វឌីម៉ាល់នេះមាន ៣ ចំពូកគឺ ពួកអលិង្គ (ឥតភេទ) ពួកបុំលិង្គ (ឈ្មោល) ទីបំពួកឥត្ថីលិង្គ (ញី) ពួកអលិង្គមានចំនួនស្ងាប់ជាច្រើនបំផុត បន្ទាប់មកពួកបុំលិង្គ ឯពួកឥត្ថីលិង្គក៏មានស្ងាប់ដែរ ។ ពេលកេតនុះក្តៅខ្លាំងវាជាហេតុធ្វើឲ្យចំនួនឌីម៉ាល់ថយតិចពីសំបុករបស់វា ។ តែកាលណាអាកាសមិនវាង ពួក

ឥម៉ាល់តែងជែកដេកនៅចន្លោះស្រមាប់។ នៃសំបុកវាក្នុងវេលាយប់ ។ លុះដល់ថ្ងៃរះឡើងទើបវាទាំងគ្នាចេញពីសំបុកទៅ ខាងក្នុងសំបុកក៏ភ្លឺអឺកធឺកទៀង ។ ពួកអលិង្គទាំងគ្នាហើរច្រកត់ ពួកបុំលិង្គក៏ទំធ្វើការយ៉ាងខ្លាំងយ្នាត ឯពួកឥត្ថីលិង្គក៏សម្លុំស្ងៀមទៅ ។

លុះនៃកាលណា ពួកអលិង្គ ពួកបុំលិង្គនឹងពួកឥត្ថីលិង្គធ្វើកិច្ចការតាមមុខគ្រប់គ្នាវាស្រួលហើយក៏ស្ងាប់ទៅ ។ ប៉ុន្តែពួកឥត្ថីលិង្គដែលកើតក្រោយ ។មក ក៏មានកំឡាំងរឹងប៉ឹងចំណាប់ជាងពួកបុំលិង្គដែរ ។ ឯការចាំគន់មើលឥម៉ាល់មេដោះកំពុងបញ្ចុកចំប៉ាងចំណីឲ្យកូនវានោះ វាគន់ណាធុញគ្រាន់ទេ មានឥម៉ាល់មេដោះមួយបានទឹកឃ្មុំមកប្រោងពោះ ហើយលបចំទៅខាងមុខល្អែងរន្ធតូចមួយ ហើយវាន់ទក្សាលមែមាត់ទៅ ហើយកូនវា (នៅជាដង្កូវ) ក៏កំរើកក្សាលឆើងើ វាមិនចាន់ប៉ោកឆ្អែតទេ មេឥម៉ាល់ក៏ជាក់មាត់វាទៅប៉ះនឹងមាត់របស់កូនវា ហើយបញ្ចូកទឹកឃ្មុំ ១ ដំណក់ទៅ រួចមេដោះនេះក៏ចេញពីល្អែងរន្ធនេះ ទៅកាន់ល្អែងរន្ធឯទៀត ។ ធ្វើដូច្នេះទៀត ។ ឯកូនវាក៏លេបទឹកឃ្មុំដែលវាក់ចូលទៅក្នុងបំពង់គរបស់វាទៅ រួចបន្តិចមកវាក៏ដេកលក់ទៅ ។ ប្រសិនបើមេដោះកេរទឹកឃ្មុំឲ្យកូនវាមិនបាន វាក៏ចាប់សម្លាប់សត្វល្អិត ។ បានហើយវាក៏កំរេចឲ្យល្អិតខ្ទេចហើយ ទើបយកទៅឲ្យកូនវា ។ ប្រសិនបើស្រាំងឫគាន មកដល់ណាមកវាហាចំណីរបស់ពួកមេដោះវា ក៏ត្រូវវា

ក្នុងធម្មបទសូត្រមានសេចក្តីដំណាលថា ព្រះមហាកច្ចាយនត្ថេរ មាន
ព្រះជន្មមកដល់ក្រោយព្រះពុទ្ធបរិនិព្វាន ដូចមានរឿងដំណាលថាកាល
លោកនៅឯមគុន្ទាវន ដែនមធុរាផងជានិ ព្រះចាតមធុរាផងអនុឡឹបុត្រ
ស្តេចចូលទៅរកលោកហើយ ត្រាស់សួរថា បពិត្រព្រះកច្ចាន:ដ៏ចំរើន
ពួកព្រាហ្មណ៍គេប្រកាន់ថា ពួកគេជាមនុស្សប្រសើរចរិសុទ្ធ កើតមក
អំពីព្រហ្ម ចំណែកណេកតើលោកយល់ដូចម្តេច ? លោកទូលសំដែង
អំពីវណ្ណ:ទាំង ៤ ពួកមិនមានវិសេសប្លែកគ្នាទេ ។ ព្រះចាតមធុរាផង ត្រង់
ព្រះសណ្តាប់ហើយ ក៏មានព្រះទ័យសោមនស្ស សំដែងព្រះអង្គជា
ឧបាសក សូមដល់ព្រះរតន:ទីបីព្រះធម៌ជាទីពឹងទីរលឹក ព្រះរតន:ទូល
ហាមថា សូមមហាពាជកុំប៉ះយកអាត្មាភាពជាសរណ:ឡើយ ចូរត្រង់

យកព្រះដ៏មានព្រះភាគ ដែលជាសរណៈរបស់លោក ទុកជាសរណៈ
របស់ព្រះអង្គចុះ ។ ទើបព្រះបាទមគុរកេវត្រាស់សួរថា ចុះព្រះដ៏មាន
ព្រះភាគ ទ្រង់គង់នៅឯណា ។ គាលទ្រង់ជ្រាបថា ព្រះអង្គ
បរិនិព្វានផុតទៅហើយ ទើបទ្រង់ត្រាស់ថា បើព្រះអង្គទ្រង់ជ្រាបថា
ព្រះដ៏មានព្រះភាគទ្រង់គង់នៅឯណា នោះបើដឹតធ្វាយយ៉ាងណាក៏ដោយ
ព្រះអង្គនឹងស្តេចទៅតាលទ្បាលតែបាន តែព្រះដ៏មានព្រះភាគ បរិ-
និព្វានហួសទៅហើយ ខ្ញុំព្រះករុណា សូមដល់ព្រះដ៏មានព្រះភាគ ដែល
ទ្រង់បរិនិព្វានទៅហើយ ព្រមទាំងព្រះធម៌ព្រះសង្ឃជាគំពីរទីលឹក ។
ឥឡូវនេះបង្អស់ឲ្យយើងឮថា ព្រះតថាគតនោះ លោកមានជន្មាយុមកដល់
ត្រឹមណា ព្រះពុទ្ធបរិនិព្វាន តែមិនបានឮថា លោកមានអាយុប៉ុន្មាន
ឬះលោកមានអាយុសង្ខារសមគួរនឹងកាលវេលាហើយក៏បរិនិព្វានទៅ ។

ចប់ប្រែត្តិសង្ខេបព្រះកថាយនត្តោតែប៉ុណ្ណោះ ។

លោកអាចារ្យ ឈឹម-ស៊ីម សុទ្ធម្មប្បញ្ញា

អាចារ្យបង្រៀនសៅសាលាជាឡើងាន់ខ្ពស់ រៀបរៀងតាមសេចក្តីចង្អាប់អំពីព្រះគុណព្រះធម្មលិខិត ជាងហ្វាងសាលាជាឡើងាន់ខ្ពស់ (មុន) ដោយសេចក្តីត្រូវការរបស់លោក ព្យាយុយប៉ុងង់ អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។

ព្រះពុទ្ធឃោសាចារ្យ ជាព្រះថេរៈ ១ អង្គ ដែលមានព្រះនាមល្បីល្បាញអស្ចារ្យក្នុងពួកអ្នកកាន់ពុទ្ធសាសនាបែកខាងខត្តិណនិកាយ, មានប្រវត្តិហេតុដែលព្រះគន្ថរចនាចារ្យពាំងឡាយបានរៀបរៀងទុកក្នុងគម្ពីរជាច្រើន គឺគម្ពីរមហាវង្ស, ពុទ្ធឃោសនិទាន, វិសមាលិនី, ញាណោទ័យ, សុត្តដាតកនិទានានិសង្ស នឹងពុទ្ធឃោសប្បវត្តិកថាជាដើម ។ ខ្ញុំដែលសៀបក្តីក្នុងរឿងពាំងនោះ ស្របគ្នារហូតពីដើមដល់ចុងចប់ក៏មាន, ប្លែកគ្នាខ្លះជាយអង្គើ ។ ក៏មាន ។ ឥឡូវនេះ ខ្ញុំបានពិនិត្យមើលរឿងពាំងនោះហើយ ស្រង់សេចក្តីមករៀបរៀងជារបៀបមួយដោយខ្លីតដូចតទៅនេះ ។

ក្នុងកាលដែលព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិនិព្វានកន្លងទៅបាន ៨៤៦ វស្សា មានព្រះរាជា ១ ព្រះអង្គទ្រង់ព្រះនាមព្រះបាទ "មហានាម" សោយរាជសម្បត្តិក្នុងលង្កាទ្វីប ។ សម័យនោះ មានមាណពម្នាក់ឈ្មោះ

យោសៈ (๑) កើតក្នុងត្រកូលព្រាហ្មណ៍មួយជាកដបុរោហិត នៅនាទីដ៏ត
ពោធិមណ្ឌល ក្នុងមជ្ឈិមប្រទេស ទាន់ឯដម្ពូថ្ងៃ ។

សេចក្តីក្នុងធម្មបទយោសទិទានថា: ក្នុងសម័យមុនដែលមាណពនេះ
ពុំទាន់កើត, មានព្រះអរហន្តមួយអង្គ ពុំច្បាស់ជាមានព្រះនាមដូច
ម្តេច ជាវត្តុនៃព្រាហ្មណ៍ឈ្មោះកេសិនីធ៌ ព្រាហ្មណីឈ្មោះកេសិនី លោក
តែងចូលទៅកាន់ត្រកូលព្រាហ្មណ៍នោះ ។ ដោយហេតុតែព្រះអរហន្ត
អង្គនោះ មានព្រះទ័យឈឺខ្លាលចំពោះព្រះពុទ្ធសាសនាណាស់ ថាន
ជាកន្លងថ្ងៃមួយ លោកមានបរិវិតក្កកើតក្នុងព្រះទ័យថា: អើហ្ន៎! ព្រះពុទ្ធ-
វចនៈគឺព្រះត្រៃបិដកព្រមទាំងអដ្ឋកថា ដែលព្រះធម្មសង្គាហកត្ថេរទាំង-
ឡាយ ថាទាំកក្នុងស្លឹកតែ មានតែជាភាសាសីហឡៈ នៅឯលង្កា-
ទ្វីបឯណោះ បើដូច្នោះ ឆ្កើដូចម្តេចអេះ ទើងថាន ព្រះពុទ្ធវចនៈទាំងនោះ
ផ្សាយមកដល់ដម្ពូថ្ងៃនេះ ជាភាសាមគធដូច ? តាលដែលលោកកំពុង
មានបរិវិតក្កដូច្នេះ ក៏ស្រាប់តែលោកនឹកឃើញថា: មានតែយោសទេវបុត្ត
ដែលនៅឯហានគុសិតឯណោះ ទើបជាបុគ្គលមានអភិនិហារបារមីភ្លា អាច

---

๑ សេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គ៍ថា: ក្នុងកាលដែលកុមារនេះប្រសូតចាកផ្ទៃ, ពួកបរិសទ្យ
ទាំងឡាយរបស់ព្រាហ្មណ៍មានទាស:ខ្លួនកម្មការដាក់ដើម ស្រែកសន្ធឺកកងកាន់គ្នាទៅវិញ
ទៅមក, ព្រោះហេតុនោះបានជាដាំងឲ្យឈ្មោះកុមារនោះថា "យោសៈ" ។ កន្លែងខ្លះ
ទៀតថា: កុមារនោះបានជាឈ្មោះថា "យោសៈ" ព្រោះបេះតុនៃកើតក្នុងស្រែកឈ្មោះយោ-
សត្រាម ។ កន្លែងខ្លះថា កុមារនេះឈ្មោះ "ធម្មយោស" ផ្លូវច្រើនក៏មាន ។

វែបត្រែវត្តែបំដកត្រមាំងអដ្ឋកថា ដែលជាសីហឡភាសាមកជាមគធ-
ភាសាបាន ។

លុះលោកនឹកឃើញដូច្នេះហើយ ក៏និមន្តទៅកាន់ឋានតាវត្តឹង្ស,
ចូលទៅថ្វាយព្រះពរសម្តេចអមរិន្ទ្រាធិរាជ សូមឲ្យព្រះអង្គទៅអញ្ជើញ
យោសទេវបុត្ត ឲ្យចុះមកចាប់បដិសន្ធិកន្លែងក្នុងផ្ទៃនៃនាងកេសិនីជាភរិយានៃ
ព្រាហ្មណ៍ឈ្មោះកេសិ ដែលជាទុជ្ជាតរបស់លោក ។ ព្រះឥន្ទ្រក៏ទទួល
យកភាសា សម្រេចការប្រគេនបានដូចបំណង ហើយបានតាំងទុក
ជានាថានឹងដួយឈើគ្រាលកន្លែងការវែបត្រែវត្តែបំដកនោះទៀតផង ។

កាលដែលយោសទេវបុត្ត ចុះមកកើតកន្លែងក្នុងផ្ទៃនៃនាងកេសិនី ច្រ-
សូតចាកផ្ទៃមក បានឈ្មោះថា "យោសកុមារ" មានរូបល្អក្នុងថ្ងៃក្រោយ មាន
ប្រាជ្ញាមុះមុត អាចរៀនចំណេះចេះចប់ត្រែវេ(១) កន្លះវាងអាយុ៧ឆ្នាំ ។

---

១ ត្រែវេ គឺសេចក្តីដំណឹង វិជ្ជា, ចំណេះ, មាន ៣ បែប ឬ៣ផ្លូវនៃលស់ផែនរៀបរៀងខាង
សាសនាព្រាហ្មណ៍ មាន ៣ ប្រភេទ ។ ក្នុងសម័យដើម មានត្រែមតែ ៣ យ៉ាង គឺ ១— ឫគ្វេ
ឬឥរុវេទ មានដំណើរសេចក្តីជាភាសាឆន្ទ សម្រាប់សូត្រសរសើរព្រះទេវតា; ២— យជុរ្វេទ ឬ
យជ្ជុវេទ មានដំណើរសេចក្តីជាភាសាយញ្ញ៍ សម្រាប់សូត្រប្រាប់ឬបួងសួង; ៣— សាមវេទ
មានដំណើរសេចក្តីជាភាសាឆន្ទ សម្រាប់សូត្រក្នុងពិធីថ្វាយទឹកសោម ។ វេទទាំង ៣ នេះ
សុទ្ធតែប្រើភាសាស្រុកៗ ហៅថា "វេទត្រ័យ ឬ ត្រ័យវេទ្យា" ដូច្នេះក៏មាន ។ ពួកព្រាហ្មណ៍
ប្រកាន់ជឿស៊ប់ថា មកពីព្រហ្មប្រសិទ្ធិឲ្យ ពីនេះឡើង ។ លុះចំណេះមក កើតមាន "អថព្វវេទ
ឬ អថព្វវេទ" សម្រាប់សូត្រហៅឬបណ្តេញខ្មោចបិសាច ១ ទៀមទាកទៀតជាវេទ ៤ ។

ថ្ងៃមួយ យោសកុមារ ចូនស្តាប់ព្រះអភិធម្មកថាសំណាក់ព្រះអរហន្ត ដែលជាដីតុនោះ ក៏មានសេចក្តីដែរថា ដោយការយល់ឃើញថាជាវិជ្ជាមួយមានអត្ថសេដ៏ជ្រៅល្អិតជាងវិជ្ជាដែរ ដែលខ្លួនធ្លាប់សិក្សាមក, ទើបសួរព្រះអរហន្តនោះថា វិជ្ជានេះឈ្មោះអ្វី? ព្រះអរហន្តឆ្លើយថា វិជ្ជានេះឈ្មោះតុដ្ឋមន្ត ។ ខ្ញុំព្រះគុណា សូមសិក្សាផងបានឬទេ? បាន, ប៉ុន្តែត្រូវអ្នកឯងបួសសិន ។ យោសកុមារក៏ចូលទៅលាមាតាបិតាចេញទៅបួសដើម្បីរៀនតុដ្ឋមន្តនោះ ។ មាតាបិតាអង្វរយោត់ច្រើនលើក ក៏កុមារនោះខំរឹតខ្ជូលាដោយភាក្យប្តេជ្ញាថា ខ្ញុំបានទៅបួសគ្រាន់តែរៀនតុដ្ឋមន្តចប់ប៉ុណ្ណោះទើតត្រឡប់មកវិញពុំខាន ។ មាតាបិតាក៏អនុញ្ញាតឲ្យទៅបួសតាមចំណង់ ។ (សេចក្តីនេះគួរឲ្យអ្នកមានគំនិតរិះគិតដោយយ៉ាងក្រៃលែងដែរឲ្យឃើញថា យោសកុមារនេះមានទំនិញ្ញាណប្លែកជាងមនុស្សឯទៀត) ។

ចំណែកខាងសេចក្តីកថារបស់ភិក្ខុថា ថាៈយោសកុមារនោះកូវ ក្លាកក្នុងសិល្បសាស្ត្រគ្រប់យ៉ាង ចេះចប់ត្រៃវេទ ហើយគ្រាច់ទៅគាន់ស្រុកនិគម ជនបទ កដជាន៏ កន្លងផុតទៅ, តែងចូលទៅធ្វើសាកច្ឆាកន្លងនឹងដែលមានភ្លក្សមណៈទំនឹងព្រាហ្មណ៍ជាអ្នកចូរដ្ឋនៅគ្រប់ដម្បន់ ។ ភ្លក្សមណៈទំនឹងព្រាហ្មណ៍ដទៃ មិនអាចដើម្បីធ្វើយប្រស្នាដែលយោសកុមារនោះសួរបានឡើយ ។ ឯយោសកុមារទើបអាចដោះស្រាយប្រស្នាដែល

ពួកសមណៈទំនឹងព្រាហ្មណ៍ដទៃសួរបានឥតមានខ្សែសាល់ ។ ឃោសកុមារនោះ សង្កត់សង្កិនខ្លួនអ្នកសកលជម្លៀបដោយចំណេះវិជ្ជាយ៉ាងនេះហើយបានទៅដល់វត្តមួយ ។ ក្នុងវត្តនោះមានតិក្ខជាច្រើនរយរូប ព្រះសង្ឃនៅព្រៃនាមវេត្តដ៏មានអាយុ ជាមហាទីឈាស្រព ដល់ខ្លួបដំសម្ពិត ជាអ្នកញាំញីខ្លួបរបស់ក ។ លុះកន្លែយប៉ំនោះ ឃោសមាណព ស្ងួតខ្លួបាតភ្លេលីមន្ត(១) ដ៏ច្បាស់លាស់ក្រឹមត្រូវគ្រប់គ្រាន់ ។ ព្រះថេរៈបានឮសម្លេងឃោសមាណពកំពុងស្មូធ្យាយន៍ ក៏ជ្រាបថា "មាណពនេះមានប្រាជ្ញាច្រើនល្មមអាត្មាអញខ្លួនបាន", ទើបមានថេរដីកាហៅមាណពនោះមកសួរថា: ម្នាលព្រាហ្មណ៍ នណាវែសកសម្រែកដូចជាសត្វលា ? ឃោសមាណពសួរតបវិញថា: បពិត្របពូជដ៏ចំរើន, លោកស្គាល់សម្រែកសត្វលាឬ? ចំរើនពរ អាត្មាស្គាល់ ។

សេចក្តីដោយឡែកថា ឃោសមាណពនោះពិចារណារកមិនឃើញខ្លួបហេតុដើមនៃគម្ពីរទាំងឡាយក្នុងវែ ដែលមានឥតិហាសៈជាគម្រប់ ៥ នោះសោះ, ទាំងអាចារ្យរបស់មាណពនោះ ក៏ពិចារណារកមិនឃើញដែរ; ទើបឃោសមាណពនោះសួរព្រះថេរៈចំពោះដើមហេតុនៃគម្ពីរនោះ ។ ឯព្រះថេរៈជាអ្នកចេះចប់ត្រៃវេតាមប្រកតីមកស្រាប់ ថែមទាំងបានបដិសម្ភិទាឧត ជានជាលោកឥតជួន់ព្រះទ័យក្នុងការដោះ

(១) ធម៌សម្រាប់សូត្រថ្វាយបង្គំព្រះព្រហ្មជាដើម ។

ស្រាយប្រស្នានោះសោះ, លោកដាស្រាយប្រស្នាដ៏ឆ្ងាយនោះ មួយរំពេច
ក្នុងខណៈនោះឯង ហើយមានថេរដីកាចំពោះយោសមាណគថា ម្នាល
ព្រាហ្មណ៍ដ៏ចំរើន, អ្នកឯងសួរអាត្មាច្រើនលើកណាស់ហើយ, ឥឡូវនេះ
តែវអាត្មាសួរប្រស្នាតែមួយចំពោះអ្នកឯងវិញ ។ ឥតុណាថព្វដ៏ចំរើន,
សូមលោកសួរមកចុះ ។ ព្រះថេរៈសួរប្រស្នាក្នុងចិត្តយមកៈដូចេ្នះថា "ចិត្ត
របស់បុគ្គលឯណាកើតឡើងមិនរលត់, ចិត្តរបស់បុគ្គលនោះនឹងរលត់ ឥឯ
មិនកើតឡើង; ពុំនោះសោតថា ចិត្តរបស់បុគ្គលឯណានឹងរលត់ ឥឯមិន
កើតឡើង, ចិត្តរបស់បុគ្គលនោះ រមែងកើតឡើងមិនរលត់ តើបុគ្គលនោះ
ជាអ្វី? មាណពនោះស្រាយពុំរួច ទើបសួរថា បពិត្រឥតុណាដ៏ចំរើន,
ប្រស្នានេះឈ្មោះអ្វី? ម្នាលព្រាហ្មណ៍, ហ្នឹងឈ្មោះតុច្ឆមន្ត ។ លោកម្ចាស់ អាច
ឲ្យតាតុច្ឆបញ្ហានេះដល់ខ្ញុំតុណាបានឬទេ? អាត្មាអាចឲ្យបានចំពោះតែអ្នក
ប្រាជ្ញតែប៉ុណ្ណោះ ។ លំដាប់នោះ យោសមាណគក៏សូមបព្វជ្ជា ដើម្បីរៀន
មន្ត ។ ព្រះថេរៈបានបំបួសយោសមាណគនោះ បានឲ្យឧបសម្បទាហើយ
បង្រៀនតុច្ឆបញ្ហាតែព្រះអង្គឯង ។ យោសគិក្ខុនោះមានឈ្មោះថា
"តុច្ឆយោសៈ" ដូច្នេះឮការដកដង់លោក[1] ។

---

๑ សេចក្តីរៀបរៀងក្នុងបុរាណនេះ មិនដាក់ឲ្យគួរអ្នកគិតប្រើតំនាក់តំនៃទេ ព្រោះដាសេចក្តីដាយ
ដំណាលៗគ្នាមកយោងរាប់ណាមកខ្លះចេញ ដែលមិនត្រូវ។ មិនមែនក្នុងកាលអាយុ ៧ ឆ្នាំទេ, កាលណាដែលត
ពេលបព្វជ្ជាចំនួនឧបសម្បទាកំពេញអាចយល់ជាន់ថាក្នុងកំណត់អាយុ ២០ ឆ្នាំឡើងលើ ។

សេចក្តីកន្ត សុត្តជាតកនិទានានិសង្សនៃពុទ្ធយោសនិទានជា យោ-
សកុមារបានបព្វជ្ជាជាសាមណេរក្នុងសំណាក់ព្រះអរហន្ត ជាឧបជ្ឈាយ៍
ហើយមានកិត្តិស័ព្ទសេចក្តីសរសើរថាជាកុលបុត្រមានវត្តប្រតិបត្តិល្អសំខាន់
តីសាមណេរនេះមានសេចក្តីព្យាយាមថ្មោសសំអាតខ្លាំងណាស់, ព្យាយាម
ដើរបិណ្ឌបាត, ព្យាយាមធ្វើវត្តគួរវត្តធំចំពោះព្រះឧបជ្ឈាយ៍, ព្យាយាម
សិក្សាព្រះត្រៃបិដកតាមព្រះឧស្ឋព្រះឧបជ្ឈាយ៍ ជាកុលបុត្រប្រកបដោយ
ប្រាជ្ញាធ្វើឈ្មោះរាងធំវែ, សេចក្តីដែលព្រះឧបជ្ឈាយ៍ពន្យល់រួមប្រាំតែ
មួយបទ ក៏អាចយល់រហូតដល់រយដល់ពាន់បទ, រៀនចាំស្ទាត់ជាបដល់
បទព្រះត្រៃបិដកចាំង ៩ ហ្មឺន ៤ ពាន់ធម្មក្ខន្ធតាន់ច្រឡឹងឡើយ ។
កាលដែលលោកចំរើនវ័យដល់ព្រះជន្ម ២០ ឆ្នាំ លោកបានឧបសម្បទា
ជាភិក្ខុបាននាមជា "ពុទ្ធយោសៈ" ជាអ្នកល្បីល្បាញខាងឯការសំដែង
ធម៌ពីពេះក្បែរក្បាយ ប៉ុនប្រសប់ដោះស្រាយអាថ៌ប្រស្នាវិសេសជាងអ្នក
ប្រាជ្ញទាំងពួង ។ កាលបើសេចក្តីសរសើរកើតឡើងដល់លោកតាន់តែ
ចំរើនច្រើនឡើង ក៏លោកគិតក្នុងព្រះទ័យថា "ព្រះឧបជ្ឈាយ៍របស់អញ
ប្រហែលអស់ចំណេះប៉ុណ្ណឹងហើយដឹង" តាន់តែគិតប៉ុណ្ណេះ ក៏ព្រះ
ឧបជ្ឈាយ៍ជ្រាប ហើយហាមមិនឲ្យព្រះពុទ្ធយោសាចារ្យធ្វើវត្តប្រតិបត្តិ
តទៀតដោយសេចក្តីចោទប្រកាន់ថា ព្រះពុទ្ធយោសាចារ្យមើលងាយ
ឧបជ្ឈាយ៍ ។ ព្រះពុទ្ធយោសាចារ្យអង្វរសូមទោស ទើបព្រះឧបជ្ឈាយ៍

ដាក់ទណ្ឌកម្មថា "លុះតែអ្នកឯងទៅរៀបព្រះវិត្តមិដកព្រមចាំឯអដ្ឋកថា ឯលង្កាទ្វីបដែលជាសម័យឧត្តរសាសនាមកដាមនុស្សតាសាឲ្យចប់សព្វគ្រប់ ហើយនាំត្រឡប់មកដម្កល់ទុកវិញទើបរួចទោសនេះ" ។ តិច្ចទណ្ឌកម្មប៉ុណ្ណេះក៏មិនដាក់ការធ្ងន់ដល់ព្រះពុទ្ធឃោសាចារ្យសោះ ហាក់ដូចជាគេរុញត្រីធំទម្លាក់ទឹកសមុទ្រ ។ ព្រះពុទ្ធឃោសាចារ្យព្រមទទួលទណ្ឌកម្មដោយសោមនស្សហើយ ចូលរៀបចំនឹងទៅលង្កាទ្វីប ។ ប៉ុន្តែមុននឹងចេញដំណើរទៅនោះលោកលាព្រះឧបជ្ឈាយ៍ ទៅជូនានមាតាបិតាឲ្យរក្សាសុខ ឲ្យចំរើនកម្មដ្ឋានបានសម្រេចសោតាបត្តិផល ហើយលាមាតាបិតាទៅគាល់ព្រះឧបជ្ឈាយ៍វិញ ដើម្បីទទួលចេញដំណើរទៅលង្កាទ្វីប ។

សេចក្តីកថាពុទ្ធឃោសបច្ឆាវត្ថុកថាថា: ព្រះពុទ្ធឃោសាចារ្យបានឧបសម្បទារួចហើយ ទៅកាន់វត្តខោះ ជាន់ធ្លើតម្តីមួយចេះឈ្មោះ "ញាណោទយ" រួចស្រេចហើយ តំពូនច្បាវត្តដើម្បីធ្វើតម្តីអដ្ឋសាលិនីអដ្ឋកថាអតិធម្មសង្គណី ទីឯអដ្ឋកថាបវត្តិ(១) ក៏ស្រាប់តែព្រះមហាថេរ

---

๑ ការបកប្រែនេះមកចេញពីសេចក្តីឡេយល់ថា "ព្រះបរិត្តឬកាណាកិរៈជ្រោកដាំដាព្រៃខន្តរចនាចារ្យ ជាតរៀបរៀងឆ្នាំ ព. ស. ៩៥៦" ។ បំណងរបស់ព្រៃពុទ្ធឃោសាចារ្យចំពោះកំណែនេះ ប្រែរៀបរៀងមិនសរម្រេចជាតិត្រឡប់យើញដែរឈ្មោះព្រៃវេរៈអនេមទស្សី ជាអ្នករៀបរៀងអដ្ឋកថាបាកាណាកិរៈវិញ ។ ព្រៃអនេមទស្សីនេះមានព្រៃតាមត្រាកដក្នុងសៀវភៅ "រឿងប្រែតិស្ស" ព្រៃសង្ឃរក្សាមវត្តក្នុងលង្កាទ្វីប" របស់ក្រុមព្រៃគាំ ថែនាជាតុភាគ ជាជាព្រៃគង្គកថាចារ្យ ๑ រូបទៅលង្កាទ្វីប ក្នុងចំណោមព្រៃអដ្ឋកថាចារ្យ ២៧ រូប ។

មានថេរដីកាថា ម្នាលពុទ្ធឃោសៈ ក្នុងជម្ពូទ្វីបនេះ មានព្រះវិនិច្ឆិតដ៏មិនមានគ្រប់គ្រាន់ ក្នុងសីហឡទ្វីប (លង្កាទ្វីប) ទើបមានគ្រប់គ្រាន់ ព្រមទាំងអដ្ឋកថាជាភាសាសីហឡៈ ដែលព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត[1] ជាដើមបានលើកឡើងតាក់តែងសង្គាយនាហើយ; ហេតុដូច្នេះ គួរអ្នកឯងនៅសីហឡទ្វីប ប្រែអដ្ឋកថាទាំងអស់នោះមកជាមគធភាសា, អដ្ឋកថានោះ នឹងនាំមកនូវប្រយោជន៍ដល់សត្វលោកទាំងពួង ។ កាលបើព្រះមហាថេរមានថេរដីកាយ៉ាងនេះ, ព្រះពុទ្ធឃោសៈដ៏មានអាយុក៏មានចិត្តសោមនស្សស្រស់ស្រាយរីករាយ ថ្វាយបង្គំលាព្រះថេរដ្ឋាយ៍ធំក្នុងសង្ឃនិមន្តត្រឡប់ទៅកាន់កំពង់ ឡើងគង់លើសំពៅ ទៅដល់ពាក់កណ្តាលមហាសមុទ្រ ឃើញព្រះថេរៈឈ្មោះ "ពុទ្ធទត្ត" ដែលកំពុងនិមន្តមកតាមនាវា គ្រឡប់មកជួបគ្នា ចរចាពាក់ព័ន្ធសព្វកិច្ចការ ហើយលោកនិមន្តហួសពីនោះទៅដល់កំពង់នៃកោះលង្កា ។

---

๑ មិនមែនព្រះសារីបុត្តជាធម្មសេនាបតីទេ, គឺព្រះសារីបុត្តភេលង្កាទ្វីប ដែលជាក្រុមព្រះសង្ឃតិកាចារ្យធ្វើឱកាសការប្តូរសង្គាយនាក្នុង ព. ស. ៤៣៣ ។ តក្រោយពីព្រះពុទ្ធឃោសៈចារ្យ (ព. ស. ៩៤៦) មក មានព្រះអង្គឯកឋាចារ្យព្រះនាមសារីបុត្ត ១ រូបទៀត ។ ព្រះថេរៈនេះមានសេចក្តីសរសើរក្នុងសៀវភៅ "សទ្ធម្មបកាសទីបិកា" ថាមានប្រាជ្ញាឈ្លាសវៃ ចេះចប់ ១ សេចក្តីឯណាតែម្តងអាចចាំបានដល់ ១០០ គាថា ។

សេចក្តីកន្លងទុក្ខយោសវិភាគ ទីឆ្នាំសុត្តជាតក ដំណាលអំពីការចេរ.
ចាសំណេះសំណាលរបស់ព្រះពុទ្ធទត្តទីឆ្នាំព្រះពុទ្ធយោសៈថា កាលដែល
ព្រះពុទ្ធយោសៈចុះសំពៅទៅខោះ មានព្រះឥន្ទជាតៃកុងកាន់ចង្កូតសំពៅ,
រោលដែលដួចទឹងសំពៅព្រះពុទ្ធទត្ត ក៏ព្រះឥន្ទកាច់ចង្កូតឲ្យសំពៅអែប
ជិតគ្នា; ទើបព្រះពុទ្ធទត្តសួរព្រះពុទ្ធយោសៈថ្លាបជាក់ជាទៅថែតម្ដងឯ
ណោះលង្កា កំលាន់ព្រះឧស្ដថា អាវុសោ! បំណាងរបស់ឯកនេះ ត្រែងឆ
មិនសម្រេចទេឆំនា? លាក់ប៉ាំងច្បី! ខ្ញុំនេះឯងហើយដែលមានបំណងដូច្នោះ,
ខ្ញុំចញពីផ្ទៃម្ដាយទៅលង្កាខ្ញុំបតាំងតាំងក្មេង ដាចដល់ឥឡូវនេះខ្ញុំមានអាយុ
១០០ឆ្នាំ, ខ្ញុំថែបានតែ ១ តម្លើរ, តម្លើរនោះ ខ្ញុំសន្មតឈ្មោះថា "ជីនា.
លង្កា", កាលបើមិនសម្រេចដូចប្រាថ្នា ក៏ខ្ញុំត្រឡប់មកវិញដោយដុតសង្ឃឹម;
អាវុសោ, អ្នកទៅឥតកំពើរទេឆំងឬ? ព្រពុទ្ធយោសៈថា
ម្ដេចក៏ព្រះថេរៈថាដូច្នោះ? ម្នាលអាវុសោ, ព្រែរតម្លើរគោសាស័ហស្ស:
នោះល្អិតល្អន់ណាស់! មានពន្លឺរស្មីភ្លឺឆ្ងាយណាស់! មិនងាយទឹង
ពាណាឲ្យដុះដាយបានទេ ។ ព្រះករុណា, សេចក្តីនេះ ក៏គួរជឿ
ដែរហើយ, ប៉ុន្តែសូមមានអតិយាទាសចុះ ហាក់ដូចជាខ្ញុំព្រះករុណាក៏ជា
មនុស្សចេះសមុខឆំ, ក្នុងរឿងនេះខ្ញុំព្រះករុណា យល់ឃើញសេចក្តីទ.
មាថា: ឱនបុរសម្នាក់ចង់ជាន្ទប្រពន្ធ, កាលបើបានឮគេថា មានកូន

ក្រមុំបេះស្រគែកូលមួយមានរូបល្អ ជាស្រីគ្រប់លក្ខណ៍, បុរសនោះបានឃើញដាក់ ហើយមានចិត្តច្រេកគិតខ្ជិ អត់ពុំបានក៏ចូលទៅដណ្តឹងខំផ្តាច់ផ្តួនយ៉ាងណា ក៏មាតាបិតាពុំព្រមឲ្យកូនក្រមុំនោះដល់បុរសនោះសោះ; ដល់ថ្ងៃក្រោយទៀត មានបុរសដទៃ បម្រុងទៅស្តីដណ្តឹងនាងក្រមុំនោះដែរ, ស្រាប់តែបុរសមុននោះមកឃាត់ថា កុំទៅ! គេមិនឲ្យទេ! ។ ខ្ញុំព្រះករុណាយល់ថា បុរសមុននោះ ពុំគួរឃាត់បុរសឯទៀតទេ, ចាប់តែខ្លួនជាមនុស្សឥតកត្តព្វ, ម្តេចក៏ចង់ឲ្យគេឥតកត្តព្វជួចខ្លួនដែរ? ។

ព្រះពុទ្ធទត្តស្តាប់សេចក្តីឧបមានេះចាន ក៏បញ្ជាក់ថែមទៀតថា "អាវុសោ, អ្នកឯងមិនដឿងតម្លៃរស៊ីហឬ: មានសេចក្តីល្អិតល្អន់ណាស់ទេតើ! ប៉ុដូច្នេះ អ្នកឯងមើលត្រឹមតែតម្លៃដំនាលផ្លាវដែលខ្ញុំប្រែមកនេះចុះ ក៏អាចដឹងចានថាការនេះក្រែមន," ហើយលោកយកតម្លៃដំនាលផ្លាវនោះ មកឲ្យព្រះពុទ្ធឃោសៈពិនិត្យមើល ។ ព្រះពុទ្ធឃោសៈពិនិត្យមើលយល់សេចក្តីច្បាស់លាស់ ហើយឃើញសេចក្តីខ្វះដែលគាស់ កំដួយពន្យល់ដល់ព្រះពុទ្ធទត្តថែមទៀត ។ ព្រះពុទ្ធទត្តមានអំណរយ៉ាងខ្លាំង ទើបឲ្យស័ក្តិសាធុការថា "អាវុសោ, អ្នកឯងជាអ្នកប្រាជ្ញពិតប្រាកដមែន ល្មមទៅប្រែគម្ពីរឯលង្កាខ្លីបចានមែន," រួចលោកប្រគេនថ្លែងសម័ន្តដែកថារ ព្រមទាំងថ្នមសំលៀង ដល់ព្រះពុទ្ធឃោសៈថា: វត្តទាំងនេះ

ព្រះតេជគុណបានប្រែគេនដល់ខ្ញុំ គាំងពីកាលដែលខ្ញុំចេញដំណើរទៅប្រែគម្ពីរឯ
កោះលង្កា ជាវត្តមានអានុភាពវិសេសណាស់, ផ្ទៃសម៉ាន់នេះ បើនាន់
តែមតែមួយប៉ុណ្ណោះ អាចនឹងបំបាត់ពេគគ្រប់យ៉ាងបាន, ដែតចារនេះ
បើសំលៀងនឹងថ្មនេះតែម្តង អាចចារគម្ពីរព្រះត្រៃបិដកបាន ១ ចប់; ឥឡូវ
នេះ ខ្ញុំប្រែគេនទៅលោកទៀត, ប៉ុន្តែសូមលោកយកគម្ពីរដ៏នាលង្កា
របស់ខ្ញុំ ទៅកែតម្រាឲ្យខ្ញុំផង ។ ព្រះពុទ្ធឃោសៈ ខ្ញុំល្អតែប្រែគេន
ភ្លាមមួយរំពេច ហើយស្រែចបានការជាគម្ពីរត្រឹមត្រូវល្អ ជាងសេចក្តី
ដែលព្រះពុទ្ធទត្តធ្វើអស់កាលជាអង្វែងមកហើយ ។ ព្រះពុទ្ធទត្តមាន
សេចក្តីគោតស្បប់ស្រេង ឲ្យសំភុសាធុការសរសើរសព្វគ្រប់ប្រការ ហើយ
ចែកចាកគ្នាទៅតាមផ្លូវរៀងខ្លួនទៅ ។ ព្រះពុទ្ធឃោសៈ បានទៅ
ដល់តំពង់នៃគោះលង្កា ក្នុងផ្ទៃសម័យនៃព្រះបាទមហានាមព្រះចៅ
លង្កាទ្វីប ។

សេចក្តីដំណាលសរសើរប្រាជ្ញាដ៏ឆៃឆីតាវតង់អាចរបស់ព្រះពុទ្ធ-
ឃោសៈ ១ លើកទៀតថា: គ្រាដែលលោកទៅដល់ទៅកំពង់លង្កា-
ទ្វីប, មានតាស៊ីរបស់សេដ្ឋីម្នាក់ ឈ្មោះទេវដ្ឋិត, កំពុងតែណែនាំក្តម
ភេញដោយទេវឡើងមកមិនទាន់ផុតពីមាត់ច្រាំង ដូនជាមានតាស៊ីរបស់
សេដ្ឋីដទៃម្នាក់ទៀតជាស្រីកាច មានកំរោលចោកចោះ កាន់ក្តមគ្រវែគ្រវាត់

ចុះទៅជិនចឹកដែរ, ក្អមពាសដែរកំពុងចុះទៅ ប៉ះគ្នាចិនឆ៍ក្អមពាស ដែលកំពុងឡើងមកបែកខ្ចាយអន្លកយ៉ាងពីរ, ពាសក្អមស្រាលក៏ដេរ ដៀលគ្នា ដល់ពួកអ្នកបួរទុកម្ភាយទឹងចៅហ្វាយរបស់ពាសក្អមធ្ងន់ដែលកំពុងឡើងមក, នាងនោះដេរតបវិញ ក៏ក្តាយៗជាជម្លោះយ៉ាងធំ ក្រយដំណាត់ជាក់គ្នាអស់ចិត្ត ទើបត្រឡប់ទៅផ្ទះវិញតែរៀងខ្លួន ។

ចំណែកខាងព្រះពុទ្ធឃោសាចារ្យ តាំងតាំតាលដែលឃើញពាសកំណាចកំពុងដេរមក ក៏ចាប់ក្តីគន្ធឹកឃើញមុនថា "កំរិយាស្រីនេះ ទឹងបណ្តាលឲ្យកើតជាជម្លោះ ឥឡូវនេះពុំខាន; បើស្រីទាំងនេះឈ្លោះគ្នាមែន, ច្បាកជាអាចដល់គាត្មាអញជាសាក្សី; បើអាត្មាអញធ្វើយថាមិនដឹង ទឹងជាមុសាវាទ, បើធ្វើយតាមដឹង មិនសមត្រកាដ្បិតខ្លួនជាសង្ឃ មិនគួរធ្វើសាក្សីឲ្យគ្រហស្ថាសង្គាឡើយ; ល្អើយចុះបើដូច្នេះ គួរអាត្មាអញកត់សំដីដែលវាឈ្លោះគ្នានោះទុកឲ្យហើយ", ទើបលោកលួចយកស្លឹករឹតទឹងដែកចារ ចូលមកដល់ព្រះហស្តកាលណា ក៏ស្រីទាំង ២ នាក់នោះឈ្លោះគ្នាភ្លាមកង់កាលនោះមែន ។ ឯសំដីអ្នកសីហឡៈញាប់ស្រាប់ជាច្បកតិ, ជាងសំដីអ្នកប្រទេសឯទៀត ដល់មានជម្លោះគ្នាទៀតក៏រឹតតែញាប់ដោយកៀកលែង, ដូចជាស្ទាបកង្ហារដែលកំពុងរលីងខ្លាំង ។ សំដីដែលស្រីទាំងពីរនាក់ឈ្លោះគ្នានោះ កប់បានចំនួន ២ ពាន់ម៉ាត់ម្នាក់ៗ

ឥតខាត់ឥតរអាក់រអួលសោះ, ដល់ម្ចាស់ ក៏តង់តែព្រះពុទ្ធឃោសាចារ្យ កត់ត្រាទន់ឥតគាន់ច្រឡំ[1] ។

ឯភាស្តីក្តមស្រាល ដាស្រែកំណាច ថានត្រឡប់ទៅដល់ផ្ទះហើយ ក៏ចូលទៅលំអុកទ្យេសេដ្ឋីដារ៉ាយរបស់ខ្លួន ក្នែងសំដីនិយាយបង្កាច់ថា "ខ្ញុំកំពុងដើរជាសុខស្រាប់តែមេតាស៊ីឈ្មោះនោះ របស់សេដ្ឋីឯណោះ សុះមកបំភ្លេចឲ្យបែកក្តមខ្ញុំ ហើយវាដេរដៀលពួជប្រជុំចសន្ថាន ជំនោរមកលោកជាចៅហ្វាយឯណោះជាន់ខ្លៅត, មេតាស៊ីនោះមិនគួរបើ ឯកើនមើលជាយដល់ម្ចាស់សោះ នេះព្រោះតែវាអាងដល់ចៅហ្វាយវាជាច្មាកជ" ។

សេដ្ឋីនោះភ្លាដូច្នោះហើយ ក៏ខឹងក្រេវក្រើតឡើងថា "មែនហើយ ហាន! បើដូច្នោះ អញនឹងប្តឹងឲ្យវិនាសខ្លួនវាព្រមទាំងម្ចាស់វាឆន"

---

១ សេចក្តីត្រង់នេះ បើតំណាងអ្នកឆ្លើយមែន កំពូរឲ្យកោតដោយយ៉ាង ។ ប៉ុន្តែនេះ បើតំណាងរឿងដែរ គេអាចយល់ថាសេចក្តីប៉ិនប្រសប់ខែបនេះ កើតដោយតំណាងបុណ្យតំណាងដោយអំណាចនៃការរៀន ។ បើតំណាងអ្នកឆ្លើយ គេអាចយល់ថា សេចក្តីប៉ិនប្រសប់ខែបនេះ កើតដោយអំណាចនៃការរៀន, គឺព្រោះពុទ្ធឃោសាចារ្យនេះ ជាមនុស្សម្នាក់ដែលបានរៀនសែសហៅថា Sténographie នេះវិជ្ជាមួយដែលហៅថា "Sténographie" សញ្ញាលេខនវិជ្ជា" ជាវិជ្ជាទាំងការសរសេរឆាប់ល្អើតតំណាងនិយាយ ដោយប្រើត្រឹមសំឡាស់ ។ ប៉ុន្តែបើព្រះពុទ្ធឃោសាចារ្យកត់ភាក្យមនុស្សឈ្មោះគ្នានោះគេញសេចក្តីទាំងអស់ នោះមិនមែនប្រើ Sténographie នេះទេ; ត្រូវតែជាមានវិជ្ជាមួយដែលលឿនសាសនហៅថា "ពម្តិជាពជាវិជ្ជា" ចំណេះឬទេចក្តីតង់អាងដែលជាឯលរបស់បុញ្ញកម្ម ។

ហើយសេដ្ឋីនោះទៅក្រាបបង្គំទូលព្រះពុទ្ធជាម្ចាស់ថា ដល់សេដ្ឋីជាចៅហ្វាយផង ។ ព្រះពុទ្ធជាម្ចាស់ត្រាស់ឲ្យបង្គំគូវ៉ាទាំងសងខាង ស្តេចបញ្ជាក់សព្វគ្រប់សេចក្តី ក៏វិនិច្ឆ័យសេចក្តីដោយយុត្តិធម៌ពុំខានបន្តិចឡើយ ដោយព្រោះគូវ៉ានៅតែមានពាក្យដោះសារទៅវិញ ; ព្រះពុទ្ធជាម្ចាស់ត្រាស់សួរភេសាក្សី ក៏ទាស៊ីខ្លួនពីរនាក់ឆ្លើយអាងថា "កាលដែលខ្ញុំម្ចាស់ប្រកែកគ្នា មានតែព្រះសង្ឃ ១ អង្គគង់នៅលើសំពៅ ឃើញច្បាស់ផង" ។ ដើមព្រះពុទ្ធជាម្ចាស់ត្រាស់បង្គាប់ឲ្យអាមាត្យម្នាក់ ទៅនិមន្តព្រះពុទ្ធឃោសាចារ្យមក ដោយខ្លាំពុំទាន់ជ្រាបជាព្រះសង្ឃអង្គណាសោះ ។ កាលអាមាត្យបានទៅដល់សំពៅ ក្រាបបង្គំទូលតាមព្រះពុទ្ធបញ្ជា, ព្រះពុទ្ធឃោសាចារ្យដំកបសេចក្តីតាមគន្ថិតរបស់ខ្លួនហើយ ឲ្យកំណត់ដែលកត់ពាក្យស្រែឈ្លោះគ្នានោះ ទៅថ្វាយព្រះពុទ្ធជាដំបូងខ្លួន ។ ព្រះមហាក្សត្រខ្លាំងសព្វព្រះទ័យកំណត់នោះហើយ ជ្រាបក្នុងព្រះរាជហឫទ័យថា នេះពិតជាស្នាព្រះហស្តរបស់ព្រះសង្ឃជាអ្នកប្រាជ្ញ, ទើបខ្លាំវិនិច្ឆ័យសេចក្តីថា "មេទាស៊ីអ្នកស្រាល ជាស្រីអន្ធពាល នាំបណ្តាលហេតុឲ្យកើតកោលាហលដល់អ្នកដំ ហើយមើលងាយដល់អ្នកមានបណ្តាសិក្ខិផង, ហង៍ឯងត្រូវចាញ់! បើតាមកំហុសនេះ ហង៍ឯងត្រូវបង់ពិន័យតាមព្រះច្បាប់, ប៉ុន្តែដោយរឿងនេះជាប់ទាក់ទងដល់ព្រះសង្ឃផង ហង៍ឯងត្រូវសងត្រឹមតែក្អមតេ មួយគុណជាបីប៉ុណ្ណោះចុះ" ។

ភាស័ក្តមស្រាលនោះ ក៏ទូលថាស់ព្រះពាជទុង្គារថា "ម្តេចក៏ព្រះអង្គដឿតាមកំណាត់ឋេរសំលោកសង្ឃតម្រែកំនោះ? លោកសង្ឃនោះ មិនមែនជាអ្នកកាន់ក្រឹត្យវិន័យទេ! ប្រាកដជាអ្នកជំនួញ ចុះសំពៅមកជួញ. ខ្ញុំម្ចាស់យើញលោកអង្គុយសំកុកជ្រប់មើលតែផ្លូវអ្នកទិញទំនិញ; សូមព្រះអង្គបដិសេធតាក្យនោះចេញ កុំយកជាប្រមាណឡើយ ។ ព្រះពាជាត្រាស់ថា យ៉ាអើ! មេភាសិនេះមាត៌ន៌, ហ៊ានមើលងាយដល់ព្រះសង្ឃទៀត; បើដូច្នេះ ត្រូវហាន៌ឯងឆាំភៅសូមទោសចំពោះព្រះតគ្គលោកទៀត! ទើបរួចទោសនេះបាន ។

ចំណែកភាន៌ព្រះពុទ្ធយោសាចារ្យ មានប្រាថ្នាទំន៌ភៅថ្វាយបង្គំព្រះមហាថេរដែលជាអធិបតីលើសង្ឃក្នុង៌លង្កាទ្វីប, ទើបឡើង៌ពីសំពៅសំដៅភៅវត្តមហាវិហារក្នុង៌អនុពធបុរី ។ សម័យនោះ ព្រះសង្ឃបាលត្ថេរនាទីជាសម្តេចព្រះមហាសង្ឃរាជ កំពុង៌ឋិតនៃនធម៌វិន័យដល់ព្រះសង្ឃជាច្រើនរូប, ព្រះពុទ្ធយោសាចារ្យឃើញតិច្នោះ ទើបគិតថា "បើអាត្មាអញចូលភៅ, សមជាន៌ឆាក់តាបង្រៀន", ហើយរលាកភៅអែបភៅទី ១ ដ៏សមគួរ មិនឲ្យព្រះសង្ឃបាលត្ថេរឃើញឡើយ ។ ឯព្រះសង្ឃបាលត្ថេរកាលដែលព្រះពុទ្ធយោសាចារ្យចូលភៅដល់ ក៏ស្រាប់តែភ្លេចបាត់សេចក្តីទំន៌ទំនេរតាក្យអ្វីតន្យល់សិស្សត្រៅទៀតពុំឃើញ; មានសេចក្តីអៀនអន់

ក្នុងព្រៃទំយណាស់ កំចូលទៅសម្ងំក្នុងបន្ទប់ ដាច់ព្រៃតគ្នាហាក់ដូចជាផ្ទះបេះដូងថ្មើមច្រមាត់ជាត់ពីក្នុងអង្គ ។

សេចក្តីត្រង់នេះ មានពាក្យអ្នកប្រាជ្ញខ្លះតោះសួរគ្នាថា : ពុះ ហេតុដូចម្តេចបាន ជាគ្រាន់តែព្រះពុទ្ធយោសាចារ្យចូលមកដល់ កំព្រះសង្ឃបាលត្តេរក្តេចជាត់ស្មារតីសូន្យឈឹងដូច្នោះ? អាចារ្យដែលបានបុព្វនិវាសវិជ្ជាធ្វើយថា ដោយអំណាចកម្មពីព្រៃង ។ កម្មពីព្រៃងដូចម្តេច? កម្មពីព្រៃង គឺអំពើឆ្គាំឆ្គងដែលព្រះសង្ឃបាលត្តេរនោះធ្វើពីជាតិមុនមក, ព្រោះកាលពីដើមព្រះសង្ឃបាលត្តេរនេះ កើតជាអ្នកគង្វាលគោ ឈ្មោះគោបាលមាណព តែងកៀនគោទៅឃ្វាលដាច់វត្ត ។ កាលនោះ ព្រះពុទ្ធយោសាចារ្យកើតជាកិក្ខុ ១ រូបកំពុងសាធ្យាយទេញ្ញធម៌ កំភ្ញាក់ភ្លាន់ច្រឡំធម៌ដែលកំពុងទេញ្ញនោះបាត់ពីមាត់ ដោយហេតុតែឮសទ្ធឹកគោនឹងសូរសៀវនៃគោបាលមាណពនោះ; ឥឡូវនេះកម្មនោះក៏ផ្តល់ផលមកដល់ព្រះសង្ឃបាលត្តេរនោះក្តេចធម្មតាពីមុនវិញ ទើបពន្យល់សិស្សតទៅខ្វៃតពុំកើត ដោយត្រឹមតែដំណើរចូលមកនៃព្រះពុទ្ធយោសាចារ្យប៉ុណ្ណោះ ។

ចំណែកខាងព្រះពុទ្ធយោសាចារ្យ ឃើញកិរិយានោះហើយក៏ជ្រាបថា "ព្រះសង្ឃបាលត្តេរនេះក្តេចគណ្តើ" ទើបលោកសរសេរសេចក្តីកង្គណ្តិត្រង់កន្លែងដែលព្រះសង្ឃបាលត្តេរក្តេចនោះ ទុកនៅកន្លែងបន្តែន ហើយរៀបចេញទៅ ។

ព្រះសង្ឃបាលត្មេរ ចេញពីកន្លែងចន្លុះមកវិញ បានឃើញសេចក្តី
នោះក៏ភ្ញាក់ឡើងមួយរំពេច ហើយសួរសិស្សថា ទេវតាឬមនុស្ស
ណា មកសារសេរអក្សរខ្មែរនៅទីនេះ ល្អណ្តុះច្បាស់សេចក្តីដល់ម្ល៉េះ?
សិស្សក៏ទូលតបថា ខ្ញុំព្រះករុណា បានឃើញលោកសង្ឃ ១ អង្គថ្មែក មាន
រូបល្អចំឡែកមកឈរពេលជិតទីនេះ, ប្រហែលជាលោកសង្ឃនោះទេដឹង
ដែលសារសេរអក្សរនេះ ។ ព្រះសង្ឃបាលត្មេរស៊ើបសួរសព្វគ្រប់ជាមថា
លោកសង្ឃនោះគឺព្រះពុទ្ធយោសាចារ្យ ដែលគង់នៅឯសំពៅដ៏កំពង់,
ក៏ប្រគិតកុសង្ឃជាសិស្សរបស់ខ្លួនឲ្យតាមទៅនិមន្តមក ។ ព្រះពុទ្ធ-
យោសាចារ្យបានមកដល់ ថ្វាយបង្គំព្រះសង្ឃបាលត្មេរដោយគោរព;
កាលបើព្រះសង្ឃបាលត្មេរសួរ, ក៏ក្រាបទូលសព្វគ្រប់ថា ពីវេលាមុន
ខ្ញុំព្រះករុណាបានឮមកដល់ទីនេះ, បានដឹងជាព្រះមហាថេរមានសេចក្តី
ភាន់ច្រឡំ ក៏ខ្ញុំព្រះករុណាគិតខ្លាចទូលឲ្យផ្ទាបកន្លែងទីចំពោះព្រះកន្ត្រក្ខាម។
ជុំវិញ្ចាក់ជូចជាអួតអាងចំណេះវិជ្ជាខ្ពាំងពេក; បើមិនតិតទូលសោះ,
ហាក់ដូចជាមើលបំណាំដល់ព្រះពុទ្ធសាសនា; ហេតុដូច្នេះ បានជាខ្ញុំ
ព្រះករុណាសរសេរដើម្បីកែសេចក្តីភ្លាត់ភ្លាំង, សូមមានព្រះមហាថេរ
អត់ឱនឲ្យខាន ។ ព្រះសង្ឃបាលត្មេរទូលសំណេរថា ម្នាលអាវុសោ!
លោកជាអ្នកប្រាជ្ញ, ខ្ញុំមិនសេចក្តីត្រូវអាត្មាពេកចំពោះកិច្ចដែល

លោកបានដួយចំពេញ, ហើយខ្ញុំមានសេចក្តីស្រឡាញ់គោរពចិត្តចំពោះលោក ដែលមានសេចក្តីចេះដឹងច្រើន, ហេតុដូច្នេះ ខ្ញុំសូមអាពាធនាខំមន្តលោកឲ្យនៅក្នុងវត្តរបស់ខ្ញុំ ដើម្បីជួយបង្រៀនព្រះវិន័យដល់ភិក្ខុសង្ឃ, សូមលោកនឹងព្រមដោយសេចក្តីអនុគ្រោះដល់ព្រះពុទ្ធសាសនា ។ ព្រះពុទ្ធឃោសាចារ្យប្រែតែកថា សូមមានមេត្តាប្រោស, ខ្ញុំព្រះករុណាមកកាន់ទីនេះ ដោយព្រះឧបជ្ឈាយ៍បានតាំងខ្ញុំឲ្យមកប្រែព្រះវិន័យដកព្រមទាំងអដ្ឋកថាភាសាសីហឡៈ ជាភាសាមគធៈ រួចស្រេចហើយក៏ត្រឡប់ទៅវិញភ្លាម; ចំខ្ញុំព្រះករុណានៅដួយបង្រៀនព្រះវិន័យដកក្នុងទីនេះ, ឃើញថាខុសទាស់នឹងអាជ្ញាព្រះឧបជ្ឈាយ៍ខ្លាំងណាស់ ។

ព្រះសង្ឃបាលត្បៀតដូច្នោះហើយ ក៏តែតែមានសេចក្តីពេញព្រះទ័យខ្លាំងឡើងដោយយល់ឃើញថា លោកនេះប្រហែលជាចេះដឹងផ្នែកណាស់បានជាព្រះឧបជ្ឈាយ៍ហ៊ានប្រឹងឲ្យមកប្រែគម្ពីរសីហឡភាសាជាមគធភាសា, ប៉ុន្តែព្រះសង្ឃបាលត្បៀតពុំទាន់ជឿសិប់ថាប្រាកដជាប្រែបានប្តូពុំបាននៅឡើយ, ទើបលោកដំណាលថ្លាប់ថា ម្នាលអាវុសោ! ការដែលអ្នកមានបំណងធំធ្ងន់នេះគ្រាន់ណាស់! ដែលមានបំណងដូច្នេះមិនគ្រឹមតែអ្នកម្នាក់ឯងប៉ុណ្ណោះទេ, តាំងពីមុនមកមានព្រះថេរៈ១ អង្គឈ្មោះពុទ្ធទត្ត បានមកប្រែគម្ពីរសីហឡភាសាជាមគធភាសាដែរ, លោកធ្វើអស់

វេលាជារៀងខ្លាំ ជាន់តែមកតែមួយគម្ពីរហើយទើបនឹងតែឡប់ទៅវិញក្នុងវេលាមុននេះថ្មីៗ ។ ព្រះពុទ្ធឃោសាចារ្យថា ព្រះករុណា, ពិតដូច្នោះមែនហើយ, ទាំងព្រះពុទ្ធទត្តសោត ក៏ខ្ញុំព្រះករុណាបានជួបដែរ, ខ្ញុំព្រះករុណាបានទាំងជួយតែងសេចក្តីនៃគម្ពីរដើមាលង្កាដែលព្រះពុទ្ធទត្តធ្វើមិនទាន់តែមត្រូវនោះទៀតផង ។

ព្រះសង្ឃបាលត្ទេរឮហើយ ត្រែកអរព្រឺព្រួចក្នុងព្រះទ័យទីកថាលោកនេះប៉ុនប្រមាប់តាន់ហើ ប្រហែលជាចេះដឹងរៀនមែន, បើដូច្នោះអាត្មាអញសួរប្រស្នាដ៏ល្អិតល្អន់ មានអត្ថសេដ្ឋខ្ពស់ចំពោះលោកនេះមើលអេះ, ហើយលោកលើកប្រស្នាដែលខេត្តសួរព្រះសម្ងាសម្ពុទ្ធមកសួរព្រះពុទ្ធឃោសាចារ្យតាមពាក្យខេត្តថា

អន្តោជដា ពហិជដា ជដាយ ជដិតា បជា
តំ តំ គោតម បុច្ឆាមិ កោ ឥមំ វិជដយេ ជដំ?

សេចក្តីថា: បណ្តាញតិណ្ហាខាងក្នុងក៏មាន, បណ្តាញតិណ្ហាខាងក្រៅក៏មាន, ពពួកសត្វសុទ្ធតែត្រូវបណ្តាញតិណ្ហារួបតែ (ឥតសល់រួបណា); បពិត្រព្រះគោតម ព្រោះហេតុនោះ ខ្ញុំសូមសួរព្រះអង្គចំពោះរឿងនោះថា នរណាទើបកាប់ផ្តាច់បណ្តាញតិណ្ហានេះបាន?

ព្រះពុទ្ធឃោសាចារ្យ តបតាមព្រះពុទ្ធដីកាដែលព្រះសាស្តាទ្រង់
តបនេះគាថា :

សីលេ បតិដ្ឋាយ នរោ សបញ្ញោ
ចិត្តំ បញ្ញញ្ច ភាវយំ អាតាបី និបកោ ភិក្ខុ
សោ ឥមំ វិជដយេ ជដំ ។

សេចក្តីថា នរជនឯណា ជាអ្នកទ្រាំចាក់ធ្លុងវដ្តសង្សារ តបដោយ
បញ្ញា គឺបដិសន្ធិជាវិត្រហេតុក : ដែលកើតអំពីកុសលកម្ម[1] ហើយដំ-
កល់ខ្លួននៅក្នុងសីលផង ចំរើនឲ្យចិត្តគឺសមាធិផង ចំរើនឲ្យបញ្ញា[2] គឺ
វិបស្សនាផង ជាអ្នកមានព្យាយាមដុតកំដៅនូវកិលេស មានបញ្ញាចាស់
ក្លា[3] នរជននោះ ទើបកាប់ផ្តាច់នូវបណ្តាញគឺតណ្ហានេះបាន ។

(សេចក្តីនៃប្រស្នានេះជ្រាលដ្រលាយណាស់ ជាគោលនៃសេចក្តីប្រតិ-
បត្តិ១ចប់ ព្រះពុទ្ធសាសនា ; បើសំដែងដោយពិស្តារ ត្រូវគ្នានឹងព្រះវិន័យ
ជាដក៨ហ្មឺន៤ពាន់ព្រះធម្មក្ខន្ធ) ។ កាលបើព្រះពុទ្ធឃោសាចារ្យវិស្សជ្ជ-
នាដូច្នេះស្រេចហើយ, សម្តេចព្រះសង្ឃបាលត្រេះមានសេចក្តីត្រេះថ្លា
ពេញព្រះទ័យណាស់ ហើយមានថេរដីកាថា ម្នាលលោកអ្នកប្រាជ្ញ!

---

១ ប្រែជាថ្វីទី ១ នេះ ហៅថា សជាតិបញ្ញា ។ ២ ប្រែជាថ្វីទី ២ នេះ ហៅថា វិបស្សនាបញ្ញា ។
៣ ប្រែជាថ្វីទី ៣ នេះ ហៅថា ជវនបញ្ញា ។

លោកអាចារ្យ ស្រាយប្រស្នានេះត្រូវតាមពុទ្ធកាសិតឥតមានខ្ចោះ, ជាហេតុឲ្យខ្ញុំកុណាជឿថា ព្រះពុទ្ធវចន ពាំងអស់ លោកម្ចាស់ចាំបានឥតមានសល់; ហេតុដូច្នេះ ខ្ញុំកុណា សូមអាចធនា សូមឲ្យលោកម្ចាស់មេត្តាចេញាតម្ពីរ សំដែងអំពីសីល សមាធិ បញ្ញា ដែលជាគោលដើមនៃព្រះពុទ្ធសាសនា ឲ្យខ្ញុំកុណាមួយចប់ កំណត់វេលាចឹងទៀ តើលោកម្ចាស់អាចធ្វើឲ្យបានឬទេ ? ព្រះពុទ្ធឃោសាចារ្យទទួលថេរដីកាថា សូមបានមេត្តាប្រោស, ខ្ញុំព្រះករុណាជានាវចនាប្រគេនបាន, ហើយទំងយកមកប្រគេនក៏វេលាព្រឹកស្អែកនេះដាច្បាកដ ។ សម្តេចព្រះសង្ឃ-ជាលត្តេរ មហាសង្ឃរាជ ទំកគោតកក៏ព្រះពុទ្ធឫទ្ធិឃ ហើយមានថេរ-ដីកាថា ខ្ញុំកុណាមានសេចក្តីសង្ឃឹមមាំថា មុខជាទំងបានឃើញស្នាដៃដែលសម្រេច ដោយបញ្ញាបារមីនៃលោកម្ចាស់ជាអ្នកច្បាស់ក្នុងវេលាឆាប់ៗ នេះពុំខាន ។

ព្រះពុទ្ធឃោសាចារ្យ កាលចប់បានទទួលការខានទំងដូច្នេះហើយ ក៏ក្រាបបង្គំលាសម្តេចព្រះសង្ឃជាលត្តេរ ត្រឡប់ទៅកាន់សំណាក់នៅមាត់តំពង់វិញ ចាប់យកដែកចារទំងស្មុំតរឹត មកគងំលើក្បាលសំណៅ ដើម្បីរៀបរៀងគម្ពីរ ក្នុងវេលាបឋមយាមក្តីនៃថ្ងៃភេញ-បូណ៌មីនោះ ។

គ្រានោះ សម្តេចអមរិន្ទ្រាធិរាជ ជាន ប្រាប់ដល់ចន្ទទេវបុត្រឲ្យ ចេញពាក្យទូន្មឲ្យភ្លឺអស្តារ្យ, ប្រាប់លោហការទេវបុត្រឲ្យបកស្ទាត់ពាក្យកុំឲ្យ ប៉ាន់ស្មានព្រះចន្ទ្រ ។

ព្រះពុទ្ធឃោសាចារ្យ ចាប់ចារឿងរឿងគម្ពីរ ចប់កន្លះលោចប់ម-យ៉ាមកគ្រានោះសន្ធគឲ្យឈ្មោះ "វិសុទ្ធិមគ្គ[1]" សំដែងអំពីសីល សមាធិ បញ្ញា ហើយចូលកាន់ទីសយនាសនៈលក់មួយស្រែចក់ ក៏ព្រះឥន្ទ្រលបន្ត

---

១ គម្ពីរវិសុទ្ធិមគ្គនេះ ជាទីនិយមប្រើការរបស់អ្នកកាន់តាមពុទ្ធសាសនាប៉ែកខាងទក្ខិណនិកាយ រហូតមកដល់សម័យនេះ, ដែលឃើញមានចោះក្តុម្តងហើយ ចំនួនជាង ៨៤០ ទំព័រអក្សរញឹក ល្អិត បើពិតជាព្រះពុទ្ធឃោសាចារ្យរៀបរៀងចប់ក្នុងរាត្រីង ១ យ៉ាមដូច្នេះមែន ជាហេតុឲ្យតឹងតំនឹង រះសំអ្នកល្ងង់ហើយប្រឹងតែពិតតោះខ្លាំងណាស់ ។ ព្រោះមានមនុស្សខ្លះ មិនត្រេមជឿសេចក្តី អស្ចារ្យរបស់អ្នកមានបុណ្យបែបនេះទេ ដោយអាងថាខ្លួនទើធ្វើដូច្នោះដែរហើយ នៅតែមិនកើត ម្ល៉ោះហើយក៏ទាញឈ្មោះអ្នកដែលធ្វើកើតតោះមកជាក់ថាមិនកើតដូចខ្លួនផង ។

ខ្ញុំក៏មិនជាមនុស្សដែកឆ្មេចចាំតែរដឹទេ ប៉ុន្តែពុំហ៊ានបង់សេធរសេចក្តីដែលគេបានតាំរកទុក មកហើយនោះសោះ ដោយយល់ឃើញថា មនុស្សយើង បើគិតអាស្រ័យតែក្នុងខ្លួនតែឯង ម្តេចនឹងឲ្យគេហៅថា អ្នកមានបុណ្យកើត! មនុស្សមានបុណ្យចាំឡើង មិនត្រឹមតែព្រះពុទ្ធឃោស: នេះទេ គង់មានមនុស្សឯទៀតជាច្រើនឈ្មោះ ប៉ុន្តែផ្សេងគ្នាតឹមតែអ្នកខ្លះមានបុណ្យបែបនេះ ខ្លះបែបនោះប៉ុណ្ណោះ; ដូចពន្លូសេនាបតី អាចការប់តែ ១ ជាឲ្យជាច្បាស្សី ៦០ ដើមដែលគេ ជាក់ស្តែងនៃការពេញខាងក្នុង, អាចបញ្ចាំតែ ១ ព្រួញសូម្បីតន្លះបន្តោលរទេះ ៥០០ នឹងជាប់ការមនុស្ស ៥០០ នាក់ទៀតជាដរ, ទេះក៏ជាមនុស្សមានបុណ្យចាំឡើងក៏មិនគួរឲ្យជឿសោះដែរ ប៉ុន្តែកាលបើ តំណាលើកពុទ្ធភាសិតថា "នត្ថិ កម្មភយំ សមំ តិតភម្ចាំនត្ថិ នឹងភម្ចាំនភយ្ហ" តែប៉ុណ្ណោះ ក៏ ជាហេតុឲ្យខាតជើតុំកើត ។ មនុស្សដូចព្រះពុទ្ធឃោសៈនេះ គេហៅថា "អច្ឆរិយមនុស្ស" ឬ "អច្ឆរិយមនុស្ស" ត្រូវនឹងភាសាបារាំងសែសថា «génie» ។

យកគម្ពីរនោះទៅលាក់ចាត់ ដើម្បីទំនើងប្រកាសបុញ្ញានុភាពរបស់ព្រះថេរៈអគ្គនេះ ។ ព្រះពុទ្ធយោសាចារ្យតើនឡើងក្នុងវេលាមជ្ឈិមយាម, រកគម្ពីរពុំឃើញ ក៏ចារមួយគម្ពីរទៀត ចប់កងវេលាមជ្ឈិមយាម ហើយសឹងមួយស្របត់ទៀត, ព្រះឥន្ទលបយកទៅទៀត នាំគម្ពីរទាំងពីរចប់នោះទៅហាទគាវត្តិន្ទ្រ បង្គាប់ឲ្យតួកទេពអប្សរធ្វើខ្ទៀងជោត ធ្វើសំពត់រុំ ។ ព្រះពុទ្ធយោសាចារ្យ តើនឡើងចារគម្ពីរដែលបានមួយចប់ទៀត ក្នុងវេលាបច្ឆិមយាមទើបឃើញព្រះឥន្ទនាំគម្ពីរពីរចប់មុននោះ មកប្រគេនវិញ ហើយលោកជាក់ទណ្ឌកម្មឲ្យព្រះឥន្ទថា ដោយកំហុសដែលទៅកាជបានធ្វើហើយនេះ ត្រូវទៅកាជទទួលទណ្ឌកម្ម លីគម្ពីរទាំងបីចប់នេះទៅប្រគេនសម្តេចព្រះសង្ឃថ្កាលត្រេ កុំគេចដោះខ្លួនទៅណាឡើយ គ្រាន់អាត្មាទំនងអាងជាសាក្សី ដើម្បីកុំឲ្យព្រះសង្ឃថ្កាលត្រេរិះគន់ថ្កោលទោសដល់អាត្មាបាន ។ ព្រះឥន្ទក៏យល់ព្រមទទួលទណ្ឌកម្មដោយសេចក្តីសោមនស្ស ហើយទៅបបួលតួកបាតុម្ភហាពជិការទៅគាឲ្យចុះមកជួយហែរគម្ពីរឡើងពីកំពង់តម្រង់ទៅវត្តមហាវិហារ, តួអង្គព្រះឥន្ទឯទីលីគម្ពីរទៅជាមុន, ព្រះពុទ្ធយោសាចារ្យនិមន្តតាមជាប់ពីខាងក្រោយ, តួកបាតុម្ភហាពជិការទៅគាខ្លះកាន់ទង់ ខ្លះកាន់ផ្កាដ៏ចិត្រ ដោយពណ៌ផ្សេងៗ ហែហមពីខាងស្តាំខាងឆ្វេង ចូលទៅកងវត្តមហាវិហារ,

ស្តាប់ពួកមហាជនបានឃើញទេវតាដោយដាក់ច្បាស់ ហើយចោមរោម
ជួយហែហមគ្រប់គ្រា ។ ព្រះពុទ្ធឃោសាចារ្យបានលើកគម្ពីរទាំងបី
ចប់ប្រគេនផ្ទាល់សម្តេចព្រះសង្ឃថ្កាលគ្រេរ ។ ព្រះសង្ឃថ្កាលគ្រេរបាន
ទទួលដោយអំណរណាស់ ហើយមានថេរដីកាថា ខ្ញុំព្រះករុណាមាន
សេចក្តីត្រេកអរច្រើន ដោយបានដួចខ្ញុំឯលោកម្ចាស់ជាអ្នកប្រាជ្ញអាចធ្វើ
ការមានថ្វីដៃតូចតែ ប៉ុន្តែខ្ញុំព្រះករុណាឃើញថាលោកម្ចាស់ហាក់ដូចជាបញ្ចេញ
អំនួតបន្តិច ព្រោះខ្ញុំព្រះករុណាសូមឲ្យរៀបរៀងគម្ពីរតឹមតែមួយចប់ ឥឡូវ
នេះ លោកម្ចាស់បំផ្លើសឲ្យលើសពីរចប់ទៀត ឡើងចំនួនដល់បីចប់
នាំមកបង្អួតពួកយើងអ្នកលង្កា, ភ័ន្តយោនេះ! ត្រង់មិនសមជាគតិអ្នកប្រាជ្ញ
ទេដឹងលោកម្ចាស់? ព្រះពុទ្ធឃោសាចារ្យនឹកក្នុងព្រះហឫទ័យថា, អុញហ្ន៎!
រឿងនេះមកដល់ហើយតើ! ពីដើមមក អាត្មាអញបាម្តេចណាស់ក្នុងរឿងនេះ,
ឥឡូវនេះ បានព្រះសង្ឃថ្កាលគ្រេរចោទចំដូច្នេះ ជាហេតុឲ្យស្អាតខ្លួន
មិនឲ្យមានទន្ទិញគេវៀតបាន, ទើបលោកទូលតបថេរដីកាថា សូមទ្រង់
ព្រះមេត្តាប្រោស! អំពើនេះមិនមែនខ្ញុំព្រះករុណាធ្វើដើម្បីអួតអាង ឲ្យ
អ្នកលង្កាគោតទេ, ប្រាកដជាធ្វើដោយសុទ្ធចិត្ត; គម្ពីរនេះបានជាឡើង
ចំនួនដល់បីចប់ដូច្នេះ ព្រោះចារពីហានសួគ៌ចេះតែមកលួចយកចាត់ៗ
ទៅ, ខ្ញុំព្រះករុណានឹងរង់ចាំកែគម្ពីរដែលចាត់ទៅឲ្យឃើញសិនសឹមយក

មកប្រគេន, ក្រែងដួនជាតុំចាន់លោងដែលសន្ធុត, ហេតុដូច្នេះ ជានជាខ្ញុំព្រះករុណាចំចាមួយចប់ហើយមួយចប់ទៀត ដើម្បីដន្ធូសគម្ពីរដែលជាត់ទៅនោះ, ចប់គម្ពីរទើបិ ស្រាប់តែព្រះឥន្ធូនាំយកគម្ពីរពីរចប់មុននោះមកឲ្យវិញ, សូមទ្រង់ព្រះមេត្តាប្រោស! នេះព្រះឥន្ធូ! ដែលជាអ្នកលួចគម្ពីរយកទៅ, ឥឡូវនេះ ខ្ញុំព្រះករុណាសូមនាំយកមកប្រគេនជាបន្ទាល់សាក្សី; រឿងនេះដូច្នេះទេតើ សូមទ្រង់អភ័យទោស ។

គ្រានោះ ភិក្ខុសង្ឃប្រជុំគ្នាអានគម្ពីរភាំងចប់នោះត្រមជាមួយគ្នា, អតមានដំណើរផ្សេងគ្នាដោយឥន្ទ្រិ: ដោយអក្ខរៈ ដោយបទ ដោយព្យញ្ជនៈ ដោយអត្ថ ដោយពាក្យដើមពាក្យចុង ដោយថេរវាទ ឬដោយព្រះពុទ្ធដីកាឡើយ ។ កាលថើគម្ពីរភាំងចប់ដែលព្រះពុទ្ធ-ឃោសាចារ្យធ្វើឲ្យសម្រេចយ៉ាងនេះហើយ, ទេវតាទាំងឡាយ ក៏ធ្វើសាធុការគេងរំពង, ទាំងពួកភិក្ខុសង្ឃដាច្រើនពាន់អង្គក្នុងវត្តមហាវិហារ ក៏ចុះមូលមកប្រជុំគ្នា ឃើញហេតុអស្ចារ្យដូច្នោះ ក៏មានចិត្តរីករាយជាសោមនស្ស ឲ្យសាធុការឮសំឡេងខ្ទរខ្ទារថា លោកនេះឯងជាកូនអង្គព្រះមេត្តេយ្យពោធិសត្វ ទ្រង់ចុះមកបំភ្លឺសត្វលោកអតសង្ស័យទៀតឡើយ ។

លំដាប់នោះ ព្រះចុន្ទមហាថេរ មហាកស្សបត្ថេរក្តី ទ្រង់ព្រះសរទៅការឮសំឡេងអស្ចារ្យនោះហើយ ទ្រង់ចេញចាកព្រះបរមកដ៏ង

ដោយព្រៃកដសរីរដ៏ថ្លៃថ្លាន ទាន់តួកកដបរិស័ទ្យចោមរោមមែរមាមជាបរិវារ ក្សត្រាទ្រង់ស្តេចចូលទៅកន្លែងវត្តមហាវិហារ ថ្វាយបង្គំព្រះភិក្ខុសង្ឃហើយ ថ្វាយបង្គំចំពោះព្រះពុទ្ធឃោសាចារ្យថា សូមព្រះគុណខ្លួចជ្រាន់តែងដំណាក់ខ្ញុំកុណា ត្រាតែរៀបព្រះធម៌ចប់ កុំឲ្យត្រួយថ្ងៃម្តងឡើយ ។ ព្រះពុទ្ធឃោសាចារ្យ ថ្វាយទទួលបវារណាដោយតុណ្ហីភាព ។

គ្រានោះ ភិក្ខុសង្ឃថ្វាយប្រគល់គម្ពីរព្រះវិន័យត្រៃបិដកពាំនឹងភ្លាមថាភាសាបាលី ព្រមពាំនគម្ពីរអដ្ឋកថាពាំនឹងភ្លាមថាភាសាស៊ីហឡ: ទៀមកព្រះពុទ្ធឃោសាចារ្យ ។ ព្រះពុទ្ធឃោសាចារ្យទទួលយកគម្ពីរពាំនអស់នោះ យកទៅតាំនៅកន្លែងក្នុងថ្ងាសាទមួយឈ្មោះ បជាទឃរ,(១) ក្នុងភាគពាយព្យនៃវត្តមហាវិហារ រៀបអដ្ឋកថាភាសាស៊ីហឡ: ពាំនអស់មកជាភាសាមគធៈដែលជាមូលភាសា ។

សេចក្តីពិតថា អដ្ឋកថាភាសាស៊ីហឡ: មាន ៣ បែបគឺ មហាអដ្ឋកថា ១ បែប, បច្ចរិយអដ្ឋកថា ១ បែប, កុរុន្ទីអដ្ឋកថា ១ បែប ។

---

១ ក្នុងរឿងពុទ្ធឃោសនិទាន នឹងគម្ពីរសុត្តដាតក មានសេចក្តីថា ព្រះសង្ឃរាលស្តេច បានប្រគល់លោហប្រាសាទឲ្យជាទីតាំងធ្វើការងឺល់ព្រះពុទ្ធឃោសាចារ្យ ។ បជាទឃរៈនេះ ជាសាលារៀនដាំខ្ពស់ ដែលព្រះសង្ឃរាលស្តេចទ្រង់បង្រៀនសិស្សដោយព្រះអង្គឯង ។ សេចក្តីសន្និដ្ឋានថា បជាទឃរៈនេះប្រែហៃលជាសាលារៀន ១ ក្រុមមានច្រើនខ្នង, ប្រាសាទ ១ ខ្នង នៃលៅក្នុងចំណោមបជាទឃរៈនោះ ឈ្មោះលោហប្រាសាទ ។ ប្រវត្តិនៃលោហប្រាសាទនេះមានសេចក្តីពិស្តារក្នុងគម្ពីរមហាវង្ស ។

អដ្ឋកថាដែលព្រះមហាមហិន្ទ លើកឡើងតាន់មហាសង្គីតិហើយនាំទៅធ្វើជាសីហឡភាសាឈ្មោះថា មហាអដ្ឋកថា ។ តាមភាសាសីហឡៈហៅក្សួនថា "បច្ចរិយ", អដ្ឋកថាដែលព្រះអដ្ឋកថាចារ្យទាំងឡាយតង់លើកក្សួនហើយធ្វើ ឈ្មោះបច្ចរិយអដ្ឋកថា ។ មានវត្តមួយឈ្មោះកុរុន្ទិ-វេឡុវិហារ, អដ្ឋកថាដែលព្រះអដ្ឋកថាចារ្យទាំងឡាយតង់ក្នុងវត្តនោះហើយធ្វើ ឈ្មោះកុរុន្ទីអដ្ឋកថា ។ ភាពដែលអាចារ្យទាំងឡាយអ្នកមានមតិស្រេបគ្នាតង់ក្រុមព្រះសង្គីតិកត្តេរជាន់មុន តាន់យកនូវខ្លឹមនៃព្រះពុទ្ធដីកាមកធ្វើនោះឈ្មោះថាថេរកំ ។

មុនដំបូងព្រះពុទ្ធឃោសាចារ្យ បែកកុរុន្ទីអដ្ឋកថាចាកភាសាសីហឡៈធ្វើអដ្ឋកថាព្រះវិន័យឈ្មោះសមន្តបាសាទិកា ដោយភាសាមគធៈដែលជាមូលភាសា ។ លំដាប់ពីនោះ លោកបែមហាអដ្ឋកថាកង់ព្រះសុត្តន្តបិដកចាកភាសាសីហឡៈ រៀបរៀងអដ្ឋកថានៃគម្ពីរទីឃនិកាយឈ្មោះសុមង្គលវិលាសិនី, រៀបរៀងអដ្ឋកថានៃគម្ពីរមជ្ឈិមនិកាយឈ្មោះបបញ្ចសូទនី, រៀបរៀងអដ្ឋកថានៃគម្ពីរសំយុត្តនិកាយឈ្មោះសារត្ថប្បកាសិនី, រៀបរៀងអដ្ឋកថានៃគម្ពីរអង្គុត្តរនិកាយឈ្មោះមនោរត្ថបូរណី ។ លំដាប់ពីនោះ លោកបែបច្ចរិយអដ្ឋកថាកង់អភិធម្មបិដកចាកភាសាសីហឡៈរៀបរៀងអដ្ឋកថានៃគម្ពីរធម្មសង្គណិប្បករណៈឈ្មោះអដ្ឋសាលិនី, រៀប

រឿងអដ្ឋកថានៃវិភង្គប្បករណ៍ឈ្មោះសម្មោហវិនោទនី, រឿបរឿងអដ្ឋកថានៃបញ្ចប្បករណ៍ (គម្ពីរអភិធម្មដាំង ៥ ខាងចុង) ឈ្មោះបរមត្ថទីបនី ។ ព្រះពុទ្ធឃោសាចារ្យ បានធ្វើអដ្ឋកថាព្រះវិន័យបិដកដែលជាភាសាសិង្ហឡៈពាំងអស់ឲ្យជាភាសាមគធៈដែលជាមូលភាសាយ៉ាងនេះ ។ អដ្ឋកថាព្រះវិន័យបិដកដែលព្រះពុទ្ធឃោសាចារ្យធ្វើនេះសម្រេចក្នុងរវាង ១ ឆ្នាំ ។

ក្នុងកាលដែលព្រះពុទ្ធឃោសាចារ្យប្រែអដ្ឋកថាព្រះវិន័យបិដកចប់សព្វគ្រប់ ក៏កើតមានហេតុអស្ចារ្យ គឺក្រមារាមហាប្រថពីករគ្រឹករំពើកញាប់ញ័រ ពួសូរស័ព្ទហាក់ដូចជាសម្រែកវិស្សកទេវបុត្រអំណរ ខ្លះខ្លែរពេញពាំងលោកសន្ធិរាស ។

ព្រះពុទ្ធឃោសាចារ្យ ធ្វើការប្រែគម្ពីរអដ្ឋកថាព្រះវិន័យបិដកគ្រានេះ លោកសម្រេតសម្រាំងធម៌វិន័យត្រឹមត្រូវបរិសុទ្ធគ្រប់អន្ទៃ ចាត់ជាសង្គាយនាទី ៣ ក្នុងលង្កាទ្វីបឬចាត់ជាសង្គាយនាទី ៥ ពាក់ព័ន្ធបឋមសង្គាយនាក្នុងជម្ពូទ្វីបមក ។

ព្រះពុទ្ធឃោសាចារ្យ កាលបើប្រែគម្ពីរអដ្ឋកថាចប់ស្រេចហើយ ក៏គាបបង្គំលាសម្តេចព្រះសង្ឃឫទ្ធិលត្តេរជាមហាសង្ឃរាជ ទីឯកិក្ខុសង្ឃថ្វាយព្រះពរលាព្រះចាតុមហានាម ម្ចាស់ផែនដីលង្កាទ្វីប ព្រមទាំងព្រះ

ពាជសេវកៈនឹងអ្នកដែលគួរលោភាំងអស់ ហើយនាំគម្ពីរចុះកាន់សំពៅ ដើម្បីត្រឡប់ទៅកាន់ជម្ពូទ្វីបវិញ ។ គ្រានោះ ពួកភិក្ខុបរិសទ្យអ្នកលង្ការទ្វីប មានព្រះចុន្ទមហានាមនឹងព្រះសង្ឃឃោសាចារ្យជាដើម បានជូនដំណើរចុះទៅកាន់សំពៅ បានថ្វែងនមក្សរពាក្យតិះពោលដ៏សាគ្គរឲ្យជាប់ចិត្តជាច្រើនប្រការ ។ ព្រះពុទ្ធឃោសាចារ្យមានសេចក្តីសោមនស្សអស់ពីព្រះទ័យទើបថ្វាយព្រះនាមាឈ្មោះ អដ្ឋគ្គសេតមន្ត្តិ[1] ចំពោះព្រះពាជាថា "បពិត្រមហាពាជ, អាត្មាភាពមានអំណរនៃក្រពេកចំពោះបដិសណ្ឋារកិច្ចរបស់ព្រះអដ្ឋទ្ធនឹងព្រះសង្ឃទាំងអស់, ទំហំដុតនៃដំណើរមកនេះ អាត្មាភាពឥតវត្តុអ្វីថ្វាយទុកជាទីលើកទេ, មានតែព្រះនាមាទេនេះដាបន្ទមសក្សីការចំពោះព្រះបាទាំងគូនៃព្រះសព្វញ្ញុពុទ្ធដាម្ចាស់ សូមព្រះអង្គស្វាធ្យាយសូត្រឲ្យរឿយៗចុះ ព្រះអង្គនឹងបានសុគតិសួគ៌ជាសម្បុកយកពុំខាន" ។ លំដាប់នោះ នាយកេគ្រាចាត់ការបើកសំពៅនាំព្រះពុទ្ធឃោសាចារ្យត្រឡប់ទៅកាន់ជម្ពូទ្វីបវិញ ។ ព្រះពុទ្ធឃោសាចារ្យឡើងទៅតមស្សការច្រៀនគម្ពីរវេស់ព្រះមហាថេរដោយបដ្ឋាយ៍ បានចូលតស៊ូសាធុការនឹងសេចក្តីសរសើរច្រើនប្រការដែលបដ្ឋាយ៍ បានកត្តិខាម

---

๑ ធម្មសរសើរព្រះជាវ ដែលមានបាលីថា "យស្ស បាទេ សុជាតានិ ទ្វេ បញ្ហានិ មហេសិនោ នានាការេហិ បុណ្ណានិ តំ វន្ទេ បុរិសុត្តមំ" ន្លឹះដោះដើម ដែលព្រះសង្ឃប្រែទេសៈយើងច្រើនតែសូត្រក្នុងរង្វាន់ភ្ជុំបិណ្ឌ ។

ល្បីល្បាញច្រាកដក្នុងលោក ថាជាអ្នកច្រៅដូចមច្ឆាក្នុងពុទ្ធសាសនា បែកខាងខន្តិណាតិកាយថានជាព្រះគន្ថរចនបណ្ឌិតខាងឆ្លាយ ក្នុងនានាប្រទេសអត់គ្រាំពុំបាន បានតែងរឿងសរសើរព្រះពុទ្ធយោសាចារ្យជាច្រើនបែប(១) ។

រឿងប្រវត្តិព្រះពុទ្ធយោសាចារ្យមានសេចក្តីផ្សេងៗ ជាច្រើនបែបដល់ម្ល៉ះ បានជាខាំឲ្យអ្នកមើលមានចិត្តងឿងឆ្ងល់គ្នាជាច្រើន តែអ្នកខ្លះដែលសម្បូណ៌ដោយសទ្ធាយល់ថា រឿងព្រះពុទ្ធយោសាចារ្យខាំងប៉ុន្មាន សុទ្ធតែពិតខាំងអស់; អ្នកខ្លះដែលច្រាសចាកសទ្ធាពុំជឿថាពិតទេ, ព្រោះរឿងខាំងនោះសំដែងសេចក្តីសរសើរព្រះពុទ្ធយោសាចារ្យលើសលុបពេក ឃើញថាព្រះពុទ្ធយោសាចារ្យអង់អាចហួសវិស័យមនុស្សធម្មតាដែលគេឆ្ងាប់ឃើញនឹងក្អែក, អ្នកខ្លះដែលមានសទ្ធាប្រកបដោយច្រាជ្រាយល់ថា

---

๑ រឿងមហាវង្សពង្សាវតារលង្កាទ្វីប, ពុទ្ធឃោសនិទាន, វិសមាលិនី ញាណោទ័យ, សាត្ថតិតកនិទានានិសង្ស, ពុទ្ធឃោសប្បវត្តិកថា, ស្បាមួបសម្បទាវត្ត, រឿងច្រៃតិស្ថានព្រះសង្ឃ ស្បាមវង្សក្នុងលង្កាទ្វីបដាដើម; រឿងទាំងនេះ ជាភាសាបាលីក៏មាន ភាសាសៀម ភាសាខ្មែរដែលប្រែពីបាលីក៏មាន ភាសាសៀមនៃលេខែតែងសេចក្តីវិនិច្ឆ័យ ទំនងសេចក្តីសន្និដ្ឋានក៏មាន ។ ក្នុងពុទ្ធឃោសនិទាន មានសេចក្តីមួយកន្លែងថា ព្រះពុទ្ធឃោសាចារ្យនេះជាពួកអគ្គអគ្គសាវកនៃព្រះអរិយមេត្តេយ្យ, ប៉ុន្តែខ្ញុំចំស្រែវង្រៃរកដើមហេតុនៃពាក្យនេះ ឲ្យឃើញថាជាពាក្យរណ៌របស់ព្រះអរហន្តអង្គណាពុំឃើញសោះ ។ ក្នុងរឿងពុទ្ធឃោសប្បវត្តិកថាថា ព្រះពុទ្ធឃោសាចារ្យបិតទៅជាសុទ្ធាវាសព្រហ្មលើអស់ព្រះជន្មបានទៅកើតក្នុងឋានតុសិត ។

រឿងនោះតិតដោយច្រើន, ប៉ុន្តែគង់មានសេចក្តីលើសលុបហួសខ្នងខ្លះក៏មាន; ដូចរឿងដែលបានថ្លែងមកហើយនេះ ហុចសេចក្តីឲ្យយើញថា "ព្រះពុទ្ធឃោសាចារ្យប្រែអដ្ឋកថា ព្រះវិនៃចំដកមួយចប់តែម្នាក់ឯងតត់, ធ្លើហើយស្រេច ក្នុងរវាង ១ ឆ្នាំ សង្គាយនានោះហៅថា "តតិយសង្គាយនា កន្លងផ្លាទ្វីប" ។ សេចក្តីនេះពុំសមបុរសមដើមទេ, ព្រោះចំនែកការសង្គាយនាតាំងពីបឋមសង្គាយនា ទុតិយសង្គាយនា តតិយសង្គាយនា កន្លងផុតទ្វីប ដែលព្រះអរហន្តទាំងឡាយ មានព្រះមហាកស្សបជាដើម បានធ្លើរៀងមក លោកតែងប្រជុំព្រះអរហន្តច្រើនរយអង្គណាស់ ក្នុងគ្រាដែលធ្លើសង្គាយនាមួងៗ, ចុះម្ល៉ែកអ្វីតែសង្គាយនារបស់ព្រះពុទ្ធឃោសាចារ្យនេះ លោកជាបុថុជ្ជនសោះទេ ម្តេចក៏ធ្លើត្រមោចត្រមង់តែម្នាក់ឯងដូច្នេះ ។

សេចក្តីសន្និដ្ឋានថា ព្រះពុទ្ធឃោសាចារ្យជាអ្នកប្រាជ្ញចម្បងតិតមានបុញ្ញាវិទ្ធិលើសវិស័យមនុស្សជម្មតាមែន ប៉ុន្តែគ្រាដែលធ្លើការនេះប្រាកដជាលោកប្រជុំអ្នកប្រាជ្ញជាតិសីហឡៈជាច្រើនរូបមកធ្លើរួមផង, ដូច្នេះទើបការនេះគេចាត់ជាសង្គាយនាបាន ។

មានតំណុតាងមួយកន្លែងទៀតដែលលម្អឲ្យសន្និដ្ឋានថា ការនេះ អ្នកប្រាជ្ញច្រើនរូបប្រជុំគ្នាធ្លើ គឺគេសង្កេតយើញតម្លាអដ្ឋកថាដែលមានឈ្មោះ

ថាព្រះពុទ្ធឃោសាចារ្យធ្វើតាំងប៉ុន្មានទោះ ប្លែកគ្នាដោយរបៀបពាក្យ នឹងអត្ថស្រយ៉ាងច្រើនអនេក, តែខ្លឹងខ្លះមានរបៀបពាក្យល្អល្អះលះសេចក្តីបង្អុលប្រាប់ហេតុផលធំៗ គួរឲ្យសន្និដ្ឋានថាជាស្នាដៃព្រះពុទ្ធឃោសាចារ្យមែនៗ តែខ្លឹងខ្លះមានសេចក្តីតិចស៊ីៗ ពុំសូវបង្អុលប្រាប់ហេតុផលច្បាស់ទេ; គួរឲ្យសន្និដ្ឋានថាពុំមែនស្នាដៃព្រះពុទ្ធឃោសាចារ្យឡើយ ។ ម្យ៉ាងទៀត ព្រះពុទ្ធឃោសាចារ្យ ធ្លើតែមួយអង្គឯងពិត តែវេលាដែលលោកស្រួលតែងអត្ថបែបប្រាប់ លោកធ្វើការបានល្អ, ដូនជាវេលាដែលលោកពុំស្រួលតែងអត្ថតុះប្រាប់បន្តិច លោកធ្វើត្រឹមតែគាត់សឲ្យតែរួច ។ ទៅដូច្នេះទេដឹង! ប៉ុន្តែ បើយ៉ាងនេះ ការនេះមិនមែនជាសង្ស័យខ្លាំងទេ ។

ចប់ពុទ្ធឃោសប្រវត្តិតែប៉ុណ្ណោះ ។

ក្នុងសៀវភៅសាមគ្គីរបស់ព្រះគ្គ មានសេចក្តីថា តាំងពីព្រះពុទ្ធ-
ឃោសាចារ្យចេញទៅធ្វើសង្គាយនាកាល ព.ស. ៩៥៦ ក្នុងដែនដីព្រះ
ចាវមហាមេ ពេលកាន់ព្រះមហាថេរ ដែលបានតែងគម្ពីរក្នុងផ្លូវព្រះ
ពុទ្ធសាសនាចំនួនជាមួយគ្នាជាប់នាមខុក ២៧ រួមគឺ:

๑- ព្រះពុទ្ធវង្ស
๒- ព្រះចរិយាបិដក
๓- ព្រះជោតកាលង្ការ
๔- ព្រះទេម
๕- ព្រះធម្មសិរី
๖- ព្រះនន្ទ
๗- ព្រះអាទន្ត
๘- ព្រះអនុរុទ្ធ
๙- ព្រះឧបតិស្ស
๑๐- ព្រះពុទ្ធឃោសាចារ្យ
๑๑- ព្រះមោគ្គល្លាន
๑๒- ព្រះហរិបុត្ត (ព្រះសារីបុត្តនេះមានសេចក្តីដែលគេសរសើរក្នុងមកថាលោកមានការចង់ចាំយ៉ាងវិសេសណាស់ បើបានស្តាប់សេចក្តីណា សូមប្រែតែម្តងក៏អាចចាំបានដល់ ๑๐๐ គាថា) ។
๑๓- ព្រះសង្ឃរក្ខិត
๑๔- ព្រះសុមង្គល
๑๕- ព្រះវង្គីស
๑๖- ព្រះធម្មកិត្តិ
๑๗- ព្រះនាគសេន
๑๘- ព្រះភទ្ទន្ត
๑๙- ព្រះវិរៈហារ
๒๐- ព្រះពុទ្ធវិរិយៈ
๒๑- ព្រះអរិយទេវ
๒๒- ព្រះសោលកសង្ឃាថេ
๒๓- ព្រះសង្ឃរក្ខិតមុល

២៤- ព្រះអនុរុទ្ធ	២៦- ព្រះមាយាវបរ
២៥- ព្រះធីបង្ករ	២៧- ព្រះធម្មសេន

ក្រៅពីនេះ មានពួកបណ្ឌិតជាគ្រហស្ថ ដែលបានរួមការជាមួយគ្នា ៩ នាក់ទៀតគឺ:

១- សន្ធូបច	៦- បុរូលុតេមី
២- ធម្មគិត្តិបច	៧- តាគមបក្កវត្តិ
៣- ធីរនាគបាល	៨- បវក្កមបណ្ឌិត
៤- ពជមុខារី	៩- អាតរបណ្ឌិត
៥- តរិពជសេខរ:	

ព្រះសង្ឃទីធ គ្រហស្ថជាបណ្ឌិត ដែលមានសំដែងនាមខុសគ្នាសៀវភៅវេស្សាមួយសម្បទាគ្នាតាំងនេះ តុំត្រាំកដជាលោកណាបានតែងគម្ពីរអ្វីខ្លះ ពីកន្លងកាលណាខ្លះសោះឡើយ ? ប៉ុន្តែបើខុសជាដូច្នោះ ក៏គង់មានអ្នកខ្លះយល់ថា "ប្រហែលជាលោកអ្នកជ្រាជ្ញតាំងនេះហើយ ដែលធ្លើសគ្នាយនាជាមួយនឹងព្រះពុទ្ធឃោសាចារ្យ" ។ សេចក្តីយល់ស្មានដូច្នេះ ខ្ញុំមិនចុះអនុមតនឹងទេ ។

សុមន៍

សេចក្តីផ្តួចផ្តើមលើកទី ៥

អំពីពុទ្ធសាសនបណ្ឌិត្យ

ទឹងជួនរង្គាន់ជាទីពេញបិត្ត

ដោយក្រសួងពុទ្ធសាសនបណ្ឌិត្យ គ្រូវការរៀងពីដំបូណ្យចូលគ្នាតាមវ័ន្ទរៀមរាល់ខែ ដែលគេធ្លាប់ជាសណ្តាប់រៀងមក, ដើម្បីសូមក្រុការសរសើរអស់លោក-អ្នកដែលមើលនូវឆ្នាំវត្តមួយសុំយោបល់យើងម្ចាស់ណាមួយក៏ដោយ ដែលមានសេចក្តីចេះចាំរឿងនេះច្បាស់លាស់សុំឲ្យគែទ័ាសេចក្តីយការដោយល្អិតតិស្តាគោមរបៀប តាំងអំពីដើមរហូតដល់ចប់ដោយនិយកំណត់ដូច្នេះ :

ក- ការឆ្លើមបុណ្យ មានរបៀបដូចម្តេចខ្លះ?

ខ- កន្លងពីដំបូណ្យតាំង ៣ ថ្ងៃ តើមានកិច្ចដែលគ្រូវធ្វើដូចម្តេចខ្លះ? ប្លុះរៀបរៀងដោយតិស្តារ តាមលំដាប់មុនក្រោយដោយយ៉ាងពៅ ?

គ- របៀបធ្វើទៅផ្ទះ ដូចម្តេចខ្លះ? ធ្វើទៅទីធំវត្តដូចម្តេចខ្លះ? ចូរអធិប្បាយឲ្យសព្វគ្រប់ ?

ឃ- កន្លងពីដំបូណ្យនេះ មានលេងល្បែងគ្រឿងកំសាន្តខ្លះ របៀបលេងខាងដូចម្តេច? មានគ្នាតិចគ្រើនប៉ុន្មាននាក់? សូមឲ្យអធិប្បាយ

ដោយឯង្គត ត្រូវតាំងកត់ឈ្មោះសិស្សដែលខំខ្មីឃ្មាតរៀនអំបាលនោះឲ្យ
សព្វគ្រប់ផង ។

៥- តប្បីតែងតាមពិត តាមដែលខ្លួនបានដឹង បានឃើញរបៀប
ដែលគេធ្វើក្នុងស្រុករបស់ខ្លួនឬក្នុងតំបន់នានា ? ឃើញពីកាលណា ?
ឲ្យកត់ផង កុំឲ្យខ្វះ កុំឲ្យបំផ្លើសលើស ។ បើមានពាក្យសុភាសិត
ឬពាក្យប្រដៅ ឬខំខ្មីរៀនក្នុងកាលបួលឆ្នាំ
ឲ្យកត់ចម្លងដាក់ទៅផង ។

ក្នុងតំបន់នេះ ក្រសួងពុទ្ធសាសនបណ្ឌិត្យបានតាំងជាវគ្គខុក ៣
ជាន់ គឺវគ្គលេខ ១ លេខ ២ លេខ ៣ សម្រាប់ជូនដល់អ្នកតែងល្ខ
យ៉ាង លេខ ១- លេខ ២- លេខ ៣ ។ ហេតុនេះលោក-អ្នកដែលស្ម័គ្រតែងរឿងនេះ កាលតែងចប់ហើយ សុំឲ្យបញ្ជូនទៅក្រសួងពុទ្ធ-
សាសនបណ្ឌិត្យនៅភ្នំពេញ ក្រសួងនេះបានទទួលហើយ ទំនងជាក់ឲ្យ
ក្រុមជំនុំពិនិត្យ ហើយទំនងជូនវគ្គខុកដល់លោក-អ្នកដែលតែងល្ខ ដូច
បានកំណត់ខាងលើនេះជាពិតប្រាកដ ។ ការតែងរឿងនេះ មិនមែន
ត្រូវការដល់ទៅសរសេរឲ្យល្អ ឬជាក់អក្សរឲ្យត្រឹមត្រូវនោះទេ ត្រូវការ
តែឲ្យបានសព្វគ្រប់ ហើយជាសេចក្តីពិតផង អ្នកណារួមបានសព្វ
គ្រប់ ខុកជាបានការ ហើយឲ្យបានយ៉ាងយូរត្រឹមថ្ងៃ ១ កើតខែដេស្ន

ឆ្នាំមុមែបញ្ចស័ក ។ ក្រុមដំទុំពិនិត្យហើយ យើញថាបេសកម្មណាល្អ
ទើនាំចុះផ្សាយកងកម្មដសុរិយា ។

សូមឲ្យលោក-អ្នក មើលសៀវភៅកម្ពុជសុរិយា ជួយផ្សាយដំ-
ណឹងនេះ ទៅដាយរួសពន់ជន ។

សូមអរគុណទុកជាមុន

ថ្ងៃ ២៩ ខែមីរ្ឋ ឆ្នាំ ១៩៤៣

ពុទ្ធសាសនបណ្ឌិត្យ

តាំងអំពីឆ្នាំ ១៩៦៣ ខ្ញុះដាដើមទៅ យើងបានចាត់រៀបចំទស្សនាវដ្តី "កម្ពុជសុរិយា" តាមរបៀបថ្មី ដូចជាទស្សនាវដ្តី (Revue) ទាំងឡាយរបស់ក្រៅប្រទេស លោក-អ្នកគ្រាន់តែក្រឡេកមើលក្របសៀវភៅខាងមុខបង្គស់នេះ ក៏អាចគ្រាបបានមួយរំពេចថា ខាងក្នុងសៀវភៅនេះមានរឿងអ្វីខ្លះ ព្រមទាំងតាមអ្នករៀបរៀងរឿងនោះៗ ។

ដោយហេតុមានខ្ចប់សន្តឹងក្រក្រែងសោះពុម្ពដាប់ជ្រុតក្នុងសម័យសព្វថ្ងៃនេះ តាំងទស្សនាវដ្តីកម្ពុជសុរិយា ក៏ត្រូវបានចេញផ្សាយទាំងយឺតយ្យរខុសឧម្មាសព្វដងដែរ ទើបយើងរួបរួមរឿងរ៉ាវផ្សេងៗក្នុងរាងៗ ៣ ខែនោះមកបញ្ចូលក្នុងមួយសៀវភៅនេះ ដែលមានចំនួនដល់ ១៨០ ទំព័រ សម្រាប់ខែឃុំងអិយេរ ហ្វេរ្រីយេរនឹងម៉ាស ហេតុនេះ យើងសូមទោសគស់លោក-អ្នកដាវ ដែលទស្សនាវដ្តីរបស់យើង ចេញផ្សាយយឺតយ្យរមិនទាន់ក់ណាត់ក្នុងទាសនេះផង ប៉ុន្តែយើងសូមដំរាបទុកជាមុនថា បើមិនមានឧបសគ្គអ្វីទេ ចាប់តាំងពីខែអាវិលនេះតទៅ ទស្សនាវដ្តីកម្ពុជសុរិយានឹងចេញផ្សាយក្នុងក់ណាត់ ១ ខែ ១ ក្បាលដូចសព្វដងរៀងទៅ ។

មួយវិញទៀត យើងសូមជូនដំណឹងថា សាសនក៏ថ្វាន្ទុក្រមដែលធ្លាប់ចោះចេញផ្សាយកាល់ៗខែនោះ ពីឡូវត្រូវឈប់ទាន់ចោះពុម្ពតទៅទៀត តែយើងនឹងប្រមូលយករឿងផ្សេងៗក្នុងសាសនក៏ថ្វាន្ទុក្រមនោះមកដាក់ក្នុងទស្សនាវដ្តីនេះវិញ ទាំងបុងភាគសៀវភៅនេះ ហេតុនេះតាំងពីពីឡូវនេះទៅ កម្ពុជសុរិយានឹងមានរឿងរ៉ាវទាងសាសនក៏ថ្វាន្ទុក្រមមកបញ្ចូលខ្លះផង ដូចមានដំណឹងតាំងពៅអធិការនឹងបុណ្យបញ្ចុះសីមាជាដើម ។

សៀវភៅចោះពុម្ពចេញថ្មី អំពីពុទ្ធសាសនបណ្ឌិត្យ

១ — តំរូក្បាច់ជាក់ខ្មែរ សម្តេចព្រះបិតុច្ឆាវស្មីសោភ័ណនរោត្តម ទ្រង់រៀបរៀង សៀវភៅ ៤នេះមានប្រយោជន៍ដល់ស្ត្រីជាតិខ្មែរខ្លួងទៅ ព្រោះតំរូក្បាច់ដែលមានទៅក្នុងសៀវភៅនេះ មានបែបផ្សេងៗជាច្រើនគប់រយមុខ តួរតែកូមារីជាតិខ្មែរទិញទុកប្រើការផ្ទាល់ខ្លួនគស់គ្នា ។ សៀវភៅនេះដំឡៃ ១ ក្បាល ៣រ.៦០ ។

២ — មិលិន្ទប្បញ្ហាភាគ ១ ចោះពុម្ពឡើងវិញហើយ ដំឡៃថ្មី ១ ក្បាល ១រ.៤០ ។

៣ — អភិធម្មត្ថសង្គហៈសម្រាយចំណាយអស់យូរហើយ ពីឡូវចាប់ចោះពុម្ពឡើងវិញ ដំឡៃថ្មី ១ ក្បាល ១រ.៤០ ។

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀមអក្សរសាស្ត្រ ព្រមទាំងផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនឥតទ្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ ពៅ-សុីម អ្នកគ្រូពត្រាំ
សិស្សនៅសាលាជាលីដាន់ខ្ពស់

បញ្ជីរឿង

		ទំព័រ
ផ្នែកអក្សរសាស្ត្រ		
ឃុនឥតទ្ធមន្ត្រី ញ៉ុក-ថែម . . .	រឿងកុលាបចៃលិខ	១៨១
" "	ពង្សាវតារប្រទេសចិន ស្រង់ចេញអំពីគោល	
	ចារឹកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) . .	១៩៤
លោកអាចារ្យ គឹម-អាន	រឿងព្រះជាទេអសោកមហាភត (តមក)	២០៣
អ្នកនាងកញ៉ាខេស្ពាវិនិច្ឆ័យកែវ-ហង្ស	រឿងប្រែអៅចិត្ត (ពាក្យកាព្យ) (តមក)	២១៦
ចម្លងចេញអំពីប្បាប់សាស្ត្រាស្ទឹកវែត	រឿងត្រែងខ្មែរ: រឿងចៅធុងចៅសាញ់	២២៣
ផ្នែកសាសនា		
ដំណឹងអំពីក្រសួងធម្មការ . . .	អំពីការតាំងចៅអធិការថ្មី នៅវត្តនាគ (ក្នុងខែ	
	ហ្វេព្រៃយេរ)	២៣៦
" "	ពិធីបុណ្យបញ្ចុះសីមានៅវត្តនាគ	២៣៩
ឃុនឥតទ្ធមន្ត្រី ញ៉ុក-ថែម . . .	ប្រស្នាធម៌អំពីព្រះនិព្វាន	២៤១

ឆ្នាំទី ១៩— លេខ ៤ ប្រចាំខែអាប្រិល ១៩៤៣ ។
ដំឡៃជាវ: ១ ឆ្នាំ ១០ រៀល— ៦ ខែ: ៥ រៀល ។

XVe Siècle, no 4.

KAMBUJASURIYĀ

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Khoun Nibandhamantri Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Kao-Sim, Surveillant général de l'Ecole Supérieure de Pāli.

TABLE DES MATIÈRES

Partie littéraire

		Pages
Khoun Nibandhamantri Nhok-Thèm ...	Rœung Kolap-Pailin (Roman khmer).	181
» » ...	Histoire de la Chine. Extraits de divers documents de l'histoire universelle (suite).....	194
Feu l'Achar Kim-Ann	Légende de l'Empereur Açoka de l'Inde antique (suite).....	203
Oknha Chesdayinichay Kèo-Hang.....	Prâdaochet (poème) (suite).....	206
	Conte populaire cambodgien inédit : " Chao Thaung Chao Sanh ".....	223

Partie religieuse

Informations du Ministère des Cultes.....	Nominations de nouveaux Chao Atthikar.....	236
» »	Cérémonie des Sīmā dans diverses pagodes.....	239
Khoun Nibandhamantri Nhok-Thèm	A propos du Nirvāna.....	241

15e année — N° 4. Avril 1943 — Abonnement: un an 10$00.

រឿងកុលាបម៉ៃលិន

វគ្គទី ១

គ្រាកាលព្រះសុរិយោទេវបុត្រ ទ្រង់គង់លើវិមានកែវផលិកដែលជាវេជព្រះទីនាំងធម៌ដោយសេះអាជានេយ្យ ១ ពាន់, ទ្រង់បរបែទក្សិណភ្នំព្រះសិនេរុកដ តាំងអំពីទិសបូពាយាគ្រាសំដៅទៅទិសបស្ចឹម តាមចក្រពាលនៃសុរិយចក្រវាឡ, លុះដល់កំណាត់បត់ព្រះពាដវេចូលចាំងផ្ទៃមហាបតូគា រស្មីព្រះសុរិយោគ៌ជ្រៀងជ្រែចូលគាន់សន្ធ្យាកាគ្រី, នាវេលានោះជាខាងខ្នើត ១៥ កើត ខែកត្តិកឆ្នាំចចត្វាស័ក ព.ស. ២៤៧០; ព្រះចន្ទ្រទេវបុត្រយាងឡើងគង់លើវិមានច្បាក់ ជាពាដវេព្រះទីនាំង, បរវេញមកពីទិសបូពា ទ្រុះពន្លឺព័ណ៌ច្បាក់ទៅសត្វផែនពសុធា; ព្រះចន្ទ្រហាក់ដូចជាមេឃឹងមើលមកយ៉ាងស្រស់ញញឹម ឆ្ពោះចំទៅលើដំបូលគេហស្ថានមួយនៅខាងលិចផ្សារស្វាយចេ៉ា ដែលជាផ្សារវិលកង់ទីរួមខេត្តច្បាត់ដំបង ។

ឯគេហស្ថាននោះ ជាផ្ទះចាស់ប្រក់ក្បឿងដំបូលពីរជាន់, ជញ្ជាំងក្តារ, គ្រាលក្តារ, សសរមូល, ទៅះហាជាងមានរូបចម្លាក់ឈើធ្វើជារូបកហូរលេចខែ, នៅខាងគ្រែមវេនេះគេឆ្លាក់ជាអក្សរមូលតួធំៗ ថា "សិរិ-ឥន្ទ្រ" ជាផ្ទះខ្មែរបែបបុរាណ ដែលនៅសេសសល់ដល់មកសម័យឥឡូវនេះ ។

កន្លែងនោះ ពន្លឺរស្មីនៃដួងបន្ទូរកំពុងចាំងចូលមកតាមបង្អួចបើកចំហ ហើយមានខ្យល់ត្រជាក់ បក់ជាតំណាយចូលមកយ៉ាងរំភើយ។ ល្អើយត្រសៀកល្មមត្រជាក់ស្រួល, នៅខាងកន្លែងគេហដ្ឋាននោះ មានកូនចង្រៃមួយប្រមាណ ១ បង់ក្បូរខ្នែងជញ្ជាំងក្តារល្មមតែងពន្លឺ ឲ្យមើលមកឃើញបុរសជាម្ចាស់ មានកាយស្គាំងស្គមឥតសាច់ឈាម មានតែស្បែកដណ្តប់ឆ្អឹង ដេកស្តូកស្តឹងនាកណ្តាលល្វែងបន្ទប់, នៅក្បែរខាងបុរសជានេះ មានក្មេងកំឡោះម្នាក់ មុខមាត់ស្រស់ឆើតឆាយ អង្គុយចាំបំរើថែរក្សាជម្ងឺរបស់បុរសជា ដោយកិរិយាឫកពាស្រទន់ស្រពាប់ស្រទូតស្រដាំត់ ឥតមានរីករាយបន្តិចឡើយ, ដ្បិតចង់អត់ធន់ចំពោះជម្ងឺរបស់បុរសជា ដែលត្រូវជាឪពុកបង្កើតរបស់ខ្លួន អស់រយៈ ៣ យប់មកហើយ ។

ឯបុរសដែលមានជម្ងឺជាទម្ងន់ កំពុងដេកស្តូកស្តឹងនៅលើដំណេកនេះឈ្មោះ "ពិម, ត្រកូល សិរីពង្ស" កំពុងតែធ្ងាក់ខ្លួនទៅជាចំណីអាហារនៃរោគជា យូរៗ គាត់ដកដង្ហើមធំវែង។ លុះយូរគាត់ទំលើកភ្នែកគ្រលឹកមើលទៅតាមរបេញ្ចាំងល្វែងបន្ទប់ដេក ភ្នែកចាំងគូរបេះគាត់សំឡឹងទៅចំមុខក្មេងកំឡោះម្នាក់ ដែលអង្គុយនៅក្បែរខាងខ្លួនគាត់ ។ ឯក្មេងកំឡោះនេះឈ្មោះ ទៅចិត្រ, ជាកូនបណ្តុលចិត្តរបស់គាត់ ហើយជាប្អូនបង្កើតរបស់ត្រកូល "សិរីពង្ស" តាំងពីអនាគតផង ទើបគាត់ចំញញឹមចាំងត្រឹមត្រូវ ប្រឆងនិយាយដោយសូរសំឡេងញ័រ ។

ថា "ចិត្រ កូនមាសថ្លៃម៉ុងក! យប់យន់ណាស់ហើយ មិនចាន់ទៅដេកទេឬ? ទៅ, កូនទៅដេកទៅ" តាចឹមគឿនបង្គំឲ្យកូនទៅដេកវិត្រងអត់ដឹងខ្លួយទៅជាឈឺចាប់ ។

ទៅចិត្រត្រីកាលដោយអាការបដិសេធ ព្រមចាំងមានទឹកមុខប្រកបដោយចិត្តអាណិតអាសូរបិតា ទើបនិយាយដាបទៅវិញថា "ខ្ញុំចាខមិនចាន់ដឹងខ្លួយទេ, លោកម៉ុងក! ប្រសៃហលជាលោកម៉ុងកមិនចាន់ពីសាថ្នាំយោងកម្ចាំងទេដឹង? លោកគ្រូពេទ្យបានផ្តាំខ្ញុំចាខថា សូមឲ្យលោកម៉ុងកពីសាកុំខាន ។

"ថ្នាំឬ កូន! តាចឹមនិយាយឮតែកង់បំពង់ក ខំនង់ចំអកឲ្យថ្នាំនោះព្រោះដាថ្នាំគាត់ដឹងថា ឥតមានគុណវិសេសអ្វីបន្តិចឡើយ ហើយគាត់និយាយថា "ទ! កូនអើយ ថ្នាំនេះម៉ុងកបានផឹកមកច្រើនលើកហើយមិនឃើញមានគុណវិសេសអ្វី ដែលអាចជួយបន្ទរបន្ទយជម្ងឺឲ្យបានស្រាកស្រាន្តសោះឡើយ, ពេតចំពួកនេះម៉ុងកស្គាល់ច្បាស់ថាជាពេតប្រចាំកាយ "រក្សាក៏ស្លាប់ មិនរក្សាក៏ស្លាប់" ឬទ្ធីអំណាចរបស់ថ្នាំកុងខណៈនេះមិនវិសេសជាងទឹកទន្លេទេ, កូន! ។

ទៅចិត្រមិនចាន់បាននិយាយតបទៅម៉ុងកវិញ ស្រាប់តែសេចក្តីសេកណ្តាលអាយុម្ភាក់ដើរចូលមកកង់ជន្លប់, ហើយដាក់ត្ងូថគង់ក្តុយក្បែរ

ខាងអ្នកផង់ ហើយសួរថា "ម៉េចទៅតាថ្ងៃនេះ អាការៈពេតបានជួរ
ស្មើយ ឬទេ ?

"ខ្ញុំ! ភ្ញុង, ពុង! តាចឹមលាន់មាត់ឡើង កាលបានឮលោក
ត្រៃពេទ្យសួរខ្លួនជូនោះ ហើយគាត់និយាយតទៅទៀតថា "ខ្ញុំ! លោកគ្រូ
អើយ, វេលានេះ ក្អែកខ្ញុំបានវៃស្រែកាំងងងឹតអស់ហើយ សូមអត់
ទោសបុះ ខ្ញុំបាទមិនដឹងជាលោកគ្រូអង្គុយនៅត្រង់ណាទេ" ។ ឯចៅ
ចិត្រ កាលបើបានឮសំដីខ្មុកនិយាយគ្នាឮក្អែរជូនោះ ទឹកក្អែកក៏ហៀរ
ហូរស្រាក់ ដោយចិត្តអាណិតខ្មុកពន់ពេក ហើយក៏សំឡឹងមើល
គ្រូពេទ្យ និយាយអង្វរសុំឲ្យជួយស្រោចស្រង់សង្គ្រោះបិតាឲ្យមានជីវិត
តែគ្រូពេទ្យដែលស្គាត់ជំនាញក្នុងវិធីមើលជម្ងឺ ក៏គ្រវីក្បាលដោយអស់
សង្ឃឹម, ខ្សឹបប្រាប់ដំណឹងទៀតចៅចិត្រថា "ធ្ងន់មិនផុតអំពីយប់នេះទេ" ។

តាចឹមនិយាយមួយៗ ទាំងហត់ដង្ហក់ចប្រមាត់សស្ទាំង ញ័រចំប្រប់
ចំនិយាយទៀតថា "ខ្ញុំបាទគង់មិនមានជីវិតរស់នៅ ពាល់តែបានឃើញ
ឥម្ដូចរកចិត្តក្នុងត្រីកស្អែកនេះទៀតទេ" ខ្ញុំបានយល់ថា មិនមែនជាការ
ចំឡែកពុំសមគួរទេ ព្រោះមរណៈធម្មជាសភាវៈទៀងទាត់ ដែលមនុស្ស
សត្វដួតៅត្រូវតែទទួលយកនឹងចៀសវាងឲ្យផុតពុំបានឡើយ ; ឯវិញ្ញាណ
នឹងកាយខ្លួនខ្ញុំបាទ ឥតមានស្រណោះអាល័យប៉ុន្មានទេ ស្រាប់
ហើយត្រូវទៅតើតដាអ្វីក៏តាមយថាកម្មចុះ; ហើយបែរទៅនិយាយផ្តែផ្តាំ

ថា "ចិត្ត កូនសំឡាញ់មាសឥតុក! តាលបើឥតុកអស់បុណ្យទៅហើយ ជីវិតអ្នកមុខជា សាត់អណ្តែតអតបង្គើលជាបង្អែកដូចជាសំណាត់ដែលអណ្តែតកន្លងទន្លេដូច្នោះ" ។

ឯចៅចិត្តអួលដើមកទិយាយអ្វីមិនរួចសោះ មានតែចំកន្លែតហូរស្រក់ទឹកមុខជ្រប់ត្រាបចុះដីតដើងឥតុក ។ ចំណែកខាងត្រកូលទាំងអស់ក៏ភ្លាតមុខបែរទៅខាងបង្អួច ស្ទើរតែត្រាំទប់ទឹកភ្នែកពុំបានដែរ ។

តាចឹមនិយាយផ្តាំទាំងហត់ថា "នែចិត្ត កូនសំឡាញ់ឥតុក! តាលបើឥតុកស្លាប់ទៅហើយ ចូរចាំបណ្តាំឥតុកទុកចុះថា "ធម្មជាតត្រូវយ៉ាងក្នុងលោកនេះ ដែលមនុស្សលោកសំគាល់ថា ជាការរុងរឿងថ្ងៃថ្ងៃនោះ គឺការតាំងខ្លួនឲ្យបានស្តុកស្តម្ភដោយទ្រព្យសម្បត្តិ. ឯការដែលរស់នៅគោកយ៉ាកនោះ អ្នកផងទាំងពួងគេមិនយកក្តែកមើលទេ ការរស់ថែបនេះមិនមែនទាំឲ្យបានសុខសប្បាយទេ. ប៉ុន្តែពេលនេះកូនអើយ! ឥតុកនឹងប្រាប់អ្នកឲ្យធ្វើដូចម្តេច ទើបបានសេចក្តីចំរើននោះពុំបានទេ សុំឲ្យត្រាន់តែរលឹកដល់ពុទ្ធគាថាបទ១បទថា "អត្តា ហិ អត្តនោ នាថោ" "ខ្លួនត្រូវពឹងរបស់ខ្លួន' ប៉ុណ្ណោះឲ្យរឿយៗចុះ" ។ ឯត្រូវទិយាយដែកក្នុងខណៈនោះថា "តាកុំអាលអស់សង្ឃឹមហើសពេក ពេនរបស់តាដែលធ្ងន់ដូច្នេះ ក៏មិនទាន់ជាអ្វីទេ នៅមានសង្ឃឹមនឹងសះជាឡើងវិញបាន" ។

តាចឺមតបដើន្បីឲ្យគ្រូពេទ្យថា "សះជាឬ? លោកគ្រូ, គ្មានផ្លូវសះជាឡើងវិញជាក្រែងជ មានតែផ្លូវស្លាប់ ១ មុខ ក្នុងពីរស្អែកប្លុយប៉ន្មានេះ ប្តូនឲ្យវានេះ ក្នុងពេលណាមួយដាមិនខាន" ។ តាចឺមឈប់និយាយ ១ ស្របក់ ហើយចាប់និយាយតទៅទៀតថា "អែន! ចិត្តកូនសំណាញ់ឪពុក; ឪពុកនឹងស់ក្រណាស់ គ្មានកេរ្តិ៍មត៌កបន្តិចបន្តួចប៉ុណ្ណឹងទុកឲ្យកូនឡើយ, ដល់ឪពុកស្លាប់ទៅមានតែសតនិងពាក្យបណ្តាំប៉ុណ្ណោះទុកឲ្យកូន; ឯវិញ្ញាណក្ខន្ធរបស់ឪពុក ដែលនឹងបានទទួលសេចក្តីសុខក្សេមក្សាន្តក្នុងលោកខាងមុខនោះ លុះតែកូនប្រតិបត្តិតាមបណ្តាំរបស់ឪពុកចាំបាច់ប៉ុន្មានម៉ាត់នេះដែលជាបណ្តាំចុងក្រោយបំផុតរបស់ចិតា; មួយទៀត ទ្រព្យដែលឪពុកទុកជាក់ឲ្យកូនចំរើនសូត្រ ដកបចាស់តែត្រឡប់ជាប់សញ្ញាប័ត្រនោះទុកជាមត៌កមានដំរៃមួយ ឥ! តាំងពីថ្ងៃនេះទៅហើយ ឪពុកអស់បានជួយចំនុកបំរុងកូនតទៅទៀតហើយ" ។

ទៅចិត្រ តាលេបើបានស្តាប់ពាក្យបណ្តាំរបស់ឪពុកចប់សព្វគ្រប់ហើយ ក៏ស្រក់ទឹកភ្នែកគ្រាក ១ ដោយមានចិត្តអាល័យនឹងអាណិតឪពុកជាខ្លាំងផុត ឥតក្សាល់ទៀបដើរឪពុក ហើយចំនិយាយតាំងខ្ញុំត្រឡប់ដំកបឪពុកថា "លោកឪពុក! បណ្តាំគ្រប់ ៗ ម៉ាត់ខ្ញុំជាខន្ធឹងកត់ត្រាចាំទុកក្នុងចិត្ត ខិតខំប្រតិបត្តិតាមបណ្តាំគ្រប់ប្រការ, សូមលោកឪពុក

កុំបីព្រួយបារម្ភឡើយ, ខ្ញុំបានមានជីវិតរស់នៅជាមួយណា; ទឹងចំតាំងខ្លួន
ប្រាណដល់ដំណើរឆ្ងាត្រូលឲ្យបានចំរើនជាមួយនោះ" ។

តអំពីពេលនោះ គាប់មានអាការវង្វក់គាន់តែញឹកញាប់ខ្លាំងឡើង
មានអាការក្រវល់ក្រវាយខ្លាំងស្មុកស្មាម ហើយខ្ទង់ពាប់ទៅកាល់ៗ គ្រា
មរណៈស្រាមកំពុងខ្ញាន់ខ្ញាប់ចូលមកដិតអ្នកជម្ងឺគ្រប់ៗវេនឥឡូវ ទើបគាត់ទំ
ព្រឹងនិយាយទៅកូនប្រុសពេទ្យដែលមានមេត្តាចិត្តចំពោះខ្លួនដោយសូរសំ
ឡេងខ្សាវៗ ជាខ្លាំងសេចក្តីថា "ពានព្រោសលោកគ្រូ! ខ្ញុំបានធ្វើងាប់
ឲ្យលំស្បាប់ក្នុងពីរ - បីនាទីនេះហើយ សូមអរព្រះគុណធ្វើសូមជូនបុណ្យ
លោកគ្រូដែលមានព្រះគុណលើខ្លួនខ្ញុំបានជាអនេក ដោយបានចំណែកគាំ
រក្សាតាំងបង់ខាតថ្លៃថ្នាំជាច្រើនផង ហើយមិនមានគិតថ្លៃរក្សាទុំដំថ្លៃថ្នាំ
បន្តិចឡើយ, ខ្ញុំបានឥតមានអ្វីតបស្នងសងគុណលោកគ្រូទេ, ន! ព្រះគុណ
អើយ, គ្រូចៀកខ្ញុំបានលេងក្តាហើយ ន! ចិត្តកូន! ពុទ្ធោ អរហំ! ។

ចៅចិត្តនុបនុកជាប់ ហាក់ដូចជាមិនព្រមឲ្យវិញ្ញាណក្ខន្ធរបស់គា
ប់មរត់ចេញពីពាងកាយទៅបាន តែបើខុកជាចៅចិត្តចំប្រឹងនប់ខ្លាំងណា
ក៏គង់តែមិនសំរេចដូចបំណង ព្រោះ ជាតិ, ជរា, ព្យាធិ, មរណៈ,
(កើត, ចាស់, ឈឺ, ស្លាប់) ជាមគ្គរបស់សត្វលោក គឺមានសត្វណា
មួយ គេចវេះចៀសវាងឲ្យរួចផុតទៅបានឡើយ អម្បាលដូចយ៉ាងព្រះ
អរហំសម្មាសម្ពុទ្ធម៉ែចក៏គង់តែស្លេចចូលបរិនិព្វានមិនខាន ។

នៅចំពុតនេះ គាចឹមក៏ភ្ជាក់ខ្លួនទៅជាចំណីអាហារមួយកដ តិជាប់ឱ្យស់ផុតដង្ហើមក្នុងកណ្តាប់ដៃរបស់លៅចិត្រជាកូន គាចឹមក៏ខ្លួលមរណ-ភាព ក្នុង ឯៈដែលជួនបន្ទុមស្តគ្គតចាត់ពន្ធីស្មើ ត្រមជាមួយគ្នាក្នុងគ្រោះខោះឯង ។

ជីវិតរបស់ក្មេងកំព្រា

កាលបានចាត់ចែងធ្វើបុណ្យបូជាសពរួចស្រេចហើយ ទើបលៅចិត្រដឹកខ្លួនចាស់លាស់ថា "ខ្ញុំខ្លួនអញអើយ កណ្តែងតណ្តោចភ្ញោចផ្លូតែម្នាក់ឯង ហើយនឹងឆាកវេទៅពីឯបងប្អូនញាតិសាច់សាលោហិតដ៏តខាងឯណាក៏គ្មាន ណ្តើយចុះត្រូវតែតស៊ូនឹងសេចក្តីទុក្ខលំបាកត្រង់ឯងចុះ ត្រើមែចកើតមកជាប្រុសកំព្រាម្តាយអាពុក សមដូចជាប្រុសាសន៍លោកទុព្ភកថាំទុកថា "ចិត្រកូន ! កាលបើគស់បុណ្យអំពីដុតហើយ ជីវិតរបស់អកដូចសំណាត់ឈើដែលអណ្តែតតង់កណ្តាលទន្លេដូច្នោះ" ។

លៅចិត្រក៏គិតឃើញថា ពិតពលោកទាំងមូលនេះ ធំទូលាយស្រួលសប្បាយមែនសម្រាប់អ្នកដទៃ តែបែរជាឯងគ្មួចចន្លឿតលំបាកពន់ពេកចំពោះខ្លួនអាត្មាអញដែលកំព្រាម្តាយដុតពុត ទំងបងប្អូនញាតិសាលោហិតខ្លះឆាកមុខទៅផ្តែកកោនពីឯងាក់អ្នកឯណា ក៏គេឥតត្រូវការសោះ ព្រោះមនុស្សទៀតាល់ត្រលំបាកដូចជាអាត្មាអញនេះ គេមិនត្រូវការសេពគប់

ពប់រកឡើយ, ខុកជាសុំការគេធ្វើ ក៏ឥតមានឧរណា ជួយសង្គ្រោះរកការងារឲ្យធ្វើបានឡើយ ទេ ! ខ្លួនអាត្មាអញអើយ តើតមកកន្លែងនេះ លំបាកអ្វីក៏សែនលំបាកប្លែកជាងគេម្ល៉ះ ; តែថាតើតមកជាអង្គបុរសហើយ មិនត្រូវខ្លាចសេចក្តីទុក្ខព្រួយលំបាកទេ គោងតែតស៊ូនឹងសេចក្តីទុក្ខព្រួយលំបាកអស់នេះឲ្យឃើញសិនទៅចុះ ។

ចៅចិត្តកំពុងតែឈរជញ្ជឹងរំពឹងគិត រកការធ្វើតែម្នាក់ឯងយ៉ាងស្ងាត់ៗ នៅចំរៀងខាងមុខផ្លូវ ក៏ងើបមើលទៅលើឃើញព្រះចន្ទអណ្តែតត្រសែតនៅកណ្តាលពពក បញ្ចាំងពន្លឺរស្មីភ្លឺចែងចាំងសព្វទីបរិវេណ មានខ្យល់បក់ផាត់មកយ៉ាងត្រជាក់ស្រែង ឮសូរសំឡេងព្រះសង្ឃសូត្រធម៌នៅវត្តព្រះពិតិជាកមយ៉ាងច្បាស់លាស់ អណ្តែតលឿនលយមកតាមបណ្តោយខ្យល់ លុះចៅចិត្តបានឮសូរសព្វព្រះសង្ឃសូត្រធម៌នោះ ក៏ជាហេតុនាំដួចឲ្យទំនរលើកដល់ឥតុក ដែលខើចខឹលអន្ទិចកម្មទៅថ្មីៗមិនដឹងបើឥឡូវនេះ ចៅពន់ធកត់អ្នកឯណា ហើយក៏បែរមុខមើលទៅក្នុងបន្ទប់ ឃើញមានពន្លឺចង្កៀងភ្លឺផ្លេត ។ នៅទីនោះហើយដែលឥតុកឆ្លាប់មូរថ្នាំស្លឹកសង្កែពីសាជាមិញ តែឥឡូវនេះហានតែចៅចិត្តម្នាក់ឯង, ចៅចិត្តគិតអាណិតខ្លួនណាស់ ទឹកនេត្រាក៏ហូរចេញមកសស្រាក់ដោយឥតដឹងខ្លួន ។

ខណៈនោះ ចៅចិត្តក្រឡេកមើលទៅខាងមុខ ស្រាប់តែឃើញមនុស្សម្នាក់ស្លៀកសំពត់សរដើរចូលមក ទើបចៅចិត្តក្រោកឡើងស្រែកសួរទៅថា "នរណាន៎ុះ?

"គ្មានឯណាទេ ចៅចិត្តឬអីហ្នឹង? បុរសនោះសួរមកវិញ ។ ចៅចិត្តនឹកស្មានថាប្រហែលគ្រូពេទ្យ ទើបស្រែកអញ្ជើញថា "សូមអញ្ជើញលោកគ្រូ" ។

គ្រូពេទ្យក៏ឈានដើរឡើងផណ្តើរទៅលើផ្ទះ ហើយអាក់គូថអង្គុយលើកៅអី តាមសេចក្តីអញ្ជើញរបស់ម្ចាស់ផ្ទះ ។

"សុខសប្បាយជាទេឬចៅចិត្ត? គ្រូពេទ្យសួរដោយមេត្រីចិត្ត ។

ចៅចិត្តតបថា "ខាន ជ្រាស, ចំណែកខាងកាយសុខសប្បាយជាទេ ប៉ុន្តែចំណែកចិត្តវិតក្កជាបំផុត ឥតសប្បាយមួយពេលឡើយ តាំងអំពីលោកនាំពុកអនិច្ចកម្មទៅ; រីឯណាខ្ញុំបាទនេះហាក់ដូចជាធ្លាប់ឈឺនពុំដឹងអ្វីឡើយ! ។

គ្រូពេទ្យធ្វើកន្ត្រាក់ចំនួនជីពចរតាមសរសៃដៃចៅចិត្ត ទើបសួរដែលទៀតថា "ពុះសព្វថ្ងៃនេះ បានឆ្លើការខៅតន្លែងណាហើយឬនៅឡើយទេ?

ចៅចិត្តនិយាយស្ទើរៗសោះកក្រើកថា "ខាន ជ្រាស! នៅម៉ឺនេះខ្ញុំបាទកេការគ្មានបានធ្វើទេ, តារាងគ្រែបង្អែកហាក់ដូចជាខ្ពស់ជាង

ចំណេះរបស់ខ្ញុំបាទ ដែលបានរំលឹកសូត្រមកដូចជាច្រែនណាស់ តែ
ហាក់ដូចគ្រាន់ច្រើការបានត្រឹមតែមើលសំបុត្រស្នាមបន្តិចបន្តួច, មើល
ឈ្មោះហាងផ្សេង។ ទើបមើលប្រគ្រាមតាមភេនកុន-ល្ខោនប៉ុណ្ណោះ ។

គ្រូពេទ្យនិយាយដោយសេចក្តីអាណិតយ៉ាងស្មោះត្រង់ថា "ខ្ញុំក៏ទ័ក
អាសូរអ្នកច្រែនណាស់ដែរ! ចិត្ត" ហើយនិយាយបន្ថែមថា "ខ្លួនអ្នកជា
កូនប្រុសតែរកលន់ធំវិស័យលោកិយទៅមុខទៀតច្រែនណាស់ បង្អង់
ឲ្យខ្ញុំគិតពីរ-បីនាទីមើល ក្រែងខ្ញុំគិតរកឧបាយជួយសង្គ្រោះខ្លួនអ្នកឯង
បានខ្លះ" ។

ទៅចិត្តនៅតែស្ងៀម ។ គ្រូពេទ្យដញ្ជឹងគិតមួយស្របក់ក៏ញញឹម
លាន់មាត់ចេញសំដីថា "ទឹកឃើញហើយ។! ខ្ញុំមានមុតុកមាម្នាក់ ជា
អ្នកស្គុកស្គម្ភគ្រាន់បើ មើលទៅបើលោកជួយធុរៈ មុខជាអ្នកឯងបាន
ការធ្វើមិនខាន តែគោងនឿយហាត់បន្តិចមុនដំបូង ។

ទៅចិត្តញញឹមញញែមហើយដកបទៅគ្រូពេទ្យថា "ខ្ញុំបាទខ្លួល
អត់ធន់សេចក្តីលំបាកគ្រប់យ៉ាងតាំងអស់ សុំឲ្យមានតែការធ្វើទីឯគេចុះ
គ្រាន់ទីឯបានចិញ្ចឹមជីវិត កុំឲ្យមានពាក្យគេដំនៀលប៉ុណ្ណោះ ខុតជាដឹកដ
លើសែងវែកពុទ្ធយ៉ាងណាក៏ដោយ ខ្ញុំបាទក៏ស្ម័គ្រធ្វើតាំងអស់" ។

គ្រូពេទ្យមានទឹកមុខរីករាយ ដោយសេចក្តីពេញចិត្តហើយថា "ខ្ញុំ
គិតថានិយាយថា អ្នកឯងជាកូនប្រុសអាចខ្លួលធ្វើការគ្រប់ចំពូកបាន អធ្យា-

ស្រែយអ្នកឯងគួរសរសើណាស់, ប៉ុន្តែចៅចិត្ត! ការដែលអ្នកឯងត្រូវធ្វើ
នោះ, មិនមែននៅកន្លែងនេះទេ គឺនៅឯស្រុកបម៉ែលិនឯណោះ" ។

"បម៉ែលិនឬទាន ជ្រាស! ចៅចិត្តធ្វើយ៉ាងម្តេចទាក់ ជាតិកំសត់មុខ
ញញឹមរីករាយមួយរំពេច ហើយនិយាយតបញាត្តែរថា "ទានជ្រាស, គេ
ថាស្រុកនោះចាញ់ណាស់ មានតែពួកកូមាកូឡា ទើបនៅតំរាកស្តុកដ៏ច
នោះបាន; ខ្ញុំបានទឹកត្រែដ៏តែត្រាំខ្លួនកំដៅអាកាសនៅទីនោះមិនបានទេ
ពីណា! គ្រូពេទ្យខ្លួនាន់ថា "អ្នកឯងនិយាយដូចេះកំត្រូវដែរ ប៉ុន្តែអ្នកដែល
ទៅហើយឈឺចាញ់ទៅទីនោះ ច្រើនធ្វេសប្រហែសមិនចេះរក្សាខ្លួនឲ្យផុត
ពីជម្ងឺគ្រុនចាញ់; ចុះចំណែកអ្នកឯងក៏ចានរៀនសូត្រចេះក្បួនពេទ្យមកខ្លះ
ក៏ល្មមនឹងការពារខ្លួនបាន; មួយវិញទៀតជម្ងឺគ្រុនចាញ់នេះ មិនចំពោះ
តែជាតំយើងទេ ទុកជាជាតិណាក៏ដោយ ធ្វើទាស់ទំនងហើយ មុះជាឈឺ
ចាប់ដួចត្នាំងាប់អស់" គ្រូពេទ្យនិយាយខ្លួនានៅចិត្តឲ្យមានក្តីហាន
ខ្លាំងហើយពោលតទៅទៀតថា "ឯឪពុកមាខ្ញុំនោះ ពីដើមធ្វើជាមន្ត្រីមួយ
ហៅតាមបណ្តាសក្តិថា "ហ្លួងវេនសម្បត្តិ" រីណានេះអាយុលោក ៥០
ជាងបន្តិចហើយ លោកមានអង្គស្រែយល្អ; ពួកកូឡាកូមាទៅទីនោះ
ពប់អានលោកណាស់ តាលពី ២-៣ អាទិត្យមុននេះ លោកមានសំបុត្រ
១ ឆ្ងាយមកដល់ខ្ញុំ សុំឲ្យរើសរកមនុស្សម្នាក់ទៅធ្វើការលោក ចំពោះរូប

អ្នកឯងមួយនេះខ្ញុំពុកចិត្តណាស់; ដ្បិតការដែកគ្បួងនឹល គេត្រូវការតែមនុស្សសុចរិតស្មោះត្រង់" ។

លៅចិត្រនិយាយថា "ការនេះជាការល្មោងនឹថ្មី កូនជំរិតរបស់ខ្ញុំបាទ" ។ គ្រូពេទ្យ ថា "គ្រាន់បើជាងនេះទំនេរមិនគាន់មានការអ្វីធ្វើមែនទេ? បើត្រមែនខ្លួលខ្ញុំនឹងចាត់បញ្ជូនអ្នកឯងនៅវេលាថ្ងៃ ១ នេះ ដោយខ្ញុំមានសេចក្តីសង្ឃឹមពុកចិត្តថា អ្នកឯងនឹងធ្វើការម៉ឺងម៉ាត់ជាងពេញចិត្តគេមិនខាន" ។

លៅចិត្រលើកដៃសំពះ ហើយត្រាបចុះដោយសេចក្តីគោរពចំពោះគ្រូពេទ្យ លោកក៏សរសេរស្តីបុត្រ ១ ច្បាប់ឲ្យលៅចិត្រ ហើយលាចុះដើរលៅពីផ្ទះនោះលៅ ។

វគ្គទី ២

ការធ្វើជំណើរទៅបង្កែលិន

លុះលៅចិត្របានទទួលសំបុត្រគ្រូពេទ្យហើយ ក៏ចាត់ចែងសំពត់អាវដាក់ក្នុលិសផ្តៅនឹងអីវ៉ាន់សម្រាប់ធ្វើដំណើរទៅរួចស្រេចហើយ ក៏ប្រុះដេកសម្រាកដោយសេចក្តីត្រេកអរដ៏លើសលុប ក្នុងយប់នោះស្ទើរតែដេកមិនលក់ភ្លាល់ភ្លឺ ។ ដល់ម៉ោង ៥ ដឹកភ្លឺ នាឡិកាឯផ្សារលឺលាយឮសូម្បីង ។ យ៉ាងច្បាស់លាស់រហូតដល់ផ្ទះលៅចិត្រ ។ គ្រែកឡើងលុបលាងមុនមាត់រួច ។

(នៅមានត)

វគ្គទី ២

បិនធំជំងឺហួន

កាលអស់បុណ្យព្រះពាកជាធំពជ្រុំធ-ទី ហើយ កជវង្សចិន ក៏តាំងនៅតមកមិនបានយូរប៉ុន្មាន ដោយហេតុតើតចលាចលអាធ្លក្នុងស្រុកឡើង ហើយពួកហួនក៏រុកពាន់ខ្នាតចូលមកនៅទិសខាងជើងស្រុកចិន អាណាព្រះចិនក៏រំតើបរំជួល រហូតមកដល់មានមេទ័ពពួកម្នាក់ឈ្មោះ លៀវ-ប៉ុង ទើបអាចប្រមូលជាតិចិនឡើងវិញបាន ហើយបណ្តេញពួកមនុស្សព្រៃ គឺពួកហួនឲ្យចេញទៅបាន ។

មុនលៀវ-ប៉ុងឡើងសោយរាជសម្បត្តិនោះ ត្រូវច្បាំងតស៊ូនឹងមេទ័ពចិនម្នាក់ទៀតឈ្មោះហៀង-យូ ។ នោះជាមនុស្សមានលក្ខណៈកាចសាហាវណាស់ដូចសត្វសាហាវ ដូយគ្នានឹងលក្ខណៈរបស់លៀវ-ប៉ុងដែលជាមនុស្សមានរាមត្រាតុណាជាប្រក្រតី ។ សង្គ្រាមគ្រានោះ លៀវ-ប៉ុង, ខាន់កំឡាំងជាងហៀង-យូដរៃប៊ិន តែទៅចំបង់តែឡប់ទៅជាមានជ័យជំនះ ហើយហៀង-យូក៏ស្លាប់ទៅ កាលពីពុទ្ធសករាជ ៧៤២ ។ លុះលៀវ-ប៉ុងមានជ័យជំនះហៀង-យូហើយ ក៏ម្ចាស់ស្រុកឡើងទៅកាន់រាជធានី-ស៊ុ ដ្បិតមានពួកហួនរុកចូលមកតាមផ្លូវនោះ ចម្បាំង

គ្រានេះលៀវ-ប៊ុង ក៏មិនមានកំឡាំងល្មមទំនងនឹងច្បាំងតស៊ូនឹងពួកហួនបានទេ ស្ទើរតែនឹងអស់សង្ឃឹមទៅហើយ ស្រាប់តែកើតគំនិតលែងខ្លាចឡើង តើជ្រើសរើសបានស្ត្រីរូបស្រស់ម្នាក់ក្នុងពួកប្រពន្ធចុងរបស់ខ្លួន ធ្វើជាទុយ្យទៅមេទ័ពធំរបស់ពួកហួន ជាហេតុធ្វើឲ្យពួកហួនលើកលែងច្បាំង ហើយថយទ័ពត្រឡប់ទៅវិញ ក្នុងពុទ្ធសករាជ ៣៤៣ អ្នកមើលប្រវត្តិសាស្ត្រចិន គន់នឹងបានឃើញទៅមុខទៀតថា ការលើកស្ត្រីរូបល្អទៅបំប៉នឲ្យសឹកសត្រូវ តាំងឲ្យឈប់វាយកុកកូនត្រូវដែនដីនោះ ជាវិធីដែលចិនចូលចិត្តធ្វើណាស់ ហើយសម្រេចដូចបំណងមកគ្រប់គ្រានលើកគ្រប់គ្រា ។

តអំពីនោះមក លៀវ-ប៊ុងបានប្រកាសតាំងខ្លួនជាព្រះចៅវាជាធិបតីនៃប្រទេសចិន ចាត់ជាបឋមក្សត្រៀវរបស់ពួកហ៊ានខុកជាវាជវង្សទី១ ដែលបានគ្រប់គ្រងដែនដីចិន រហូតមកបានដល់ ៤ សតវត្សរ៍ គឺតាំងពីពុទ្ធសករាជ ៣៤៤ ដល់ពុទ្ធសករាជ ៧៦៣ ក្នុងរជ្ជសម័យនៃរាជវង្សហ៊ាននេះ ទីក្រុងរបស់ចិនជាន់ដើមតាំងនៅ ស៊ុ-ង៉ាន ក្នុងខែត្រសេន-ស៊ី ជាវេលា ២០៧ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៣៤២ ដល់ ៥៤៩ គឺពីនោះមកផ្លាស់មកតាំងនៅ ឯលោ-យ៉ាង ឬ ឡុក-អៀង ក្នុងខែត្រហ៊ូ-ណាន ។

ក្សត្រៀវរាជវង្ស លៀវ-ប៊ុង មួយអគ្គទ្រង់ព្រះនាមថា វូ-ទី ដែលទ្រង់បានត្រួតត្រាដែនប្រទេសចិនរហូតដល់ពុទ្ធសករាជ ៤៥៦ បានពង្រីកវាតអាណាខេត្តចុះទៅខាងត្បូង ហើយបានច្បាំងឈ្នះទ្រព្យសម្ភារនៅទិសខាងកើតទៀតផង ។

នៅកន្លែងវត្តព្រះពុទ្ធសាកាជ ៧១០ ឆ្នាំនោះ នោះខាងខ្មែរស៊ី-កៀង (ជាខ្មែរសំខាន់មួយរបស់ចិនតាតខាងត្បូង) ក្នុងខេត្តក្វាង-ទុងនោះ មានអាណាចក្រមួយមានអាណាខេត្តនៅខាងលិចនឹងស្រុកតុងកឹង ឈ្មោះថា អាណាចក្រណាន់យួយ ប្រជាជនជាជាតិយួន តែពាក់វង្សក្សត្រដែលគ្រប់គ្រងជាជាតិចិន ។ ក្នុងពុទ្ធសាកាជ ៨៣២ ចិនបានចូលមកយកអាណាចក្រនេះ ហើយយកបានស្រុកតាំង-តាំងដែលជាទីក្រុងរបស់អាណាចក្ររួមចូលទៅក្នុងមហាណាចក្រចិនទៀតផង ។ លុះកន្លង ៣ ឆ្នាំមក ចិនបានលើកទ័ពទៅវាយស្រុកសេចួនបានទៀត ដែនដីដែលយើងហៅថាប្រទេសចិននោះ រៀវលែងតែយួន-ណាន់មួយចេញ សឹងបានរួមចូលក្នុងគ្រប់គ្រងរបស់មហាណាចក្រចិនតាំងអស់ ។

ក្នុងសម័យដែលស្រុកតាំង-តាំង នឹងស្រុកសេចួនភ្ជាប់ទៅនៅក្នុងកណ្តាប់ដៃចិននោះ ជាសម័យប្រែប្រួលយ៉ាងសំខាន់មួយ នៃប្រវត្តិសាស្ត្រពុទ្ធចក្រប្រទេស ។ ចូរគិតសម្លឹងចុះថា កាលវង្សពុទ្ធសាកាជ ៧១០ ឆ្នាំនោះ អាណាចក្ររបស់ចិនមិនធំសំបើម ដល់ជាក្លាយទៅជាប្រទេសធំបំផុតក្នុងលោក ក្នុងកំណត់វេលា ១០០ ឆ្នាំប៉ុណ្ណោះទេ ។ ម្យួយវិញទៀត ព្រះបាទភូ-ឌិ ដែលធំអាចពង្រីកអាណាខេត្តរបស់ចិនរហូតទៅដល់តាក់កណ្តាលទ្វីបអាស៊ីគឺទ្រង់ស្តេចនោះ ជារឿងដែលគួរដើរគន្លងសារសើរសេចក្តីអង់អាចរបស់ចិនជាច្រើន ដូចមានរឿងសារសេចក្តីនៅ ។

រឿងអាមាត្យធាង-កៀន

ដែនដីដែលហៅថា ពាក់កណ្តាលខ្ទីបអាស៊ីនោះ នៅកន្លងអំណាច
ពួកហួន យើងបានឃើញតំខាងដើមមកហើយថា ពួកហួនបានរុកកន
ន្លែងដែនដីចិនជាច្រើនលើកច្រើនគ្រាមកហើយ ទុកជាចិនបានទំក
សាន់កំតែងយ៉ាងធំសំបើម ខ្លួចបង់ប្រាក់ទាសន៍ដ៏តែរបស់មនុស្សក្រប់
ប្រមាណមិនបានក៏ដោយ ក៏នៅតែមិនអាចការពារកំយអន្តរាយអំពីពួក
ហួននោះបានឡើយ ។ ព្រះចៅវ៉ូ-ឌី ជាព្រះចៅពូជាធំពាជមុន្តដំបូង
ដែលទ្រង់តាំងព្រះទ័យយ៉ាងមុតមាំ ដើម្បីនឹងធ្វើចម្បាំងតស៊ូនឹងពួកហួន
ឲ្យជាការដាច់ស្រេច មិនបាច់ការនឹងឲ្យពួកហួនលើកចូលមក ជិតកំតែង
ធំដូចមុនទៀតឡើយ ទើបព្រះចៅវ៉ូ-ឌីទ្រង់កំណត់គ្រាន់ការ នឹងលើក
ទ័ពទៅបង្ក្រាបនឹងពួកហួនឲ្យដល់ស្រុករបស់ពួកហួនតែម្តង តែពាស់ដោយ
ហេតុពួកចិនមិនសូវស្គាល់ច្រកផ្លូវនឹងភូមិប្រទេសច្បាស់លាស់ល្អ ទើប
ទ្រង់ជ្រើសរើសចាត់ឲ្យយួនអាមាត្យ ដែលមានសតិបញ្ញាឈ្លាសវៃយ៉ាង
ចំណាប់ម្នាក់ឈ្មោះធាង-កៀន ។ ឲ្យចេញដំណើរទៅកន្លងឆ្នាំពុទ្ធសករាជ
៤០៩ ដើម្បីពិនិត្យច្រកផ្លូវនឹងគ្រួតមើលភូមិប្រទេសឲ្យបានស្គាល់ជាក់
ច្បាស់ ។ ធាង-កៀនបានចេញដើរផ្លូវទៅចូលតែម្តង ម្តងល្ង,
បៃតាន, កំពង់រ ខ្លួនសុំដំនឹងតាំន កន្លងវេលាកំពុងធ្វើដំណើរទៅតាមផ្លូវ

នោះ ឆាង-កៀន ត្រូវពួកហួនចាប់យកទៅឃុំខុកជាវេលាជាង ១០ ឆ្នាំ ទើបបានលបលួចគេចចូលទៅកាន់ខែត្រ តង្ឃរក-សៀន ដែលជាដែនដីរបស់ពួកយួរអេដ៏ ឆាង-កៀនបានចូលជាមិត្តយ៉ាងល្អរបស់ពួកយួរអេដ៏ ហើយបានជួយពួកយួរអេដ៏ ច្បាំងនឹងពួកគ្រែកនៅជាតិត្រែនជង ហើយនៅទីបំផុត បានត្រឡប់ចូលមកស្រុកចិនទាង់ស្រុកទីបេត៍ ពាក់ព័ន្ធតាំងពីវេលាដែលឆាង-កៀនចេញពីស្រុកចិនទៅហើយ ត្រឡប់ចូលមកនេះជាវេលាជាង ១៤ ឆ្នាំ ហើយបានស្គាល់ស្ងាត់ខ្លួនច្បាស់ក្នុងមិប្រទេសតាមដំបន់អស់នោះ យ៉ាងជាក់ច្បាស់ សមដូចព្រះពាគបំណងរបស់ព្រះចៅវ៉ូ-ឌី ទើបត្រង់រៀបចំធ្វើចម្បាំងធំនឹងពួកហួនតែម្តង ។

រឿងដែលគោលមកនេះ សឲ្យឃើញនិស្ស័យដ៏ធំរបស់ឆាង យ៉ាងម៉ាំមួន មិនចេះសោយរបស់ព្រះចៅវ៉ូ-ឌី ព្រោះតាមធម្មតានោះ បម្រើដែលទៅធ្វើការចាត់ឥតដំណឹងអ្វីសោះ ជាវេលាជាង ១០ ឆ្នាំដូចជាឆាង-កៀននោះ ប្រសិនបើជាអ្នកដទៃវិញ គង់លែងតែនឹកនាឯងធ្វើចម្បាំងកំឆងដល់អ្វីតទៅទៀត តែព្រះចៅវ៉ូ-ឌី ត្រង់តាំងព្រះទ័យយ៉ាងមុតមាំ ទើបត្រង់ត្រូវធ្វើចម្បាំងបានល្អតែម្តង ។

ឯឆាង-កៀនសោតវិញ គួរតាំងជាអាទិភាគ្យជាន់ឯកសមជាទីពុកព្រះទ័យរបស់ព្រះមហាក្សត្រមែនបាន ព្រោះឆាង-កៀនបានត្រួតពិនិត្យក្នុងមិប្រទេសបានហ្មត់ចត់ល្អណាស់ ថែមទាំងបានលួចរៀនយុទ្ធវិធីនឹងរបៀប

ចាត់ទុក រវាងពួកហួនសម្រាប់យកមកបង្ក្រាបនៅឯចាម្ពាចិនផង ហេតុនេះ ក្នុងឆ្នាំពុទ្ធសករាជ ៤២៤ គឺទ័ពចិន ២ កងមានចំនួនមនុស្សចាំងសែនលើកចេញទៅពីស្រុកចិន ដោយមានមេទ័ពពូកែៗ ព័ទ្ធព័ន្ធឈ្មោះហ៊ូ-កៀវតិងនិងវ៉ែ-ពុងជាអ្នកនាំទ័ព បានឆ្លងវាយរុករុលមកដល់ខ្ទួនបំផ្លាញដីតែជាតិហួនជាច្រើនពាន់ៗ ហើយវាយយកបានដែនដីខ្ពស់ស្ងួត ។ ត្រង់នេះ តំបន់ដែលកងទ័ពនេះលុកចូលទៅតែងតែមានជ័យជំនះគ្រប់អន្លើ ក្រៅពីខ្ពស់ស្ងួត កងទ័ពរបស់ព្រះបាទភូ-ទី បានរុកឡើងទៅទិសខាងកើតឆ្ងៃងខាងដើម វាយបានដែនលៀវ-គុងនិងដែនគៅលីកាលពីពុទ្ធសករាជ ៤៣៤ ដោយហេតុនេះ ទើបឃើញថា ព្រះចៅ-វ៉ូទី កងពលវង្ស៍ហ៊ានេះ គួរបានទទួលកិត្តិយសថាជាអ្នកបណ្តាលឲ្យប្រទេសចិន មានអាណាខេត្តហ៊ាងដូលាយចេញទៅខ្វែតយ៉ាងសំបើម ។

លុះអស់បុណ្យព្រះបាទភូ-ទីហើយ សេចក្តីចំរើនរុងរឿងរបស់ចិនក៏ថយខ្សោយតទៅ ក្នុងឆ្នាំពុទ្ធសករាជ ៤៥៣ ស៊ី-កួង-លី ជាមេទ័ពពូកែបំផុតរបស់ចិនមួយ តែត្រឡប់ជាបរាជ័យដល់ពួកហួនទៅវិញ ហើយចិនក៏ឈប់ផ្សាយអំណាចតាំងអំពីនោះមក រហូតមកដល់សម័យព្រះបាទសុ៊ីអួនទីដែលត្រប់គ្រងប្រទេសចិនជាវេលា ៦៥ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៤៧១ ដល់ ៤៨៤ ចិនត្រឡប់ជាមានកម្លាំងខ្លាំងពូកែឡើងវិញ មានមេទ័ពពូកែឈ្មោះឆាវ-ហួយធ្វើការប្រឆាំងប្រយុទ្ធពួកហួនបានខ្លាំង ។

គ្រានេះ បណ្តាប្រទេសជាន់ខ្សោយក្នុងអាស៊ីកណ្តាល សំដៅទៅកាន់អំណាចរបស់ព្រះចៅកាជាធិបតីនៃប្រទេសចិន តាំងតាំពីបុរាណកាលរហូតមកដល់រាជវង្សតួកគីក-ម៉ែនមានអំណាច ។

ការរៀបចំមន្ទីរបង្ហាញសិល្បៈជាដើមនៅក្នុងប្រទេសយ៉ាំងល្អៗគ្រប់ពេក ខាងការតែងតាំងស្តេចនៅប្រទេសក៏មានរបៀបល្អដែរ មិនចាញ់ប្រទេសខាងហានឡេ ព្រោះការរៀបចំនេះ បានតាំងការអាណាចក្រ ធ្វើឲ្យទីក្រុងជាទីប្រជុំជាន់ការតែងតាំងនៃតែងស្តេចទៅក្នុងប្រទេស ព្រះបាទវ៉ូ-ទីមានស្រុកជាចំណុះព្រះអង្គដល់ ១០០ ស្រុក ពាក់តែចំពោះស្រុកធំៗ ។ ឯតំណែងតួនាទីការខ្លះ អំតាំដើមមកទៅក្នុងដៃរបស់ពួកតែកូលជាន់ខ្ពស់តាំងអស់ ពោលគឺមនុស្សដែលចូលមកធ្វើការជាន គោងតែជាមនុស្សកើតក្នុងត្រកូលខ្ពស់ ។ ព្រះបាទវ៉ូ-ទីជាមហាក្សត្រអង្គដំបូង ដែលទ្រង់ប្រកាសលើកលែងលក្ខខ័ណ្ឌនេះចេញ ហើយទ្រង់ជ្រើសរើសយកមនុស្សមកធ្វើការតាមរយៈការប្រជាជនត្រង់ជាន់ត្រង់ថ្នាក់ដែលមានចំណេះចេះដឹងល្អ ព្រះអង្គខំតែរកមហាក្សត្រជាលំដាប់ៗ មកកាន់ព្រះរាជវង្សរបស់ព្រះកង្គឈឺនទ្រង់ព្យាយាមបន្ថយអំណាចរបស់ពួកមហាក្សត្រ តែងតែស្រុកផ្សេង ។ មកទៀតផ្លាស់សម្តេចព្រះកាជាធិបតីមួយព្រះអង្គដោយដាច់ខាត ព្រះបាទស៊ីអួនទី ទ្រង់ឲ្យតាត់តពួកត្រកូលជាន់ខ្ពស់ជាច្រើនតាក់ដែលអួតខ្លួនថាខ្លាំងខ្លាំងនឹងព្រះរាជអាជ្ញា ។

រុឺង-ម៊ុងឡើងគ្រងរាជ្យ

រហូតមកដល់ពេលនេះ ជារហូតនាំឲ្យពួកគ្រូសាស្ត្រ ខ្ពស់ស្អប់ខ្ពើមការវិនិច្ឆ័យរបស់ពួកគេ ហេតុនេះក្នុងឆ្នាំពុទ្ធសករាជ ៩៩៤ សេនាបតីដែលមានចិត្តរំលោភម្នាក់ឈ្មោះរុឺង-ម៊ុង បានផ្តួលរំលំរាជវង្សគ្រប់គ្រងចេញពីរាជបល្ល័ង្ក ហើយតាំងខ្លួនឯងជាព្រះមហាក្សត្រ តែរុឺង-ម៊ុងធ្វើដូច្នេះបណ្តាលឲ្យកើតចលាចលក្នុងស្រុកឡើងយ៉ាងសំបើម ។ មានមនុស្សមួយពួកហៅថា "ពួកចិញ្ចឹមក្រហម" បង្កការចលាចលឡើងក្នុងស្រុកចាន-ឆុង (ឬសង់-ឆុង) ព្រះពុទ្ធសាសនាដែលគ្រឹះជាប់ជាមួយនឹងការគោរពកម្រាបក្រាបក្រាមឲ្យសូន្យរម្ងាប់បាន ហើយពួកពុទ្ធសាសនិកត្រូវបានមានទុក្ខវេទនាយ៉ាងខ្លាំង ។ មានព្រះអង្គម្ចាស់ក្នុងព្រះពុទ្ធវង្សមួយអង្គព្រះនាម "លៀវ-សៀវ" ជាប្រមុខ ហើយគាត់ក៏កើតចម្បាំងគ្នាឡើងយ៉ាងសាហាវជាមួយពួកក្សត្រពុទ្ធសាសនិក ។ មានជ័យជំនះជាបន្តបន្ទាប់រុឺង-ម៊ុងទៅឃុំពុកកន្លែងតុកទៅស្រុកស៊ី-ង៉ាន កាលពីពុទ្ធសករាជ ៩៦៦ ពុទ្ធវង្សដែលទើបនឹងសាបសូន្យទៅមួយគ្រា រវាងរយៈពេល ១៥ ឆ្នាំនោះក៏ត្រូវបានតាំងឡើងជាថ្មីវិញបាន ហើយព្រះអង្គម្ចាស់លៀវ-សៀវ ក៏ឡើងគ្រងរាជសម្បត្តិជាព្រះចៅពុទ្ធាធិបតីព្រះនាមព្រះបាទក្វាង-វូទី កាលពីពុទ្ធសករាជ ៩៦៧ ហើយទ្រង់គ្រប់គ្រងប្រទេសចិនរហូតដល់ពុទ្ធសករាជ ៩៧០ ។

ពួកហ្លួងបែកសាមគ្គី

ព្រះមហាក្សត្រកាដវេន្ទ្រហ៊ានត្បាល់តាំងខ្លួនវិញបានហើយ តែព្រះមហាក្សត្រអង្គថ្មីគាន់ជាប់ឆ្លើមរួមរួមរាណាបត្រជាថ្មីឡើងវិញមួយគ្រាខ្លះ ទើបព្រះចៅគ្វាង-វ៉ូ ទ្រង់ផ្ញាស់ទីក្រុងពីស្រុកស៊ី-ជាន ទៅតាំងនៅលោយ៉ាង ដែលជាទីតាំងនៅត្រង់ភាគកណ្តាល សម្រាប់ជាទីត្រួតត្រាស្រុកឯទៀតៗ បានដោយងាយ ហើយជាទីការរាវក្រង់បានចំណាប់តាមទ្វារយុទ្ធសាស្ត្រជង តំណាងមេតទ្រង់ក៏ចាត់ការនើរពួកចិរញ្ញាមក្រុងឲ្យស្ងប់ទៅជាមុន ទើបចេញទៅជ្រាបជ្រាមស្រុកឯទៀតៗ តទៅទៅទីបំផុតរហូតដល់ស្រុកសេ-ជួនបានទៀត គាលពីពុទ្ធសករាជ ៥៧៨ ស្រុកចិនតាំងមូលក៏ស្ងប់រាបទាបអស់រលៅ ។ ទើបព្រះចៅគ្វាង-វ៉ូទីបែរទៅជ្រាបជ្រាមអាណាខេត្តដ៏តភាគវែលខ្លាប់ជាស្រុកចិណុះចិន មកអំពីដើម តែមកកើតរឹងទទឹងមិនព្រមចំណុះក្រុងខណៈវែលបានសចិនកំពុងមានការចលាចល ។

(ទើមាន)

រឿងព្រះចាន្ទអសោក

(ត)

គ្រានោះ មានគហបតីម្នាក់ព្រមទាំងភរិយា ទៅសែ្វងរកវត្ថុដ៏មានដំ-
ឡៃដើម្បីចិញ្ចឹមជីវិតនៅទីសមុទ្រ ខណៈកំពុងតែធ្វើដំណើរទៅ ក៏ភរិយាមានគតិ
ហើយបានប្រសូតកូនប្រុសមួយនៅទីសមុទ្រនោះ ទើបឲ្យឈ្មោះបុត្រ
នោះថា "សមុទ្រកុមារ" ។ គ្រាកាលកន្លងមក ១២ ឆ្នាំ គហបតីនោះ ក៏នាំ
ភរិយាចេញពីសមុទ្រ ត្រឡប់មកស្រុកកំណើតវិញ តែត្រូវពួកចោរ
សមុទ្រចាំង ៥០០ ចូនដណ្តើមយកទ្រព្យសម្បត្តិហើយវាយសម្លាប់គហបតី
នោះទៅ ។ គ្រានោះសមុទ្រកុមារនៅតែម្នាក់ឯងអនាថា ទើបចូល
ទៅបួសក្នុងព្រះពុទ្ធសាសនា ។ លោកគ្រាប់សែ្វងរកអាហារបិណ្ឌបាត
ត្រប់ស្រុកតូចស្រុកធំនិតមជនបទរៀងៗ ទៅហួតដល់មកក្រុងបាដលិ-
បុត្រ លុះឃ្លុំចីវរដោបរមណ្ឌលតាមសមណកេរហើយ ក៏ចូលទៅកន្ល
ក្រុង ដើម្បីបិណ្ឌបាត លោកនិមន្តរៀងៗ ទៅស្រាប់តែចូលទៅក្នុងគុក
ជាទីសុខសម្រាន្តនោះដោយមិនដឹងខ្លួនថាជាមន្ទីរអ្វី លុះឃើញដូច្នោះ
ហើយទើបពោលពាក្យនេះថា "ឥដ្ឋ! មន្ទីរនេះ ពីខាងក្រៅមុខគួរជាទី
ពេញចិត្តពេក តែខាងក្នុងហាក់ដូចជាស្ថានទេវតាសុទ្ធសោតសោះ" ។ លុះ
ភិក្ខុនោះនឹងត្រឡប់មកវិញ នាយចណ្ឌគិរិកៈយាត់មិនឲ្យចេញ ក្រាប់តិក្ខុ
នោះថា "ឥឡូវនេះ លោកត្រូវនៅក្នុងទីនេះ គឺត្រូវពិឃាតជីវិតបង់ លោក

មិនត្រូវគេបណ្តេញចេញទៅណាទេ" ពាក្យពោលនៃប៉ុណ្ណោះ ក៏កិកុនោះនៃស្រែក
ខ្លោចហើយសោយសោកយ៉ាងខ្លាំងទៅទៀត ដោយការឥតស្រាកឥតឈប់ ចំណែកតិរិតវិញក៏ដួលបោះ
ទើបសួរថា "ព្រោះហេតុអ្វីបានជាលោកស្រែកយំយែបដូចជាពាក្យដូច្នេះ" ។

កិកុនោះតបថា "អាត្មាមិនមែនយំសោកព្រោះទ្វាចសេចក្តីស្លាប់
ដូច្នេះទេ តែយំដោយស្តាយ ដោយការនឹងសាបរង់នូវសមណធម៌ដែល
អាត្មាត្រូវបាន ព្រោះថាអាត្មាទើបនឹងបួសហើយថ្មីៗ មិនទាន់បានសម្រេច
មគ្គផលអ្វីនៅឡើយសោះ ។ ការបានអត្តភាពមកជាមនុស្សជាការបាន
ដោយកម្រ ធម៌របស់ព្រះពុទ្ធជាសាសនាក៏បានជួបប្រសព្វ ព្រោះអាត្មា
ទំនងជាល់រឿងនោះហើយបានជាអាត្មាយំស្តាយ" ។ បណ្ឌិតិរិតក៏ប្រាប់ថា
"តាំងពីយូរមកហើយ ព្រះពុទ្ធជាម្ចាស់ដ៏វិសេសបានព្រះទាន្តទានឲ្យខ្ញុំថា
បើមានមនុស្សក្មេងមកមិនត្រូវឲ្យចេញទៅវិញទេ ត្រូវឲ្យបែបការដ៏វិសេស
ក្នុងកំពែងនេះឯង" ។

កិកុនោះនិយាយអង្វរថា: "អាត្មាភាពសូមឲ្យអ្នកអាណិតខ្មុកដ៏វិសេស
អាត្មាបាន ៧ ថ្ងៃសិន ទាល់ក្រោយពី ៧ ថ្ងៃនោះទៅបើអ្នកចង់សម្លាប់
អាត្មាភាពក៏សម្លាប់ចុះ" ។ បណ្ឌិតិរិត: ក៏ព្រមអនុញ្ញាតឲ្យតាមសេចក្តី
អង្វរ ។

គ្រានោះ ព្រះបាទអសោកបានទតឃើញនាងស្នំកំពុងបរចាស់ដោយ
កាមកតជាមួយនឹងព្រះអគ្គម្ចាស់តំណែងមួយព្រះអង្គ ដែលជាសហាយ

លុះទ្រង់ទស្សនាការដូច្នោះហើយ ក៏ទ្រង់ព្រះតម្រេកទើបត្រាស់បង្គាប់ឲ្យ
នាំតាំងពីនោក់នោះចូលទៅក្នុងគុកជាទីសុខសម្រាន្ត តែមួយវេរាពេចនោះ
ក៏ចណ្តែតរីកៈបុកច្រំតំទេចគួរនាក់តាំង ២ នាក់នោះ សំពង់ក្បាលនឹង
អវែនដែក លៀនក្អែកក្រែកឡាតក្រលួងៈចញមកខាងក្រៅ ។ ដោយ
ការយើញកម្មត្តស្លែងយ៉ាងនេះ តំកុនោះទើបថ្លែងទៅថា "អា! ព្រះ
វាចារបស់ព្រះបរមគ្រូជាម្ចាស់ ព្រះអង្គពេញទៅដោយសេចក្តីករុណា
ទ្រង់ត្រាស់ដោយបញ្ញាពិចារណាយើញពិតថា: រូបកាយមិនមែនជារបស់
រឹងប៉ឹងមាំមួនទេ មានសភាពដូចជាពពុះទឹក ។ រូបកាយនេះបែកធ្លាយទៅ
ដោយឆាប់រហ័ស ឥតមានបន្ទរបន្តួយសោះឡើយ ឥឡូវនេះរូបឆោម
ដ៏ល្អនោះទៅណាទៅហើយ ? ទឹកមុខស្រស់ប្រឹមប្រិយ ទន់ឆវីវណ្ណតាំង
អស់នោះ ក៏វិនាសសូន្យទៅអស់ហើយ ។ "ឧអនិច្ចា! ក្នុងរូបនិមិត្ត
នេះឯងហើយ ដែលជាទីពេញចិត្តនៃពួកជនល្ងង់អបាឥតច្បាស់ ដែល
មានតំនិតយល់ឃ្លាតខុសគ្នានឹងធម៌របស់ព្រះសម្មាសម្ពុទ្ធ អាត្មាអញបាន
ឃើញច្បាស់មែនពិតតាមធម៌របស់ព្រះអង្គនោះហើយ ទៅក្នុងថ្ងៃនៃនាយ
ពេជ្ឈឃាតនេះ អាត្មាអញនឹងមិនលះចលនចុះទៅកន្លងទុយៈតាមគុណ
ទៀតឡើយ" ។

កន្លងមួយភ្លែតំាងមួលនោះ តំកុនោះពិចារណាឃើញត្រង់តាមបរម-
ពុទ្ធោវាទដូចខាងលើនេះ លោកបានទំលាយបង់នូវចំណង (សំយោជនៈ)

ពាំងអស់ ហើយបានសម្រេចសោតាបត្តិផល ហេតុដូច្នោះ លោកទំ
ព្យាយាមជាលំដាប់នៃមគ្គតៈ៧ ទើបបានសម្រេចដល់អរហត្តផល ។

លុះអវសានរៀងឆ្នើង ដល់ពេលគ្រប់ ៧ ថ្ងៃកន្លងទៅហើយ បណ្ឌ-
តិកៈទើបទូលសួរភិក្ខុនោះថា "កន្លង ៧ ក្រឹត្យទៅហើយ ថ្ងៃនេះជា
ថ្ងៃទី ៨ លោកធំឆ្លងខ្លួលកម្មវៀរនោះហើយ" ។

ភិក្ខុនោះតបថា "ក្រឹត្យរបស់អាត្មាកន្លងទៅផុតហើយ ដួងព្រះ
អាទិត្យរបស់អាត្មានេះឆ្នើងហើយ ពេលជាបង្គំលមកដល់ហើយ អ្នកធំ
សក្តប់អាត្មាក៏ធ្វើតាមច្បាប់ចុះ" ។

បណ្ឌិតិកៈ យើញហេតុថ្លែងអំពីថ្ងៃមុនដូច្នោះ ទើបសួរថា: "សំដី
លោកនិយាយថា ក្រឹត្យរបស់អាត្មាកន្លងផុតទៅហើយ ដួងព្រះអាទិត្យ
របស់អាត្មានេះឆ្នើងហើយ ពេលជាមង្គលមកដល់ហើយ ចូរលោក
អធិប្បាយភាក្យពាំងអស់នេះឲ្យសព្វគ្រប់មកមើល" ។

ភិក្ខុនោះតបថា: "អាត្មាភាពស្ថិតនៅក្នុងក្រឹត្យ គឺអរិយាដែលប្រព័ន្ធដ
មិនឲ្យមើលពន្លឺអ្វីឃើញសោះ អកុសលពាំងឡាយទាំងពួងឲ្យភ្លាត់ភ្លេច
ដែលជាចំណងដ៏មាំគឺសំយោជនក្លិសនេះ ក៏អាត្មាភាពបានដំណាយ
បង់ដែរស្រឡះហើយ មិនបានត្រឡប់មកកាន់អាត្មាវិញទេ ពាំងអស់ខ្ញុំបាន
សេចក្តីថា: ក្រឹត្យរបស់អាត្មាកន្លងផុតទៅហើយ ចិត្តរបស់អាត្មាជួរផង

ហើយដោយប្រាជ្ញា បានមើលឃើញច្បាស់នូវលោភជាន់ជាប់ ជាន់អស់នុះ បានសេចក្តីថា: ដួងព្រះអាទិត្យរបស់អាត្មានរឹងហើយ ។ កិច្ចដែលព្រះសម្ចាស់មុខធ្វើហើយ ជាកិច្ចដែលអាត្មាបានបំពេញសព្វគ្រប់ហើយដែរ ជាន់អស់នុះបានសេចក្តីថា: ពេលជាមគ្គលមកដល់ហើយ ។ កន្លែងកាយនេះក៏រស់នៅមកយូរអង្វែងណាស់ដែរហើយ បើអ្នកសម្រាប់អាត្មាក៏តាមតែចិត្តអ្នកចុះ" ។

បណ្ឌិតរិក: ជាអ្នកប្រាសចាកសេចក្តីកំណាញ់ មានចិត្តរីរួសជ្រួចជ្រួ សិលាបណ្តាលពោល: កន្លែងអាត្មានរឹងតែភ្ញាក់ឡើង ឥតមានគោតក្រែងដល់កម្មទៅអនាគត ក៏លើកខ្លះធំដាក់លើជើងគ្រានក្តៅ កន្លែងធ្លាក់នោះមានទឹកដ៏ពេញលាយទៅដោយខ្វាញ់លោហិត,ខ្លួកន្លែងធ្លុង លាមក(អាចម៍)ទឹកមូត្រនឹងកំរេចកំញាមជាន់ច្បាយ ក៏ចាប់កិក្ខុនោះឥតមានមេត្តាចោះទៅក្នុងខ្លះធំនោះ ស្រែកប្រាប់មនុស្ស អ្នកជុតក្តៅនឹងឲ្យប្រើនឹងឱ្យាតយ៉ាងសម្បើមពីខាងក្រោម ធ្វើយ៉ាងនោះហើយ។ សន្ធឹងសម្រាមកំនេះ សន្ធោរសន្ធៅខ្លាំង តែមិនមានចំហាយក្តៅដល់កិក្ខុនោះសោះ សូម្បីតែបន្តិចបន្តួចក៏គ្មានផង នាយពេជ្ឈឃាតឃើញដូច្នោះក៏ខឹងយោះយៅនឹងអ្នកជុតក្តៅនស្ទុះទៅកាយមួយដំបងហើយជុតក្តៅដោយដៃខ្លួនឯង ក្តៅនក៏ឆេះសន្ធោរខ្លាំងជៃក្រៃលែងជាងមុន តែមិនមានកំដៅសោះ នាយពេជ្ឈឃាតតែតែងខឹងខ្លាំង ក៏ចាប់ភេចគ្រឿងទ័ព្ទសម្ភារមន្ទីរនោះយកមកជុតលាយនឹងសំពត់

ជាច្រើនផ្នត់ ក្លៀងក៏នែនៗលើសលុបខ្លះធំនោះ ប៉ុន្តែទឹកនៅតែត្រជាក់ដដែលដូចមុន កំនាយពេជ្ឈឃាតទឹកស្ងួចទឹងហេតុអស្ចារ្យចំឡែកនោះ ក្រឡែកមើលទៅក្នុងខ្លះ ឃើញតិក្ខនោះអង្គុយសមាធិលើផ្កាឈូកធំមានត្រចកមួយតាន់ស្រាប់ ខណៈនោះនាយចណ្ឌគិរីកៈ មានសេចក្តីស្រប់ស្ងៀងចិត្តតាន់ពេក កំរត់ទៅក្រាបទូលដល់ព្រះកដាឲ្យទ្រង់យាងមកឧត្តហេតុអស្ចារ្យនោះផង ។

ព្រះកដាស្តេចយាងមកត្រមដោយចរិតាដាច្រើនតាន់ទ្រង់ខំលាយកំពែងតុកដាទិសុខសម្រាន្តនោះ ដើម្បីពួកអ្នកនគរាំងអស់ពាប់ដោយកោដំ ទាំគ្នាចូលទៅមើលតិក្ខនោះបាននដោយដាយ ។ ពេលនោះតិក្ខនោះបានក្រាបថា: ឥឡូវនេះដល់វេលាដែលលោកគួរទ្រង់ទ្រង់ព្រះមហាកឋ្ឋត្រិយ៍ ឲ្យទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាហើយ ទើបលោកសំដែងឥទ្ធិបាដិហារ្យផ្សេងៗ ច្រើនមែន-ឃាំង មានចំរើនដ៏ចំរុះស្មុគស្មាញចេញចាកខ្លះដែលគេញ្ញេវៀរដាយអាចាជាតុនាកណ្តាលប្រជុំជនដ៏ច្រើនឲ្យបាននឃើញគ្រប់ៗគ្នា លោកហោះទៅកាន់អាកាសវេហាស៍ ហើយសំដែងឥទ្ធិបាដិហារ្យគ្រប់យ៉ាងធ្វើឲ្យមានចំណែកតាក់តណ្តាលដងខ្លួនចេស់លោក ខាងលើបន្តើតឡើងជាទឹក ហូរចេញមកឥតស្រាក ចំណែកតាក់តណ្តាលដងខ្លួនចេស់លោកខាងក្រោម បន្តើតឡើងជាក្លៀងនេះក្លី

ច្រាលរន្ធូលពណ្ណាយ ហាក់ដូចជាភ្នំមួយដ៏ធំ មានរស្មីភ្លឺលត្ឋាតរុងរឿងទៅទាកណ្ដាលអាកាសនោះ ។

កាលខ្ញុំឧត្តរយើញកិកុនោះហោះទៅកន្លងវេហាសប្រទេសជាហេតុចំឡែកអស្ចារ្យគួរស្ញែងដូច្នោះ ព្រះពជាក៏ខ្ញុំឧត្តរឆ្ពោះទៅខាងលើ លើកព្រះហស្តឡើងប្រណម្យដោយគ្រពុំនៃអញ្ជលីជាទីគោរព ហើយខ្ញុំមានព្រះបន្ទូលថា:

"កិកុនេះ ដូចគ្នាទំនងយើងសព្វគ្រប់អន្ទេ មានរូបកាយជាមនុស្សសាមញ្ញ តែឫទ្ធានុភាពនឹងសេចក្តីចរិសុទ្ធរបស់លោកចំឡែកអស្ចារ្យលើសលុបជាងមនុស្សធម្មតា លោកហោះឡើងទៅលើអាកាសរហោស ហើយសំដែងឲ្យយើញឫទ្ធិដ៏សម្បើមអស្ចារ្យហួសវិស័យនៃសត្វលោក ។ ឥឡូវនេះខ្ញុំមិនទាន់ស្គាល់លោកម្ចាស់ទេ ប៉ុន្តែខ្ញុំសូមជ្រកកោនទៅក្នុងឧត្តមដ៏វិសេសរបស់លោក ធ្វើដូចម្តេចហ្ន៎? ទ័ងថាខ្ញុំឆ្លងធម៌ ដែលលោកម្ចាស់សំដែងដល់ខ្ញុំនោះ បើបានដឹងហើយ ខ្ញុំនឹងបានប្រតិបត្តិតាមដោយកំណាំនឹងថ្ងាស់ថ្ងាររបស់ខ្ញុំ[1]" ។

ខណៈនោះ កិកុបានដឹងច្បាស់ថា ព្រះបាទអសោកជាមហាទានបតី ១ ដែលនឹងអាចបានចែកចាយព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធដើម្បីជាប្រយោជន៍ដល់ទេពតានឹងមនុស្សតាំងឡាយ ព្រោះដូច្នោះ

---

១ មហាវង្ស: ព្រះបាទអសោក ទ្រង់ធ្វើឆ្លាជាងបួង នឹងនិរព្រៃធសាមណេរ ។

តំកុនោះទើបថ្វាយសែដ្ឋនា ដល់ព្រះបាទអសោកថា: "ព្រះសម្មាសម្ពុទ្ធ
ព្រះអង្គបានត្រាស់ថា: តថាគតមានគុណា ដ៏ធំជាអ្នកតាត់បង់នូវចំណង
គឺសំយោជន:បាន ។ អ្នកដែលប្រតិបត្តិតាមធម៌ដ៏សមគួរដល់ធម៌ ឈ្មោះ
ថាជាតុសៃនៃព្រះពុទ្ធក្នុងលៃតែកត អ្នកនោះទើបានសម្រេចនូវអមតមហា-
និព្វាន ។ ព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រះអង្គឈ្នះដោយខ្លួនឯងហើយ
ញ៉ាំងអ្នកដទៃឲ្យឈ្នះផង ព្រះអង្គបានដល់ទីក្សេមហើយ ញ៉ាំងអ្នកដទៃ
ឲ្យដល់ទីក្សេមផង ព្រះអង្គបានដល់នូវទីរំលត់ទុក្ខហើយញ៉ាំងអ្នកដទៃ
ឲ្យបានដល់ទីរំលត់ទុក្ខផង ។ បពិត្រមហាក្សត្រ សូមទ្រង់ជ្រាបថា: ព្រះ
សម្មាសម្ពុទ្ធបានព្យាករទុកហើយដោយច្បាស់លាស់ទៅក្នុងអនាគតថា
ខាងក្រោយអំពីបរិនិព្វានរបស់តថាគតទៅមួយរយឆ្នាំ ទ្រង់ធំធ្វើបាន
សោយរាជក្នុងក្រុងបាដលិបុត្រ មានព្រះនាមថាអសោក ទ្រង់ធ្វើជា
ស្តេចបរិត្តិជាធម្មិករាជ ត្រួតត្រងខ្ពើបមួយកន្លះខ្ពើបទាំងបួន ទើជាស្តេច
ប្រកបដោយសច្ចធម៌ បានចែកចាយព្រះសារីរិកធាតុត្រមង់ធំបានសាង
ព្រះស្តូប ៨៤,០០០ សុទ្ធសឹងដ៏ខ្ពង់ខ្ពស់ មហាបពិត្រ ឥឡូវនេះត្រូវប់
ជាមានដល់ផ្តុំយគ្នាទៅវិញ ព្រះអង្គបានសាងគុណធំនេះ ដែលជួចជា
ស្ថានតេសុទ្ធសោត ទ្រង់បានបំភ្លាញដីវិតកប់ចំនួនដោយពាន់មនុស្ស ។

បពិត្រមហាកប ឥឡូវនេះ សូមទ្រង់ព្រះកជ្ជទានអភ័យឲ្យដល់សត្វលោកទាំងអស់ សូមទ្រង់ប្រព្រឹត្តបំពេញសេចក្តីប្ដាប្ដូរបស់ព្រះសម្មាសម្ពុទ្ធ សូមទ្រង់ព្រះកជ្ជទានអភ័យ ដល់មនុស្សទន់ខ្សោយទាំងឡាយ សូមព្រះអង្គធ្វើមេត្តាករុណាចិត្តឲ្យកើតឡើងហើយសូមចែកចាយព្រះសារីរិកធាតុទាំងជួយផ្សាយធម៌ពិតធម៌មែនឲ្យចំរើនរុងរឿងធំទូលាយឡើង" ។

ព្រះកប៉ាទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ មានព្រះហឫទ័យយោនចុះកាន់ធម៌របស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គប្រកបដោយប្រសាទសទ្ធាដ៏ថ្លា ទ្រង់ប្រណម្យអញ្ជលីឡើងគោរពចំពោះព្រះទុរាសរបស់ព្រះទសពល ទើបទ្រង់មានព្រះបន្ទូលថា :

"អំពើរបស់ខ្ញុំពីមុនមក ជាកម្មដ៏អាក្រក់បំផុត សូមឲ្យលោកម្ចាស់ទទួលអត់ទោសនៃចុបកម្មរបស់ខ្ញុំនោះពេលនេះ ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក ខ្ញុំសូមដល់នូវព្រះធម៌ជាជយមង្គល ដែលព្រះតថាគតត្រាស់សំដែងហើយជាទីពឹងទីរលឹកហើយ[1] ចាប់ដើមតាំងតែពីត្រឹមថ្ងៃនេះទៅ ខ្ញុំនឹងផ្តើមបំពេញតែការគុសល ខ្ញុំនឹងសាងព្រះស្តូបឲ្យបានដេរដាសនៅលើផ្ទៃនៃប្រថពីនេះដើម្បីជាបូជនីយស្ថាន ជាទីរលឹកដល់ព្រះអង្គ" ។

---

១ ជាតំណស្ទួរសារណាមួយ មិនបើញក្នុងច្បាប់ដើម ។

គ្រានោះ កងកុនោះបានឃើញព្រះពាសេ្តចមានសព្វាបរិបូណ៌ហើយ ក៏ចេញបាតមទ្វីរនៃនាយពេជ្ឈឃាតទៅតាមផ្លូវអាកាស ព្រះមហាកស្សបក៏ស្តេចចេញមកព្រមផង នៃចណ្ឌគិរីក: ទូលឃាត់ព្រះអង្គថា: "តាលពីមុន ព្រះអង្គបានព្រះពាសាតវដល់ខ្ញុំព្រះអង្គថា បើអ្នកណាមួយចូលមកកងគុកជាទីសុខសប្រាន្តនេះហើយ នឹងចេញទៅវិញពុំបានជាជាប់ទាត" ។

ព្រះពាសាគ្រាស់តបថា: "ឯងជ្រាបថានឹងសម្លាប់យើងឬទេ?"

នាយពេជ្ឈឃាតទូលតបថា "ព្រះករុណាវិសេសទូលព្រះបង្គំជាខ្ញុំជ្រាបនឹងសម្លាប់ព្រះអង្គផង" ។

ព្រះមហាកស្សបគ្រាស់សួរថា "យើងទាំងពីរនាក់នេះ អ្នកណាចូលមកកងទីនេះមុនគេ" ។

នាយពេជ្ឈឃាតក្រាបទូលថា "គឺខ្ញុំព្រះអង្គហ្នឹងឯងដែលជាអ្នកចូលមកមុនគេ" ។

ព្រះពាសាគ្រាស់ថា "អើមើឯងចូលមកមុន គ្រូវតែអញសម្លាប់ឯងមុន" ។

ខណៈនោះ ព្រះមហាកស្សបទើបគ្រាស់ឲ្យហៅពាសបរិពារមកឲ្យចាប់ចណ្ឌគិរីក: នាំយកទៅកាន់ទិពិយាត បណ្ឌគិរីក: គ្រានោយពេជ្ឈឃាត

ឯទៀតវាយផ្តាញ់ផ្តាលជាដំណាំ ហើយទើបគរទេសបង្កាត់ភ្លើងដុតចណ្តតិរកៈពាំងវាស់ឲ្យឆេះជាធូលីក្នុងទីនោះទៅ ។ ព្រះពាជាទ្រង់ត្រាស់ឲ្យទំលាយគុកជាទីសុះសម្រាន្តនោះហើយ ចាប់ដើមតាំងតែពីតឹមនោះមក ទ្រង់ប្រទានអភ័យដល់សត្វលោកពាំងអស់ ។

គ្រានោះ ព្រះចុតអសោកព្រមដោយចតុរង្គិនីសេនា ស្តេចយាងចូលទៅកន្លែងភជគ្គំ ព្រះអង្គឲ្យតាត់ឲ្យបើក ព្រះស្តូបដែលព្រះចុតអជាតសត្តុកជាន់ទុកនោះ ទ្រង់ឲ្យគាស់កកាយយកព្រះសារីរិកធាតុពាំងអស់នោះ ហើយព្រះអង្គឲ្យចែកចាយផ្សាយទៅស្ថានទីផ្សេងៗតពីនោះមក ទ្រង់ឲ្យសាងព្រះស្តូបមួយធំនៅត្រង់កន្លែងដែលនោះ ។ ចំណែកទីឯទៀតដែលមានបញ្ចុះព្រះសារីរិកធាតុទ្រង់ក៏ឲ្យគាស់កកាយយកជាលំដាប់មក នៅកន្លែងទី ២ ទី ៣ ។ល។ ទី ៧ ព្រះអង្គយកព្រះសារីរិតធាតុពីទីនោះ។ ពាំងអស់ដូចគ្នា តមកស្តេចយាងចូលទៅកន្លែងស្រុកកាមត្រាមដែលជាទីសំណាក់អាស្រ័យនៃស្តេចនាគឈ្មោះសាគរៈ ដោយមានព្រះបំណងនឹងយកព្រះសារីរិកធាតុក្នុងទីនោះទៀត ។

គ្រានោះ ស្តេចនាគបានសំដែងកាយឲ្យឃើញច្បាស់ជាខ្លាំងហើយទូលអញ្ជើញព្រះមហាក្សត្រាធិរាជ ឲ្យស្តេចយាងចូលទៅកន្លែងពិតពនាគហេតុដូច្នោះ ព្រះពាជាស្តេចយាងចុះគាន់ព្រះទីនាំងនាវ រួចយកចូលទៅកន្លែងប៉ុរីនៃស្តេចនាគ ។

ស្តេចនាគបានក្រាបទូលព្រះបរមគ្រូតែយ៍ថា: "សូមព្រះពុទ្ធគេជះ ខ្ញុំព្រះអង្គមានក្តីជ្រះថ្លាខ្លាំងក្រៃពុកនៅព្រះសារីរិកធាតុនេះ សូមទ្រង់ព្រះមេត្តាប្រោសព្រះពុទ្ធគុណឲ្យខ្ញុំព្រះអង្គ ទីឯកបានធ្វើសក្ការបូជាព្រះសារីរិកធាតុនេះផង សូមព្រះអង្គស្តេចអនុគ្រោះកុំប៉ះយកបេះខ្ញុំព្រះអង្គទៅ" ។

ព្រះពុទ្ធជាម្ចាស់ឯតយើញស្តេចនាគធ្វើសក្ការៈគោរពកប់គាន់បូជាដោយក្តីងឿងឆ្ងល់ចំពោះព្រះសារីរិកធាតុពីរដងមួយថ្ងៃ ឃើញថាជាការវិសេសថ្ងៃថ្លាជាងពួកមនុស្សទៅទៀត ទើបទ្រង់ឲ្យទុកព្រះសារីរិកធាតុក្នុងព្រះស្តូបនោះមិនបានយក ហើយស្តេចយាងត្រឡប់មកព្រះនគរព្រះអង្គវិញ ។

លុះដល់មកព្រះបរមកជកាំងហើយ ទ្រង់បានឲ្យជាងសាងប្រអប់ដប្រសើរ ៨៤.០០០ ប្រដាប់ដោយមាសថ្លាក់ទីងតែវិពិត្តក្នុងប្រអប់មួយៗនោះ ទ្រង់ឲ្យបញ្ចុះព្រះបរមសារីរិកធាតុមួយគ្រាប់ៗ មិនតែប៉ុណ្ណោះសោតទ្រង់ឲ្យសាងក្អម ៨៤.០០០ ទីងគ្រប ៨៤.០០០ ដែលជារបស់មានដំឡៃ ហើយទីងសំពត់កម្ពល ៨៤.០០០ សំឯងមានពណ៌ផ្សេងៗ ផ្សេងៗគ្នា ដើម្បីទីងរុំវត្ថុដ៏មានដំឡៃខ្លាំងនោះ ។

ព្រះអង្គទ្រង់ព្រះពុទ្ធគុណព្រះបរមសារីរិកធាតុឲ្យដល់ពួកយក្ស ក្នុងម្នាក់ៗ មួយគ្រាប់ទ្រង់គ្រាស់បង្គាប់ឲ្យដើរទៅសព្វមណ្ឌលនៃជម្ពូទ្វីប ឲ្យ

យកទៅសាងព្រះស្តូបនៅកន្លែងគ្រប់ៗ ប្រទេស ដែលមានមនុស្សចំនួនមួយកោដិ តាលចាត់ចែងដូចសំដែងមកនេះ យក្សទន្ធនេពតាចាំងឡាយក៏បានទាំយកព្រះបរមសារីរិកធាតុចាំងអស់នោះដង្ហែទៅកន្លែងទិសចាំងបួនដើម្បីនឹងសាងព្រះស្តូបចាំងនោះ ។

គ្រានោះ មានយក្សម្នាក់បានទទួលព្រះសារីរិកធាតុមួយគ្រាប់ហើយ នាំទៅតាន់នគរតក្កសិលា ចំណែងនឹងសាងព្រះស្តូបមួយទៅទីក្រុងនោះ តែពួកអ្នកប្រទេសនោះបានទិយាយថា "មនុស្សទៅក្នុងប្រទេសយើងមានចំនួន ៣៦ កោដិ បើដូច្នេះត្រូវអ្នកឲ្យប្រអប់ ៣៦ មកយើង" ។

គ្រានោះយក្សទន្ធនេពតាក៏ត្រឡប់មកគ្រាបទូលសេចក្តីនោះដល់ព្រះមហាក្សត្រិយ៍វិញ ព្រះអង្គមានព្រះដម្រិះថា: "មនុស្សចាំងឡាយមានចំនួនច្រើនណាស់ ប្រសិនបើធ្វើតែយ៉ាងនេះព្រះបរមសារីរិកធាតុនឹងមិនបានជ្រាយទូទៅសព្វជម្ពូទ្វីបចាំងមូលទេ បើដូច្នេះ ត្រូវរកឧបាយនឹងបញ្ឈប់ការចែកចាយត្រឹមនេះ" ។ ទើបនោះ ព្រះពាជាទ្រង់ត្រាស់ឲ្យយក្សត្រឡប់ទៅប្រាប់ដល់មនុស្សចាំងនោះថា "ក្នុងប្រទេសនេះត្រូវបន្ទុយមនុស្ស ៣៥ កោដិចេញឲ្យទៅតែត្រឹមមួយកោដិ ដែលនឹងត្រូវបានព្រះបរមសារីរិកធាតុមួយគ្រាប់ប៉ុណ្ណោះ" ។

(នៅមានត)

ប្រដៅចិត្ត

អ្នកនន្ទកញ្ញាចេស្តាវៃជ្ជយ (កែវ-ហង្ស)

(ត្រមក)

អាខ្ញុចយើញមាសច្រាក់អស្រ្តាច តាំងពីដំរួចលួចគ្នានសល់ អ្នកស្ងួនៅល្ងើឆ្កួស្រងឹល់ ខ្ញុចអស់កំណាល់ខ្លួនមានគ្រោះ ។ នេះហើយចៅអើយដឿឲ្យល់មាត់ ច្រាកដដឿជាក់អស់ពីពោះ ផុងជ្រុលគំនិតឥតពិរគ្រោះ អាចោកក្បែកស្រែងយកច្រាក់ចាន ។ ចៅអើយនេះអ្នកខ្លាំងពូកែផែមើលយើញគ្មានសល់ខាន យើញតែម្នាក់គេដ្បឿស្ងាប់ច្រាណ ខាន់អន្ទះជានមករលំខ្លួន ។ ហេតុនេះគួរចៅគិតឲ្យឆ្ងាយ ចុងយពាលាច្រែនចៃបច្ចួន ចេះតាមសម័យតេញសំនួន កែខ្លួនឆ្លើកល់ឆ្លល់ពេញស្រុក ។ ជួនកាឆ្លើឫកចៃបច្រាជ្រុំយ អធិប្បាយធម៌អាចរំពៅញបន្ទុក គ្រាក្រោយឲ្យឯងបពមុខ ចាប់ខ្នុងឯងលក់ខ្ញុចអសារ ។ អាណិតអ្នកនោតកោតអ្នកពាល មានច្រែនតាសកំលជ្រួលខ្យៀវភ្ញារ ចៅកែមក្រែសួងតុលាការ ឆ្លើកោសយ៉ាងណាក៏មិនអស់ ។ លោកចាប់ផ្ទុះនេះកាកែនោះ ពាក្យខន់ពីពោះសំដីស្រែស់ អ្នកស្ងួនបងំគ្រែញខ្ញុចបេស់ អាពាលយកអស់ខ្លួនខ្ញុំគេ ។ ចគួរតាណិតចៅល្ងង់ពេក ធាប់ត្រែកធាប់ផ្ដើគ្រុំម្ល៉ះទេ ពាល់ជាក់បម្រែការច្រាក់គេ ខ្លួនឯងលេនជរតែសព្វថ្ងៃ ។ ព្រោះដឿអាពាលបេះពាក់ច្រាក់ ខ្លីនេមកជាក់ឥតសំចៃ មិនដឹងពុតពាលខ្ញុចពេកក្រៃ យកតែចួល

ត្រៃពៅកន្តើយ ។ ខម្ញុំបង្ហាប់ផ្សឹងាំងអស់នេះ អាចុកវាចេះគ្មានសល់ ឡើយ វាធ្លើបែបនេះច្រែនដងហើយ ចៅអើយចៅឆោតអួតអម្បាយ ។ មានពាលចាស់ខ្លះឈ្លាសចង់ស្រែ ខោះមានស្ងួមប្តូមេម៉ាយ ចេះលេចេះ លួងប្រែលែបខាយ តំបូកលន់ទាយអាយដោយវាវៅ ។ ដូចយ៉ាងវាធ្លើ ជាចំណាន គ្រូធម៌កម្មដ្ឋានចេះគ្រប់ផ្លូវ ស្រាៗពួរហើយនាំគ្នាវៅ សុំរៀន ដម្រែតាមច្បាប់ ។ អាខូចបានដៃនាំភេស្វាត់ រកវិប្រតិបត្តិបកធម៌អាថ ធ្លាយក្អែកត្រៃចៀកមនុស្សធម្មតា បកផ្លូវយ៉ាងណាក៏បណ្តោយ ។ មិន ត្រមតាមគ្រូឯណាបាន ផ្លូវធម៌កម្មដ្ឋានលោកគ្រូទៀ ទឹងគេចនឹងកែប្តូរបែរ ក្រោយ ផ្តុលភ្នែយវៅហើយច្រើនសំនំ ។ ចៅប្តីដឹងជាក់ពួរគេថា តក៏ ជាដែកស្ទើរវាយដំ សរសើរអាខូចថាចេះធំ មិនដឹងមនោរម្យផ្លូវខាងក្នុង ។ ខុកចិត្តតរិយារៀនកម្មដ្ឋាន រៀនបានបកញ្ញាក៏ដឿស្ងួត ត្រលឹមត្រលប់ ស៊ូផ្តត់ផ្តង់ ដាក់ថ្នាក់តាមអង្គកងបន្ទប់ ។ អួតច្បាប់គេឯងឥតប្រពន្ធ ទំរៀនពេកពន់ពាំងថ្លៃយប់ ខ្ចោចម៉ែខ្ចោចឪក៏ឃើញសព្វ គ្រូច្បាប់ថា បបំធាប់ជាងគេ ។ នុះនុអាណិតតែចៅប្តី ម្តេចដឿតែស្រីអ្នម្ល៉ះទេ មិន ដឹងប្រពន្ធដាច់តាមេ ត្រៃត្រែកដូនគ្រូតាលណា ។ នេះហៅច្បាក់ បង់ថង់ក៏ដាច ពាលច្បាដូគាចប្រុងប៉ងច្បាថ្នា បែរខ្នងបែរមុខតាមត្រូវ ការ វាធ្លើយ៉ាងណាឥតសង្ស័យ ។ មុខគួរសរសើរពាលចេះដល់ សាង ផលអតីតឬសម័យ ដឹកជាប់តាមមកជាបច្ច័យ ឥតមានខ្វៃយអ្វីច្បាក់

ចាយសល់ ។ ចាន់តែទេសតែគន់តែត្រៃ អ្នកស្រែចំការក៏ជួយផ្តល់ ម្ហូបសាមសិបរៀលមកតាមផល ចេះដល់មិនខ្វះទ្រព្យធនធាន ។ ប៉ើនឆ្នាំសាធផលឬអំពៃ លក់យកកំរៃធ្វើជាមាន គ្មានព្រួយលំបាកឬអត់ឃ្លាន គោតផលគេចាន់តែមានខ្លះ ។ ក្មេងស្លាប់ចាស់ច្រើបាប់តាមតិច្ចកល់ ធ្វើយថ្លៃសួរចាស់យ៉ាងរហ័ស លោកតានេះចេះដំណាប់ណាស់ ជម្ងឺចាស់ទឹងថ្លើចេះគ្មានខាល់ ។ ទុំយកពាលាច្រែនច្រកវា គេថាប៉ុនចោកអស់គ្មានសល់ មិនដែលជួបម្តងច្រើនតែឆ្ងល់ តាឆ្លាប់ធ្វើតស់ចោកឬទេ ។ ចាស់ឮក្មេងថាចំលើខ្លួន តែកូនច្រកែកថាទេ។ តាមិនដែលចោកបេស់គេ គ្រាន់តែច្រាប់ចៅឲ្យចាន់ដាំង ។ គេខួចច្រដូចមកលើតា តាលណាគេឮគេនឹងខឹង ប៉ើចៅដឹងហើយច្រាផ្ញយ៉ាងហ្នឹង ចៅស្រីមឲ្យឈឺងកុំបរចោ ។ ក្មេងសួរម្តងទៀតតាកំណាត់ ច្រាកដមិនមែនកូកឯណា ចោកគេនោះពិតជាខ្លួនតា សូមតែកុណាច្រាប់ឲ្យត្រង់ ។ ចាស់ចាល់គំនិតគិតតែតួ ក្មេងដដីកសួរគ្មានចោះបង់ ឯងចាន់អធិប្បាយវិលដូចកង់ ច្រាប់ត្រង់ថាពិតជាខ្លួនតា ។ ចៅអើយគិតចុះជាតិយើងខ្មែរ គួរតែនឹកដល់ព្រះសាស្តា កាលគង់ព្រះដន្ធរនៅឡើយណា គ្មានបានបរិក្ខារដូចខ្លះហ្នឹង ។ ចាន់ផាស់រស៊ើតើបង្ហុកូស យកស្នូបខ្មោចចោះបមកចំប្រ៉ង ចោកលាងឈាមខ្លះជាប់គាំងរឹង បណ្តាយចន្ទឹងល្មមដេរជាន ។ ធ្វើជាចីវរត្រង់ច្រប់កន្ត្រ អនុញ្ញាតឲ្យសង្ឃច្រើច្រាស់ចាន សាវកធំៗត្រូកម្មដាន សិស្ស

មិនដែលបានថ្វាយដៃគ្រែទេ ។ ព្រះសង្ឃសព្វថ្ងៃនៅក្នុងវត្ត ខ្លះអត់ស្ទើរតែខ្លួនទេ ចីវរហែកស្បង់គ្មានទេ ព្រោះតែមិនចេះធម៌កម្មដ្ឋាន ។ បើចេះមិនខ្វះរថស៊ីអ្វី បានដៃគ្រែថ្មីយ៉ាងតុំផាន ច្រាក់កាសគោដនពាំងប៉ុន្មានមិនបាច់ចង់បានក៏បានដែរ ។ ព្រះសង្ឃសម្មតិទេព្រះផ្នួស បួសតាមពុទ្ធដីកាសាសនាខ្មែរ ជាទក្ខិណេយ្យឬជាស្រែ បុណ្យខ្មែរផ្តើមានយកកុសល ។ មិនឃើញទាសកថ្វាយដៃគ្រែ គួរឲ្យសង្ស័យរំលឹតទ្រូល លោកជាស្រែបុណ្យបង្កើតផល ប្រឹងខ្វល់ឲ្យដៃគ្រែទៅគ្រហស្ថ ។ មិនដែលក្សាពាំងសីល៥ ឬរៀនឲ្យចាំនោះគ្មានសោះ មានលោកសង្ឃខ្លះច្រឡោះចោះយកវត្តចំពោះដោយប្រពៃ ។ អ្នកបួសមិនខ្វាចខ្លួចសំក្តា វាខ្លាមិនគិតខុសវិន័យ កេរជាបព្វជិតទ្រង់សីលសេយ្យ ហេតុអ្វីសំពះឯគ្រហស្ថ ។ មានខ្លះដែលផ្តាសាខ្មាស្រី រួចមានសព្វថ្ងៃនៅស្រុកកោះ ទន្ទេសឆ៍ខាងនៅចន្លោះ ហៅកោះស្តេចទ្រង់ក្នុងក្រចេះ ។ គ្មានគិតគ្មានយល់តិចឡើយនៃ ប្រព្រឹត្តប្រស៊ែយយ៉ាងដូច្នេះ ពាក្យកុតមិនពិតធាប់ដៀម្ល៉ះ ស្តុងចិត្តថែបនេះគ្មានយល់អ្វី ។ ដើរថាមាតាអ្នកបុណ្យធំ បង្គំជ្រួលជ្រើមជាប្រក្រតី ឆោតអ្វីឆោតម្ល៉ះពាំងប្រុសស្រី អ្នកមានបុណ្យអ្វីកើតច្នេះណា ។ តាលអង្គសម្តេចព្រះសម្ពុទ្ធ ចម្មកុដដៃគ្រែលោកជាសាស្តា រើសគោត្រគែកូលខ្ពស់អស្ចារ្យ ក្សត្រាភិរាតស្តុបរ៉ី ។ ជាន់ទ្រង់ចុះចាប់យកតំណើត គ្រកូលខ្ពស់ឆើតដោយប្រពៃ មិនមែនថោកថាប

ដូចឮល្បី សរសើរទោសថាមានបុណ្យ ។ តាំងពីតាតូចតាឮល្បី ប្រុស
ស្រីនិយាយច្រែនរោកវាន់ ខ្យល់បក់ខ្យែរច្រាប់គ្នាយើងចាំគន់ មើលអ្នកមាន
បុណ្យបានកើតហើយ ។ យើងប្រឹងគំនិតនឹងស្មារតី ពាំងប្រុសពាំងស្រី
កុំឆ្ងូសខ្លែយ យើងបានថាន់អ្នកមានបុណ្យហើយ មិនខេះខ្លែយម្តាយ
នៅច្រងោ ។ មានពាំង១ថាសកន៏ឯលោកសង្ឃ ចិត្តកួចថ្ងាញ់ត្រង់សំពះ
គោ នៅទេត្តតាកែវស្រែកក្បាលពោរ ថាជាព្រះគោមេគោញី ។ ខ្លះ
ទៅសំពះសត្វ១ឆ្កែ ពាស់ន៏ឯអន្ទង់សត្វពាំងពីរ សុំទឹកខ្យែរលែ្ងតាមសញ្ញា
ខ្លះបែរវាខ្លែឯមនុស្សឆ្កួត ។ ថាអ្នកមានបុណ្យភ្ញាំងពួកែ ជិតធ្វាយឲ្យតែ
ឮគេអួត ទាំងាស្រែងក្តិនតាមអំនួត មនុស្សឆ្កួតថាជាអ្នកមានបុណ្យ ។
តាំងពីអង្កែងយូរធ្លាំហើយ ចៅអើយសត្វថ្លៃមិនតិតគន់ ជាមែនមិនមែន
អ្នកមានបុណ្យ តយគន់មិនគ្រួចដឿពេតវៃក ។ ក្មេងស្តាប់ពាក្យចាស់
ចេះច្រាវច្រាយ លែបតាយច្រាប់ត្រង់សព្វសេចក្តី សួរថាលោកតាចុះ
សត្វថ្លៃ ហេតុអ្វីកំធ្លើបែបយ៉ាងញឹង ។ ពាក្យតាចរោពាំងប៉ុន្មាន ខ្ញុំប៉ាន
ស្តាប់ចប់ខ្ញុំចង់ដឹង ចំណែកតាងឹតា។ កុំឲ្យ ចង់ដឹងឲ្យច្បាស់ពីលោក
តា ។ លោកតាចេះធម៌ច្រែនចំឡែក ក្នុងបែកខាងធម៌ព្រះសម្មា- សម្ពុទ្ធ
ជាម្ចាស់សាស្តាចារ្យ ម្តេចហើយលោកតាមិនច្បព្រឹត្ត ។ ចៅអើយតា
ច្រាប់ចៅឲ្យត្រង់ បើដួងឯីបត្រូវចូនអ្វីខ្លួ តោងច្រើ១ថ្ងៃយតាមគំនិត
អ្នកដឿជាក់ពិតបានណាតា ។ ពាន់តេកំពុងនៅវេធឿងឆ្ងល់ ច្របល់ពាស់

ខែឆ្នាល់រំលោ ធម៌ចាស់ធម៌ថ្មីប្រឈ្មោះគ្នា មុខជាស្មុគ្នចិត្តខ្វះមិនខាន ។ ចាន់ជាតាតិតគំនិតថ្មី គ្មានអ្វីលើសពីធម៌កម្ពុជាន ប្រុសស្រីចាស់ក្មេង តាំងពុំខ្លាន ពួកធម៌កម្ពុជានចូលចិត្តណាស់ ។ ខំរាំគេដឹងគន់យូរឆ្ងាយ សប្បាយសិស្សច្រៀងតាំងក្មេងចាស់ លោគាចាន់ត្រមាំងច្រាក់គាស ខ្លួនចាស់មិនចាន់ខ្លួយកំឡាំង ។ ដល់ចាស់មែនខែនឹមយើងគិតគំនិតធ្វើតាមព្រះអរហំ ឲ្យត្រូវតាមធម៌ជាខ្លាំង សង្វេគខ្លុំតាមយថា ។ ក្មេងធ្វើយទៅចាស់ថាសូមទោស ពីពេះពេកណាស់ពាក្យលោកគា អធិប្បាយវែងឆ្ងាយជាអស្ចារ្យ កិច្ចតស់យ៉ាងណាចេះគ្មានសល់ ។ តាចេះចំណេះនេះយ៉ាងថ្លៃ សព្វថ្ងៃគ្មានអ្នកណាចេះដល់ ច្រាជ្ញពិតច្រាជ្ញមែនច្រាជ្ញកិច្ចតស់ បិទឲ្យគេធ្លល់ធាប់ជឿចាន ។ ខ្ញុំខ្ញាចច្រាជ្ញតាហៅចេះដល់ គ្មានសល់ចន្ទោះតាមលំអាន ថ្ងៃកណាស់ត្រង់ផ្លូវធម៌កម្ពុជាន បញ្ចូលចិត្តចាន់តាំងប្រុសស្រី ។ តាថាគ្មានឃើញម៉ែឧទេ ចុះគេរំរៀនច្រយោជន៍អ្វី តាច្រាប់ឲ្យអស់ផ្លូវសេចក្តី ពួលប្បីពេកណាស់ច្រាកដជាក់ ។ តាធ្វើយសារសព្វថាចៅតា ហៅថាកម្ពុជានេះណាអ្នក បើចាន់រៀនហើយគ្រូឲ្យលាក់ គ្មានជាក់ពិតខ្លាចៅតា ។ ច្រាជ្ញគ្រូច្រាប់សិស្សថាឯងចាន់ កម្ពុជានច្រាសហើយកុំចរចា ឲ្យអ្នកផងដឹងនឹងបែកការ តាលណានិយាយខ្សឹបឲ្យដឹត ។ ចៅតាពាក្យខ្សឹបពួតាំយណាស់ ពាក្យចាស់បុកណាពីអតីត ក្អែកមួយក្តាយដល់ដប់ពិត គំនិតច្រាជ្ញតាលង្វាត

ពេកវែក ។ ពោលពីមហាជនផងនានា ពាល់គ្នាចៅតាតែសព្វថ្ងៃ ខ្លះនៅ
ធោតលូងំពាំងប្រុសស្រី គ្មានគិតសេចក្តីចង់ឲ្យបេះ ។ អស់លោក
អ្នកប្រាជ្ញលោកប្រឹងរំ សន្សំរៀបរៀងអស់ចំណេះ ស្រាយពីចាលីឲ្យ
បានបេះ ខ្លះពោលថាអេះធម៌បែបថ្មី ។ ខ្លះមិនព្រមមើលធម៌ស្រៀវតៅ
ស្រែចនោស្ងឹតតែយើងប្រកែក ខ្លះថាចង់ដឹងពាំងប្រុសស្រី តាមដោយ
សេចក្តីប្រែច្នាត់ចត់ ។ អ្នកខ្លះពោលថាធម៌បុកណា គម្ពីរក៏មានពិតប្រាកដ
ពោលនេះគឺត្រូវតាមសន្ធតិ ប្រាកដថែបណាក៏មិនដឹង ។ ខ្លះមិនដែល
ម៉ើលឲ្យចង់ចាំ គ្រាន់តែចំណាំថាធូរតឹង ខ្លះពុតគ្នាថាដូចច្បង់ ប្រឹងរំ
សំគាល់ថាបុកណា ។ អ្នកប្រាជ្ញលោកវែកប្រែចាលី ឲ្យដឹងសេចក្តីយល់
ដើមដាន ខ្មែរយើងសព្វថ្ងៃស្តាប់មិនបាន ចាលីប៉ុន្មានគ្រាន់តែចាំ ។
ដូចជាអដ្ឋៈសូត្រតត់មាត់ កេះផ្តាំកំណត់ជាចំណាំ មិនដឹងថាម្តេចរវេចវៃ
ផ្តាំ យូរនែ៎យូរទៅដឹងនោះគ្មាន ។ បដិសង្ខាយោនិសោចីវ៉ា សូត្រ
ជាប្រកែកតែមតិលាន មិនយល់ថាម្តេចស្មានបំភាន ចំរើនឲ្យបានឥតពុក
ផ្តាយ ។ ខ្លះថាឲ្យបានទៅអ្នកស្រុក គេឲ្យចុយតែកញ្ចាតជិតឆ្ងាយ
ខ្លះថាបដិសង្ខោរៈថ្លៃចុយ តាមពាក្យបរិយាយប្រាប់សេចក្តី ។ ក្មេង
ស្តាប់ភ្លុះហ៊ាយសួរទៅថា លោកតាឯងនេះតួកធម៌ថ្មី ចានជាសរសើរ
ប្រែចាឡី ខ្ញុំនៅសង្ស័យជាបំផុត ។ (នៅមានត)

រឿងចៅឆុន-ចៅសាញ់

បទកាកគតិ

បពិត្រអញ្ញ៉ុំ ហត្ថាបង្គំ ប្រណម្យវន្ទា សូមមានតេជៈ ដូចព្រះកាមា
សូមមានប្រាជ្ញា ដូចព្រះមហោសថ ។ ខ្ញុំថ្វាយបង្គំ ព្រះពុទ្ធទត្តម ប្រាជ្ញ
មោះមុត តែងនាំសត្វជន ឆ្លងឆ្លងសមុទ្រ សង្សារចំហុត ជាក់ដល់សួគ៌ ។
ព្រះអង្គត្រាស់ត្រែច សាងសំការស្រេច ផ្លាច់វដ្តសង្សារ លើសលែង
រៃតែកព សាយសព្វទិសា ព្រះអង្គផ្តាញ់មារ ដល់និព្វានហោង ។ បង្គំ
ព្រះពុទ្ធ ចារមិពិសុទ្ធ ពិសេសឥតហ្មង ពន្ធីរស្មី ភ្លឺត្រែកទ្វង ដល់សួគ៌
នាយហោង ភ្លឺផ្ទៃកសព្វស្ថាន ។ បង្គំព្រះធម៌ តិសេសមានអាថ៌ ជ្រៅពន់
ប្រមាណ អាចតែងត្រងរង សត្វជង់សព្វស្ថាន ជាខ្ញុំមប្រធាន រៃតំធ
សម្បត្តិ ។ បង្គំព្រះសង្ឃ ប្រសើរសីងខ្ចង់ សីលសុទ្ធប្រតិបត្តិ ជាស្រែ
រៃសបុណ្យ មានគុណគាប់ក្លាត់ តាមផ្លូវប្រតិបត្តិ ព្រះសង្ឃតាំងឡាយ ។
លោកទំសង្វាត យកបំណុលបុត ប្រោសសត្វសម្ងួយ ឲ្យរួចអស់ទុក្ខ
ទោសនៅកង់កាយ សត្វជង់តាំងឡាយ ចូរសន្ធោហោង ។

នេះនំងស្រដី បុរសប្រុសស្រី ពីរនាក់ជាមួង ប្តីនំងប្រពន្ធ ឥតជន
ជានផង ឪតញ្ញាតិសោតហោង ឥតរៀវសន្ធាន ។ រកស៊ីនៅនា ក្នុងរៃ
ព្រឹក្សា យូរទៅទើបបាន កាប់ឈើរៃព្រៃ នៅកង់ស្នុះសាន បន្តិចទើប
បាន ចំការមួយហោង ។ នោះឯងធំរៃត្រែ ប្រមាណនៅនៃ ៥ សិនជាមួង

ជាអ្នកតំណត់ ខុតិតកន្ទួង ហេតុនោះសោតហោង ត្រែតអរពេកក្រៃ ។ លុះដាំស្រូវទៅ កន្លងចំការក្លូវ ស្រូវនោះប្រពៃ ទឹកថាន់ស្រូវ អញ្ជានេះល្អក្រៃ តុម្ពធំណាស់នៃ លើសស្រូវអ្នកផង ។ ជាយូរលន់ទៅ រីឯដើមស្រូវនោះក្លូវសោតហោង ល្អៗប្រពៃ តួរវែងកន្ទួង ជាក់តួរល្អាយល្អង ខន់ ។ តាមគ្នា ។ ល្អល្អះប្រពៃ រីស្រូវនោះនៃ ខុំពេញចំការ រន្ធាលប្រាលផ្លៅ ផ្លែស្រូវនោះណា ពាសពេញចំការ បរិបូណ៌ជារត្រៃយ ។ រីឯបុរសតាំងពីស្មោនស្មោះ បបួលគ្នាហើយ ទៅច្រូតនៃស្រូវ នោះក្លូវជារត្រៃយ ឃុតស្រូវមកហើយ ដាក់លើផ្ទះហោង ។ លុះដល់ផ្លូវ នាំគ្នាយកស្រូវទៅដាំខៀតផ្គង ដូចតាលសត្វគ្រា ពីដើមនោះផង ស្រូវនោះឯងហោង ល្អដូចដើមនៃ ។ យូរលន់ទៅណា ចានគោជន៍អាហារ តែតែច្រើនក្រៃ ពេញបរិបូណ៌ណាស់ ឥតខ្វះឡើយនៃ ត្រែតអរពេកក្រៃ ធ្វើជង្រែកឯង ។ មួយនោះធំក្រៃ ហើយវែងផងនៃ ច្រាក់ដដាក់ស្លែង ឆេងធំខ្លួលាយ ខ្ពស់ក្រៃគួរស្ញែង ជង្រែកច្រាំល្អែង ឥតក្រែងអ្នកផង ។ ជាយូរទៅណា នាងមានកូនក្មេ មួយល្អកន្ទួង ឲ្យឈ្មោះអាសាញ់ ពេញចិត្តណាស់ហោង ស៊ីចាយច្រើនផង មួយឆ្នាំងមួយថ្លៃ ។ លុះដល់តំរង់ ច្រាំមួយដងណ្តាប់ ឆ្នាំហើយសោតនៃ បរិភោគអាហារ តាន់តែច្រើនក្រៃ នាក្នុងមួយថ្ងៃ បីចាំងអង្គរ ។ ម្តាយឪពុក ចេះតែកើតទុក្ខ តិយតែពីក្រៃ រីស្រូវចំការ តាន់តែមិនល្អ តិយតែពីក្រៃ

ធ្វើស្រែមិនចាន់ ។ ទើបមកគិតគ្នា បើទុំកុកវ ឃើញជាមិនគ្រាន់ ពីដើមយើងមាន ឥឡូវយើងកាន់- តែថយសម្បុន្ន សម្បត្តិហិនក្រ ។ រីស្រែចំការ យូរឆ្នាំហើយណា កាន់តែមិនល្អ ទុកវធ្វើអ្វី នាំតែឲ្យក្រ សម្លាប់ឲ្យមរណ៍ អាចោរចង្រៃ ។

បទព្រហ្មគីត

ទុពុកហៅកូនហើយ អាសាញ់អើយមកឲ្យទាប់ ដូរគអញចង់ទៅភាប់ ឈើឯព្រៃភ្នំនោះណា ។ អាសាញ់ឮបានឮហើយ ដើរព្រងើយច្រាប់មាត ថាម៉ែដាំចាយវ៉ា ដូរគខ្ញុំទៅភាប់ឈើផង ។ ម្ដាយឮអាសាញ់ច្រាប់ ដាំចាយធាប់ពេកកន្ទុង ខ្ជប់ឲ្យអាសាញ់ហោង ហើយអាសាញ់ស្ដាយដើរវៃ ។ ទុពុកហៅអាសាញ់ កុំសូញសាញ អាចង្រៃ ហើយក្រែងមិនចាន់ថ្លៃ ទឹងរិលវឹងមិនចាន់ហោង ។ លុះចរយាត្រាទៅ ដល់ព្រៃជ្រៅដុងដែនដង ឃើញឈើមួយដុងផង សំ-ន្ធូនប៉ុនបីតួបតឹង ។ អាសាញ់ឮរាចាយហើយ ឈរព្រងើយធ្វើមិនដឹង ទុពុកប្រឹងសំឡឹង ធ្វើខ្មឹងខ្មែងទៅ ។ ទុពុកហៅថានែ អាកុំប្រែឈរសំឡឹង អញកាប់ឈើទឹងដឹង ចាំខ្លួលវ៉ីយអាសាញ់ ។ ទុពុកប្រឹងតែកាប់ ប្រុងសម្លាប់អាសាញ់ហ្នឹង អាសាញ់ឈរបែរស្ងើង សូរទៅខ្ពែរឈើនោះណា ។ ទុពុកស្រែកថាវ៉ីយ ប្រយ័ត្នធ្លាក់ឈើអាវ៉ា ឈើនេះធ្វើខ្លួកក្ដារ កុំឲ្យបែកចាក់ឡើយវ៉ី ។ ឯឈើចាក់សង្កត់

អាសាញ់ស្រែតលិចក្តងដ៏ ឧពុកវៃស្រែកថាថ៎ ម្តេចក៏លិចបាត់ទៅហើយ ។ គិតស្រែចហើយយាគ្រា ដើរម៉្លេមកតន្តើយ ថាវាស្ងាប់ទៅហើយ កាលណានឹងសៅឡើងវិញ ។ ដើរមកធ្លើព្រលឹយ ក្តេចថ្កុយហើយ តុំនឹកមិញ តុំត្រឡប់វិលវិញ ទៅយកថ្កុយមកស៊ីឡើយ ។ គាត់ដើរចិត្តនឹកគិត ក្តងគំនិតគាត់ជាត្រីយ តុំបាននឹកថ្កុយទេរ៉ូយ ចេះតែគិតក្តងឥន្ទ្រីយ ។ កាលព័ដើមមកនៃ អញនឹកព័ស៊ីតែព័ស៊ី ឥឡូវគ្មានគ្នាគ្នី មកតាមស៊ីបំផ្លាញឡើយ ។ តុំដឹងខ្លួននឹងស្ងាប់ តៀរសម្លាប់តេនោះហើយ តេតុំស្ងាប់សោះឡើយ តៀរនោះហើយស្ងាប់ខ្លួនឯង ។ ដើរមកវាលំទៅ វាឆ្នែងផ្លូវដាច់សង្វែង អត់ថ្កុយស៊ូតនោះឆង ត្រាំពីរថ្ងៃក្រ៉ូយជន្មា ។

ទឹងថ្ងៃងងក់ទៅវិញ ឯទៅសាញ់នោកំត្រា ដើរបុកឡើងម៉្លេម្តាវកម៉ិតាតុំឃើញឡើយ ។ ច្រឹងវៃស្រែកដង្ហើយហៅ ថាឧឪទៅណាហើយ អញ្ជើញមកផ្ទះអើយ មកបរិភោគអាហារហាង ។ វៃស្រែកហៅតុំឮធ្វើយ ខ្លុកតុំស្រ៉ូយឧពាវ ទើបវិលមកវិងផ្តង យកអាហារបរិភោគ្តា ។ រួចហើយទើបត្រៀកដើរ ទៅយកឈើលើលើស្មា ដំហាំបីឧបណា ល៉ើលើស្មាហើយដើរទៅ ។ រវេកផ្លូវខ្លះតណា ឯកអង្គ្រាម្នាក់ឯងក្តូវ ឥតគ្នាជាព័រនៅ ត្រាំទន់ដើរទៅរេមណ្តាល ។ រីផ្លូវដែលដើរមក ឥឡូវរកក៏តុំយល់ ចេះតែដើរលិលវល់ ហើយអម្ពល់ក្តងវៃត្រៃត៎ក្ស ។

ចៅសាញ់ដើរចៅ រកខ័ណ្ឌនៅអាត្មា តុំយើញឡើយណា វង្វេងក្នុងព្រៃវែកវី ។ ទំនងថ្ងៃតរៅ ឯម្ដាយនឹត្យទៅផ្ទះខ្ញុំ ចាំមើលផ្លូវប្ដី តុំយើញថាត់ចាល់ស្ងាចណា ។ ចេះតែទន្ទឹង សញ្ជប់សញ្ជឹងខ្ញោចផ្សា ព្រួយក្នុងចិត្តា តុំចាននិទ្រាតិចឡើយ ។ ឮមាន់រងាវ ស្មានជាប្ដីហៅតិតឆ្នើយ បើកទ្វារឡើងហើយ រកមើលតុំយើញឡើយណា ។ ស្ដាប់ជាក់ជាមាន់ក្នុងចិត្តខ្ញាញ់គ្នាន់សោះសា ថាតុអនិច្ចា អ្នកជាស្វាមីខ្ញុំនេះ ។ ក្សយប្ដូចម្ដេច ចានជាអ្នកចាត់ដល់ម្ល៉េះ ថ្ងៃមិញយប់នេះ ក៏តុំទាន់យើញមុខមាត់ ។ មើលផ្លូវចាត់ហើយ ខានទៅព្រឹកឯើយស្ងៀមស្ងាត់ ហេតុដ្បិតប្ដីចាត់ ស្ងៀមស្ងាត់រកស៊ីចៅណា ។

នេះនំងថ្ងាថ្ងៃង ទិចានចាយចែងចរចា ចៅចៅសាញ់ណា ឯកាដើរតែកូនតែព្រៃ ។ ចេះតែដើរចៅ តុំដែលដំងផ្លូវឡើយនៃ ដើត្រាច់កូនតែព្រៃ រកផ្ទះតុំយើញឡើយណា ។ យើញប៉ុន្តែសត្វ កូនចិត្តស្ងប់ស្ងាត់សោះសា ថាតុអនិច្ចា អញអើយតំព្រាម្ចាក់ឯង ។ តុសត្វតាំនឡាយនៅសុខសប្បាយឥតវៃកែង អញអើយតែឯង ហៅមហាចំបែងតុំស្បើយ ។ មិនដូចសត្វផង ច្រើនតែកន្ទុំងជាគ្រើយ មូលនំងគ្នាហើយ ដើរចៅឯណាច្រើនតែព្រៃ ។ អញដើរតែឯង តិតត្រប់តួរស្ងែណាស់ខ្ញុំ តែកែងសត្វអ្នី ។ រាមកយាយីភាពា ។ រឹងដើមឈើ ដែលអញលើស្មាណា ខើសនំង

ត្រីក្បា ក៏ចាក់មែកវាស្រឡះ ។ ដើរមកយូរហើយ ឪវែងជាត្រៃយកខ្លះ ចំដើរកេងខ្លះ ពុំឃើញពុំយល់ឡើយណា ។ រីឯចៅសាញ់ កូនចិត្តគ្នាខ្ទាញ់ណាស់សា គោះទាំងអាហារ នោះក៏ពុំបានបរិភោគ ។ ដើរតែកូនតែព្រៃ សង្រែងសង្រៃខ្លុកសោក ចំតែដើរកេង ពុំឃើញចេះតែយាត្រា ។ រីដំណើរនេះ យើងនឹងទុកស្នេះក្បាណា បង្ហានខ្លុកជាដើរតែកូនតែព្រៃឯកអង្គ ។

នេះនៅស្រដី ទៅឯបុរីពេជម្ប មួយទាមទត្តម នគរព្រះបាទព្រហ្មទត្ត ។ ព្រះអង្គសោយពេជ្យ មែនមានអំណាចពេកក្លាត់ គ្រងអស់ពស្ត្រផ្ទៃ ទៅកូនីនគរកូមិស្រុក ។ ស្តេចសុខសប្បាយ អស់ពស្ត្រពាំង-ឮប្បាយឥតខ្លុក ព្រះអង្គសិងសុខ ពុំដែលមានខ្លុកភ័យសោះ ។ មនុស្សជន្លែនតែក សប្បាយសព្វថ្ងៃពាំងអស់ គោះស្រែគោះប្រុស ស្រែចស្រស់ក្សេមក្សាន្តចិន្តា ។ ខ្លះលក់ខំនិញ អ្នកខ្លះសោតទិញគ្នាណា ខ្លះកាត់ថ្ងៃថា ប៉ាខ្ញែនសាមសិបល្មមថ្ងៃ ។ លក់ដូរទៅមក រកែករគោក សព្វថ្ងៃ ពុំដែលមានភ័យ ជ្រាប់សុខរឿងៗមកណា ។ មានតាលមួយថ្ងៃ យកក្បូរមួយកាចតែក្រសោះសា ចិត្តវាមោហា វាន់ងឹមណាមិនខាន ។ យកក្បូរខាងឯណា ចិត្តវាហានក្លាកូនក្រាណា ចង់ស៊ីក្បូរតែក្បាត្ត មិនដឹងខ្លួនស្ងាប់ឡើយហោង ។ ទើបយកក្បូរមោហា ក្រាយក្រាប់ស្តេចថាជាម្ហូង ឲ្យកេមនុស្សជន្លែន មកជាក់សួយឲ្យអញថ្ងាត់ ។ បើពុំព្រមជាក់

សួយឲ្យអញជាក់ច្បាកដ គោះខាំនមហាក្សត្រ អញស៊ីពុំលែងឡើយ
ណា ។ យក្សច្បាយច្បាប់ហើយ វិលវិនព្រងើយសោះសា ដល់
ស្ថានហើយណា ម្ដេចចូលទៅវិញ ។ កាលគ្រាយយក្សទៅ ព្រះ
បាទចមទៅស្ដេចភ័យ គោះពស្ដេចន្ទី ប៉ុន្មានសន៌ភ័យពុំស្បើយ ។
ខ្លះតម្ដីម្ដា ច្បាប់គ្នីច្បាប់គ្នាជាច្រើយ ថាវែនវ៉ីអើយ កុំទៅណាឆ្ងាយ
ឡើយណា ។ អស់មនុស្សខាំនឡាយ តិតភ័យប្រញាយសោះសា
ថាទុអនិច្ច ជាហេតុប្រកាសស្លាប់អ្វី ។ បេះតែកើតទុក្ខ ពុំបានចំញាស់
ឡើយនៃ បេះតែតិតភ័យ ខ្លាចក្បាយជីវិតពាស់គ្នា ។ ស្ដេចត្រាស់ឲ្យ
ហៅ អាធុនចូលទៅម្ដីម្ដា ត្រាស់ថខ្ញុលថា អាធុនអញចង់ប្រើឯង ។
ទៅថ្ងៃឯងច្បាប់យក្ស ថាអញត្រមជាក់សួយស្ដេច ចាំធ្វើកន្ទែង ច្បាំពីរ
ថ្ងៃខ្ញើតក្បាលហោង ។ ក្បាតឯងជាអ្នក ច្បាជ្ញាដើរជាក់ជាមួង
ឯងច្បាប់ក់ដង ដោយខ្លួវដំណើរកេញថា ។ អាធុនចងចាំ ដោយខ្លួ
បណ្ដាំពជា ទើបចង្ដិលា យាត្រាវិលវិនទៅឋាន ។ ដល់មកដូរហើយ
ជាទុក្ខពុំស្បើយក្នុងច្បាណ ទើបរិះគិតឆ្ងាន អញយកច្បាជ្ញាបណា ។
គិតស្រេបហើយនៃ ចុះដើរទៅវិញសោះសា រិះកច្បាជ្ញា ដោយ
ខ្លួវុចាយកលហោង ។ ដើរទៅហើយណា ដល់ស្ថានយក្សដូច
បំង ចរកូលទៅផ្ដួង ដល់នៃលំទៅយក្សស្រេច ។ ទើបយក្សសួរ
ថា ឯងមកនេះប្រការម្ដេច ដំណើរសេចត្រួច ដូចម្ដេចច្បាប់អញ

ឲ្យហើយ ។ អាជុងទូលថា បពិត្រឪពុកខ្ញុំអើយ អ្នកឯងដាស់គ្រើយ ខ្ញុំសូមជាឥតកុំ ។ ឥឡូវនេះនៃ ព្រះមហាក្សត្រថ្លៃឧត្តម ព្រះអង្គប្រទូន ឲ្យមកដាក់បណោកខ្ញុំ ។ ព្រះអង្គត្រមដាក់ សួយឲ្យជាន់ជាក់ហើយ កូវ ប៉ុន្តែឲ្យខ្ញុំ ចាំត្រាតែវិលទៀតហោង ។ ចាំផ្ទើសាលា រួចស្រេចហើយណាជាមុនិ សូមនុះទៅហោង ព្រះអង្គស្តេចជាក់សួយឲ្យ ។ យក្សស្តាប់តាក្សពោចន៍ អស់អាថិសេចគ្រេចច្នេះហើយ គរឯងពុំស្បើយហេតុពៀរវែកអាត្មា ។ ខ្ញុំងក្រើយដីវិត ខ្ញុំនឯងពុំតំតទៀយណា ហេតុដ៏ត្តមោហា ដែលវ៉ា ប្រាសេស្តេចហោង ។ ទើបយក្សមោហា ឮបាប់អាជុងថាដាមុនិ អញត្រមដែរហោង ឯងវិលទៅទូលស្តេចចុះ ។ យក្សឮបាប់ស្រេចហើយ ពិតពុំលន់ឡើយកាលនោះ ទើបអាជុងឆ្ពោះលាយក្សមកផ្ទះអាត្មា ។ មកដល់ផ្ទះហើយ ពិតពុំលន់ឡើយម្ល៉ោ ចរចុះយាត្រា ទៅទូលព្រះមហាក្សត្រថ្លៃ ។ ទៅដល់ហើយណា ក្រាបទូលក្សត្រាជ្ញាដ្ឋាយ ឥឡូវនេះនៃ យក្សនោះក៏ត្រមហើយណា ។ ស្តេចទ្រង់ដំណាបហើយ ពិតពុំលន់ឡើយក្សត្រា ឮបាប់អស់សេនា ឲ្យរៀបអស់តែគ្នីនឹងឮបាប់ ។ ទំនឹសង្ឃសាលា ត្រាតែវិលថ្ងៃណាឲ្យឆាប់ឲ្យបានប្រញាប់ នៅកន្លះកំណាត់ប៉ុណ្ណោះ ។

បទតំនោល:

កាលនោះព្រះបាទក្សត្រា បង្គាប់សេនា ស្រេចហើយក៏យាង

ចូលទៅ ។ សេនាឋយចេញទៅគ្រៅ ទើបបង្គាប់ទៅ អស់ពាំនគ្នាក់ ជារពាំនឡាយ ។ ឲ្យនាំឈើចូលមកអាយ ដ្បិតព្រះធោមធាយ ព្រះអង្គឲ្យធ្វើសាលា ។ ក្នាក់ជារស្តាប់ព្រះអាជ្ញា ហៅគ្នាម៉ឺមា នាំឈើចូលមកធាប់រៃ ទើបរៀបច្រងាប់ទីតៃ នាំឈើតិរៃត្រ រំពេចដូចព្រះបង្គាប់ ។ ខ្លះគឿនគ្នាថាប្រញាប់ រៀបធ្វើឲ្យធាប់ ឲ្យរួចដូចព្រះអាជ្ញា ។ ខ្លះធ្វើប្រញាប់ម៉ឺមា លុះរួចសាលា ទើបចូលទៅគ្រាបទូលហោង ។ ព្រះបាទព្រហ្មទត្តច្បាស់ច្បង ទ្រង់ជ្រាបហើយហោង ឲ្យហៅអាធុងចូលទៅ ។ អាមាត្យរត់ដល់លំនៅ អាធុងហើយហៅ ប្រាប់ទៅដូចព្រះឆង្ការ ។ ទ្រង់មានព្រះបន្ទូលថា ឲ្យទៅម៉ឺមា អញ្ជើដូចព្រះប្រញាប់ ។ អាធុងខោះឃ្មាតស្តែងស្តាប់ បន្ទូលឲ្យប្រាប់ ប្រញាប់រៀបអង្គអាត្ម ។ ចរចុះដើរទៅម៉ឺមា ដល់ចុងភេងណា គ្រាបថ្វាយបង្គំក្សត្រថ្ងៃ ។ ព្រះអង្គទតយល់អារៃត្រ បន្ទូលថាហៃ អាឯងរកមនុស្សជាក់ស្តួយ ។ មនុស្សដែលមានទោសដល់មួយ មរណ៍ឯងកុំត្រួយ ជាក់ស្តួយនាថ្ងៃមួយហោង ។ អាធុងគ្រាបលាជាម្ចាស់ យកមនុស្សទោសផង ទៅជាក់ស្តួយដូចបង្គាប់ ។ រួចហើយឋយចេញប្រញាប់ រលែងតែក្រឡាប់ ដើរមកផ្ទះពាំនក័យភ្លាក់ ។

ទីនថ្ងៃនតែងប្រឹងជាក់ ទៀងទៅឯយក្ស អប្បល័ក្ខណ៍ចោរគាចចំនែង ។ ដល់គ្រប់គំរប់នាថ្ងៃ យក្សចោរចំនែង មោហកាគាចអច្ឆិយ ។

មកដល់សាលាហើយ ខ្ញុំ ចូលទាប់ម្ចាម្ដី វែកស៊ីសាច់មនុស្សនោះទៅ ។
តែសព្វៗថ្ងៃនិត្យទៅ ៖ លុះបានដល់ទៅ ត្រាំថ្ងៃនោះឯងហោងណា ។
យើងស្ទេរពុំទាន់ចរចា នេះនឹងថ្ងៃនិយាទៅឯចៅសាញ់ដាតែម្ដង ។
មកដល់កងពុងស្រែកហើយ ត្រួយត្រាណពុំស្ដាប់ ចិត្តខ្ញុំក្រាកជាម្ដង ។ អត់ថ្នាយដើរតែឯងឯង ចិត្តមែហើយហោង ដើរតែកងពៃជាក់ស្ដែង ។ គន់គិតកងចិត្តអង្គឯង អ្នកឯណាតែង សាលាដាក់ទានទៅនេះ ។ ហើយនឹកថាតំពូអញអេះ ជានសាលានេះ ត្រាន់ឈប់តាស្រ័យជាម្ដង ។ លុះដើរដល់សាលាហោង ចំលាក់ឈើផ្ដង កំពូលទ្វីកខ្លាំងពៃក្រ ។ ទឹងថ្ងៃជ្រៅអាធុងនៃ ឮសំពូខ្លាំងពៃក្រ ទឹកថាសន្ធឹកសំពូអ្វី ។ គិតៈស្រែចខ្លើចចុះទៅដី ដើរទៅទាប់ខ្ញុំ ក៏ឃើញអាសាញ់ក្រអេះ ។ ហើយនឹកថាអាជែងនេះ មកពីណាអេះ គួរអញទំងន់ទៅសួរពេ ។ គិតៈស្រែចហើយចរយោគ្រា ទៅដល់សាលា ក៏ឃើញនៃឈើនោះហោង ។ ឃើញធំពាន់ពេកកន្ទុង គួរខ្លាចជាម្ដង គួរយកគេជាក្ដើអញ ។ គិតស្រែចទេរ្ដើងទៅឃ្នាតខ្លាញ់ ហៅថាសំឡាញ់ ឯងមកតើស្ដានឯណា ។ អាសាញ់ឮហើយទ្រើយថា ដោយខ្លួវកំណា គាត្មាក៏ឃ្លានចុះយូរដង ។ រីឯខ្លួនអញនេះហោង ពុំដឹងស្រែកដង ដើរតែកងពៃទេណា ។ ចិត្តៈលំបាកអាត្មា ទោះតាំងអាហារ នោះក៏ពុំឃ្លានបរិភោគ ។ ពុំដឹងទីស្ដានផ្លូវច្រក ចេះតែដើរមក ទើបបានឃើញសាលានៃ ។ ទៀបណាស់ចូល

ឈប់អាស្រ័យ សាលានេះនៃ សំពះកត់ឡាំងក្បាលហោង ។ ចាំតែចាត់
ក្តៅពេយខ្នង ឧន៍យាគ្រាផ្តង ទៅតេលទៅជាគ្រែយ រឹងអាធុងធ្នុះធ្លើយ
ថាសំឡាញ់អើយ ចូរឯងទៅទៅឧន៍អញ ។ គេះចាំងបាយខំតនោះ
មិញ ជានាទៅអញ ឧន៍ចិញ្ចឹមឯងជាម្តង ។ អាសាញ់ឆ្ងាស់ធ្លើយ
រឹងស្នង ថាអញនេះហោង បរិភោគអាហារច្រែនណែ ។ អាធុងថា
អញសង្ស័យ ឯងស៊ីច្រែនណែ មួយថ្ងៃតើអស់ប៉ុន្មាន ។ អាសាញ់ធ្នុះ
ធ្លើយរឹងថ្ពាន អញស៊ីប្រមាណ តិចទេមួយថ្ងៃបីចាំង ។ អង្គរសស្រែត
សម្រាំង មួយថ្ងៃបីចាំង នោះឯងទើបបានគ្រាន់អញ ។ អាធុងធ្លើយ
ថាសំឡាញ់ ជានាទៅអញ ចិញ្ចឹមរក្សាឯងហោង ។ អាសាញ់ព្រម
ពាក្យជាម្តង ទើបចុះទៅផ្តង ជាមួយនឹងអាធុងណា ។ លើកឈើលីទៅ
សោះសា ហើយចរយាគ្រា ម៉ឺម៉ាទៅផ្ទះអាធុង ។ ដល់ហើយចំលាក់ពួកក្តុង
មុខផ្ទះអាធុង ក៏បែកខ្ចាត់ខ្ចាយពីគ្នា ។ អាធុងច្បាប់ទៅតរយោ ខ្លួរអស់
មនុស្សម្នា ឲ្យរកបាយបរិភុះគ្នាត ។ អស់ខ្ញុំដណ្តាំបាយសោត បានបរិ
ភុះគ្នាត ស្រែចឲ្យអាសាញ់បរិភោគ ។ សម្លសូបខ្លែឃ្មោក អាសាញ់
បរិភោគ បរិភុះក៏អស់ទៅហោង ។ រឹអស់មនុស្សម្នាខោះផង សឹងស្រែង
កន្ទុង ព្រោះយល់បរិភោគច្រែនណែ ។ ព្រឹកល្ងាចលុះបានពីរថ្ងៃ កំឡាំង
ច្រែនណែ ដូចកាលពីដើមវៀងជាត់ ។

ខិធីថ្ងៃនីមួយៗ ដល់ឯយក្ស កំណត់ពាក់ផាត់ ជាកន្ល៉ៃថ្ងៃនោះនៃ ។
រសៀលត្រាស់ប្រាប់យោងទ័យ រំអាសាញ់នៃ បរិភោគជាយប្រពេលហើយហោង ។
ទើបអាធុងឆ្លៀតប្រាប់ដើមទង អាសាញ់ជាម្ចាស់ អញប្រើឯងឲ្យទៅការប្រាក់ ។
ដ្បិតនុះអញគាត់ជំពាក់ ឯងទៅការប្រាក់ យកមកគ្រាន់ទំញ្ញស្រួស្ដី ។
បន្តិចគាត់មកឯទី សាលានោះឡើ ឯងទៅចាំគាត់មុនណា ។ អាសាញ់
ឮនស្តាប់បញ្ជា ទើបចរយាត្រា ទៅឯសាលានោះនៃ ។ លុះថ្ងៃ
ជ្រាំងខិធីមាត់ព្រៃ យក្សចោរចង្រៃ ហោះមកកាចាប់មនុស្សតែ ។ យក្ស
ដល់សាលាមខ្លី ឡើងទៅធាប់ឮ ដល់នៃមាត់ទ្វារជោះត្រើយ ។ អា-
សាញ់ត្រែកឡែកឃើញហើយ ថាខ្លែងអើយ អាធុងវាឲ្យការប្រាក់ ។
យក្សស្តាប់ពាក្យអាសាញ់ជាក់ ស្រដីការប្រាក់ យក្សក្រាក់គាន់តាំងស្មារ-
តី ។ យក្សថាជំពាក់ប្រាក់អ្ហី អញពុំមានក្តី ជំពាក់ប្រាក់កាសខនណា ។
អាសាញ់ឆ្លុះឆ្លើយទៅថា អាធុងចរចា ថាខ្លួនជំពាក់ជាម្ចាស់ ។ មួយកន្លាំង
ប៉ុណ្ណោះហោង ហៅតុនោះជាម្ចាស់ ទើបវាប្រើខ្ញុំមកការ ។ យក្សស្តាប់ពុំ
ចេញចរចា សួរទៅប្រាក់ ចាប់ខ្លួរអាសាញ់ឆ្លាប់ហើយ ។ ច្រចាប់តមិន
លេងឡើយ ទើបអាសាញ់ឆ្លើយ ថាឥលេងអញចេញក ។ លេងក្តៅដៃឆ្ងន់
ពេកណា លែងអញចេញក លេងម្តេចដៃឆ្ងន់អម្បាយ ។ ឲ្យលែងមិន
លែងគេងាយ ច្រចាប់ស្មើរភ្លាយ បំពាន់តគេជាម្ចាស់ ។ អាសាញ់ប្រាប់ទៅ

ច្រើនដង មិនលែងឡើយហោង ថានែឪលែងអញចេញ ។ បន្តិចត្រូវកំ
ភ្លៀងមិញ មិនលែងកចេញ អញទះកំភ្លៀងឥឡូវ ។ កុំលេងដៃធ្ងន់ពេក
ក្លូវ ទើបថានែឪ លែងអញឱ្យធាប់ម្ដងមា ។ យកស្លាប់តុំលែងឡើយ
ណា ទំតែប្រាក់ កាប់កឱ្យបាក់ជាមួង ។ អាសាញ់គ្រែងគ្រែកខ្លួន
អត់តុំបានហោង ក៏ទះកំភ្លៀងនែឯយក្ស ។ នោះស្លាប់ទៅប្រាកដជាក់
អាសាញ់លោតជាក់ ថែមត្រូវមួយចុងដើងទៀត ។ ទើបអាសាញ់ពាទៅ
ភ្លៀត ស្លាប់ដង្ហើមទៀត ក៏ផុតដង្ហើមជាគ្រែយ ។ ខ្លួនក៏ត្រជាក់អស់
ហើយ ទើបតិតជាគ្រែយ អានេះវាស្លាប់ហើយណា ។

(នៅមានត)

ការយល់ឃើញរបស់អធិការនៃគណៈសង្ឃ

នៃស្រុកកំពង់ត្រឡាចក្នុងខែវិច្ឆិកា ឆ្នាំ ១៩៤៣

១- សញ្ញាប័ត្រលេខ ៧ ចុះថ្ងៃ ៨-៦-៤៣ តាំងគ្រូសូត្រសេក-ខឹម កើតឆ្នាំច អាយុ ៥៧ វស្សា ៣៧ នាមធាយ ចន្ទត្ថេរ ជាចៅអធិការវត្តពោធិព្រឹក្ស ឃុំកុញ្ជរ ស្រុកទ្រូង ។

២- សញ្ញាប័ត្រលេខ ៨ ចុះថ្ងៃ ៨-៦-៤៣ តាំងគ្រូសូត្រកុក-មុត កើតឆ្នាំឆ្លូវ អាយុ ៤៦ វស្សា ១៨ នាមធាយ ធម្មជោត ជាចៅអធិការវត្តត្រពាំងក ឃុំតាមៅ ស្រុកទ្រូង ។

៣- សញ្ញាប័ត្រលេខ ៩ ចុះថ្ងៃ ៨-៦-៤៣ តាំងគ្រូសូត្រអឹម-ខឹម កើតឆ្នាំមមែ អាយុ ៧៦ វស្សា ៥៦ នាមធាយ តិក្ខញ្ញោ ជាចៅអធិការ វត្តពោធិព្រឹក្ស ឃុំរលាំងកែន (ស្រុកកណ្តាលស្ទឹង) ។

៤- សញ្ញាប័ត្រលេខ ១០ ចុះថ្ងៃ ១០-៦-៤៣ តាំងគ្រូសូត្រ នាង-មុត កើតឆ្នាំរកា អាយុ ៣៤ វស្សា ១១ នាមធាយ រៃយក្ខេត្តោ ជាចៅអធិការវត្តពោធិ ឃុំចំបក់ ស្រុកកំដួល ។

៥- សញ្ញាប័ត្រលេខ ១១ ចុះថ្ងៃ ២២-៦-៤៣ តាំងគ្រូសូត្រ ម៉ូច-ម៉ុញ កើតឆ្នាំមមី អាយុ ៣៧ វស្សា ១៧ នាមធាយ មុទិត្ថេរ ជាចៅអធិការវត្តពោធិអង្គុល ឃុំសំបួរ (ត្រាំង) ។

៦- សញ្ញាប័ត្រលេខ ១២ ចុះថ្ងៃ ២៦-២-៤៣ តាំងត្រួសូត្រ ខេស-សេន កើតឆ្នាំខាល អាយុ ៤១ វស្សា ២០ នាមធាយ៉ា ព្រហ្ម-សុវណ្ណ ជាចៅអធិការវត្តថ្មម្ប៉ាមុម ឃុំថ្មម្ប៉ាមុម ស្រុកត្រាំង ។

៧- សញ្ញាប័ត្រលេខ ១៣ ចុះថ្ងៃ ២៦-២-៤៣ តាំងត្រួសូត្រ ហ៊ាន-សុខន កើតឆ្នាំកេង អាយុ ៣៨ វស្សា ១៨ នាមធាយា សុវណ្ណបញ្ញា ជាចៅអធិការវត្តព្រៃឈើខាល ឃុំឆ្នុក ស្រុកត្រាំង ។

៨- សញ្ញាប័ត្រលេខ ១៤ ចុះថ្ងៃ ២៦-២-៤៣ តាំងត្រួសូត្រ ឯម-ឆែត កើតឆ្នាំរកា អាយុ ៣៤ វស្សា ១៣ នាមធាយា លិក្ខិតត្ថេរ ជាចៅអធិការវត្តបាកយណ៍វិហារតាវ ឃុំព្រៃស្វាយ (ត្រាំង) ។

៩- សញ្ញាប័ត្រលេខ ១៥ ចុះថ្ងៃ ២៦-២-៤៣ តាំងត្រួសូត្រ គោះ-ឆិន កើតឆ្នាំជូត អាយុ ៣១ វស្សា ១១ នាមធាយា ចន្ទបញ្ញា ជាចៅអធិការវត្តសូកេសួស្តី ឃុំឆ្នូក ស្រុកឆ្នូក (ត្រាំង) ។

១០- សញ្ញាប័ត្រ លេខ ១៦ ចុះថ្ងៃ ២៦-២-៤៣ តាំងត្រួសូត្រ សៅ-តាក កើតឆ្នាំថោះ អាយុ ៤០ វស្សា ២០ នាមធាយា ធម្មសុវណ្ណ ជាចៅអធិការ វត្តស្វាយជ្រូ ឃុំក្រាំចម្ប៉ាមុម ស្រុកត្រាំង ។

១១- សញ្ញាប័ត្រលេខ ១៧ ចុះថ្ងៃ ២៦-២-៤៣ តាំងត្រួសូត្រ ហេង-កុល កើតឆ្នាំមមី អាយុ ៣៧ វស្សា ១៣ នាមធាយា កន្ធត្ថេរ ជា ចៅអធិការវត្តគោធ្នង់ខ្ពស់ ឃុំសំបួរ ស្រុកត្រាំង ។

១៦- សញ្ញាប័ត្រលេខ ១៨ ចុះថ្ងៃ ២៤-៤-៤៣ តាំងត្រួសូត្រ អ៉ម-ប៊ុំ កើតឆ្នាំម្សាញ់ អាយុ ៣៩ វស្សា ១៥ នាមឆាយា ព្រហ្មវត្ថ្មា ជាចៅអធិការវត្តពោធិសួស្ដិ៍ ឃុំចុងឃណ្ដ ស្រុកត្រាំង ។

១៣- សញ្ញាប័ត្រលេខ ១៩ ចុះថ្ងៃ ២៤-៤-៤៣ តាំងត្រួសូត្រ ជ័ន-ឃុត កើតឆ្នាំច្រូវ អាយុ ៣៤ វស្សា ៨ នាមឆាយា ខន្ធវត្ថ្មា ជាចៅអធិការ វត្តពោធិខន្ធីម ឃុំសំបួរ ស្រុកត្រាំង ។

១៤- សញ្ញាប័ត្រលេខ ២០ ចុះថ្ងៃ ២៤-៤-៤៣ តាំងត្រួសូត្រ យូរ-ត្រែប កើតឆ្នាំកុរ អាយុ ៣២ វស្សា ១២ នាមឆាយា បឋមវត្ថ្មា ជាចៅអធិការវត្តបន្ទាយ ឃុំត្រពាំងធំ (ត្រាំកក់) ។

១៥- សញ្ញាប័ត្រលេខ ២១ ចុះថ្ងៃ ២៤-៤-៤៣ តាំងត្រួសូត្រ ខៀវ-ធា កើតឆ្នាំកុរ អាយុ ២៤ វស្សា ២៣ នាមឆាយា ឥន្ទវេសរ ជាចៅអធិការវត្តវិហារទាស ឃុំត្រពាំងធំ (ត្រាំកក់) ។

១៦- សញ្ញាប័ត្រលេខ ២២ ចុះថ្ងៃ ២៤-៤-៤៣ តាំងត្រួសូត្រ ម៉ុ-អាំ កើតឆ្នាំមមី អាយុ ៣៧ វស្សា ៧ នាមឆាយា ធម្មបញ្ញា ជាចៅអធិការវត្តសាគ្រាម ឃុំសាគ្រាម (កំពង់ស្វាយ) ។

១៧- សញ្ញាប័ត្រលេខ ២៣ ចុះថ្ងៃ ២៤-៤-៤៣ តាំងត្រួសូត្រ ម៉ែន-ជួរ កើតឆ្នាំកុរ អាយុ ៥៦ វស្សា ៣១ នាមឆាយា ធនវត្ថបញ្ញាគីរី ជាចៅអធិការវត្តប្រឹសមាស ឃុំត្រប់ ស្រុកជើងព្រៃ ។

๑๘- សញ្ញាប័ត្រលេខ ๒๔ ចុះថ្ងៃ ๒๔-๒-๔๓ តាំងគ្រូសូត្រ សៅ-ខូច កើតឆ្នាំកុរ អាយុ ๓๒ វស្សា ๑๒ នាមធាយ៌ ឥន្ទសុវណ្ណ ជាចៅអធិការវត្តគោះជុំ ឃុំដងឡែង ស្រុកជុកាន ។

ដំណឹងសុំអនុញ្ញាតធ្វើបុណ្យ

បញ្ជុះទណ្ឌសីមាក្នុងខែហ្វ្រីយេ ១៩៤๓

๑- បុគ្គហ្វាយលេខ ๔๔๘ ចុះថ្ងៃ ๘-๒-๔๓ អ្នកអាចារ្យ ដោក-ឈុន, សុំអនុញ្ញាតធ្វើបុណ្យបញ្ចុះសីមា វត្តអម្ពិលទួរ, ឃុំសំពងជៃ ស្រុកដងជៃ ខែត្រកំពង់ចាម ចំនួន ๓ ថ្ងៃ គិតពីថ្ងៃ ๑๘ ដល់ ๒๑ មីរ្យ ๑๙๔๓ នេះ ។

๒- បុគ្គហ្វាយលេខ ๔๖๘ ចុះថ្ងៃ ๘-๒-๔๓ អំពីអាចារ្យ សេក-ឌី សង្កាត់វត្តប្រតល់ ឃុំព្រែកគោធ៌សួស្តី ស្រុកស្រីសុន្ទរ ខែត្រកំពង់ចាម សុំអនុញ្ញាតធ្វើបុណ្យបញ្ចុះសីមា ๔ ថ្ងៃ គិតពីថ្ងៃ ๓๐ មីរ្យ ដល់ថ្ងៃ ๒ អាវ៉ែល ๑๙๔๓ ។

๓- បុគ្គហ្វាយលេខ ๖๔๘ ចុះថ្ងៃ ๑๑-๒-๔๓ អំពីអាចារ្យ ម៉ម-អូម, សង្កាត់វត្តដីមាន់ ឃុំព្រែក ស្រុកត្បូងឃ្មុំ សុំអនុញ្ញាត ធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ๓ ថ្ងៃ គិតពីថ្ងៃ ๑๕ ដល់ថ្ងៃ ๑๗ មីរ្យ ๑๙๔๓ នេះ ។

៤-ចុងហ្វាយលេខ ១០៤ ចុះថ្ងៃ ២៦ - ២ - ៤៣ អំពីអាចារ្យ ជ្រាក់-ខ្ពង់, សម្រាប់វត្តព្រៃសុវណ្ណ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង សុំធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ៣ ថ្ងៃ គិតពីថ្ងៃ ១៧ ដល់ថ្ងៃ ១៩ មីនា ឆ្នាំ ១៩៤៣ នេះ ។

៥-ចុងហ្វាយលេខ ១០៣ ចុះថ្ងៃ ២៦ - ២ - ៤៣ អំពីអាចារ្យ សុក - ឌីន, សម្រាប់វត្តអង្គិល ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង សុំធ្វើបុណ្យបញ្ចុះសីមាវត្តនេះ ចំនួន ៣ ថ្ងៃ គិតពីថ្ងៃ ១០ ដល់ថ្ងៃ ១៤ មីនា ឆ្នាំ ១៩៤៣ នេះ ។

ប្រស្នាធម៌

អំពីព្រះនិព្វាន។

បុច្ឆា: តេថា ព្រះអរហន្តស្លាប់ទៅសូន្យមែនឬ?

វិសជ្ជនា: តាមធម្មតា យើងនេតល់គ្នាដែលទៅជាបុថុជ្ជន មិន
អាចយល់ច្បាស់ចាត់ថ្នុកន៏ប្រស្នា នេះឡើយ ប៉ុន្តែបើគិតទៅតាមស្មាម
លំអានយោបល់ព្រះអរហន្តហាក់ដូចជាព្រះអរហន្តដល់មរណភាពទៅមិន
មែនជាសូន្យឈឹងទេ ទើបលោកពោលថា ព្រះអរហន្តកូលនិព្វាន ឯ
ព្រះនិព្វាននោះ ជាស្ថានរំលត់ទុក្ខ ប្រកបដោយសេចក្តីសុខតែម្យ៉ាង
ដូចព្រះពុទ្ធភាសិតថា "និព្វានំ បរមំ សុខំ" ព្រះនិព្វានជាធម្មជាត
ប្រកបដោយសេចក្តីសុខយ៉ាងក្រៃលែង ។ មួយវិញទៀត ព្រះអរហន្ត
តែងយល់ថា ខន្ធ៥ជាភ្លុំទុក្ខ ជាទីប្រជុំកើតឡើងនៃទុក្ខ មានជាតិទុក្ខ
ជរាទុក្ខ ព្យាធិទុក្ខ ទន់ទីមរណៈទុក្ខជាដើម ទើបលោកឥតចិត្តចេញចាក
ខន្ធ៥ ឥតឧបាទាន ពិចារណាខន្ធទាំង៥ ឲ្យឃើញពិតតាមព្រះត្រៃ
លក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា ខន្ធ៥កើតឡើងហើយតែងរលត់ទៅវិញ
ជាធម្មតា ដូចទានសេចក្តីសាកច្ឆាវបស់ព្រះមហាសារីបុត្តត្ថេរនឹងយម-
កកិក្ខុ សំដែងទុកក្នុងសុត្តន្តបិដក គាថា ៣៣ ត្រង់ខន្ធសំយុត្ត មជ្ឈិម
បណ្ណាសក: ថេរវគ្គទី ៤ ចព្វ: ទី ១៩៨ មានសេចក្តីសង្ខេបថា:

តនឹងសម័យមួយនោះ មានតិត្ថមួយរូបឈ្មោះយមក: កើតមានទិដ្ឋិអាក្រក់ យល់ឃុលថា "អញ្ញដ៏ទៃក្រៅពីសន្ទនៃមិដែលព្រះដ៏មានព្រះភាគសំដែងហើយ ដូចជាព្រះចន្ទ ស្រឡាំងកាំងស្រស់ភ្លឺហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់ខាតសូន្យរំលាស់ទៅមិនត្រឡប់ទៀតទេ" ។ ឯតិត្ថតាំងខ្លួនយល់ដឹងច្បាស់ជាច្រើនបានដឹងច្បាស់នូវពាក្យនេះហើយ ក៏ចូលទៅរកយមកតិត្ថហើយសួរថា លោកយល់ថាព្រះចន្ទ ស្រឡាំងកាំងស្រស់ភ្លឺហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅរមែងដាច់ខាតសូន្យទៅមិនត្រឡប់ទៀត រមែងដូច្នេះទេ ? យមកតិត្ថក៏ឆ្លើយថា ខ្ញុំសុំណាយល់ហើយ លោកដូច្នេះមែន ។ ពួកតិត្ថតាំងនោះក៏យល់ឃើញថា ម្នាលអាវុសោយមក: លោកកុំពោលយ៉ាងនេះឡើយ លោកកុំពាល់ប៉ះបង្កាច់ព្រះដ៏មានព្រះភាគ ការពាល់បង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រោះព្រះអង្គមិនបានត្រាស់ថា តិត្ថ ជាឈ្មោះស្រឡាំងកាំងស្រស់ភ្លឺហើយខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់ខាតសូន្យ មិនត្រឡប់ទៀតយ៉ាងនេះទេ ។ ឯយមកតិត្ថក៏មិនយល់ព្រមតាមតិត្ថតាំងនោះឡើយ ទៅតែប្រកាន់តាមយោបល់យល់ឃើញរបស់ខ្លួនដដែល ពួកតិត្ថតាំងនោះក៏មិនអាចរាំរាស់ស្រាយដូចម្តេចតទៅទៀតបាន ទើបនាំគ្នាទៅទីមុខព្រះសាស្តាត្តេ ឲ្យរំលេកជួយនិយាយពន្យល់ រាំរាស់ស្រាយសេចក្តីយល់ឃុលរបស់យមកតិត្ថផង ។ ទើបព្រះ

សារីបុត្តត្ថេរោ ទេសូរព្រះយមកគគ្គិកថា ម្នាលអាវុសោយមក: លោក
មានសេចក្តីយល់ឃើញ មានសភាពដូច្នេះពិតមែនឬ? ។

យមក: ម្នាលអាវុសោ យ៉ាងហ្នឹងមែនហើយ ។

សារីបុត្ត ម្នាលអាវុសោយមក: លោកសំគាល់សេចក្តីនោះដូច
ម្តេច រូបខៀនឬមិនខៀនទេ ។

យ. មិនខៀនទេ អាវុសោ ។

សា. ចុះវេទនា សញ្ញា សង្ខារ វិញ្ញាណ តើខៀនឬមិនខៀនទេ ។

យ. មិនខៀនទេ អាវុសោ ។

សា. ម្នាលអាវុសោយមក: លោកសំគាល់សេចក្តីនោះដូចម្តេច
លោកពិចារណាឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាសត្វឬ ។

យ. មិនមែនដូច្នោះទេ អាវុសោ ។

សា. ចុះលោកសំគាល់ពិចារណាឃើញថា សត្វមានក្នុងរូប វេទនា
សញ្ញា សង្ខារ វិញ្ញាណ ឬ ។

យ. មិនមែនដូច្នោះទេ អាវុសោ ។

សា. ចុះលោកពិចារណាឃើញថា សត្វផ្សេងអំពីរូប វេទនា
សញ្ញា សង្ខារ វិញ្ញាណទៅឬ ។

យ. មិនមែនដូច្នេះទេ ។

สา. ចុះលោកគិតថាណា យើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណថាជាសត្វឬ ។

ឃ. មិនមែនដូច្នោះទេ ។

สา. ចុះលោកគិតថាណា យើញសត្វនេះថា មិនមានរូប មិនមានវេទនា មិនមានសញ្ញា មិនមានសង្ខារ មិនមានវិញ្ញាណឬ ។

ឃ. មិនមែនដូច្នោះទេ ។

สา. ម្នាលអាវុសោ ឯងកុ: តាលបើលោកតំណាត់សត្វថាទៀងថាពិត ក្នុងបច្ចុប្បន្ននេះហើយ ទើបគួរលោកនោលថា អញដឹងច្បាស់នូវធម៌ដែលព្រះជាម្ចាស់ព្រះគោតសំដែងហើយ ដូចជាព្រះវណ្ណ ស្រេច តែទំ. លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងជាប់មាតសូន្យទៅ មិនតែតទៀតទេដូច្នេះឯង ។

ឃ. ម្នាលអាវុសោ សារីបុត្ត តាលព័ដើមខ្ញុំមិនដឹងថា ទិដ្ឋិរបស់ខ្ញុំនោះជាទិដ្ឋិខុសអាត្រកំរ៉ាទេ តែឯ្ឍនេះខ្ញុំលះបង់ទិដ្ឋិកាត្រកំរ៉ានោះហើយ ត្រាះបានស្តាប់ព្រះធម្មទេសនារបស់ព្រះសារីបុត្តដ៏មានអាយុនេះ ម្តួយវិញទៀត ខ្ញុំក៏បានសម្រេចធម៌វិសេសផងហើយ ។

สา. ម្នាលអាវុសោ យកុ. បើឥនភាំងឮយ៉ាគេសួរលោកហើងនេះថា ម្នាលអាវុសោ តិក្ខឯណា ជាព្រះអរហន្តទំណា ស្រេច តិក្ខ

នោះខំណាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅនឹងកើតទៀតឬ
ដូច្នេះ តើលោកគប្បីព្យាករដូចម្តេចទៅ ។

ឃ. ម្នាលអាវុសោ បើមានគេសួរខ្ញុំយ៉ាងនេះ ខ្ញុំគប្បីព្យាករថា
ម្នាលអាវុសោ រូបមិនទៀងទេ រូបឯណាមិនទៀង រូបនោះជាទុក្ខ រូបឯ
ណាជាទុក្ខ រូបនោះរលត់ទៅ ដល់នូវសេចក្តីវិនាសទៅ ឯវេទនា សញ្ញា
សង្ខារ វិញ្ញាណ ដែលមិនទៀងជាទុក្ខក៏រលត់ទៅ ដល់នូវសេចក្តី
វិនាសទៅដែរ ។

ង. ម្នាលអាវុសោយមកៈ ត្រូវហើយៗ ខ្ញុំនឹងធ្វើសេចក្តីឧបមាឲ្យ
លោកស្តាប់ ដើម្បីឲ្យសេចក្តីនោះច្បាស់លាស់ឡើងទៀត ។

ម្នាលអាវុសោយមកៈ ដូចជាគហបតីឬបុត្រគហបតីជាអ្នកមាន
ទ្រព្យសម្បត្តិស្តុកស្តម្ភ ប្រកបដោយការការក្សាខ្ជួនយ៉ាងមាំមួន ពេះបើបុរស
ណាមួយមានទ្រាថ្នាចង់សម្លាប់គហបតីឬគហបតីបុត្រនោះ ក៏គិតត្រិះរិះ
យ៉ាងនេះថា គហបតីឬគហបតីបុត្រនេះ ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ
មានការការក្សាខ្ជួនមាំមួន អញមិនងាយនឹងទៅសម្លាប់គេបានទេ ដូច្នេះ
មានតែអញចូលទៅនៅបំរើ ធ្វើឧបាយល្បួងលួងលោមឲ្យបានស្និទ្ធស្នាល
ចិត្តគ្នាសិនសឹមសម្លាប់ បុរសនោះចូលទៅសូមនៅបំរើគហបតីឬគហបតី-
បុត្រនោះ ប្រព្រឹត្តជាទីគាប់ចិត្ត ពោលតែពាក្យជាទីស្រឡាញ់ពេញ
ចិត្ត ឯគហបតីឬគហបតីបុត្រ ក៏ជឿទុកចិត្តថា បុរសនោះជាមិត្តល្អដែរ

ជាអ្នកមានចិត្តល្អដែរ តែមានសេចក្តីស្និទ្ធស្នាលនឹងបុរសនោះ លុះវេលាត្រឡប់មកគេហបតីឬគេហបតីបុត្រ តែពុំនៅក្នុងទីស្ងាត់ បុរសនោះក៏សម្លាប់គេហបតីឬគេហបតីបុត្រនោះ ដោយសស្តាប់មុត ។

ម្នាលអាវុសោ យមកៈលោកសំគាល់សេចក្តីនេះដូចម្តេច កាលដែលបុរសពួលទៅសូមនៅជាមួយគេហបតីឬគេហបតីបុត្រក្តី វេលាធ្វើការជាទីគេញ៉ាំចិត្តក្តី វេលានៅក្នុងទីស្ងាត់ក្តី ក៏គប្បីតគេហបតីឬគេហបតីបុត្រនោះមិនដឹងថាបុរសនេះជាអ្នកសម្លាប់ខ្លួនដូច្នេះមែនទេ ។

យ. ត្រូវហើយអាវុសោ ។

សា. ម្នាលអាវុសោ បុថុជ្ជនអ្នកមិនចេះដឹង មិនគប្បីឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនគប្បីឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ រមែងមើលឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួនខ្លះ ឃើញខ្លួនថាមានរូប វេទនា សញ្ញា សង្ខារ វិញ្ញាណខ្លះ ឃើញរូប វេទនា សញ្ញា សង្ខារ វិញ្ញាណក្នុងខ្លួនខ្លះ ឃើញខ្លួនក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណខ្លះ ។ បុថុជ្ជននោះរមែងមិនដឹងច្បាស់តាមសេចក្តីពិតថា រូប វេទនា សញ្ញា សង្ខារ-វិញ្ញាណ មិនទៀងជាទុក្ខមិនមែនជាខ្លួនមានបច្ច័យតាក់តែងឡើង រមែងមិនដឹងច្បាស់នូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអ្នកសម្លាប់ខ្លួនឯង ។ បុថុជ្ជននោះរមែងចូលទៅប្រកាន់ខ្លាប់ នូវរូប វេទនា សញ្ញា

សង្ខារ វិញ្ញាណ ថាជារបស់អញ ។ ចាក្ខន្ធទាំង ៥ នេះ ដែលបុថុជ្ជន ចូលទៅប្រកាន់ខ្ជាប់ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីជាទុក្ខ អស់កាលជាអង្វែង ។

ម្នាលអាវុសោយមក: ឯព្រះអរិយសាវ័កជាអ្នកបេះដ៏ឆ ខ្ជាប់ចាន ឃើញពួកព្រះអរិយៈ ឈ្មោះសប្បុរិសក្នុងអរិយធម៌ ជ្ជាប់ចានឃើញពួកសប្បុរស ឈ្មោះសប្បុរិសក្នុងសប្បុរិសធម៌ រមែងមិនឃើញ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន មិនឃើញខ្លួនថា មានរូប វេទនា សញ្ញា សង្ខារ វិញ្ញាណកន្លងខ្លួនក្តី មិនឃើញខ្លួនកន្លងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្តី ។ អរិយសាវ័កនោះ រមែងដឹងច្បាស់តាមពិតថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនទៀងជាទុក្ខមានបច្ច័យតាក់តែងឡើង ។ ដឹងច្បាស់តាមពិតថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ហ្នឹងឯងជាអ្នកសម្ងាប់ ។ អរិយសាវ័កនោះមិនចូលទៅជិត មិនប្រកាន់ខ្ជាប់ មិនតាំងសេចក្តីប្រាថ្នារូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួនរបស់អញ ។ ចាក្ខន្ធទាំង ៥ នេះ ដែលព្រះអរិយសាវ័ក មិនចូលទៅជិត មិនប្រកាន់ខ្ជាប់ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ។

ឃ. ម្នាលអាវុសោសារីបុត្ត កាលសិតចំនួនដ៏នេះមានជាល់លោកដ៏មានអាយុទាំងឡាយឯណា លោកដ៏មានអាយុទាំងនោះចានឈ្មោះថាជា

សត្រហ្មចារី ជាអ្នកអនុគ្រោះ បង់ឲ្យបានប្រយោជន៍ ជាអ្នកឲ្យទុក់ជាអ្នកប្រុងប្រយ័ត្ន (ឥឡូវ) ចិត្តរបស់ខ្ញុំបានរួចផុត ស្រឡះចាកអាសវៈទាំងឡាយ មិនប្រកាន់មាំ (ដោយទុក្ខាពាន) ព្រោះបានស្តាប់ព្រះធម្មទេសនា របស់ព្រះសារីបុត្តដ៏មានអាយុយ៉ាងនេះឯង ។

ចប់សេចក្តីបុច្ឆាវិសជ្ជនា របស់ព្រះថេរៈទាំងពីរប៉ុណ្ណេះ យើងគិតពិនិត្យ តាមដំណើរធម្មសាកច្ឆាដែលគោលមកនេះ នឹងឃើញថាបន្តិចយល់ បន្តិចស្តាប់ចន្លិច ប៉ុន្តែល្មមឲ្យមើលឃើញដំរុយដែលនៅឆ្ងាយលម្ខឹមនោះបានខ្លះហើយ ទុកជាមិនច្បាស់លាស់ គំល្មមឲ្យយល់បានថា យោបល់របស់ព្រះអរហន្តមែងផ្ចុយនឹងយោបល់របស់បុថុជ្ជនជាដរាប សម្បត្តិសួគ៌នឹងសម្បត្តិមនុស្សរោកដែលប្រកបនឹងគុណទាំង ៥ ប្រការជាដើម បុថុជ្ជនតែងយល់ថាជាគួរសុះសប្បាយ ស៊ីឆ្ងាច្ចាចង់បានកាល់គ្នា តែព្រះអរិយៈយល់ថាជាគួរទុក្ខ មិនខ្វែងមានសេចក្តីប្រែប្រួល មិននៅក្នុងអំណាចរបស់បុគ្គលណាមួយឡើយ បច្ច័យតាក់តែងឲ្យកើតឡើងហើយ ក៏ប្រែប្រួលលេត់រលាយបាត់ទៅវិញជាធម្មតា មិនផុតអំពីជាតិ ជរា ព្យាធិ មរណៈទៅបាន ដើមគួរខ្លឹយណាយគួរស្អប់ខ្ពើមគួរលះបង់ទាំងអស់ មានតែព្រះនិព្វានមួយទេ ដែលជាសុខដ៏ពិតប្រាកដខ្វែងពាត់មិនប្រែប្រួល រកអ្វីប្រៀបផ្ទឹមគ្មាន ។ (ឱ. ធ.)

តាំងជាសមាជិកតំណាងសេសសព្ទីពីរវ្រះ

នៃសាលាចាក់ដែងសែសនៅបុរីបូតាប្រទេស

តាមប្រកាសលោកឧត្តមនាយកនៃប្រទេសឥណ្ឌូស៊ីន ចុះថ្ងៃ ២៧ មីរ្យ ១៩៤៣ តាំងព្រះមហាថេរៈពីរវ្រះជាសមាជិកតំណាងសេស របស់សាលាចាក់ដែងសែសបុរីបូតាប្រទេសគឺ:

ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ ជួន - ណាត, ជាគ្រូគង្វាលសាលាឡើងខ្ពស់ ។

ព្រះតេជព្រះគុណព្រះសាក្យវង្ស ហួត - ពាត, អាចារ្យបង្រៀនសំស្ក្រឹត នៅសាលាជាលើងខ្ពស់ ។

*

* *

អ្នករាជការនៅក្រសួងពុទ្ធសាសនបណ្ឌិត្យ

ចាន់ទទួលព្រះរាជទានបណ្ណាស័ក្តិ

តាមព្រះក្រឹត្យលេខ ២៥ ចុះថ្ងៃ ៥ មីរ្យ ១៩៤៣ ព្រះចៅសង្គមព្រះនរោត្តម- សីហនុរ៉ាជ ព្រះចៅក្រុងកម្ពុជាធិបតី ទ្រង់ព្រះករុណាប្រោសព្រះរាជទានបណ្ណាស័ក្តិកិត្តិយស ដល់អ្នករាជការ ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ ដូចមានតាយឈ្មោះខាងក្រោមនេះគឺ:

១- លោកហ្លួង យ៉ៀន - ចឹម, ជាគង្វាលរង ជាទីព្រះនាយកមន្ត្រី ស័ក្តិ ៦ ហ៊ូពាន់ ។

២- លោកស្មៀន តង់ - ជា, ជាទីហ្លួងរតនាធុរន្ធរ ស័ក្តិ ៥ ហ៊ូពាន់ ។

៣- លោកស្មៀន អ៊ុង - ស្បោង, ជាទីបេនសុខុមប្រជា ស័ក្តិ ៤ ហ៊ូពាន់ ។

៤- ព្រះលេខាធុរ៉ែត ឈួយ - តឹក, ជាទីឧកញ៉ាលេខាធុរ៉ែត ស័ក្តិ ៣ ហ៊ូពាន់ ។

ភម្ពុជសុរិយា សូមទទួលអំណរស្មោះត្រង់ សូមជូនពរសព្វសាធុការ សូមឲ្យអស់លោកជានច់រើនបុណ្យស័ក្តិជាភ័ស្តុភាពឡើងតទៅ ។

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនធំពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ កៅ-សុីម អ្នកត្រួតត្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

មាតិកា

		ទំព័រ
ផ្នែកអក្សរសាស្ត្រ		
ព្រះអាចារ្យ ញ. សៀង	បម្រែងទេព្តារបស់បញ្ចសិខទេវបុត្រ (ទេព បម្រែងនៅស្ថានត្រៃត្រឹង្ស)	២៤៩
ឃុនធំពន្ធមន្ត្រី ញ៉ុក-ថែម	រឿងកុណបបែលិន (តមក)	២៥៥
អ្នកឧកញ៉ាវេស្ថាវិនិច្ឆ័យកែវ-ហង្ស	រឿងប្រដៅចិត្ត (ពាក្យកាព្យ តមកនិងចប់) . .	២៦០
	រឿងត្រែងខ្មែរ: រឿងចៅធុងចៅសេញ (តមក និងចប់)	២៨៥
ផ្នែកសាសនា		
	ប្រជុំឧហាសន្តិបាតនៃពុទ្ធសាសនបណ្ឌិត្យ . .	៣០១
	ដំណឹងបុណ្យបញ្ចុះសីមានៅវត្តខ្ចាស់	៣០៧

ឆ្នាំទី ១៥ — លេខ ៥ ប្រចាំខែមេសា ១៩៤៣ ។ ដំណែ្លជាវ: ១ ឆ្នាំ ១០ រៀល ។

KAMBUJASURIYĀ

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Khoun Nibandhamantri Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Kao-Sim, Surveillant général de l'Ecole Supérieure de Pāli.

TABLE DES MATIÈRES

Partie littéraire

		Pages
Vénérable Nu. Sœung....	Le chant céleste du Pañcasikha (Dieu chanteur des Traitrimsa).....	249
Khoun Nibandhamantri Nhok-Thèm...	Kolap — Pailin. Roman (suite).....	255
Oknha Chesdavinichay Kèo-Hang.....	Pradaochet, poème (suite et fin).....	270
	Conte populaire cambodgien inédit : A Thoung — A Sanh (suite et fin).	285

Partie religieuse

	Assemblée générale de l'Institut Bouddhique.....	301
	Fête des Sèma dans diverses pagodes.	307

15e année — N° 5 Mai 1943 — Abonnement: un an 10$00.

ចម្រៀងបញ្ចសិខគន្ធព្វទេវបុត្រ

អាចារ្យ ញ. សៀង គ្រុមដំនុំព្រះវិត្រៃបដិភាណវត្តសាសនបណ្ឌិត្យ

ដកស្រង់អំពីសក្កបញ្ហាសូត្រ សុត្តន្តបិដក ទីឃនិកាយមហាវគ្គ ភាគ១៧

មករៀបរៀងជាភាសាកាព្យ

ព្រហ្មកិត្តិ

កាលដែលព្រះជិនស្រី ទើបត្រាស់ប្តីហើយចមកភព សម្រេចសម្រាក
ឈប់ គង់ក្រោមម្លប់អជបាល- និគ្រោធដ៏ត្រៃឈៃ នៅក្នុងវិព្រៃគួរ
ត្រអាល ទីនោះចាត់តាមកាល ហៅសប្តាហៈទីប្រាំ ។ ទ្រង់សោយ
រសវិមុត្តិ វិសេសផុតចាកកង់កម្ម កំលេសដ៏សាហាវ ដែលដេកគ្រាក្នុង
ហឫទ័យ ។ តីរសព្រះនិព្វាន ដ៏ជាឋានឥតទុក្ខភ័យ ហៅសុខវិសេនប្រពៃ
ខ្លៃឋតល់ថ្ងៃនោះឯងណា ។ គ្រានោះទេវបុត្រ បរិសុទ្ធមានឈ្មោះថា
"បញ្ចសិខគន្ធព្វា" ឋិតនៅនាគវត្តីន្ទ ។ ជាអ្នកស្ទាត់កង់វិស្សង គួរក
កំប្លែងដ៏រីរឹងប៉ឹង ពួកទេពទទួលដឹង ស្គាល់ថាជាអ្នកចំណាន ។ ចំណាប
កង់សួគ៌ គ្មានអ្នកណាប្រៀបធៀបបាន ខាងការលេងតំសាន្ត លំហែ
ប្រាណសព្វកាល ។ គន្ធព្វទេពនោះឯង ចិត្តចំប្រែងតាមបណ្តាល
តំបន់លេងគ្រសាល ត្រែកត្រអាលទីឆ្ងាំឆ្ងា ។ នៃតិម្ពរុក្ខជ មាន
អំណាចដ៏ក្លៀវក្លា ឈ្មោះខាងសុរិយោ វច្ឆសាប្រសើរសោយ[1] ។ តែនាង

---

១ ដែលតាមតិតគឺ "សុរិយវច្ឆសា" ប៉ុន្តែបានដាស់សរសេរថា "សុរិយោ វច្ឆសា" ដូច្នេះ ព្រោះ
លៃឡូត្រូវនឹងសម្ផស្សកាព្យ: ឈ្មោះនេះបានសេចក្តីថា "មានរស្មីភ្លឺរាយចេញតាំងអំពីពុងដើង
ឡើងទៅដល់ចុងសាខា ហាក់ដូចជារស្មីព្រះអាទិត្យដ៏ស្រែទន់" ។

មិនវាល់ មិនត្រមយល់ប្រតល់តាយ ធ្វើឫកហាក់ឮយណាយ ព្រោះ
ឱមថាយនាងជាប់ចិត្ត ។ ស្រឡាញ់ប្រុសដទៃ ឆើតប្រពៃគួរស្នេហ៍
ស្និទ្ធ មានឈ្មោះជាក់តែ "សិទ្ធិណាទេប្អូនត្រី" ។ ជាតួនមាតល់ សារថិ-
បរិសុទ្ធ ទៅហានប្រសើរផុត គឺតែតែងស្រស់ប្រពៃ ។ ឧកជាបញ្ហសិទ្ធ:
តន្ធព្វ:រិតតែល រកកលផ្សេងដទៃ ដ៏ប្រពៃមកចែចង់ ។ នាងនៅតែ
មិនដោយ មិនត្រមឲ្យប៉ះដល់អង្គ មិនជាកកក្តែតម្រង់ ចំពោះតែងំតិច
ភ្លេចសោះ ។ ទើបតួក:ទេពតន្ធព្វ កាន់ពិណគាប់ដោយចិត្តស្មោះ តគាត
ចូលចំពោះ កាន់សំណាក់នៃបរមេ ។ តិម្ពរុក្ខជបិតា លើកហត្ថាឡើង
ប្រណម្យ តែឡៃពិណឲ្យសម ទើងសំឡេងបានខ្លួន ។ ហើយតាំង
ផ្តើមចម្រៀង ដេញពិណប្រឡែងឡើងតែអួន សម្រែបប្រែកបជួន ចែចង់
ខ្លួនកន្ធង្ហា ។ ពាក់ទងដោយព្រះពុទ្ធ ព្រះធម៌សុទ្ធព្រះសង្ឃថ្លា ចម្រុះ
លាយតាមា ដោយវាចាថាដូច្នេះ ។

ពាក្យទ្រាបួន

ហៃសុប្បាវច្ឆសាធីតារម្យ !

រៀមសូមទុនលំទោនតាយថ្វាយបង្គំ ដល់ទ្រព្យបិតាធំនៃកញ្ញា ។
ឱមទឹមខ្លួនស្ទួនមាសឆ្អឺនឆ្អុំភ្លឺនសាយ នាងមានតាយផ្ការយពន្ធឺក្លិនផ្កែកថ្នា
តត្តែផ្លូវផេងធំធើមូលកុំសមនាសា ចាំងបុខាហាញញឹមស្រស់ប្រឹមប្រិយ ។
សក់ឡេីយដំខ្ចង់ផ្ទៃនះផ្ទៃលៅរៀបភ្លេា កង្ការាញ់ផ្ទួញអង្គុញខ្ទុំខ្ទង់ពីស

បើតណ្ហាណាបានមកបង្គែតកន្លង ព្រមបើតសិរីបិតចិត្តឥតអាត់ ។ ដូចដើរ
ផ្លូវត្រែវតំណៀសុបសៅខ្លួន ស្រែតនឹតធ្លួនដួនប្រុះស្រែតជាក់ ត្រែតអារ
ក្តាត់ចាត់ចារម្តក្រែថ្នាំងថ្នាក់ តាស្រ័យជាត់សំណាក់ស្រួលឥតរួលអន់ ។
ឬដូចជាញាយនបំលែងញ៉ាំញាប់(១) ជាទីតាប់ដាប់ហប្ញទ័យនៃអហេន្ត
បើបង្គែបានហានរួមកែស្មុំគ្រែនឹងតន់ ទើបានស្រែនអន់សាម្រែតស្រែក
ក្នុងថ្ងៃណា ។ បង្គែកហាល់ខ្លាំក្រែហាយតាយចំប្រែប ស្រែរសន្ធប់ថប់ឧក
ណាតណ្ហាណា សូមនាងសួយជួយដំរែតតិតឲ្យបាន ចូរក្នុងថ្ងៃណាក្សត្ត
ខ្ពុតតំនាំរំនើអនេក ។ រៀមសូមអែបនែបនៅខិត្យដំតថនា នៃតញ្ញាថ្នា
វែលក្ខណ៍តក្រែលួងឯក សូមក្រែមុំកុំខេវខ្ញីងប្រែងប្រែតែក សូមវែលតបែក
ដាក់តានមានផលា ។ បង្គែងាងងឹងប់ខប់មិនបានថ្ងៃណាក្សត្តៅ ត្រែវតែ
ស្តៅតៅនាងណ្ហសក្តីថ្នា ដូចដំរីក្តីចុះត្រែងវែងត្មោចផ្សា ដោយតណ្ហាក្នា
តង់ចិត្តឥតតិតស្ងប់ ។ ចិត្តរៀមងប់សីប់លើស្តួចន្លួនស្នេហ៍ស្ងួន រឹងប្រកិត
រឹតប្រកាន់មាំនាំចំណាប់ ដកមិនរួចតួចយ៉ាងស្អិតចិត្តត្រឡាប់ ហាក់ដូច
ផ្កាប់ស្លាប់រាបាំណាស្រែតៅ ។ ដូចជាត្រែតីសន្ធួចខ្លួចតាំងថ្ងៃណា ដោះ
មិនបានច្រានមិនក្លាត់ជាប់មាត់ផ្តៅ ដូងចិត្តបង្គែប៉ងផ្តួចផ្តួចន្លួនធោមផ្តៅ
ច្រានមិនចៅទៅមិនស្រៀមរៀមខ្លួនក្តា ។ នែធោមធាយតាយសសូល
បណ្តូលចេត ចូរត្រែឡែតត្រែតត្រែតង៉ុបបង្គែក៏ តារឧបរែតពិតជាបង្គែប៉ង
ច្រែថ្នា សូមដឹក់កុំថាម្តួចហើយគេចចេញ ។ កាមនៃបង្គែបង្គែចិន្តាឥតក្លាក់

---

១ ព្រះនិព្វាន ។

តែស្តួនក្សត្រិយសមស្រេចទ្រង់ទ្រលន់ពេញ បែរជាប្រែនកើនចំណែកបែកចំណេញ នាំជនទ្វេញពេញជន្ទឹងវែចិត្ត ។ ដូចជាគានមានតិចតួចស្តួចស្តើងទេ ប៉ុន្តែគេរវេងនិតតិតសុចរិត ឲ្យដល់លោកគោកកិលេសវិលេសសិទ្ធ ផលនោះពិតតែចំណេញពេញខ្លួលាយ ។ ឧទ្ធំមទ្ធនន្ធនពិសិស្តែចំខ្លែក រួចល្អងឯកថ្លែកសង្ឃាថ្នាំឆើតនាយ បុណ្យគ្រាស់វែកលែងលងធ្លើលើហានអាយ តែបែកចាយថ្នាយដល់ព្រះឈ្នះតណ្ហា ។ បុណ្យនោះនៃនៃតជំនួយដួយឲ្យបាន ចួចកល្យាណគ្រាណជំនិតជិតអាយ កុំឲ្យស្ទ្រើងស្ទ្រៀងចំណង់ចង់អាសា ចំណាចំហាថាស្រឡាញ់ឃ្លាញ់តម្រង់ ។ ព្រះវិនិតថ្នូរិស្ទួនផុតថ្នឹងថ្នែង ទ្រង់ប្រឹងវែងស្វែងនិព្វានភេទធូរធង់ មិនគិតមាយណាយល់ឃាតយ៉ាកដល់អង្គ ព្រះទ័យត្រង់ជ្រង់ចំពោះនោះយ៉ាងណា ។ រីទ្ធនបង់ប៉ង់បណ្តូលហើយចូលមក ប្រឹងស្វែងរកតន្ត្រកស្ទួនទ្ធនបុប្ផា សូមឲ្យបានច្រាណានៃបទនិត្យដំនាំតា ត្រែតតណ្ហាសេយ្យាខាងយ៉ង់នោះឯង ។ បើទ្រមមព្រមមូលមិត្រស្ងួនស្នេហ៍ស្និទ្ធ សមបំណងបង់ច្រាថ្នាណាចំភ្លែង រៀមអរតេកៈត្រែតត្រអាលអស់កាលវែង ផុតចំមែងវែងជាសុខស្រណុកកៃ ។ ដូចព្រះពុទ្ធធុតង្គលេសវិសេសសាលទ្រង់ត្រអាលត្រសាលធ្យានទ្រង់ញាណាញ្ញ ឥតមានទុក្ខរុកប្រជ្រែតបៀតព្រះជ័យ លែងមានភ័យជ័យជំនះឈ្នះឥតសល់ ។ ប្រសិនណាជាកោសិយសិរីថ្នូ[1] ឲ្យតាពិតតិតសម្រាំងតាំងដំកល់ បើកឲ្យបង់ប៉ង់

---

๑ ក្រែងដំនួ ។

ទឹមន្លួនស្ងួនទឹម្ចាស់ បងវែងខ្លាំងអំពាល់ចិត្តតិតពុក្កា ។ ហៃកល្យាណ
មានរូបឆោមរលោមឆាណិឆើត ពងរៀសើតកើតជាស្រីស្មើថ្លា រៀមសូម
ទុនលំនោនតាយ៉ាយវន្ធា ដល់ចិតាប៉ាអនុដ្ឋគ្រលុចលន់ ។ ដែលខបមា
ដូចវុក្ខាមានផ្កាស គ្រអូបល្អដ៏តាប់ចិត្តឥតតិតគន់ ពួកអ្នកផងប៉ងតម្រែក
គ្រែកំពេកពន់ ណាស្តុតល្ងន់សម្ផស្សទន់ខ្លែនន៎ើយ(១) ។

ភ្លុងឆ្លងលីលា

កាលបើតន្ត្រីពួរឆើតឆាយ ច្រៀងដោយលៃបទាយ យ៉ាងនេះចប់
ហើយ ។ សូរ្យាធីតាគ្រាណាត្រៃយ ខានពុំកន្ត្រើយ ព្រងើយដូចមុន ។
បែរជាស្រឡាញ់សិប់ស៊ុន ចំពោះរូបឃុន ភ្លុកខេតតន្ត្រីពួ ។ ដូចចិត្តនៃ
នាងញ៉ាញាប់ ស្រពោនស្រពាប់ ដោយតាមមកគា ។ ទើបនាងញាញឹម
ភក្ត្រា ញ៉ឹកញ៉ាក់ឆ្លើយថា ហៃបងដំទិត ។ អ្នកបងចេះច្រៀងពេកពិត
លួងលោមដួងចិត្ត នៃប្អូនពិសី ។ ចេះតែងតែចងសំដី ចម្រៀងបែបថ្មី
ប្រកបតម្រូវ ។ ព្រះពុទ្ធព្រះធម៌ជាផ្លូវ ព្រះសង្ឃត្រឹមត្រូវ ភ្លូវលាយ
តាម ។ ចាស់តែប្អូនស្រីដោយតាម ឆ្លាក់ចិត្តចុះស្នាម កិលេសតណ្ហា ។
នុះទុអ្នកបងថ្លៃថ្លា ព្រះពុទ្ធនោះណា មិនដែលជួបភក្ត្រ ។ កាលខ្ញុំឯ
សេងរួមរ័ក ពុំតងសំណាក់ ពេងសុធម្ម ។ ក្នុគេសរសើរកេលគ្នា ថា

---

១ លុះចំណេរមកខាងក្រោយ, កាលដែលព្រះសម្ពុទ្ធគង់នៅក្នុងឥន្ទសាលគុហាដ៏តភ្នំវេទិយក:
ខាងកើតក្រុងរាជគ្រឹះ ខាងជើង ព្រាហ្មណគ្រាមឈ្មោះអម្ពសណ្ឌ: ក្នុងនៃនគរនេះបញ្ចសិខគន្ធ
ទេវបុត្រ ជាឧយកបម្រៀងនេះទៅច្រៀងថ្វាយព្រះអង្គ ដោយទទួលបំរើរបស់សក្កទេវរាជ ។

ព្រះគតាគ ប្រសើរបំផុត ។ ជាទ្រាថ្មធំគាចចំហុត ព្រះកាយបរិសុទ្ធ
បពោញស្មើ ។ ទៃបធំកុំខ្ចែងសំដី ដូចខ្ចះប្អូនស្រី ឥតចិប្រែតែក ។
ប្អូនមិនក្បាច់តិតកវែក ចូរប្រុសល្អឯក- ចួបគ្នាថ្ងៃនេះ ។ តម្ងំពូមានតំភ្ញ
ថាអេះ អើហ្ន៎ឆ្ងល់ហៅចេះ ស្តាប់សូរបេម្រឹង ។ បំណងដែលបងច័ងខ្ញើង
តិតឥតឃ្លាតឃ្លើង តែងំខ្ញឹងហើយគៅ ។ ថាហើយញញឹមចូលទៅ
អែបនែបនិត្យនៅ ក្បែរពៅសូរ្យា ។ ទុនទុបក្រសោបជីវា ព្រឺព្រួច
អាត្មា ហាក់ដូចក្រឡាប់ ។ សម្លឹងស្រួប្រុសស្រីចំណាប់ តែប៉ះពាល់
ម៉ាំប់ ក្រឡាប់ក្នែកកែល ។ ក្នែកក្តីពៅជាក្នែកត្រែល មៀងមើលម៉ែលម៉ែល
មិនចប្រាស់ទេណា ។ ចំណង់ដើមសម្លឹងស្រួថ្លា នៃតួកទេព្តា យ៉ាងណាពៅ
អេះ ។ ល្ហើយប៉ុនខ្ញុំសូមឈប់ស្ងេះ បញ្ចប់ត្រឹមនេះ អស់អាថិះសេចក្តី ។
ខ្ញុំទៅបន្ទឹងរៀនតែងថ្មី សូមពួកកវី កុំបញ្ចាញាមាត់ ។ បើឃើញមាន
ខុសភ្លាំងភ្លាត់ សូមជួយផ្តៀងជ្រាត់ តម្រង់ឲ្យទាន ។ មួយទៀតខ្ញុំធ្វើ
ចំរោង ទៅលើតាក្សគ្នាន ទៅក្នុងព្រះសូត្រ ។ លើសខ្វះតិចតួច
ព្រោះច្រែត កាត់លៃសម្រួត សម្រួលឃ្លាកាព្យ ។ សូមកុំឲ្យខ្ញុំមាន
ចាប ភាគ្រក់ឆ្លុះឆ្លាប ដាបដល់អចាយ ។ ព្រោះខ្ញុំឥតមានកែវងាយ
រៀនតែងចរិយោយ ដោយចិត្តជ្រះថ្លា ។ សន្ធតសង្ឃបកាព្យា ប៉ុណ្ណោះ
ឯងណា និដ្ឋិតចប់ហោង ។

វគ្គទី ២

ការធ្វើដំណើរទៅបប៉ៃលិន

ក៏ស្ទៀតពាក់សំលៀកបំពាក់ យួរកាំលិសចុះពីផ្ទះដើរសំដៅទៅផ្សារលែ
បំរុងនឹងទៅឡើងរថយន្ត ដែលដើរផ្លូវបាត់ដំបង-បប៉ៃលិន ។ ទៅចត្រ
ទិញសំបុត្រថ្លៃកន្ទែងរួចស្រេចហើយ ក៏អង្គុយចាំជាបដល់ពេលរថយន្ត
ចេញពីទីផ្សារត្រែងបាត់ដំបងទៅ វេលាម៉ោង ៦ ន៍ង ១៥ មីនុត្រែរថ
យន្តក៏បើកចេញសំដៅទៅទិសខាងត្បូង ដល់ទៅផ្សារកោស៊ុស្រាក៏បាត់
ត្រង់ទៅឯលិចតាមផ្លូវបប៉ៃលិន ទៅចិត្តអង្គុយមើលភូមិប្រទេសសងខាង
មកវិនោះ មុខគួរឱ្យស្រេងស្រេងោចអណ្តែតអណ្តូងកន្ធិចក្តីជាច់ខ្សែក
ណាស់ ទឹកដល់ខ្នុពុតដែលទើបអនិច្ចកម្មទៅថ្មីៗ គាលណា ទឹកក្អែកក៏
ដោរដន់ចេញមកឯង តែខំទប់ទល់មិនឱ្យទឹកក្អែកស្រែកចុះចាល់តែបាន-
ដើម្បីការពារកុំឱ្យអ្នកជិះរថយន្តជាមួយគ្នា មានសេចក្តីសង្ស័យមកលើខ្លួន ហើយបន្ទំនិយាយសើចលេងកំសាន្ត ជាមួយនឹងអ្នកជិះទាំង
អស់គ្នាទៅ ។

ឯផ្លូវដែលឡើងទៅស្រុកបប៉ៃលិន មិនសូវឆ្ងាយប៉ុន្មានពីត្រែងបាត់-
ដំបងក៏តិតមែន តែជាផ្លូវលំបាកបន្តិច ដ្បិតត្រែរបររថយន្តឡើងភាគច្រ

ន៏ឯសសៀតោមដ៏ឯកុំខ្ពស់ខ្លៅន៏ឯ ហើយគោឯបរបត់បែនដូចអន្ទង់អាំង ដកចដល់ស្រែកបប៉ែលិន ខុកជាបង្ខំយ៉ាឯណា ក៏គង់តែវេយន្តរត់មិនលឿន ហើសដូចផ្លូវកេបទេ ។ ចៅចិត្តក្រែឡេកមើលភូមិបែទេសតាមសង៏ខាងផ្លូវ សឹង៏ដេរជាសៅៗដោយស្រែចម្ការច្បារដំណាំ ន៏ឯភូមិស្រុកដោយតន្ទើ ឃ្លាតឆ្ងាយជាច់ពីគ្នា លុះជិតថ្ងៃដល់បប៉ែលិន ក៏ឃើញតែព្រៃព្រឹក្សាលតាវល្វីន៏ឯកុំតូច-ធំច្រែនអនេក ត្រមាំង៏សត្វបក្សាបក្សីន៏ឯសត្វដើរដើ ក៏មានកុះករណែនណាន់នៅតាមដង៏ព្រៃព្រឹក្សាអស់នោះ ។ ចៅចិត្តជ្ងាន ឃើញសត្វសត្វអស់នោះ ក៏កើតមានចិត្តសង្វែគនឹកលើកដល់ឪពុកកាន់តែខ្លាំង៏ខ្លៅន៏ ។ ស្ទើរតែនប់ខ្លួនក៏ក្អែកតុំជ្ងាន ។

លុះដល់វេយន្តបរបើកកាត់ព្រៃកុំកែថ្មដាច្រែនអន្ទើ វេលាមៅង ១១ ថ្ងៃត្រង់ វេយន្តក៏ជ្ងាន់ទៅដល់ទីផ្សារបប៉ែលិនដោយស្រួល ។ ចៅចិត្តចុះពីវេយន្តដើរទៅស៊ើបសួរកេផ្ទះហ្ងឺរតេនសម្បត្តិ ។ មានភូមាម្នាក់នៅទីផ្សារនោះចង្អុលប្រាប់ថា ផ្ទះហ្ងឺរតេនសម្បត្តិទៅឯណោះ ចម្ងាយពីទីផ្សារនេះទៅប្រហែល ៥០០ ម៉ែត្រ កែ្សរមាត់ផ្លូវខាង៏ជើង នៅក្បាង៏ទ្វារផ្ទះនោះ មានសរសេរយីហោថា "ផ្ទះហ្ងឺរតេនសម្បត្តិ" អញ្ជើញទៅចុះតង់ន៏ឯយើញមិនខាន ។ ចៅចិត្តក៏ចេញដើរទៅតាមពាក្យភូមានោះ ហើយទៅឈរកេរកេទៅមុខផ្ទះដូចមានឃើហាង៏លើនេះ មួយស្រែបក់មានភូមាម្នាក់ ចេញមកពីតង៏ភូមិនោះសួរថា "អញ្ជើញមកពេកអ្នកណា ?

ចៅចិត្តភ្ញាក់ព្រឺត ព្រោះពេលនោះកំពុងឈរមើលក្ងមដែរ ទេស
យ៉ាងក្តៅគគ្រឹន ស្រាប់តែក្រឡេកមកឃើញបុរសខ្មៅម្នាក់ ឈរសួរតែប្រ
ខ្លួនទើបប្រាប់ថៅថា "ខ្ញុំមករកលោកហ្នឹងវតនសម្បត្តិ តើហេតុនេះលោក
ទៅឬទេ ?

បុរសនោះឆ្លើយតបថា លោកនៅខាងលើផ្ទះ បើចង់ជួបនឹងលោក
អញ្ជើញមកតាមខ្ញុំ ហើយបុរសនោះក៏ដើរនាំមុខចៅចិត្តឡើងទៅលើផ្ទះ។

គេប្រាប់ឲ្យចៅចិត្តអង្គុយលើកៅអីមួយ ទៅកន្លែបន្ទប់ខ្លួលក្បែរ
ហើយដើរចូលទៅកន្លែបាត់មួយស្របក់ ក៏លេចមនុស្សចាស់ សក់ស្កូវម្នាក់
ដើរចេញមកដោយឫកពាអធិអាច ស្ទឹកសារុងសូត្រពាក់អាវខ្មៅ តាប់
តាមខំខ្មៀមអ្នកទៅផ្ទះ ពាក្យដំបូងដែលនិយាយនឹងចៅចិត្តនោះដូច្នេះថា
"កុយមកពីណា ? ត្រូវការជួបនឹងខ្ញុំមានការអ្វី ?

ចៅចិត្តសង្កេតដឹងច្បាស់ថា លោកនេះហើយដែលហៅថា ហ្នឹង
វតនសម្បត្តិដែលខ្លួនត្រូវការជួប ទើបរំលឹកខ្លួនចុះពីកៅអីលុតជង្គង់ គ្រាប
ចុះដោយសេចក្តីគោរពគួរសម ។

ឯហ្នឹងវតនសម្បត្តិជាអ្នកជំនួញលក់ក្បូង ដែលមានកេរ្តិ៍ឈ្មោះល្បី
ល្បាញក្នុងស្រុកបម៉ែលិន ក៏អង្គុយលើកៅអី ១ ចៅចិត្តសង្កេតតាម
ឫកពាបស់លោកនេះ យល់ថាជាអ្នកមានអធ្យាស្រ័យល្អចិត្តសប្បុរស
គួរជាទីគោរពកប់អានបាន ។

"ពានះថ្លៅសហាន" ចៅចិត្រធ្វើយដោយតុនលំពេនហើយថា "លោកត្រូវទៅស្អាតបានធ្វើសំបុត្រ១ ចម្លាមកជូនត្រះភក្ត្រគុណ"។

"អើ! ទៅស្អាតយខ្ញុំនោះឬ? លោកនិយាយចាំធ្វើញញឹម តាម ដោយលោកជាអ្នកមានអធ្យាស្រ័យតែកាយជានិច្ច ហើយសួរថា "សំបុត្រ នោះទៅឯណា?

ចៅចិត្រលូកដៃទៅកន្ទុយហោះជ្រាំ យកសំបុត្រនោះជូនទៅ, លោក ហ្គួនទទួលយកទៅមើលដោយសេចក្តីត្រេកអរ លុះមើលចប់ហើយ ក៏បែរ មកតិចារណាមើលសក្ខណៈចៅចិត្រម្តងទៀត ។

ហ្គួន- "តួយឯងនៃមែនទេថ្នាក់ណាះចៅចិត្រ ដែលទៅស្អាតបាន បញ្ជូនខ្លួនមកឲ្យខ្ញុំ?

ចៅចិត្រ- "ពានះថ្លៅស ខ្ញុំបាទនេះហើយ"។

ហ្គួន- "ប៉ុនតួយធ្វើការយ៉ាងនេះបានដែរឬ? អារបស់ខ្ញុំនេះវាធ្ងន់ណាស់ គោនត្រាំងដឹកដីតម្លៃ១ថ្ងៃ ៥-៦ ទៅងទើបសូរប្រុ រួចកងស្អាត បាតដូចថាតួយនេះ ខ្ញុំយល់ថាត្រាំទ្រូកវាមិនបាន។ ប៉ុន្តែខ្ញុំមុនជាតែខ្លះនៃវាហើយ!

"មនុស្សដទៃទៀតគេធ្វើបានយ៉ាងណា ឯខ្ញុំបាទតើក្លើបានដូច ជាគេដែរ សូមត្រះតួបត្រះគុណកុំត្រួយឲ្យសោ" ចៅចិត្រពាលក់ប់ផង យ៉ាងម៉ឺងម៉ាត់ ពាក្យនេះហើយដែលធ្វើឲ្យហ្គួនពេនសម្បត្តិ បានសេចក្តី

ឥតញញឹងចិត្តណាស់ ហើយរៀបចំត្រៃនិយាយតទៅទៀតថា "ខាងគ្រូសៅ មនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ មិនត្រូវប្រកាន់ការស្រាលៗស្រួលៗទេ ខ្ញុំបាទមិនដែលគិតដូច្នេះទេ តាលបើខ្ញុំបាទមានកំណាំដ៏ធំសំដែកបណា ខ្ញុំបាទនឹងចំធ្វើការដែកបនោះ" ។

"រៀបចំត្រៃ, អ្នកឯងនិយាយនេះត្រូវណាស់" លោកហ្លួងនិយាយសរសើរហើយថា "ល្អើយចុះ, ឯខ្ញុំតែងមានការសម្រាប់មនុស្សដែលចង់ធ្វើជានិច្ច រៀលនេះ អណ្តូងត្បូងខ្សាងកើត ខ្ញុំកំពុងឱ្យចាប់ធ្វើមជីតត្បូងមាងជាមួយអន្ទេ្ង ព្រឹកស្អែកនេះខ្ញុំនឹងបញ្ជូនអ្នកឯងឱ្យទៅធ្វើការនៅទីនោះ ធ្វើការក្នុងគ្រាដំបូងនេះ ខ្ញុំនឹងតាំងប្រាក់ខែឱ្យអ្នកឯងត្រឹម ៣០ រៀលសិន ប៉ុន្តែអ្នកឯងអាចបានប្រាក់ខែច្រើនជាងនេះទៀតបើចំយកចិត្តទុកដាក់ធ្វើការយ៉ាងមុឺងម៉ាត់" ។

រៀបចំត្រៃនឹកក្បាលគ្រាបចុះដោយសេចក្តីគោរពម្តងទៀត ហើយពោលថា "សូមអរគុណព្រះគុណជាខ្លាំងបំផុត ព្រះគុណដ៏ធំធ្ងន់ធ្វើខ្ញុំបាទឱ្យបានជាមនុស្សម្នាឯនេះឡើង ខ្ញុំបាទពេញចិត្តនឹងការដែលព្រះគុណប្រគល់ឱ្យធ្វើនោះដាច់ខាតបំផុត" ។

ក្នុងខណៈនោះ មានស្ត្រីស្បែកដើមលាន់ឮពីមាត់ក្រាមឡើងមកលើផ្ទះ ព្រមទាំងមានសំឡេងហ៊ោឯណាម្នាក់ចូលទំនាក់ទំនងមកពីខាងក្រោយ រៀបត្រៃក៏ចោលកែកក្រឡុកមើលទៅ ប្រទះឃើញកែកទាំងគូកំពុងតែសំ-

ឡើងចំត្រង់មក ជាដួងក្អែកប្រកបដោយគំកងម គួរជាទីចាប់ចិត្តស្នេហ៍តែមានប្តូរតាឆ្មើងឆ្មៃបន្តិច ក៏រំយោគិកខ្លក់ញ៉ែងញ៉ងល្អាសល្ងន់ល្ងណាស់ សម្បុរស្បែកសស្អាតមុខមូលក្រឡង់ដូចវង្វែរព្រះចន្ទ្រ សូរសំឡេងស្រស់ដូចសូរគ្រាំងប្លាក់ ដំណើរល្ងន់ល្ងាសដូចថ្លាកូលាបដែលត្រូវខ្យល់បក់ល្ងិច ។ នៅតណ្ណាលសួនចម្ការដូច្នោះ ឱ, ល្អអ៊ីម្ល៉េះ! នេះប្រហែលជាអញ្ញយល់សប្តិឃើញទេដឹង!!

លៅចិត្រក្លាក់ស្មារតីលែងសំឡឹងស្រឡាំងកាំង ក្នុងពេលដែលលោកហ្លួងស្រែកហៅកូនក្រមុំនោះឲ្យឡើងមកខាងលើផ្ទះ "មកឯណោះ, នារី, ថ្ងៃនេះ ប៉ាំបានមនុស្សចូលធ្វើការថ្មីម្នាក់ទៀត" ។

នាងក្រមុំនារី ឈានជើងឡើងជណ្តើរមួយ ។ ក្អែកសំឡឹងមើលលៅចិត្រដោយកិរិយាឆ្មើងឆ្មៃបន្តិច ដែលជាទំនៀមរបស់ស្រីក្រមុំប្រុសស្រស់ ហើយសួរទៅឪពុកថា "ប៉ា! នេះឬអ្នកចូលមកធ្វើការថ្មីរបស់យើង?

លោកហ្លួងញាក់មុខឆ្លើយហើយ ឯាកទៅនិយាយនឹងលៅចិត្រថា "លៅចិត្រ! នេះនារីកូនក្រមុំរបស់ខ្ញុំ" ។

លៅចិត្រលើកដៃសំពះសួរ នាងនារីងក់ក្បាលឆ្លើយតបវិញដោយកិរិយាឆ្មើង ។ តាមនិស្ស័យរបស់នាង ។ លៅចិត្រដឹងខ្លួនថា គាំងអំពីថ្ងៃនេះទៅ មុខជាត្រូវនាងក្រមុំប្រុសស្រស់នេះមាក់ងាយមាក់ថោកខ្លះជាមិនខាន ។

នាង៨នារី សំឡឹងមើលកម្មករថ្នាំបេះផ្កាពុក តាំងអំពីក្បាលរហូតដល់ចុងជើង មើលហើយមើលទៀត នៅទីបំផុតក៏លាន់មាត់ថា "កម្មករនេះ ស្គមដូចជាអ្នកញៀនអាភៀន ន៎ ឯងមានកំឡាំងដីកដាំបានឬទ្បាំ? កូនយល់ថាគម្រេងឲ្យធ្វើការលោងចានក្នុងផ្ទះបាយវិញជាជាង ?

ចៅចិត្តកាលត្រូវសើចក្បុំស្តីដាក់មុខដូច្នេះ ក៏នឹកអៀនខ្មាសណាស់ក្រឡេកចោលកន្ទុយភ្នែកទៅនាង៨មួយភ្លែតហើយតបទៅថា "មនុស្សគ្រង់គេមិនដែលសំគាល់ថាជាមនុស្សល្ងង់ ឯមនុស្សស្គមក៏គេមិនសំគាល់ថាជាមនុស្សខ្សោយដែរ ស្គមយ៉ាងនេះឬទ្បាទេ មានកំឡាំងខ្លាំងដូចជាមនុស្សជាត់មាំដែរ គ្រាន់តែមិនសូវមានសាច់ឈាមបរិបូណ៌ប៉ុណ្ណោះទេតើ!!

នាង៨នារីធ្វើមុខក្រញូវចំនង៨ចំបន្តិច ។ ផង ដោយនាង៨មិនឧកនាថាចៅចិត្តហ៊ានធ្វើយដូច្នោះសោះ ព្រោះមិនធ្លាប់មានមនុស្សណាមួយក្នុងភូមិហ៊ានឧយាយលេង៨សំដីកំហែងនាង៨ឡើយ ។

លោកហួង៨ឃើញកូន១ង៨ដូច្នេះ ក៏និយាយបញ្ជាប់ថា "ចៅចិត្ត! ល្អើយឈប់ស្ទុះប៉ុណ្ណឹង៨ចុះ ឯង៨កំពុង៨ឡើយហត់អស់កំឡាំង ទៅកេសម្រាកខ្លួន១ឲ្យបាត់ឡើយហត់សិន១ទៅ" ។

វគ្គទី ៣

ចៅចិត្តកើតគំនិតប្លឹ

តាំង៨ពីថ្ងៃនោះមក ចៅចិត្តក៏បាន១ធ្វើជាកម្មកជីកតភ្ជួង៨ទៅតេហស្ថាន

របស់ហ្លួងវត្តនសម្បត្តិ ទោះបីការនោះជាការខ្វល់គំនរយ ចៅចិត្រក៏ឥត
មានដឹងដុញ្ញត្រាន់ តែដឹងតែចំប្លែកការនោះដោយខ្លួនឯងតែម្នាក់ឯងប៉ុណ្ណោះ ក្រៅពីនេះ
មិនមានគំនាដល់សេចក្តីខ្លាចខ្លែយហាត់ខ្លែយ ។ គាស័ត ១ បទថា "ខ្លួន
ជាទាំងអស់របស់ខ្លួន" ដែលជាភាសិតបណ្តាំរបស់បិតានោះ នៅឮសូរកង
វែងក្នុងត្រចៀករបស់ចៅចិត្រ ហាក់ដូចជាមានទេវតាមកចាំខ្សឹបប្រាប់
ខ្លួនត្រចៀកជានិច្ច ។ ការចំប្រឹងគ្រោងការយ៉ាងម៉ឺងម៉ាត់ឥតចានមន្ទិល
ដើរតម្រាស្រែយកឈ្នះរបស់ចៅចិត្រនោះ ជាហេតុធ្វើឲ្យពួកមកក្រើការជិតគ្នា
ស្រឡាញ់កាន់តែជាច្រើន រហូតដល់ហ្លួងវត្តនសម្បត្តិ ក៏មានចិត្តមេត្តា
ក្នើតំនេះនោះជាច្រើនដែរ ។

ចៅចិត្របួលមកធ្វើការនៅផ្ទះលោកហ្លួងវត្តនសម្បត្តិ អស់រោល ២ ខែ
កន្លងមកហើយនោះ តែងបានជួបប្រទះនឹងធម្មជាតិថ្មីៗ ដូចជាពៃត្តំកែថ្ម
ព្រឹកព្រលឹមវាល្ងាចនឹងអាកាសស្រស់ថ្មីសុទ្ធ ដែលជារបស់ចំប្លែកកក្នុងដីតែ
ចៅចិត្រ តែដែលចំប្លែកយ៉ាងពន្លឹកជាងនេះចៅចៀតនោះ គឺនាងនារី
ចៅហ្វាយក្រមុំរបស់ចៅចិត្រ ដែលជាស្ត្រីប្រកាន់ខ្លួនមានឫកនាឆ្មើងឆ្មៃ
ហើយជានារីមានរូបឆោមយ៉ាងក្អងឯកកក្នុងស្រុកបែលិន ហាក់ដូចជាផ្កា
គុលាបតំពុងរីក ផ្សាយក្លិនក្រអូបល្ហែលល្ហើយតំបូលក្នុងវិស្សាន្តវេលា ។ រីឯ
ដែលចៅចិត្រអង្គុយក្នុងផ្ទះស្ងាត់ ។ តែម្នាក់ឯង ច្រើនប្រមូលមកឡើង
អស់នេះបានគិតនឹកជាខ្លួនឯង ហើយនឹកខ្ទួលតែម្នាក់ឯងថា ពុះហេតុដូចម្តេច

ចានជាអញ្ចេះតែរំពឹងទឹកឥលន់នាងក្រមុំនេះអើម្ល៎ះ ចុះអញជាប់ចិត្តច្រើន-
ព័ន្ធនាងក្រមុំនេះឬអ្វី? អា ! មិនចានេ នាងនេះរូបឆោមល្អមែនហើយ
ប៉ុន្តែឫកពាឆ្មើងឆ្មៃប្រាន់ខ្លួនហួសពេក ថែមទាំងយសស័ក្តិក៏ខ្ពង់ខ្ពស់
ណាស់ ហួសវិស័យនឹងឈោងគោងបេះប្រលេះយកឲ្យបាន ចុះមាន
ប្រយោជន៍អ្វីដែលអញនៅទំគិតទឹកឥលន់គេ ខុតជាទំនេរចិត្តមិនឲ្យទំក
គិតដូចម្តេច ។ ក៏នៅតែមានចិត្តរវើរវាយរកប្រាក្សាអ្នកណានោះពាល់តែបាន!!

ចំណែកខាងនារីក៏ភ្ញាប់គិតថា កម្មករថ្មីរបស់នាងនេះ ជាមនុស្ស
ចំឡែកជាងគេ មិនចេះប្រចុបប្រចែងទៅហ្វាយខាយ ទំហាយដូចជាគេ
ឱលដំនឹងពាំងដង ឥតចេះរើកងចិត្តគេសោះ ថែមទាំងចេះនិយាយសំ-
ដីពាន់សម័យទៀតផង ចានជានាងមិនទឹតដឿថា កម្មករកំឡោះនោះចាន
រៀនសូត្រត្រឹមសាលាជាន់ខាប ត្រាន់តែចេះសរសេរ ចេះមើលប៉ុណ្ណោះ
ទេ ។ ចួរតាលនាងចានឮបុរសកំឡោះនោះរៀស្រករច្រៀងពាយទំនុកតាម
ការកំសត់របស់ខ្លួនក៏មាន ច្រៀងទំនុកយុវកវិរម្យជាភាក្យរំពឹកយុវជនក៏
មាន ទើបនាងយល់ថា កម្មករកំឡោះនោះ ច្បាស់ជារចញមកពីសា-
លាបឋមសិក្សាជាន់ខ្ពស់ជាក្រាកជ ។ នៅវេលាត្រលប់ថ្ងៃនោះជាងា
រនោច ព្រះចន្ទក៏រះឡើងបំព្រាង ។ មើលឃើញផែបរ ចំហៀង ឆ្នុះពន្លឺ
ពណិប្រផែះតង់លើបុងត្រឹក្សាយ៉ាងត្រចះត្រចង់ នារីចុះមកដើរលេង
កំសាន្តចិត្តជាមួយនឹងស្រីបំរើម្នាក់ នៅរីឆ្ងាស្ងួនចម្ងាយប្រមុខផ្លូវដែលមានស្មៅ

ពេលស្លាតដូចកម្រាលត្រៃ នាងតែងតែចោលក្អែកក្រែកខ្លែកមើលទៅកូនផ្លុះមួយដែលចេញចិត្តទៅជាញយៗ ។ ពេលនោះនាងបានឃើញផ្លុះនោះឆ្ងាំតវតតាខ្លីក្តៅឆ្ងាំ ទើបនាងនាំក្មេងស្រែបំរើ ហើយលបដើរទៀងចូលទៅឈរនៅគម្ពាជាងខ្ទមភាងមុខបង្អួច ក៏ស្តាប់តែឮសូរសំឡេងមនុស្សច្រៀង ខំនុកយុំកំរម្យាយ៉ាងពិពោះចាប់ចិត្តថា

ពួកយើងជាគណយុវជន	ស្ទុះស្ទួលលើសលន់ពាំងប្រសាំងសើ
ពួកយុវសាលាដែលទើបកើតថ្មី	ប្រយោជន៍ដើម្បីផ្តួយគ្រាមគ្រែងគ្នា ។
ឈ្មោះខងចាប់ជាក្រុមមិត្តភ័ក្តិ	ស្រាឡាញ់រួមរ័ក្សាសមគ្គា
សាមគ្គីពាំងជាតំយើងឆ្ងាងនាគា	មេត្រីត្រូវបំផ្លាជាសុខក្សេមក្សាន្ត ។
ត្រូវដួយអ្នកខ្សត់ឈ្មោះខេញទៅ	ដើរមើលលំទៅសព្វទីភូមិឋាន
មើលស្រែចំការនិងជ្រលងភ្នំ	ក៏ឮការប៉ុន្មានគោងបងចាំទុក (១) ។ ល ។ .....

នាងនាំឈរស្តាប់ខំនុកនោះហើយទើបនាងដើរទៀងស្ទៅទៅលើផ្លុះនោះយ៉ាងរួសរាន់ ដើម្បីចាប់អ្នករៀងនោះឲ្យស្គាល់មុខបង្ហាញតើគឺនរណា ? តែនាងមិនបានឃើញមនុស្សក្នុងយរៀងនៅទីនោះទេ បែរជាឃើញរាចិត្តដេកលក់សណ្តូកដើងត្រង់ស្តូក ស្រមុកតខេរ នៅលើត្រែត្រៃស្មៅមោត់បង្អួច ក្រែកខ្លែកមើលរេងើមើលស្តាំ ក៏គ្មានឃើញនរណា

---

๑ ខំនុកយុំកំរម្យានេះ មិនមែនជារបស់អ្នកតែងរៀងកុលាបបន្លែលំនេះទេ ពីជាខំនុករៀងមួយ របស់ពួកក្រុមយុវសាលា ដែលទើបកើតឡើងកាលពីប៉ុន្មានឆ្នាំកន្លងមកនេះ ។

ម្ចាក់សោះ ស្រែវាតែរបៀបចិត្តតំពុងដេកលក់ស្រួលតែម្ចាក់ឯង នាង
ទឹកទូលណាស់ ព្រោះអម្បាញ់មិញនេះឮសូរស្រែកប្រែនក្តែង។ ចុះអ្នក
ឯណាមកលួចស្រែកប្រែនទៅទីនេះអេះ?

វេលានោះ រស្មីព្រះចន្ទកំពុងតែចាំងចូលមកតាមបង្អួចបន្ទប់
បន្តូចតូច ទើបនាងមើលទៅឃើញពងគាយទៅចិត្រដេកលក់ស្កប់ស្កល់
នៅទីនោះយ៉ាងច្បាស់លាស់ នាងក៏ស្រែកជាស់ទៅចិត្រ ២-៣ ម៉ាត់ ទៅ
ចិត្រក៏ប្រែខ្លួនសុះក្រែកឡើងតាំងងឹងងុយងោក កាលឃើញអ្នកដែលចូល
មកជាស់ច្បាស់ហើយ ក៏ម្នាងិយាយអញ្ជើញឲ្យអង្គុយដោយកិរិយាទន
លំទាន ។

"អញ្ជើញអង្គុយ ឃុនពារី[1]" ទៅចិត្រនិយាយត្រមាំងលើក
កៅអីមួយជូននាងអង្គុយ ហើយនិយាយថា "ការដែលឃុនអញ្ជើញមក
លេងផ្ទះខ្ញុំបាទនេះ ខ្ញុំបាទមានសេចក្តីត្រេកអរណាស់ ទុកដូចបានទទួល
កិត្តិយសដ៏ធំធ្ងន់ហ្ន៎!

នាងនារីធ្វើមុខក្រញូវបន្តិចហើយស្តីទៅថា អ្នកណានិយាយថា ខ្ញុំ
មកលេងនឹងអ្នកឯង!

ទៅចិត្រទឹកសង្ស័យក៏សួរទៅវិញថា "ចុះឃុនអញ្ជើញមកមាន

---

๑ ពាក្យថា "ឃុនៗ" ជាពាក្យប្រើដំនួសឈ្មោះដើរយសេចក្តីគួរសមតាមទម្លាប់ស្រុក
បម៉ៃលិនៈនោះឯង ។

ការអ្វី។ នាងតបទៅវិញ ឃាត់កំបុតកំបុយថា "ខ្ញុំមកស្តាប់មនុស្សច្រៀងទេ តើ ចុះអម្បាញ់មិញនេះអ្នកណាច្រៀងខំខ្ទុតយុវកំរេម្សៃក្តែង។ ក្នុងចំនេះ?

ទៅចិត្រធ្លីក្តែតឡើងខ្លួនធំ និយាយស្តួរទៅនាងថា "នានេប្អាស យុវកំរេម្សាអ្វី, ជាសត្វឬជាមនុស្ស ខ្ញុំឮមិនដែលឮឈ្មោះសោះឡើយ?

នាងនាគទើងឡើងមុខក្រហម ហើយច្រាប់ទៅថា "នែ! អ្នកក្មេ យុវកំរេម្សាខំខ្ទុតក្មេង ឲ ខ្ញុំចង់ដឹងតើអម្បាញ់មិញនេះនរណាច្រៀង?

ចិត្រ- "អេ, ខេ នរណាច្រៀងខ្ញុំឮតដឹងសោះឡើយ តែខ្ញុំឮមិនមែនច្រៀងទេ ឯខ្ញុំឮនេះ គុំថាដល់ទៅក្មេងយុវកំរេម្សាខំខ្ទុតទំនើបថ្មីអ្វីនោះឡើយ, តែបទសកវាចុះដែរគុំឮកាលឪ្ងានោះ ខ្ញុំឮក៏ឥតចេះនឹងគេសោះឡើយ" ។

នាគ- "កុំក្តុត, ខ្ញុំឮនឮសូរសំឡេងច្រៀង អំពីខាងលើផ្ទះនេះឯង ហើយទៅលើផ្ទះនេះ ក៏មានតែអ្នកឯងម្នាក់ឯងមែនទេ?

ចិត្រ- "ឮទេ, មានតែខ្ញុំឮម្នាក់ឯងមែន តែខ្ញុំឮមិនមែនជាអ្នកច្រៀងទេ!

"អ្នកឯងច្រៀងក្តែង។ នៅតែប្រកែកនឹងគេទៀត" នាគផ្តួលភាក្យ។

ទៅចិត្រសើចហើយថា "ខ្ញុំឮដាក់ចហើយថា ខ្ញុំឮមិនចេះច្រៀងទេ តែនៅតែបង្ខំឲ្យច្រៀងទៀត, ឃុនឪ, បើខ្ញុំឮចេះច្រៀង នឹងច្រៀងជូនឃុនស្តាប់ឥឡូវនេះឯង" ។

នាងនារីនឹកឆ្ងល់រលាស់មុខស្ទុះគ្រាចខ្សែងឈរហើយថា "មនុស្ស
ថែបនេះនិយាយខ្មែរមិនចេះស្តាប់ទេ" ។

ចិត្រ- "បើមិនចេះស្តាប់ភាសាខ្មែរ ហេតុអ្វីក៏និយាយធ្វើយឆ្ងួន
គ្នាជាន ?

នារី- "ឈប់ ។ ចិត្រ កុំនិយាយថ្ងូងណាស់" នាងលើកដៃហាម
ហើយនាងប្រញាងនងចុះពីផ្ទះនោះទៅដោយរួសរាន់ តែទៅចិត្រអង្វរឃាត់
ថា "ពុទ្ធោ! ឃុននារី, ឃុនប្រញាប់អញ្ជើញទៅណាក្នាម ?

នាងធ្វើយយ៉ាងសោះកគ្រាះថា "ទៅដេក" ។

ចិត្រ- "ឃុន, កុំអាលអញ្ជើញទៅ ឃុនមិនគួរលះបង់ធម្មជាតិល្អ ។
ដ៏ត្រកាលដែលគួរពិតពិលរមិលមើលគង់វេលានេះទៅទេ ។

នារី- "ខ្ញុំក៏ចូលចិត្តធម្មជាតិល្អ ។ ដូចេះដែរ តែស្អប់មនុស្សឆ្កួត
ព្រឹលៗ" ។

"ទៅទីនេះឥតមានមនុស្សឆ្កួតទេ ឃុន" ចៅចិត្រខ្ជិលនិយាយជជែក
តទៅទៀត ថែរជានិយាយបបួលដោយស្រួលថា "ណ្ហើយឃុន មិន
ជាច់និយាយជជែកគ្នាច្រើនទេ សូមអញ្ជើញចុះទៅសន្ទូនាសេងកង់សួន
ច្បារឯណោះ មើលធម្មជាតិល្អ ។ ដ៏ត្រកាលកម្រមានណាស់!

មិនដឹងជាអំណាចអ្វី មកគ្របសង្កត់នាំឲ្យនាងនារីធ្វើតាមចិត្តរបស់
ចៅចិត្រ ស្រាប់តែចុះដើរនាំមុខទៅដោយស្រួល ទៅអង្គុយលើដងម៉ាវែង

ក្បែរដើមចំប៉ី ១ ដើម ។ ឯលោកចិត្រកឹតអង្គុយលើស្មៅក្បែរដើមនោះខ្លួនផង
តែភ្នែករំពៃឆ្លើយមើលទៅព្រះចន្ទ្រដែលឆេះពាក់កណ្តាលដ៏ដេរដាសទៅ
ដោយពពួកផ្កាយ មានចំនួនច្រើនលើសលន់គណនា ហើយលោកចិត្រ
និយាយទៅនឹងថា "ឃុនតាប់ចិត្តពន្លឺស្មើដួងព្រះចន្ទ្រឬទេ ?

នារី- "ខ្ញុំចូលចិត្តដែរ លោកចិត្រ" ។

លោកចិត្រនិយាយដោយសំដីទន់ផ្អែមថា "មែនហើយ! ឃុននារី! ធម្ម-
ជាតជារបស់ចំឡែកនេះ អាចប្រទេញមលួងលោមអារម្មណ៍របស់មនុស្ស
យើងឲ្យបានសុខស្រួល, ពន្លឺស្មើព្រះចន្ទ្រ, ឲ្យល់រំកើយជាត់, ទឹកភ្លុំង
ក្រអូបឈ្ងុយឈ្ងប់របស់ផ្កានានា; អាចធ្វើចិត្តគំនិតរបស់យើងឲ្យមានអា-
រម្មណ៍រីករាយទៅបានយ៉ាងចំឡែក ។

នាងអង្គុយស្តាប់សំដីលោកចិត្រនិយាយដោយអារម្មណ៍អណ្តែត
អណ្តូង ក៏គិតថា "កម្មករគំនេះនេះ ជាមនុស្សចំឡែកជាងកម្មករឯ
ទៀតៗ របស់នាង សំដីត្រង់ៗ ម៉ាត់របស់កម្មករនេះ តេញាទៅដោយ
សំខ្លួនអៀនហាមុខគួរឲ្យចង់ស្តាប់ មិនសមជាមនុស្សខ្សោយចំណេះចេះ
ដឹងទេ" ។

នាងនារីស្ងាត់មាត់ទៅមួយស្របក់, លោកចិត្រក៏ផ្តើមនិយាយទៀតមុន
ថា "បើឃុនគ្នាក់ឯងអង្គុយជាមួយនឹងធម្មជាតបែបនេះ តើឃុនភ្ជាប់ចិត្ត
ប្រតិដ្ឋល់ញាតិមិត្រសំឡាញ់ ដែលនៅឆ្ងាយខ្លះដែរឬ ?

នាង- "ខ្ញុំភ្ជាប់ទឹកដែរ ចិត្រ" ។

ចិត្រ-"ខ្ញុំបានក៏ភ្ជាប់ទឹកដែរ ហើយច្រែនតែជាប់នៅទីដ៏ចិត្តជានិច្ច ឯង, ច! ឃុនឱវ៉ាត់អំពីខ្ញុំបានមកនៅគាស្រែយនឹងផ្ទះឃុនខេះ ខ្ញុំបានមិនដែលឃើញអ្នកម្ចាយរបស់ឃុនដល់ម្តងសោះ" ។

នារី "ខ្ញុំគ្មានម៉ែទេ" ។

ចិត្រ- "អេះ! ចំខ្សែកដែរ បើយុនគ្មានម្ចាយ យុនកើតមកដូចម្តេចបាន?

នារី-"យ៉ាអើ! នែ, គាត់ឯងកុំទាំអុចអាលបណ្តាលឲ្យកើតខោសាណ៉ាះ; ពាក្យដែលថាគ្មានម្ចាយខេះ គឺថាម្ចាយខោះគាត់អនិច្ចកម្មទៅហើយយល់ទេ?

ចិត្រ- "ឲ ដូច្នោះទេឬ? យល់ហើយពាន្រ្តាស តែយុនខៅគ្រាន់បើជាងខ្ញុំបានច្រែន!

នារី- "អើ! ម្ចាយគាត់ឯង គាត់ទួចបង់ទៅហើយដែរឬ?

ចៅចិត្រធ្វើមុខស្រែពោនហើយថា "ឃុនខៅគ្រាន់បើជាងខ្ញុំបានច្រែន ព្រោះមានឪពុកបីជាច់ក្បា ចំណែកខាងខ្ញុំបាន គ្មានពាក់ឪពុកពាក់ម្ចាយ" ។

(មានត)

ប្រដៅចិត្ត

អ្នកឧកញ៉ាបេស្សាវិនិច្ឆ័យ កែរ-ហង្ស រៀបរៀង

(តមកពីលេខមុន)

បុពណាលោកសូត្រតែចាស់ វែប្រែថ្នឹតធម៌ល្អបរិសុទ្ធ ឬមួយខុសធម៌ព្រះសម្មុទ្ធ ធ្វើបាប់ឲ្យច្រើតដកុំមុសា ។ ដូចជាអដ្ឋៈសូត្រសត្វថ្លែ ចាស់មគធៈដូច្នេះណា មិនបានទេវ្រួជនជូនតា យ៉ាងណាសូមតាធ្វើបាប់ឲ្យជាក់ ។ ចាស់ធ្វើបាប់ក្មេងថាកុំសង្ស័យ ចាស់ជាតាក្យមគធៈ បើមិនប្រែស្រាយធំធំមិនជាក់ មគធៈខ្មែរយើងស្តាប់មិនបាន ។ ធម៌ប្រែពីព្រះចាស់សុទ្ធ ព្រះតុទ្ធតែមួយអង្គប្រៀសប្រាណ ធម៌អាចដែរទៃពាន់ប៉ុន្មាន ចៅបានចេះដឹងខ្លះហើយដែរ ។ ក្មេងថាអដ្ឋៈនោះយ៉ាងណា លោកតាប្រែស្រាយជាតាក្យខ្មែរ ដូចម្តេចខ្លះចៅគុណតូចម៉ែ ចូរប្រែឲ្យច្បាស់ណាលោកតា ។ ចាស់ថាអដ្ឋៈកុំសង្ស័យ ជាបច្ច័យបច្ចវេក្ខណា ព្រះអង្គទ្រង់មានព្រះតុទ្ធដីកា យថាហេតុជាតុជាដើមអាទិ៍ ។ ឲ្យពិចារណាតាមបច្ច័យ ពាន់ជួនសត្វថ្លែកុំប្រមាទ ។ ណៈទី១ លឲ្យឃើញជាតុ សភាពគ្រោតគ្រោតសោះសូន្យរេធ៍ ។ ទី២ សញ្ញានឹងសង្ខោ ហៅថាបដិកូលគួរស្បប់ស្បែង ឲ្យនឹកធ្វើបានទឹងចាត់ចែង ខ្លួនឯងដឹងរិគោតបច្ច័យនោះ ។ ឲ្យឃើញថាជាតុស្អាត ពាល់កាយគ្រោតគ្រោតអាត្រក់ស្មោះ បណ្តាលជាស្អុយទៅមាំងអស់ រេចស់គួរខ្ពើមរេអើមពេក ។ ទី៣ បដិសន្ធិពាន់៤វគ្គ ហៅតំណិត-

ប្បច្ចវេក្ខណ៍ ពិចារណាឲ្យជុតតាំងរេក សង្វេគរណៈបរិភោក្តា ។ ខ័ ๔ អជ្ឈៈទាំង ๔ មេ ហៅអតិតេជាលក្ខណា ទឹកភ័ររបីចប់ក៏ប្លាន៉ ព្រោះប្លាន ពិចារណាតិតពីថ្ងៃ ។ កុំឲ្យអុណារេឡើងមាន់ តែមាន់រងាវគ្រោតឡើង វ៉ៃ ឲ្យតិតសំអាតត្រប់បច្ច័យ ប្រស័យយោនិយកព្រះកម្មដ្ឋាន ។ បើមាន អ្នកទ្វិលណាចង្រៃ តែវៃបញ្ញត្តិព្រះទ្រង់ញ្ញាណ ថាមិនពិចារណាក៏ប្លាន សន្តានទុសទូបលើគាត្មា ។ ព្រោះទ្រង់សំដែងវែងត្រាច អាបត្តិភ្លូច តាបមិនមានថា ប្រជៀជាពាក្យទុបមា គ្រាស់ថាជាឥណបរិភោគ ។ ប្រដូចអ្នកស៊ីបំណុលគេ គ្មានគ្រោតាមពាក្យព្រះមានះជាគ បើមិនដូច្នោះ គង់ប្រយោគ លោតគួរនាដូចអ្នកថ្លើប្រាស ។ ដុំដែតផ្ទាំងដែតនេះឆ្លួស ស្តៅ សន្ធោសន្ធៅស្តៅភោតណាស់ ហេតុតែបភូជិតប្រពឹត្តផ្តាស់ អច្ចាយ គោនប៉ះពាល់លើខ្លួន ។ ព្រះពុទ្ធបញ្ញត្តហាមដូច្នេះ កុំធ្វេសប្រហែស ចាំឲ្យធ្លួន ប្រុងប្រៀបស្មារតែតែមាំន ๔ ដ៏ឆ្ងួនគ្រោតឡើងថ្ងាយបន្ទំ ។ អ្នកកាន់បុពណមិនសុទ្ធទុស ចំរុះត្រូវទុសយ៉ាងមធ្យម ច្រើនចាំច្រើន ខោលទ្ធវសុទុម ដុំៗ ថាធ្យុតជាត្រូវ ។ វិន័យសិក្ខាវែលបញ្ញត្តិ បំបាត់ លាក់ទុកដល់ឥឡូវ មិនឲ្យអ្នកណារៀនតទៅ ទាំងផ្លូវក្រែងចេះកើត ប្រមាទ ។ ខ្លួនគាក៏ប្លានរៀនចេះចប់ តែឲ្យប់ចោះបង់ត្រង់ផ្លូវស្អាត វិន័យបញ្ញត្តិទុកជាខ្នាត ប្រមាទលើត្រូវទៅតាំនអស់ ។ ចេវតិតមើល ចុះនៅសព្វថ្ងៃ សិក្ខាវិន័យខ្លះបង់ចោះ លេនខ្លួតចត្រង្គត្រង់ប្លុំស្ពោះ

ស្មែនរកបែបស្តាយណាស់ឈរ ។ ក្មេងថាឲ្យចាស់នៃលោកតា ត្រង់ណា
ចូលចិត្តអួតគយរ បើសេងចត្រង្គសេងខូចឆ្គង ស៊ីលតរនោះតើខុសយ៉ាង
ណា ។ ចាស់ធ្វើយប្រាប់ក្មេងថានែចៅ សំដៅត្រង់ចាស់ទឹងសិក្ខា
ព្រះពុទ្ធបញ្ញត្តិណាចៅតា សិក្ខាចៅបានចេះខ្លះហើយ ។ ក្មេងថាលោក
តាខ្ញុំចេះតិច ធ្វើម្តេចទឹងសព្វលោកតាអើយ ខ្លួនតាក៏ចេះមិនអស់ឡើយ
តាអើយតាកាន់តង់មិនសព្វ ។ គិតពីអ្នកចេះសូត្រធម៌ប្រៃ យើងខ្លះ
ធ្វើឲ្យតែគេស្អប់ បើកុំបាច់ប្រៃលែងឡប់ សូត្រចប់ដូចគេដែរឬតា ។
បុពណាលោកសូត្រតែបាលី ឮល្បីមានប្រៃពីកាលណា ហើយគ្មានឮ
ហេតុគោលពាក្យថា បាត់ដោតទេតាខ្ញុំឮច្បាស់ ។ ចាស់តបពាក្យក្មេង
ថាចៅឯង ពាក្យស្មែនេះមានមកយូរណាស់ តាលព្រះពុទ្ធអង្គលោក
បានត្រាស់ សង្ឃខ្លះចាស់គ្នាតិធម៌អាថ៌ ។ វិន័យជានិធិធម្មកថិក សន្ធឹក
ចាស់គ្នាជាអស្ចារ្យ ព្រះអង្គហាមយាត់ជាច្រើនសា មិនស្តាប់ឡើយណា
យកថ្វីដៃ ។ ព្រះអង្គទ្រង់មើញហេតុមិនស្រួល យាងចូលព្រឹក្សាបាលិ.
លេយ្យក៍ ទ្រង់សាកបង្ហឹត់បាយសព្វថ្ងៃ ស្មើរតែគ្រឿងក្រឡុយពស់អាគ្នា ។
នេះហើយលោកសុទ្ធតែបុពណា ចៅបានឮដែរផង់នោះណា មានពិត
ប្រាកដជាអស្ចារ្យ ចៅតាបាកុំឆ្ងឿឆ្ងល់អ្វី ។ បុពណាចារ្យលោកចេះ
ធម៌ លោកត្រឹមត្រូវស្អាតចេះសេចក្តី ប្រែស្រាយសំពាយពីបាលី អង្វែង
ឆ្ងាំក្រៃទើបបាត់បង់ ។ បុពណាដំណលោកនាំគ្នាលិ គ្មានក្សោសីលតែចិត្ត

ត្រង់ បើរៀនធម៌អ្វីតាមចិត្តចង់ គ្មានបង់ឲ្យត្រូវច្បាស់លាស់ទេ ។ រៀនធម៌រៀនសូត្រតែបាលី មិនប្រែសេចក្តីគិតគ្នាន់គ្នែរ សូត្រតែបាលីគង់ដូចគេ មិនចាំបាច់ប្រែឲ្យនឿយហត់ ។ ដំណាតវែងមកឥឡូវ រៀនៗសូត្រតែតាមគ្នា ស្រះអេចាអែរត់បត់ ហើយកត់សំគាល់ថាបុពណ ។ តែនៅចាំពាក្យបុពណថា រៀនធម៌រៀនអាចិត្តប់សន្តាន តឹចាំច្បាកដគ្មានក្តេចវាន ដូចបានជួបលោកច្បាជ្រទេសនា ។ ហើយបបួលគ្នាទៅស្តាប់ទេសន៍ លោកនេះចេះអត្តប្រែសាស្ត្រា ចាំភ្លត់រត់មាត់ពាល់អាត្មាតែចិត្តមិច្ឆានៅត្រង់ច្បាណា ។ ត្រង់ណោះហេតុមកពីមិនយល់ ព្រោះចិត្តនោះខ្វល់តាមលំអាន ដល់មានអត្តប្រែស្តាប់មិនបាន ព្រោះពាក្យបុពណគ្មានអ្នកច្បាប់ ។ ធម៌អាចអត្តប្រែនោះយ៉ាងណា ឮតែគេថាក៏ចាំចាប់ មិនដឹងជាអត្តប្រែសារសព្ទ ចានជាមិនស្តាប់ធម៌ប្រែថ្មី ។ ត្រង់ណោះកុំឆ្ងល់យល់ឲ្យជាក់ ធម៌នេះជាពាក្យសុទ្ធបាលី អធិប្បាយប្រែច្បាយជាសេចក្តី ពីពាក្យបាលីជាពាក្យខ្មែរ ។ ឲ្យយល់ឲ្យភ្លឺតែសេចក្តី ព្រោះយើងសព្វថ្ងៃមិនដឹងដែរ លុះតែបាននឿនយូរឆ្នាំខែ នោះទើបចេះប្រែបាលីបាន ។ ដូចជាកូនយើងតាំងអស់គ្នា ឲ្យរៀនវិជ្ជាពាល់រូបច្បាណាអស់លុយអស់ច្បាក់អម្បាលម៉ាន ប្រយោជន៍ឲ្យបានចេះភាសា ។ ដល់ចេះសព្វគ្រប់ត្រឡប់មក គេយកខ្លួនចូលធ្វើពជការ ខ្លះធ្វើជាស្មៀនក្នុងសាលា ខ្លះប្រែភាសាពាក្យបាកំង ។ យើងឃើញយើងឮតែសព្វថ្ងៃ

ហេតុម្តេចសង្ស័យប្រកាន់ខ្ជាប់ ម៉ែឪមិនចេះស្តាប់កូនគាំង គាំងត្បាំងចង់ដឹងការគេ ។ ដូចជាធម៌ប្រៃមានសព្វថ្ងៃ ប្រាជ្ញប្រៃប្រាលីគ្មានខុសវេ ប្រាលីដូចគ្នាកុំវែកវេ ស្មឹកតែមានផែនផ្ទៀងមើលទៅ ។ ស្មឹកតែច្រែនក្តាយពាក្យប្រាលី សៀវតៅជាន់ថ្មីផ្ទៀងតឹមត្រូវ ប្រាលីប្រែឲ្យដឹងពាក់ព្រៃស្គាល់ខុសស្គាល់ត្រូវមុខបាន ។ បើយើងមិនចេះយើងមិនយល់ ប្រែនខ្វល់នាំឲ្យខូចសន្ធាន សុទ្ធតែប្រាលីស្តាប់មិនបាន ការខ្ជាប់ប្រកាន់ពីត្រឹមណា ។ ថាថ្មីមិនដឹងជាថ្មីអ្វី ប្រាលីដដែលគ្រាន់តែថា ប្រែចាកមគធៈជាភាសា ពាក្យខ្មែរយើងណាឲ្យបានដឹង ។ គ្មានថ្មីគ្មានចាស់គ្មានតែប្រែ គ្រាន់តែប្រែឲ្យយល់ប៉ុណ្ណឹង មិនត្រមចង់ចេះច្រើនតែខឹង ដូច្នឹងខូចចិត្តសូន្យទេ ។ ទៅតិតកុំធ្វល់ឲ្យយល់វៃ ចាំងប្រុសចាំងស្រីការយើងគេ មិនត្រមចង់ដឹងនៅវែកវេ ខ្លាសគេជាស្រីចេះគ្មានចាស់ ។ ដល់មានបុណ្យងាន់ប្រជុំធំ ស្រីក្មេងក្រមុំសូត្រគ្មានសល់ ប្រុសលួងមិនចេះនៅស្រែងល់ ខូចចិត្តរលាស់គេចតែឯង ។ ទៅជាកេរ្តិ៍ដែលបះបៃតជញ្ជាំង ស្តាប់តាំងមើលគេព្រោះអៀនខ្លួន ឯអ្នកបួសរៀនមិនសមសួនរៀនភ្ជួនឲ្យស្រីសូត្រត្រូបគ្នា ។ ហេតុនេះមកពីប្រកាន់ខ្ជាប់ ដើរៀនសព្វគ្រប់ជាអស្ចារ្យ គេចេះប្រាលីប្រែយ៉ាងណា តាមចិត្តថ្មីយើងសូត្របាន ។ យ៉ាងនេះហៅចេះមិនមែនល្ងង់ តែល្ងង់ប្រកាន់ខូចសន្ធានជាប់ល្ងង់មួយជាតិចាស់ស្តាប់ប្រាណ គ្មានបានចេះដឹងទេអ្នកអើយ ។

ច្រៃសិនហើរៀនចេះឲ្យគ្រប់ រៃច្រៃសោយត្រឡប់មិនពាល់ឡើយ ចង់សូត្រ
ត្រង់ណាមិនតន្តើយ ចេះហើយគ្មានអៀនអន់ខ្មាសគេ ។ ឃើញអស់
មនុស្សពាំងច្រៃសស្រី រៀនរៃច្រៃបាលីគ្មានទំនេរ មិនដែលឃើញម្តាយ
ឪពុកដេរ បុពណាយើងខ្វែរហ៊ានហាមឃាត់ ។ ឃើញតែជាតិខ្វែរជាន់
សម័យ ថាចាស់ថាថ្មីវត់របត់ មិនឃើញបុពណាលោកហាមឃាត់ តែមាត់
មនុស្សល្ងង់ជាច្រកែតិ ។ ថាខ្លួនបុពណាចេះចាំ ខាស់ខ្លឹងចំណាំខ្ទើបថ្មី
បើជាខ្លួនល្ងង់មិនចេះអ្វី សមនឹងសេចក្តីពោលពាក្យថា ។ បុពណា
ច្រាកដរពេញជាត្រូវ តែមនុស្សឥឡូវគ្មានបញ្ញា ចិញ្ចឹមតែល្ងង់ល្ងល់អាត្មា
ស្មានថាបុពណាមិនមែនទេ ។ បើពិតបុពណាលោកចេះស្ងាត់ លោកចេះ
ច្រាកដធំជាងគេ ចាកែតម្តីរខំរៃរេ ជាមេទុកមកដល់សព្វថ្ងៃ ។ តែ
ពោលដូច្នេះទើងមុសា ថាតានេះអ្នកចូលធម៌ថ្មី ច្បាងជាសរសើរច្រៃបាលី
សព្វថ្ងៃថាគេល្ងង់លើសលុប ។ មិនមែនដូច្នោះកុំសង្ស័យ ធម៌ចាស់ធម៌
ថ្មីគឺតឲ្យគ្រប់ កុំចោលចាំងតីរត្រែច្រាវត្ត ផ្លៀងឲ្យសព្វគ្រប់កុំអាលថា ។
ក្មេងសួរចាស់ថាតាអាងអួត អំនួតថាថ្លែងពាក្យមុសា មានច្រៃបាលី
គម្ពីរណា គ្រាន់តែមកថាឲ្យគេកោត ។ អាងតែចេះកូតគរច្រាំងច្រាយ
បរិយាយរកតែពាក្យចាក់ដោត ច្រៃស្រោយចាលិនាំអ្នកនោត ឲ្យគោត
តាឯងខ្ញុំមិនស្បាត ។ បុពណាគ្មានច្រៃសុទ្ធបាលី ជាន់ថ្នាំច្រៃឲ្យខុស
ក្រឹត្យ ខ្ញុំហ៊ានទើងគេមិនចូលចិត្ត ព្រោះដូច្នេះគ្មានធ្វើសំគាល់បាន ។

បើតាអាងថាចុលីប្រែ មានតែតាច្រើបពាក្យបុពណ កុងគម្ពីរណាជាលំអាន ឲ្យចានៈយើញជាក់អស់សង្ឃ ។ ចាស់ថាចៅតានៅតែនោតតាគោតចៅឯងសួរមកតា មានប្រែចុលីគម្ពីរណា ចៅតាកុំឆ្ងល់សំមតាច្រើប ។ នែចៅគេហៅពាក្យបុពណ ចំណានចុលីប្រែមានស្រាប់ ពួរចៅប្រុងច្រើណាគំនិតស្តាប់ ចំណាប់យ៉ាងនេតណាចៅតា ។ គម្ពីរស្តីកតែយើងមានស្រាប់ បុពណាចំណាប់ចេះអស្ចារ្យ ចារិកទុកមកសព្វថ្ងៃណា មានពាងតាថាប្រែចុលី ។ ឲ្យយើងដឹងច្បាស់យើញនឹងក្អែក កុំច្រែកគំនិតថាធមិថ្មី គឺចាស់បុពណានោះហើយនៃ អង្វែងឆ្នាំក្រែដឹងជាក់ជា ។ គម្ពីរមហាជាតិបុពណស្មោះ ពាងអស់យើងគេគ្រប់តែគ្នាចូលនាំគ្នាបំណ្លកល់រៀល តែងស្តាប់ទេសនាមិនខានសោះ ។ កណ្តាដើមចុលីហៅទេសពារ នៃហ្នាះចៅតាស្តាប់មើលចុះ ខគរកណ្តាខ្សែចប់ចុងបង្អស់របស់បុពណហើយចៅតា ។ ពាងដប់បីតណ្តាមានចុលី ប្រុសស្រីចាប់ខ្ចោតជាធម្មតា ជួនព្រះទេសពារមេទ្រីចា ចំនួនតាថាឥតមានខ្វះ ។ ពាងអស់ខ្លះតាហើយនឹងគេ តែងតែពួតចុយងាក់តុថាស ខ្លះធួបណាជាប្រយ័ត្នណាស់ តែងខ្វះចំនួនពីតាថា ។ គ្រប់តណ្តាចុលីមានច្រើនតិចគ្មានភ្លេចយើងចាំពាល់អាត្មា បើសុទ្ធចុលីនឹងតាថា ចៅតាយើងស្តាប់ដូចម្តេចបាន ។ បុពណាលោកប្រែពាក្យចុលី ឲ្យស្រីប្រុសឮៗពាងប៉ុន្មានស្តាប់ជាក់ព្រួចច្បាស់ពាក្យបុពណ ទើបបានដឹងដើមព្រះសាស្តា ។ កាល

លោកចាប់ជាតិវេស្សន្តរ លោកចរទៅតាំព្រៃចក្ខតា តិរវច្ឆិតឆ្ងាយអស្ចារ្យ
មន្ត្រីស្វែងរកដល់ថ្ងាយ ។ ដំណឯព្រាស់ថាព្រះវេស្សន្តរ គ្រែកអាទិ៍ឯសូម
ជាងតាំងឡាយ ឲ្យទានដំរីស្គរឆើតឆាយ ដល់ព្រាហ្មណ៍ឥតស្គាយតិច
ឡើយណា ។ ដំណឯព្រាស់ថាអស់ពស្ត្រប្រជា នាំគ្នាគ្នាន់ក្នាញ់ទោមនស្សា
បណ្តេញព្រះអង្គចាកសីមា ព្រោះតែកូរគ្រាឲ្យដំរី ។ ជាទានដល់
ព្រាហ្មណ៍ដែលមកសុំ កិរិយាសោមនស្សសាងចារមិ មិនតែប៉ុណ្ណោះ
បុត្រប្រុសស្រី តាំងអគ្គមហេសីឲ្យទានទៀត ។ កាលស្តេចទៅតាំព្រៃ
ហិមភាន្ត នៅមានអស់សូមទៅជ្រែតបៀត តាមសុំបុត្រាបុត្រីទៀត
មិនគឺអ្នកណាតាជូនឥត ។ កាលស្តេចឲ្យទានបុត្រទូហ៊ា នាងមទ្រីជា
ចៅចត្រែគ្មញាន់ដឹងនៅតែកង់ចំពង់ក: "បុរសកំឡោះនេះឬជាបាឡាត់ស្រុកៗសង្កែ រូបកង់ថែមនេះមិនគួរសេពគប់សោះខ្សើយ កន្ទុង

អង្គុយក់លល្ងីងមិនអង្គុយ ទៅតែទៅប្រពៃជាតអង្គុយក្បែរឃុនទាវ៉ែតអី!

ចំណែកទាងំលោកចាឡាត់ខេះគួនហើយថ្កាប់ថា "ឃុនកុំព្រួយមានគាំក្លើងខ្លីជាប់មកមួយដែរ" ។

ហ្លួងវតនសម្បត្តិក៏សើចហើយថា "មានមួយប៉ុណ្ណឹងក៏ល្មមហើយលោកចាឡាត់" ហើយងាកទៅថ្កាប់ចៅចិត្រថា "ចេញទៅឥឡូវនេះចុះចៅចិត្រ ប៊ើចេញថយខ្លួទៅវិលានេះ ប្រហែលជាមោងឹង៤រសៀលទើបដល់ទៅផ្ទះយើង" ។

ចៅចិត្រក៏ចុះទៅវៃតាមបង្គាប់ហើយឡើងបរថយខ្លួចេញទៅ សំដៅទៅតាមផ្លូវបៃលិន សឹងដេរជាសទៅដោយស្រែចម្ការចារដំណាំលុះផុតពីភូមិក្តុំសំរៅ ភូមិស្ទឹងកាលណា មានតែព្រៃព្រឹក្សាលតាវល្ងីនឹងក្តុំគ្រំថ្មដេរជាស ផ្លូវក៏កាន់តែលំបាកឡើងថ្លៃជែនដីខ្ពស់ៗ ពាបៗ បត់បែនជាច្រែនជាន់ កាលចៅចិត្រក្រែងមើលមកក្រោយ ស្រាប់តែឃើញចាឡាត់ស្រុកនោះ និយាយក្អាកក្អាយសប្បាយរីករាយជាមួយនឹងនាងនារី ចៅចិត្រក៏កើតមោហាំងឡើង ថែមលើសេចក្តីមួម៉ៅកាលដែលទៅផ្សារចំញ្រ្តីនោះមួយជាន់ទៀត ទើបភ្លែងគាច់ចង្កឹតឲ្យបត់ក្បាលភ្នាក់ទៅជង្គឹកពក់ៗ មួយអន្ទះខ្នោះក្បែរផ្លូវ មាំស៊ីនកេះពែងដៃ ហើយខាច់ដីក់ស្ងៀមទៅនឹងកន្ទុងនោះឯង ។

ចៅចិត្តក្រឡេកមើលមកក្រោយ ស្រាប់តែឃើញក្អែកគ្រប់ៗគ្នា
សំឡឹងមើលមកចំខ្លួន ។ ជាឡាត់ស្រែកភ្ញាក់ផ្អើលព័ទ្ធអង្គុយ ហ្វូងវគន-
សម្បត្តិកំពុងយកដៃស្ទាបក្បាលដែលប៉ះទង្គិចនឹងដំបូលវេ ខានតែរឹតតែធ្ងាក់
ទ្រេតរិះតែធ្ងាក់ តែបួនជាចាប់បង្អែកខាន់ជាន ។

លោកជាឡាត់បន្ទោស: "សូហ្ស៊ីរចៅទ្រែបរវេអីយ៉ាងអីវេះ"

ខានតាវ៉ាកដម្រង់ខ្លួនហើយបន្ទោសថា "ចិត្រ តាត់ឯងមិនចេះបរ
ឡានទេឬអី?

ចៅចិត្រធ្វើយភ្លាមថា "បើមិនចេះបរ គង់មិនជាន់មកជល់
ទីនេះទេ" ។

"ចិត្រ កុំក្លាហានពេកប្រយ័ត្នពាក្យសំដីបន្ទិច" ហ្វូងវគនសម្បត្តិ
ទំយាយជាស់តឿនចៅចិត្រ ។

ចៅចិត្របែរទៅលោកហ្វូងហើយដាក់ពាក្យថា "សូមអត់ទោស, ខាន
ច្រើស, ប្រសិនបើខ្ញុំខានមិនកាច់ចង្កឹតឲ្យវ៉ាកទៅជង្គឹកទេ កង់មុខខាង
ស្តាំមុខជាប៉ះនឹងជង្គត់នោះជាប្រាកដ ហើយធ្វើឲ្យខូចពេលយូរជាងធ្ងាក់
ជង្គឹកនេះទៅទៀត" ។

លោកហ្វូងញាក់មុខខ្លួលខំនងជាយល់ដូច្នេះដែរ ហើយចៅចិត្រ
បែរមកមើលខាងក្រោយ ក៏ច្រេះនឹងក្អែកដែលសំឡឹងសំឡក់ជាក់ជា
ច្រែនជង់ច្រែនគ្នា ច្រែនគ្រប់ ។

រថក៏បត់ទៅខ្វែតដូចធម្មតា តែនាងនាវសង្កេតយល់ដឹងដល់ចិត្ត គំនិតរបស់ចៅចិត្រ តែកាលណានាងធ្វើស្មុគ្មស្មាលទឹងចាប្បាត់ស្រុកខោះ រថក៏គ្រលែងយ្លេងយ្លោង តេកលំភ្លាត់ជង្គកថ្នដើរខុសផ្លូវទៅ ស្ទើរតែមិនហ៊ានទាយយកអ្វីទឹងលោកចាប្បាត់ខ្វែត ។ តាំងពីនោះមកនាងក៏ដឹងខ្លួនថា "ចៅចិត្រមានបំណងអ្វីក្នុងខ្លួននាង ?

លុះរថយន្តបង្កុតកូមិវ្រៃផ្លៅទៅឆ្ងាយបន្តិច ក៏ឧប៉ាំរំលត់មាស៊ុនទើបចៅចិត្រលោតចុះទៅបើកគ្រឿងម៉ាស៊ុនមើល ស្រាប់តែធ្វើមាត់រៀបក្រែរ ។ អ្នកជិះទាំងអស់គ្រប់ៗគ្នា មានសេចក្តីព្រួយជាច្រើន ទើបហ្លួងតេនសម្បុត្តិ ដែលមានសេចក្តីព្រួយច្រើនជាងគេ ក៏ចុះពីរថទៅសួរចៅចិត្រថា "មុំចៅ ទៅខ្វែតបានឬទេ ? ល្មមកែកុនបានឬទេ ?

ចៅចិត្រគ្រវីក្បាលដោយអស់សង្ឃឹម ហើយជំរាបទៅលោកហ្លួងថា "ខានេះប្បាស, បរទៅខ្វែតមិនបានទេ វាខូចត្រង់កន្ទែងសំខាន់ដែលខ្ញុំបាទធ្វើមិនកើត គោងទៅជួលចិនគ្រឹងជាក់ជាថ្មីទើបបាន !

នាវី— "ម្ដងនេះស្រេច" ហើយនាងផ្តេកខ្លួនលើរថយន្តដោយអាការអស់កំឡាំងជាច្រើន ។

លោកចាប្បាត់ចុះពីរថដើរមកឈរ ចំពីមុខចៅចិត្រហើយថា "គាតឯងបរថយ៉ាងម៉េចហ្នឹង គាល់តែរថខូចអស់ !

ចៅចិត្រធ្វើយខ្លួ។ ថា "ខ្ញុំបានបរជ័យយ៉ាងមនុស្សជម្មតា លោក
ក៏បានឃើញនឹងភ្នែកស្រាប់ហើយ" ។

លោកចាត្បាត់ខាំមាត់ហើយថា "បើគាត់ឯងមិនបរឲ្យភ្លាក់ដង្ហក
អម្បាញ់មិញ ក៏គង់មិនខូចដល់ម្ដងដែរ!

ចិត្រ — "ចុះលោកគិតថា ខ្ញុំបានភ្លែងបរឲ្យភ្លាក់ដង្ហកឬអី?

ចាត្បាត់—. ផ្លូវមានគគាច មើចក៏គាត់ឯងមិនបរឲ្យត្រង់ៗតាមផ្លូវ
មានតែគាត់ឯងភ្លែងធ្វើឲ្យភ្លាក់ដង្ហក?

ចិត្រ — "លោកថាដូចម្ដេចក៏បាន តែខ្ញុំបានមិនបានភ្លែងធ្វើឲ្យភ្លាក់
ភ្លាក់ដង្ហកទេ" ។

ចាត្បាត់—. "គោងប្រយ័ត្នសំដីបន្តិចគាត់ឯង" ។

ចិត្រ—. "ខ្ញុំបានបាននិយាយដោយសំដីគួរសមណាស់ហើយតាន
ត្រាស" ។

ចាត្បាត់—. "មើចក៏គាត់ឯងព្រហើនម្ល៉ះ ត្រែងគាត់ឯងគ្រាន
តែជាអ្នកស៊ីឈ្នួលគេទេឬ?

ចៅចិត្រសើចចំអកបន្តិចហើយថា "ខ្ញុំបានជាអ្នកស៊ីឈ្នួលគេមែន
តែមិនមែនស៊ីឈ្នួលលោកចាត្បាត់ទេ" ។

ហ្លួងតេនសម្បត្តិទឹកមុខ ទឹងសំដីនិយាយជជែកគ្នានោះ ក៏ហាម
ត្រាមថា "ឈប់និយាយប៉ុណ្ណឹងហើយ លោកចាត្បាត់ ការនិយាយ

ជជែកគ្នាទៅគ្រានេះ ក៏មិនមានប្រយោជន៍អ្វីឡើយ បុពណាលោកថា "សាបមួយដៃ រៃប្រមួយចំប" មែនទេ ?

នាវី—. "បុះយើងគិតធ្វើដូចម្តេច ទើបទៅដល់ផ្ទះ ? នាងសួរដោយសេចក្តីព្រួយបារម្ភជាច្រើន ។

ហ្វូង—. "ហ្នឹងហើយ ប៉ាក៏មិនដឹងជាគិតធ្វើដូចម្តេចដែរ សួរទៅចិត្រមើល តើគេគិតធ្វើដូចម្តេច ?

នាងងាកមកទៅចិត្រសួរថា "ចិត្រ យើងត្រូវធ្វើដូចម្តេចទើបទៅដល់ផ្ទះ ?

ចិត្រ.— "ខានច្រើស, គោងតែដើរទៅទើបបាន" តបកំប្លុតៗធ្វើឲ្យនាងនាវីឡើងមុខក្រហម ។

ទៅចិត្រដើរចូលទៅកហ្វូងតេនសម្បត្តិ ហើយនិយាយដាក់ថា "យើងគោងធំចាំនៅទីនេះ ចំពាមនាវយន្តណាមួយមកដល់ទីនេះប្រាសិនបើគ្មានទេ ក៏គោងតែស្នាក់នៅទីនេះមួយយប់ . បើនឹងដើរជើងទៅត្រែងតែងាក់កណ្តាលអធ្រាត្រែទើបដល់ផ្ទះ" ។

លោកហ្វូងជកដង្ហើមធំ, នាងនាវីសួរទៅលោកដុតដោយសេចក្តីភិតភ័យថា "យើងគោងតែជជកស្នាក់តងៃព្រេនេះ ១ យប់ទៅឬចា ?

លោកហ្វូងញាក់មុខហើយថា "កូនឃើញទេ វេលានេះម៉ោង ៤ រសៀលហើយ ឬមួយកូនចង់ដើរលេងក៏តាមចិត្ត ?

នាង៩នារីតែវិក្សាលហើយថា "ទេ ចា៎, ខ្ញុំមាដើរទៅដល់ កូនមុខ ជាស្ងាប់ពាក់កណ្តាលផ្លូវមិនមានឡើយ" ។

ចៅចិត្រសើចឡើងខ្លាល់តែនាង៩នារីបែរទៅសំឡឹង៩មុខហើយសួរថា "តាត់ឯង៩សើចអី!

ចៅចិត្រញញឹមញែញែមតាមធម្មតាហើយថា "ខ្ញុំបាទសើច៩ចំកំប្លុកមួយនោះទេតើ ឯហក់លោតព័ដើមស្រម៉ាទៅដើមកន្ទួតត្រែពក្ងាត់ចំណាប់ ក្លាក់មកដល់ដីដូចប្រកាច់ បានជាខ្ញុំបាទសើច៩ចំ៩ឯ!

នារី.— "តេកើយ តេព្រួយកាល់គ្នាឯ៩តែតែពីសើចសប្បាយ" ។

ចិត្រ.— "បានជាខ្ញុំបាទសើច ពីព្រោះសត្វខ្ទុះមាន៩ដើ៩ដល់ទៅ៤ នៅតែមានក្ងាត់ចំណាប់ក្លាក់ដល់ដីខ្លាល់តែបានដូច្នេះទេតើ!

នាង៩មិនធ្វើយតបទៅ គ្រាន់តែសំឡឹង៩សំឡក់ចុង៩ក្បែកកន្ទុយក្បែកប៉ុណ្ណោះ ដោយសារសេចក្តីមួម៉ៅក្តៅក្រហាយ ប៉ុន្តែនាង៩ក្ងាប់សំដែង កិរិយាដូច្នេះជាទិច្ច ។ ចៅចិត្រថ្នឹក៩ឮនិស្ស័យបែបនេះមកច្រើនគ្រាហើយ ទើបមិនមានចិត្តព្រួយបារម្ភអ្វី ថែមទាំ៩ឃើលថា ស្ត្រីបើមិនសំដែងកិរិយា៩ក្ងិកក្ងក់ខ្លះទេ ក៏មិនល្អមើលដែរ គ្រាន់តែកុំឲ្យជ្រុលហួសពេកប៉ុណ្ណោះ ។

ឯនាង៩នារីនឹកជ្រាបពួន៩ខ្លួន៩ឯ៩ថា "កូនឈ្លើលកំឡោះនេះចំឡែកជាង៩កូនឈ្លើលដទៃ១ទៀត ជាអ្នកមាន៩អំនួតបន្តិចថែមទាំ៩ប្រើសំដីមិនចេះត្រែ៩ចិត្តអ្នកណា១ទេ តែចេះនិយាយសមហេតុសមផល ទើបនាង

ចូលចិត្តនិយាយ ប៉ុដែកពីរឿងអ្វីៗ លេង នាងឆ្ងាប់គិតថា "នាងគិតដូច្នេះនឹងមានប្រយោជន៍អ្វី ហើយគេជាអ្នកនឹងនាង គេគ្រាន់តែជាកូនឈ្លួសនាងម្នាក់ប៉ុណ្ណោះទេតើ!

លោកចាន្លាត់ដើរទៀងមកកៃ្សរនាងនារីហើយសួរថា "ចុះហេតុអីក៏ឃុនចូលចិត្តទៅនិយាយធ្វើយឆ្ងួនទឹងអាក្មេងតំឆ្លាះនោះម្ល៉េះ?

នារី — "នរណាប្រាប់លោកថា ខ្ញុំចូលចិត្តទៅនិយាយធ្វើយឆ្ងួនទឹងក!

ចាន្លាត់ —. "ខ្ញុំបានឃើញទឹងក្អែក បានឃើញក៏និយាយដែកទឹងឃុន តាល់តែឃុនតាល់ច្រតរបស់ក៏ ម្ដុំងៗទៅតែឃុនទៅនិយាយដែកទឹងក៏ទៀត ក៏ជាក្មេងព្រហើនមិនចេះគួរសមទេ ឃុនពិនិត្យមើលក៏ឲ្យមែនទែនចុះ" ។

នាងនារីញាក់មុខទំនងជាយល់ដូច្នោះដែរ ហើយធ្វើយថា "ចាំ, កម្មករនេះឫកតាព្រហើនបន្តិចមែន តែទស្សាចាំធ្វើការណាស់" ។

លោកចាន្លាត់ —. "ប្រហែលជាក៏ទើបមកនៅទេ បានជាពីដើមមកមិនដែលឃើញសោះ" ។

នារី —. "ចាំ, ក៏ទើបទឹងមកនៅមែន ប្រហែលជាង ៤ ខែប៉ុណ្ណឹង ឪពុករបស់ខ្ញុំគាត់មានចិត្តអាណិតមេត្តាដោយឃើញថា ជាមនុស្សកំព្រា

ឪពុកម្តាយ ហើយបានប្រគល់ឲ្យដឹកអណ្តូងស្បូនទៅទិសខាងកើត ដែលទើបនឹងចេីកថ្មី" ។

និយាយគ្នាបានត្រឹមប៉ុណ្ណោះ ក៏ស្រាប់តែឮសំឡេងហួងរគនសម្បត្តិស្រែកហៅនាងនារី ហើយថ្លែងប្រាប់ថា "នារីកូន, ចាត់ចែងដាំបាយទឹកទៅឪពុកនឹកឃ្លានបាយណាស់ហើយ ឲ្យទៅចិត្រជួយរកឧសក្តេីងផង" ។

ទៅចិត្រចូលមកដឹតហើយសួរថា "ឃុនឯងឲ្យខ្ញុំបានជួយធ្វេីការអ្វីខ្លះ ប្អូរប្រាប់មកចុះ ?

នារី— "ទៅរកដុំថ្មដេីម្បីមក ហើយរកឧសបង្អាត់ក្តេីងឡេីងផង" ។

នាងបង្គាប់ទៅលោកបាឡាត់ថា "លោកបាឡាត់អាណិតយកសាច់ដាក់កំប៉ុងមកឲ្យខ្ញុំពីរកំប៉ុង ទេីបសណ្តែកហាឡាន់តៅផង" ។

កំឡោះពាំងពីរនាក់ ក៏រត់ធ្វេីការផ្គាប់ផ្គុនគ្នាត្រមុំយ៉ាងមុឺងម៉ាត់ ឯទៅចិត្របានដុំថ្មតូច ៗ ជាដុំ ហើយដាក់ដំរៀបជាមុំដេីងគ្រានហើយទៅរកកាប់ឧសមកបង្អាត់ក្តេីងនេះគ្មានរវៃឡេីង ។

"ឃុនឯងឲ្យខ្ញុំបានធ្វេីអីទៀត" ទៅចិត្រសួរនាងខណៈដែលបង្អាត់ក្តេីងរួចហើយ ។

នារី— "ចៀនត្រីនាសាច់គោនឹងសណ្តែកខ្ទេីង, អេ ! យេីងគ្មានខ្លះទេ ទៅចិត្រគោងទៅរកខ្លះមក" ។

ចិត្ត "អើ, ពានគ្រាស, ខ្ញុំនេះមិនមែនជាវាសនាខ្ញុំទេ, បុះឲ្យខ្ញុំទៅ
រកខ្លះឯណាមកជួនឃុនបាន ?

នាងដកដង្ហើមធំហើយថ្លែងថា "អើ, នេះប្រុសត្រូវឆ្កាំង ម្តេច
ក៏មិនយល់ការអ្វីសោះ ខ្ញុំគ្រាន់តែឲ្យទៅរកការងារអ្វីមួយសំរែតៗ ក៏បាន
ហើយ សំពាប់យកមកចិនធាប៉ុណ្ណោះ" ។

ចៅចិត្តញញឹមហើយថា "ប៉ុណ្ណឹងទេឬ ? ហើយស្ទុះត្រាកទៅ
ឯវេយន្ត លើកពួកគ្រាលអង្គុយឡើងមើលឃើញចានស្អាន់សសំរែតៗ
គាន់លើកបង្ហាញទៅនាងនាវ៉ាថា "បែបនេះបានឬទេ ?

តាំងអំពីចៅចិត្តចូលមកនៅជួតកោនទំនងនាងនាវ៉ា នាងមិនដែល
ញញឹមម្តងសោះ ទើបតែមកពេលនេះ នាងក៏ញញឹមដំនួសពាក្យតប
ជាគ្រាដំបូង ។

លុះលាងចានស្អាន់សរួចហើយ ចៅចិត្តក៏ជាក់លើដើងគ្រាន
បរណ្តោះអាសន្ននោះឯង ។

នាវ៉ាក៏យកកន្ទាញ់ជួតជាក់ចិនក្តងចាននោះ, ចៅចិត្តក៏យកស្លឹក
ត្នោតបក់ភ្លើងឲ្យនេះឡើង ពាល់តែដៃហុយក្តុបឡើង ពាល់តែខាង
ច្រាប់ឲ្យឈប់បក់ ។

ចិត្ត— "ហ្ន៎ឯឃុនគិតពិសាតែសាច់ទេ មិនដាំបាយទេឬ ? ចៅ
ចិត្តសួរនាងដោយហេតុមិនឃើញនាងដាំបាយសោះ ។

នារី— "អើមែនហើយ, ចិត្រ. ខ្ញុំភ្លេចឈឹង, ចុះយើងរកឆ្នាំងឯណាដាំបាយហ៎ ?នាងនិយាយហើយសំឡឹងមុខចៅចិត្រ ចំនងសួរឲ្យជួយគិតគូរផង ។

ចៅចិត្រដឹងចំនង ក៏រត់ទៅឯរថយន្តម្តងទៀត រកបានកំប៉ុងបឿរមួយធំ បើកជួសយកសាច់បឿរចេញខ្ចប់អស់ ហើយក៏វិលមករកនារីសួរថា: "ថែបនេះគ្រប់ចានទេ ឃុន ?

នាងនារីញញឹមចំលួលម្តងទៀត ម្តងនេះញញឹមចេញមកដោយចិត្តសុចរិតឥតកំភូតចន្ទិចឡើយ គ្រានេះដែលចៅចិត្រឃើញថា នារីចៅហ្វាយគ្រប់មុំបេះគេនេះ មានកិរិយាចន់ក្ងុនផ្អែមល្ហែមចំឡែកណាស់ !

នារី— "ថ្លៃហែលជាគ្រប់គ្រាន់ចានហ្ន, ចិត្រ" នាងតបទៅដោយសំដីធម្មតា ។

នារី— "អើ ! ចុះយើងចានតែតពីណាមកដាំបាយហ៎ ?

ចិត្រ— "មិនអីទេ, ខុកភ្នាក់ងារខ្ញុំចានរកជូនឃុនពាល់តែចាន" ថាហើយក៏ទៅបើកបំពង់តែកងរថយន្ត តែកក៏ហូរចេញមកពាល់តែពេញកំប៉ុង ហើយយកមកឲ្យនាងនារី ។

លោកហ្ន៎ងាន់សំដីតែកងរថយន្តមកថា " ខ្ញុតគ្រាន់បើ បើមិនចានចៅចិត្រ ថ្លៃហែលជាអត់ចាយកង់ពេលនេះតាំងអស់គ្នាមិនខាន" ។

ឯលោកចាន្ទាត់ខ្លួលយកគាសារជាអ្នកជាំបាយ ដោយដឹងខ្លួនថា ខ្លួនដូចជាចាញ់ប្រៀបចៅចិត្រច្រើនណាស់ ការដែលនៅស្ងៀមមិនជួយ ខ្វល់ខ្វាយនឹងគេ ស្រាប់តែបាយឆ្អិនបរិភោគនោះដូចជាមិនចំនង់សោះ ។

ឯចៅចិត្រតអំពីនោះ មិនបានជួយធ្វើអ្វីទៀតទាល់តែដល់បាយឆ្អិន ទើបជួសបាយជាក់ចាន ជាក់ត្រីចៀន ធាសាច់គោ យកទៅជូនលោកហ្ជួង ឯខ្លួនឯងទទឹងនាងនាំបរិភោគនឹងស្លឹកឈើ ឯលោកចាន្ទាត់ស្រុកបរិភោគនឹងក្រជាសកាសែតដែលខ្ចប់អីវ៉ាន់មកពីផ្សារសង្កែ ។

វគ្គទី ៤

ចោរកម្មកើតឡើងនាកណ្តាលព្រៃស្ងាត់

លុះព្រះអាទិត្យជិតអស្តង្គតទៅ នៅតែមានស្មៅព្រឹង ។ ធ្លុះទៅបុន្តែក្បា បន្តិចក៏ដល់ពេលព្រលប់យប់ងងឹត ចៅចិត្រក៏បង្កាត់ភ្លើងឲ្យឆេះដង្គើល មានពន្លឺភ្លឺច្បាលខ្លាល, ដើម្បីឲ្យមានពន្លឺភ្លឺផង ដើម្បីការពារសត្វសាហាវយង់ឃ្នងផង ។ ឯនាងនាំអង្គុយនិយាយសន្ទនាចប្រាប់នឹងលោកចាន្ទាត់លើកំណាត់ឈើ ១ដុំ មិនចេះអស់មិនចេះហើយ ។ ចំណែកខាងលោកហ្ជួងវិលនសម្បត្តិ ដោយសេចក្តីទ្រឿយហត់អស់កំឡាំង ភេកគ្រែយដែលលោកពិសាគ្រែយរហើយ ក៏ច្បាស់សម្រាន្តលក់ក្នុងថេយន្តទៅ ។

(មានត)

ព្រះធម្មលិខិត ល្វឹ- ឯម រំដើរប្បញ្ញោ

ចៅអធិការវត្តលង្កា ឃុំលេខ ១ ស្រុកត្រពាំងប្រាសាទ ខេត្តបន្ទាយមានជ័យ

ព. ស. ២៤៨៥ គ. ស. ១៩៤៣

សំដែងអំពីពុទ្ធបញ្ញត្តិនឹងពុទ្ធានុញ្ញាតដល់ភិក្ខុ-សាមណេរ ត្រូវប្រតិបត្តិតាមក្នុងព្រះពុទ្ធសាសនា ដូចមានតទៅនេះ :

ភិក្ខុណាមួយចូលទៅកាន់បង្គន់, ភិក្ខុនោះត្រូវស្ថិតនៅខាងក្រៅដែតុ្យរបង្គន់ឲ្យគ្រប់ជាសំគាល់សិន ។ បើមានភិក្ខុចូលទៅអង្គុយខាងក្នុងបង្គន់ហើយ ត្រូវគ្រហែមតបមកវិញជាសំគាល់កុំឲ្យខានឡើយ ។

ភិក្ខុត្រូវដាក់នូវចីវរពាក់លើឫស្សី ឬឈើស្បៀងក្តី ខ្សែស្បៀងក្តី ហើយមិនរួសរាន់ ចូលទៅកាន់បង្គន់ស្រួលល្អ, មិនត្រូវស្ទុះចូលទៅកាន់បង្គន់ដោយឆាប់ហើសពេក, មិនត្រូវលាត់សើយស្បង់ឡើង ហើយចូលទៅកាន់បង្គន់, ត្រូវស្ថិតនៅលើខ្នាប់ដើងបន្ទោបង់នូវលាមក (ហើយបិទបាំងឲ្យជិត) ត្រូវស្ថិតនៅលើខ្នាប់ដើងសម្រាប់បន្ទោបង់នូវលាមក ហើយលាត់សើយស្បង់ឡើង, មិនត្រូវបន្ទោបង់នូវលាមកទំរើងមោត់ឲ្យឮខ្លាំងពេក, មិនត្រូវបន្ទោបង់នូវលាមក ទំពាស៊ីឈើសូនបណ្តើរ,

មិនត្រូវបន្ទោបង់នូវលាមកជាខាងក្រៅទុសប្រហោងខបង្គន់, មិនត្រូវបន្ទោបង់នូវបស្សាវៈជាខាងក្រៅទុសប្រហោងខទឹកនោម, មិនត្រូវទាកស្តោះទឹកមាត់ទឹកកំហាក ឬញើសសំចោរជាក់ក្នុងប្រហោងខបស្សាវៈ, មិនត្រូវកិនទូលាមកដោយចំរៀកឈើ ឬត្បែរឆ្អែតក, ឈើមានបន្លា, ឈើប្រហោង, ឈើស្អុយ ថាបើមិនបានគាន់យកឈើខ្ចិត ហើយចូលទៅកាន់បង្គន់ទេ ត្រូវអាបត្តិទុក្កដ, មិនត្រូវដំលាក់ចោលឈើខ្ចិតក្នុងអ្នកម ឬធុងសម្រាប់ដាក់នូវលាមក ។ (តំកុំធ្វើនូវបច្ចកិច្ចុបហើយ) មិនត្រូវចេញទៅអំពីបង្គន់ដោយឆាប់ហ័សតក, មិនត្រូវលាត់សើយស្បង់ហើយចេញទៅ, ត្រូវស្ថិតនៅលើក្តារឆាប់ដើងសម្រាប់លាងនូវលាមកហើយបិទជាំងឲ្យជិត។ ត្រូវស្ថិតនៅលើក្តារមាប់ដើងសម្រាប់លាងនូវលាមក ហើយលាត់សើយស្បង់ឡើង ។ មិនត្រូវទុកទឹកសម្រាប់លាងឲ្យសល់ក្នុងផ្តិលឬបំពង់សម្រាប់ដាក់ទឹកលាងនូវលាមកនោះឡើយ ។

ក៏ពាក្យថា: មិនត្រូវទុកទឹកឲ្យសល់នៅក្នុងផ្តិលឬបំពង់ សម្រាប់លាងនូវលាមកនោះ ជាពាក្យគឺព្រះធម្មសង្គីតិកាចារ្យលោកពោលសំដៅសព្វសាធារណដ្ឋាន គឺតវែងនូវទៅតាំងអស់ ។ ព្រោះមានសេចក្តីវិនិច្ឆ័យថា: តិកុំតាំងឡាយដូចនេះ។ តែងទៅមកប្រើជាស់ក្នុងទីនោះ ជាប្រក្រតី, ហេតុនោះ តិកុំលាងលាមកមិនត្រូវទុកទឹកក្នុងផ្តិលឬបំពង់

ឲ្យសល់ទៀយ តែកុំឲ្យសល់នៅហើយនឹងត្រឡប់ទៅជាខ្មែរដែលឲ្យ
ត្រូវអាបត្តិទុក្កដ ។

ចំណែកឯខ្មែរនៃនដែលគាយកគេធ្វើដើម្បីទៅមកប្រើប្រាស់ជាប់មិន
ជាប់ កន្លែងវិហារជាឯកទេស ជារបស់នៃសង្ឃក្តី ជារបស់នៃបុគ្គលក្តី
តែកុំឲ្យខ្មែរឲ្យសល់នៅកន្លែងនោះឥតមានអាបត្តិទៀយ ។ ចំណែកឯតែកុំ
ដែលបានធាន់ថ្មាំបញ្ចុះ ហើយទៅតាន់អាចមនផ្តាន់រឿយ។ កុំឲ្យ
សល់នៅកន្លែងផ្តិលឬចំពង់នោះគឺគួរដែរ, ឥតមានអាបត្តិទៀយ ។ ឯតែប្ល
ដែលចូលទៅលាងជំរះលាមក តែកុំត្រូវស្ថិតនៅលើទ្រនាប់ជើង សម្រាប់
លាងទូរលាមក ហើយចៃដន្យាំងឲ្យដួតជាដកថ ។ ថាបើបង្គន់ ប្រឡាក់
លាមកខាងក្រៅប្រហោងខាំងប៉ុន្មាន ត្រូវយកខ្មែរមកលាងជំរះ ឲ្យ
ស្អាតល្អ, បើរកខ្មែរបាន តែឥតកាជនៈ, រកកាជនៈបាន តែឥតខ្មែរ
ឬឥតចាំងខ្មែរចាំងកាជនៈ រកពុំបានសោះទៀយ ត្រូវយកឈើឬតែអ្វី
ទីមួយមកជូតឲ្យជ្រះស្អាតហើយសឹមចេញទៅ ទើបគួរឥតអាបត្តិ ។
ថាបើឈើខ្វិតតរជាតំនរច្រើន ត្រូវយកទៅចោលខាងក្រៅ ។ បើបង្គន់
កយសម្រាមច្រើនតគ្រឹកតគ្រុតមិនស្អាតក្តី ជញ្ជាំងពិតានក្តី ទីបរិវេណក្តី
បន្ទប់ក្តី ស្មោកគ្រោកមិនស្អាត ត្រូវយកអំបោសបោសឲ្យស្អាតបាតល្អ ។
បើខ្មែរកន្លែងកូមឬពាងសម្រាប់លាងទូរលាមកពុំមានទេ ត្រូវទៅដងខ្មែរ
យកមកចាក់កន្លែងកូមឬពាងសម្រាប់លាងលាមកខានពុំបាន ។ ថាបើខ្មែរ

មានហើយ កិក្ខុមិនធ្វើនូវកិច្ចដោយទឹក គឺមិនលាងលាមកត្រូវអាបត្តិទុក្កដ, ព្រោះមានបាលីពុទ្ធបញ្ញត្តិថា:

ន កិក្ខវេ វច្ចំ កត្វា សតិ ឧទកេ ន អាចមេតព្វំ យោ ន អាចមេយ្យ អាបត្តិ ទុក្កដស្ស ។

សេចក្តីថា: ម្នាលភិក្ខុទាំងឡាយ កាលបើទឹកមានហើយ កិក្ខុបន្ទោបង់នូវលាមកហើយ មិនត្រូវមិនលាងឡើយ គឺត្រូវតែលាង តែកិក្ខុឯណាមិនលាង កិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ថាបើទឹកមានហើយ តែមិនស្អាត់ក៏ចាំងគ្មានទេ, កិក្ខុត្រូវយកភាជន:មានផ្តិលជាដើម ដងទឹកយកទៅលាងតែងតែដ៏ស្អាត់ក៏ចាំងចុះ, កាលបើភាជន:មិនមានទេ ត្រូវយកជាតែដងទឹកយកទៅ, បើជាតែមិនមានទៀត ជានឈ្មោះថា មិនមានចាំងទឹកចាំងភាជន: ។ កិក្ខុគិតថា: ទឹកនេះជាសេចក្បាចាកទឹកអស់ហើយ តទៅមុខទៀតនឹងមានទឹកដទៃពិត, លុះដើរទៅខាងមុខរកទឹកពុំបានសោះ, ស្រាប់តែដល់ពេលចង្ហាន់, កិក្ខុត្រូវយកកំណាត់ឈើប្តូរតុអ្វីនីមួយដួតគិតលាមកឲ្យស្អាតចេញ ហើយសឹមទៅទួលធាន់ចង្ហាន់តី អនុមោទនាភត្តតី ក៏គួរតែមានអាបត្តិឡើយ ។

មួយវិញទៀត កិក្ខុចូលទៅកាន់ចង្កន់ ត្រូវចូលទៅតាមលំដាប់នឹងលំដាប់ដែលបានចូលមកដល់តា គ្មានកំណត់, មិនបាច់ចូលទៅតាម

លំដាប់តិក្ខុ-សាមណេរមានវស្សាចាស់ខ្លីឡើយ ដោយចាលិពុទ្ធបញ្ញត្តិនឹង
ពុទ្ធានុញ្ញាតថា :

ន តិក្ខវេ វច្ឆកុដិយា យថាវុឌ្ឍំ វន្ទា តាតញ្ច
យោ តាវេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ តិក្ខវេ
អាគតបដិបាដិយា វន្ទិ តាតុំ ។

សេចក្តីថា: ម្នាលតិក្ខុទាំងឡាយ -- តិក្ខុចូលទៅកាន់ឋានទន្ទោចង់
ទទួលសាមក មិនត្រូវធ្វើតាមលំដាប់តិក្ខុមានវស្សាចាស់ខ្លីឡើយ, តិក្ខុណា
ធ្វើ តិក្ខុនោះត្រូវអាបត្តិទុក្កដ, ម្នាលតិក្ខុទាំងឡាយ ព្រះតថាគតអនុញ្ញាត
ឲ្យដើម្បីធ្វើបន្ទោចង់ទទួលសាមកតាមលំដាប់ទីលំដាប់ដែលតិក្ខុ-សាមណេរ
ចូលទៅកាន់ឋានមុន-ក្រោយជាកំណត់ ។ ក៏ឯលំដាប់ទីលំដាប់នៃតិក្ខុ-
សាមណេរចូលមកតៗគ្នា មិនបានប្រកាន់ថា តិក្ខុ-សាមណេរមានវស្សា
ចាស់ខ្លីជាកំណត់ បានកន្លងទីទាំង ៣គឺ: ទីឋានទី ១ ទីបន្ទោចង់ទទួលបស្សាវៈ
១ ទីសម្រាប់លាងទទួលសាមក ១ ដោយពិត ។ តិក្ខុ-សាមណេរដែលបួស
សំណាក់ក្នុងព្រះពុទ្ធសាសនានេះ ត្រូវតែយកចិត្តទុកដាក់ប្រតិបត្តិឲ្យត្រឹម
ត្រូវតាមពុទ្ធបញ្ញត្តិទីឋានានុញ្ញាតអំពីវច្ឆកុដិវត្តនេះ ទើបរួចពីកំហុស
ទាំងពួងពិត ។ បើតិក្ខុប្រព្រឹត្តកន្លងទទួលពុទ្ធបញ្ញត្តិឋានណាមួយ ដូចបាន
សំដែងមកហើយនេះទើងត្រូវអាបត្តិទុក្កដកល់ៗបទ, បើសាមណេរវិញទើង
ត្រូវខណ្ឌកម្មកល់ៗបទ តាំងបានរួចពីកំហុសទាំងពួងឡើយ ។ ដូចមាន

គាថាក្នុងគម្ពីរព្រះវិនយនៃសិក្ខាបទនេះ លោកសំដែងប្រាប់ពោសធនឯ
អានិសង្សថា :

វត្តំ អបរិបូរេត្តា សីលំ ន បរិបូរតិ
អសុទ្ធសីលោ ទុប្បញ្ញោ ចិត្តេកគ្គំ ន វិន្ទតិ
វិក្ខិត្តចិត្តោនេកគ្គោ សម្មា ធម្មំ ន បស្សតិ
អបស្សមានោ សទ្ធម្មំ ទុក្ខា ន បរិមុច្চតិ ។

សេចក្តីនិន្ទាថា: សមណាឯណា មិនបានបំពេញនូវវត្តរបស់ខ្លួន
ឲ្យពេញបរិបូណ៌តាមភាវៈបញ្ញត្តិនឹងព្រះពុទ្ធានុញ្ញាតទេ, បានឈ្មោះថាមិន
បានបំពេញនូវសីលរបស់ខ្លួនឲ្យពេញបរិបូណ៌ឡើយ, សមណានោះឯង
បានឈ្មោះថា មានសីលមិនបរិសុទ្ធស្អាតហ្មត់ចត់ កំណត់ថាមានប្រាជ្ញ
តិចក្រក់ គឺអាប់ឥតបញ្ញាសោះ, ជាបុគ្គលមិនបានទូវចិត្តនឹងនោកន្ធអា-
រម្មណ៍តែមួយគឺសមាធិឡើយ; ជាបុគ្គលរមែងមានចិត្តរវើរវាយកយមាយ
មិននឹងនៅក្នុងសមាធិចិត្ត, កាលបើពុំបានឃើញនូវសមាធិធម៌ជារបស់
សប្បុរសដោយល្អប្រពៃហើយ, បានឈ្មោះថា ពុំបានរួចចាកវដ្តទុក្ខនឹង
អាចារ្យទុក្ខដោយពិត ។

យោ វត្តំ បរិបូរេត្តា សីលំ សោ បរិបូរតិ
វិសុទ្ធសីលោ សប្បញ្ញោ ចិត្តេកគ្គម្បិ វិន្ទតិ

អវិក្ខិត្តចិត្តេកគ្គោ សម្មា ឧម្មុំ វិបស្សតិ

សម្បស្សមានោ សទ្ធម្មំ ទុក្ខា សោ បរិមុច្ចតិ ។

សេចក្តីសរសើរថា: សមណៈឯណា ចាន់ព្យាយាមបំពេញនូវវត្តរបស់ខ្លួនឲ្យពេញបរិបូណ៌តាមពុទ្ធបញ្ញត្តិន៍ដ៏ពុំខ្វះខ្វាតពិត, សមណៈនោះមានឈ្មោះថា ចាន់ព្យាយាមបំពេញនូវសីលរបស់ខ្លួនឲ្យពេញបរិបូណ៌តាមពុទ្ធបញ្ញត្តិន៍ដ៏ពុំខ្វះខ្វាតពិត, ចាន់ឈ្មោះថា មានសីលបរិសុទ្ធស្អាតហ្មត់ចត់ តំណាត់ថាមានបញ្ញាស្អាងដោយវិសេស, ជាបុគ្គលចាន់នូវចិត្តនឹងនៅកន្ត៍អារម្មណ៌តែមួយគឺសមាធិពិត, ជាបុគ្គលមានចិត្តពុំចាន់រាយមាយ នឹងនៅក្នុងសមាធិចិត្ត, តាំពីរណាឃើញនូវសមាធិធម៌ដោយច្បាស់, កាលបើចាន់តាំពីរណាឃើញនូវសមាធិធម៌ជារបស់សប្បុរសដោយច្បាស់ហើយ, សមណៈនោះចាន់ឈ្មោះថា រួចចាកវដ្តទុក្ខន៍អចាយទុក្ខដោយពិត ។

សំដែងវិប្ផកុដិវត្ត ចប់តែប៉ុណ្ណេះឯង ។

ព្រះគ្រូឧត្តមមុនី មុំង-សៃស ប្រែនឹងរៀបរៀង

អារម្ភកថា

សៀវភៅធម្មគោរពនេះ ទំយោយអំពីការគោរពធម៌ដោយសង្ខេប ខ្ញុំបានស្រាវជ្រាវរៀបរៀងឡើង ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា របស់ពុទ្ធសាសនិកជនពាំងឡាយដែលត្រូវការសិក្សារៀនសូត្រធម្មវិន័យពុទ្ធសាសនា ការដែលរៀនហើយត្រូវតែប្រតិបត្តិតាម ត្រូវតែគោរពទើបមានផលានិសង្សច្រើន ព្រោះហេតុនោះ សប្បុរសពាំងឡាយគួរសិក្សារៀនសូត្រឲ្យចេះចាំច្បាស់លាស់ ហើយគោរពឲ្យមែនទែន យកជាកុប់ជាកតាមព្រះពុទ្ធជាម្ចាស់ នឹងព្រះបរមគ្រូតគ្រាជាជាពល់។ ព្រះអង្គដែលកន្លងទៅហើយ នឹងបានសេចក្តីសុខ-ចំរើនកន្លងលោកនេះនឹងលោកខាងមុខ នឹងបានសម្រេចព្រះនិព្វានជាអសោន ។

ព្រះគ្រូឧត្តមមុនី មុំង-សៃស អធិបតីមន្ទីរ ប្រែព្រះត្រៃបិដក

គារវសូត្រ

ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយព្រះដ៏មានព្រះភាគទ្រង់បានគ្រាស់ដឹងជាដំបូង ទ្រង់គង់គ្រាមដើមអជបាលនិគ្រោធទៀបឆ្នេរស្ទឹងនេរញ្ជរ ក្នុងទីរំលេចទេស ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តួន

សម្ងំនៅក្នុងទីស្ងាត់ ទ្រង់ត្រេះដំរែះថា សត្វដែលមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង រមែងនៅជាទុក្ខ ចុះតថាគតគួរសក្ការគោរព អាស្រ័យនឹងសមណៈឬព្រាហ្មណ៍ណាហ្ន៎ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រេះដំរែះតទៅទៀតថា គួរតែតថាគតសក្ការគោរពអាស្រ័យនូវសមណៈឬព្រាហ្មណ៍ដទៃ ដើម្បីបំពេញនូវសីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញ្ញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញលេញ តែថាក្នុងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស តថាគតមិនឃើញមានសមណៈឬព្រាហ្មណ៍ដទៃដែលមានសីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ និងវិមុត្តិញ្ញាណទស្សនក្ខន្ធ ពេញលេញជាងតថាគតឡើយ បើដូច្នោះ ធម៌ឯណាដែលតថាគតបានត្រាស់ដឹងហើយ គួរតែតថាគតសក្ការគោរពអាស្រ័យនូវធម៌នោះតែប៉ុណ្ណោះចុះ ។

គ្រានោះ សហម្បតីព្រហ្មបានជ្រាបព្រះដំរែះរបស់ព្រះដ៏មានព្រះភាគដូច្នោះហើយ ក៏ចុះចាកព្រហ្មលោកមកជ្រាកដក្នុងទីចំពោះព្រះភក្ត្រ ព្រះដ៏មានព្រះភាគដោយឆាប់ហ័ស ប្រៀបដូចជាបុរសមានកំលាំង លាចេញនូវដៃដែលខ្ជួចបត់ចូល ឬបត់ចូលនូវដៃដែលខ្ជួចលាចេញ ។ លំដាប់នោះ សហម្បតីព្រហ្មពានាសំពត់ចង់កនៀងស្មាម្ខាង

ហើយប្រណម្យអញ្ជលីផ្គងទៅរកព្រះដ៏មានព្រះភាគហើយក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ព្រះដំរិះនោះត្រូវហើយ។ ព្រោះថា ព្រះអរហន្តសម្មាសម្ពុទ្ធ ក្នុងអតីតកាលលោកគោរពតែត្រឹមធម៌ប៉ុណ្ណោះ ព្រះអរហន្តសម្មាសម្ពុទ្ធ ក្នុងអនាគតកាលក៏គោរពតែត្រឹមធម៌ប៉ុណ្ណោះដែរ ចំណែកព្រះអង្គជាអរហន្តសម្មាសម្ពុទ្ធ ក្នុងបច្ចុប្បន្ននេះ ក៏សូមគោរពតែត្រឹមធម៌ប៉ុណ្ណឹងចុះ។ ទើបសហម្បតីព្រហ្មភោលភាសានេះតទៅទៀតថា:

យេ ច អតីតា សម្ពុទ្ធា យេ ច ពុទ្ធា អនាគតា
យោ ចេតរហិ សម្ពុទ្ធោ ពហុន្នំ សោកនាសនោ
សព្ពេ សទ្ធម្មគរុនោ វិហរឹសុ វិហរន្តិ ច
អថាបិ វិហរិស្សន្តិ ឯសា ពុទ្ធាន ធម្មតា
តស្មា ហិ អត្តកាមេន មហត្តមភិកង្ខតា
សទ្ធម្មោ គរុកាតព្ពោ សរំ ពុទ្ធាន សាសនំ ។

(ប្រែថា) ព្រះសម្ពុទ្ធក្នុងអតីតកាលក្តី ព្រះសម្ពុទ្ធក្នុងអនាគតកាលក្តី ព្រះសម្ពុទ្ធក្នុងបច្ចុប្បន្ននេះក្តី រមែងញុំាងសេចក្តីសោករបស់ជនច្រើនឲ្យរំងាស លោកមានសេចក្តីគោរពព្រះសទ្ធម្មជាំងអស់នេះជាធម្មតារបស់ព្រះពុទ្ធជាំងឡាយ ព្រោះហេតុនោះ អ្នកដែលស្រឡាញ់ខ្លួនចង់ថ្កុំ

ន័ងធ្វើខ្លួនឲ្យថ្លៃថ្លា គួរលើកសាសនារបស់ព្រះពុទ្ធ គួរគោរពព្រះសទ្ធម្ម ឲ្យមាំមួន ។

(ចប់ការវិស្សជ្ជនា)

ក៏ឯព្រះសទ្ធម្មនោះ មាន ៣ យ៉ាង គឺបរិយត្តិសទ្ធម្ម ចានដល់ពុទ្ធវចនទាំងអស់ សង្គ្រោះដោយបិដកទាំង ៣ គឺវិនយបិដក សុត្តន្តបិដក អភិធម្មបិដក ជាធម្មចក្ខុលើកច្បាប់ផ្លូវប្រតិបត្តិ គឺសីល សមាធិ វិបស្សនា មគ្គនិងផល និព្វាន ១ ។ បដិបត្តិសទ្ធម្ម ចានដល់ធុតង្គគុណ ១៣ ខន្ធកវត្ត ១៤ មហាវត្ត ៨២ នូវសីល សមាធិ វិបស្សនា ។ អធិគមសទ្ធម្ម ចានដល់អរិយមគ្គ ៤ សាមញ្ញផល ៤ នូវព្រះនិព្វាន ១ ។

សេចក្តីនេះ យើញថាព្រះជាម្ចាស់ទ្រង់គោរពធម៌ដូចចានគោលមក ហើយ ចំណែកសត្វដទៃក៏គួរគោរពធម៌ដូច្នោះដែរ ព្រោះពួកសត្វដែលគ្មានការគោរព រមែងគ្មានសេចក្តីសុខ-ចំរើនឡើយ ហេតុដូច្នោះ ពួកសប្បុរសទាំងបព្វជិតទាំងគ្រហស្ថគួរគោរពព្រះសទ្ធម្មទាំង ៣ យ៉ាងនោះដោយអើពើ ។

ឯពាក្យថា "គោរពព្រះសទ្ធម្ម" នោះ គឺសិក្សារៀនសូត្រ ស្តាប់ព្រះវិនយបិដកឲ្យចេះចាំច្បាស់លាស់ហើយកាន់តាម ប្រតិបត្តិតាមសិក្ខាបទដែលព្រះអង្គបញ្ញត្តអនុញ្ញាតនុកមកយ៉ាងណា ហៅថា គោរពព្រះសទ្ធម្ម គឺវិនយបិដក ។

កុលបុត្រសិក្សារៀនសូត្រស្តាប់ព្រះសុត្តន្តបិដក ជាធម៌សំដែងអំពីផ្លូវប្រតិបត្តិ កុសល អកុសល បុណ្យ ផាប គុណ ទោស បានចេះចាំបា្រស់លាស់ហើយកាន់តាម ប្រតិបត្តិតាមព្រះសូត្រនោះ។ ហៅថាគោរពព្រះសទ្ធម្ម គឺព្រះសុត្តន្តបិដក ។

កុលបុត្រសិក្សារៀនសូត្រស្តាប់ព្រះអភិធម្មបិដក ជាធម៌សំដែងអំពីចិត្ត ចេតសិក រូប និព្វាន ជាដើម បានចេះចាំបា្រស់លាស់ហើយកាន់តាមប្រតិបត្តិតាម ហៅថាគោរពព្រះសទ្ធម្ម គឺព្រះអភិធម្មបិដក ។ ចាំង ៣ យ៉ាងនេះហៅថាគោរពបរិយត្តិសទ្ធម្ម ។

ពួកកុលបុត្រប្រព្រឹត្តត្រឹមត្រូវក្នុងធុតង្គគុណ ចាំង ១៣ ជាធម៌ញ៉ាំងសីលឲ្យផូរផង់ឲ្យក្រអូបក្រអែបឈ្ងុយឈ្ងប់ឡើង ប្រព្រឹត្តត្រឹមត្រូវក្នុងខន្ធកវត្ត ១៤ [1] នីឝមហាវត្ត ៨២ [2] ចាំងប្រព្រឹត្តសីលឲ្យបរិសុទ្ធល្អលុះសីលបរិសុទ្ធហើយ ក៏សិក្សារៀនសមថកម្មដ្ឋាន ទំពាំរនែតិចារណាត្រាតែបានសម្រេចកូមិសមាធិ ឬសមាបត្តិចាំង ៨ គឺរូបសមាបត្តិ ៤ អរូបសមាបត្តិ ៤ បានសម្រេចសមាធិហើយ ក៏សិក្សារៀនសូត្រក្នុងវិបស្សនា-

---

១ ខន្ធកវត្ត ១៤ មានអាគន្តុកវត្ត គឺវត្តបេស់អាគន្តុកភិក្ខុជាដើម មកក្នុងវត្តក្ខន្ធកតន្តីបោលវគ្គ។
២ ឧបាលិវត្ត ៨២ ដែលព្រះអង្គបញ្ញត្តទុកមានពាក្យថា ខ ឧបសម្បាទេតព្វំ ភិក្ខុមិនត្រូវឲ្យឧបសម្បាទិលំកុលបុត្រជាដើម មកក្នុងចារិសិក្ខន្ធកខ្លះ កម្មក្ខន្ធកត្រង់ទង្វេចតិយកម្មខ្លះ តន្តីបោលវគ្គ ។

កម្មដ្ឋាន ១ចំរើនពិចារណា តែតែបានសម្រេចរហូតដល់តែកូញ្ញាណ ដូច្នេះ ហៅថាគោរពព្រះសទ្ធម្ម តឹបដិបត្តិសទ្ធម្ម ។

កុលបុត្រចំពេញសេចក្តីប្រតិបត្តិ គឺសីល សមាធិ បញ្ញា បានសម្រេចមគ្គផល និព្វាន ហៅថាគោរពព្រះសទ្ធម្ម គឺអធិគមសទ្ធម្ម ។

១ទៀត បរិសទ្យទាំង ៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាបាន គោរពធម៌ប្រតិបត្តិធម៌របស់ព្រះសម្មាសម្ពុទ្ធហើយ ក៏ឈ្មោះថាគោរព ប្រតិបត្តិបូជាដល់ព្រះពុទ្ធជាម្ចាស់ផង ទ័ងបានផលានិសង្សយ៉ាងវិសេស ដូចព្រះបាលីថា:

យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មបដិបន្នោ វិហរតិ សាមីចិបដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ការេតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ ។

(ប្រែថា) ម្នាលអានន្ទ បុគ្គលឯណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី ជាឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយផ្លូវត្រង់ ជាអ្នកប្រព្រឹត្តតាមគន្លងធម៌ បុគ្គលនោះបានឈ្មោះថា សក្ការគោរពកាន់អានូជាព្រះតថាគត ដោយគ្រឿងបូជាដ៏ខ្ពង់ខ្ពស់ ។ ពាក្យថា "ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌" នោះគឺបុព្វភាគ-

ប្រតិបត្តិដ៏សមគួរដល់លោកុត្តរធម៌ទាំង៩ ។ ឯបុព្វភាគប្រតិបត្តិនោះ គឺសេចក្តីប្រតិបត្តិជាចំណែកខាងដើម បានដល់សីលនឹងអាចារប្បញ្ញត្តិ ទីឆុតង្គសមាទាន ។ ពាក្យថា "ប្រតិបត្តិដោយផ្លូវត្រង់" បានដល់ការប្រតិបត្តិសមាធិ វិបស្សនា រហូតដល់គោត្រភូញ្ញាណ ។ សេចក្តីគោរពធម៌ចេស់បំរើសទ្យទាំង៤ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរយ៉ាងនេះឯង ។

ទៀត សូម្បីព្រះបរមគ្រូពាក់ព័ន្ធក៏ទ្រង់មានសេចក្តីគោរពព្រះធម៌ដែរ ដូចមានរឿងកង្គតម្ពវអគ្គតាទេតាយបញ្ហកនិទ្ទានថា:

សម័យមួយ មានតិក្ខុមួយអង្គចូលទៅគាបបង្គំទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សាវ:ដូចម្តេចជាស្តេច គឺជាធំលើព្រះពាជាចក្រពត្តិដែលទ្រង់ធម៌ ។ ព្រះអង្គមានព្រះបន្ទូលថា:

ឥធ តិក្ខុ ភដា ចក្កវត្តី ធម្មិកោ ធម្មរាជា ធម្មញ្ញូ ធម្មំ សក្កច្ចំ ធម្មំ សក្កច្ចោ ធម្មំ ករុកច្ចោ ធម្មំ អបចាយន្តោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តិំ សំវិធហតិ អន្តោជនស្មិំ ។

(ប្រែថា) ម្នាលតិក្ខុ ព្រះពាជាចក្រពត្តិក្នុងលោកនេះជាធម្មរាជប្រកបដោយធម៌ ទ្រង់អាស្រ័យនូវធម៌ ទ្រង់សក្ការធម៌ គោរពធម៌ កោតក្រែង

ធម៌ មានធម៌ជាទង់ជ័យ មានធម៌ជាទង់សំគាល់យស មានធម៌ជាធំ ទ្រង់ចាត់ចែងនូវការពារក្សា ការពារគ្រប់គ្រងប្រកបដោយធម៌ដល់ពួកជនដែលនៅក្រោមបង្គាប់ ។

ពាក្យថា "ធម៌" ក្នុងទីនេះ សំដៅយកកុសលកម្មបថ ๑๐ គឺ កាយកម្ម ๓ វចីកម្ម ๔ មនោកម្ម ๓ ឬនសេចក្តីថា ព្រះបាទបរមបក្ក-ពត្តិពង្ស ទ្រង់គោរពធម៌ គឺកុសលកម្មបថ ๑๐ ហេតុនោះមនុស្សទាំង-ឡាយគួរគោរពកុសលកម្មបថនោះ តាមគន្លងព្រះបាទបក្កពត្តិពង្ស ជាធម៌ធ្វើខ្លួនឲ្យថ្លៃថ្នូរឯកល់ជាតិ ។

๑ វិញទៀត កុសលកម្មបថនេះបើបុគ្គលបានគោរព គឺថាបានប្រតិ-បត្តិដោយប្រពៃហើយ ក៏អាចឲ្យសំរេចសម្បត្តិទាំង ๓ ប្រការ គឺបានជា អ្នកប្តើនខ្លួនក្នុងមនុស្សលោក ๑ បានទៅកើតជាទេវតាដោយសមគួរតាម ប្រាថ្នា តាំងអំពីស្ថានចាតុម្មហារាជិកា រហូតដល់អកនិដ្ឋព្រហ្ម ๑ បាន សំរេចអរហត្តផល ជាទីបំផុតជាតិ ជរា ព្យាធិ មរណៈ ๑ ។

សមតាមបាលីពុទ្ធភាសិត សារេយ្យកសូត្រ គម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសក សេចក្តីក្នុងសូត្រនោះថា បុគ្គលពួក ๑ ក្នុងលោកនេះលះ បង់ចាណាតិបាត រៀរចាកចាណាតិបាត លែងកាន់ដំបងគ្រឿងប្រយុទ្ធ លែងប្រហារជីវិតសត្វ មានសេចក្តី ខ្មាសបាបខ្លាចបាប ប្រកបដោយសេចក្តីអាណិតអាសូរសព្វសត្វ ដោះ

សត្វឲ្យរួចអំពីទុក្ខលំបាក ត្រូវគោរពនឹកបំរុងឲ្យបានសេចក្តីសុខ-ចំរើន ។ លះបង់អទិន្នាទាន រៀបចាកអទិន្នាទាន មិនបានប្លន់កំហែងដណ្តើមយកទ្រព្យគេ មិនលួចលាក់ធាក់បំបាត់ច្រឹកភ្នែនបោកប្រាស់នៃបន្ទុំយកទ្រព្យអ្នកដទៃ ។ លះបង់កាមេសុមិច្ឆាចារ រៀបចាកកាមេសុមិច្ឆាចារ មិនបានសេពសម្ផុតគប់រក ប្តូរប្រពិត្តអសទ្ធម្មចំពោះស្ត្រីដែលមានមាតាថែរក្សា មានបិតាបងប្អូនប្រុសបងប្អូនស្រីពួកញាតិថែរក្សា ខ្ទង់ស្ត្រីដែលមានប្តីគ្រប់គ្រង ខ្ទង់ស្ត្រីដែលមានព្រះពជាត្រូវគោរឲ្យថែរក្សាជាក់ការជ្រះព្រះពជខណ្ឌ មិនឲ្យបុរសណាមួយទៅប្រពិត្តល្មើសតាមអំពើចិត្ត ។ ដូច្នេះហៅថាកាយកម្ម ៣ ។

បុគ្គលពួក ១ ក្នុងលោកនេះ លះបង់មុសាវាទ រៀបចាកមុសាវាទ ពោះបីទៅកន្លែងប្រជុំក្តី ទៅកន្លែងណាលបរិសទ្យក្តី ទៅកន្លែងណាលពពួកញាតិក្តី ទៅកន្លែងណាលពពួកសេនាក្តី ទៅកន្លែងណាលពដត្រូវដោយគេនាំទៅធ្វើជាសាក្សី ដើម្បីសួរបញ្ជាក់រឿងក្តីណាមួយក្តី ក៏និយាយតាមពិតតាមមែនតាមដឹងតាមឃើញ មិននិយាយភាក្យកុហកបញ្ឆោតបង្កាច់ផ្តាច់ប្រយោជន៍អ្នកដទៃ ។ លះបង់បិសុណាវាចា រៀបចាកបិសុណាវាចា ជាភាក្យញុះញង់ប្តូរសិកសៀត មិនបានឮភាក្យសំដីអំពីអ្នកឯណោះហើយនាំយកទៅប្រាប់អ្នកឯណោះ ដើម្បីបំបែកអ្នកឯណោះឬថាមិនបានឮភាក្យសំដីអំពីអ្នកឯណោះហើយ នាំយកមកប្រាប់អ្នក

ឯណោះ ដើម្បីបំបែកអ្នកឯណោះវិញ កាលបើមានគេជាស់ចែងគ្នា ជាក់បែកគ្នា ក៏យកចិត្តទុកជាក់និយាយផ្សះផ្សាឲ្យជានឹងគ្នា កាលបើគេជានឹងគ្នាស្រាប់ហើយ ក៏និយាយថែមកម្ចាំងឲ្យរឹងតែតែងជានឹងគ្នាទៀង ទៀត ជាអ្នកត្រេកអរស្រឡាញ់ចូលចិត្តនឹងការត្រមៃគ្នា តែងពោលនូវពាក្យដែលធ្វើឲ្យគេត្រមៃគ្នា ។ លុះបង់ផរុសវាចា វៀរចាកផរុសវាចា ជាពាក្យអាក្រក់ខ្លះគោះ គេម្ចាស់គេម្ចាមដោះដឹងចាក់ដោតបញ្ជឹចិត្ត ពោលតែពាក្យល្អឥតទោស ទាំមកនូវសេចក្តីសុខដល់គ្រប់ៗគ្នា ជាពាក្យ ខ្ចាន់ផ្អែម ពីពោះគួរស្រឡាញ់គួរចូលចិត្ត ។ លុះបង់សម្ផប្បលាប វៀរ ចាកសម្ផប្បលាប ជាពាក្យពោយពាយឥតប្រយោជន៍ ជាពាក្យគ្មុកគំថ្កែង លេងសើចឥតអំពើ ពោលតែពាក្យដែលមានប្រយោជន៍ដល់ខ្លួនឯងអ្នក ដទៃ ពោលកន្លងកាលដែលគួរ ពោលពាក្យពិត ពាក្យដែលត្រូវតាមអក្ខ តាមធម៌តាមវិន័យ ។ ដូច្នេះហៅថាវចីកម្ម ៤ ។

បុគ្គលពួក ๑ ក្នុងលោកនេះ មិនបង់បានទ្រព្យអ្នកដទៃមក ជាទ្រព្យរបស់ខ្លួន មិនរលេមរលមធ្វើឲ្យឈ្នួតយកនូវពែងបង់នឹងបង្ហើនទ្រព្យអ្នកដទៃមកដើម្បីខ្លួន ។ មិនមានចិត្តប៉ុនប៉ងនឹងធ្វើប្រយោជន៍នឹងសេចក្តីសុខរបស់អ្នកដទៃឲ្យវិនាស ។ មានបញ្ញាយល់ត្រូវ តាមសភាវៈធម៌ មិនបានយល់ខុសចាកសភាវៈធម៌ ។ ដូច្នេះហៅថា មនោកម្ម ៣ ។ កាយកម្ម ៣ វចីកម្ម ៤ មនោកម្ម ๓ ដូចបានពោល

មកនេះហៅថាកុសលកម្មបថ ๑๐ ។ ឯកុសលកម្មបថនេះ បើបុគ្គលឯណា
ចាន់គោរពតឹថាចាន់ប្រតិត្តតឹមត្រូវល្អហើយ ពោះបើបុគ្គលនោះមានចិត្ត
ប្រាថ្នាចង់ទៅកើតក្នុងត្រកូល ๓ គឺយមហាសាលក្តី ព្រាហ្មណមហាសាល
ក្តី គហបតិមហាសាលក្តី ក៏ចាន់សំរេចដូចប្រាថ្នាមិនខានឡើយ ។ ពាក្យ
ថា "๓ គឺយមហាសាល" គឺត្រកូលក្សត្រដែលមានទ្រព្យ ๘ កោដិ ๑ ភ្នំមាស
ព្រាហ្មណមហាសាល ទំនឹងគហបតិមហាសាលក៏ដូចគ្នា ។ ๑ ទៀត បើ
ប្រាថ្នាចង់ទៅកើតជាទេវតាក្នុងស្ថានចាតុម្មហារាជិកា . . . តាវត្តឹង្ស . . .
យាមា . . . តុសិត . . . និម្មានរតី . . . បរនិម្មិតវសវត្តី ក៏ចាន់សំរេច
ដូចប្រាថ្នាមិនខាន ។ ๑ ទៀត បើមានប្រាថ្នាទំនឹងទៅកើតក្នុងព្រហ្មលោក
តាំងអំពីព្រហ្មបារិសជ្ជាវហូតដល់អកនិដ្ឋព្រហ្ម ក៏ចាន់សំរេចដូចប្រាថ្នា ។
๓ ទៀត បើប្រាថ្នាចង់ឲ្យចាន់អរហត្តផលដ៏ខ្ពង់ខ្ពស់ជាងធម្មតាំងពួង ក៏
ចាន់សំរេចដូចប្រាថ្នា ដោយហេតុដែលចាន់ប្រតិត្តកុសលកម្មបថនោះ
ជាប្រធាន ។ ការប្រតិត្តកុសលកម្មបថអាចឲ្យចាន់សំរេចសម្បត្តិ ๓
ប្រការដូច្នេះឯង ។

ចប់តែប៉ុណ្ណេះ ។

អំពីប្រឡងរើសសិស្សថ្មី

ចូលរៀនសាលាបាលីជាន់ខ្ពស់ក្រុងភ្នំពេញ ឆ្នាំ ១៩៤៣

របៀបរៀបចំរបស់សាលាបាលីជាន់ខ្ពស់ រៀងពីឆ្នាំមកនោះ គឺលុះដល់ឆ្នាំខែ ៤ ទើបប្រឡងចេញចូលហើយ សាលាបាលីជាន់ខ្ពស់ត្រូវការប្រឡងរើសសិស្សថ្មី ឲ្យចូលរៀនក្នុងថ្នាក់ឆ្នាំទី ១ តាមព្រះរាជប្រកាសដែលពាជការអនុញ្ញាតឲ្យប្រឡងចូលរៀន ។

មុនដែលនឹងប្រឡងសិស្សថ្នាក់ឆ្នាំទី ៤ ចេញទៅនោះ ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ ចាងហ្វាងសាលាបាលីជាន់ខ្ពស់ នឹងលោកគ្រូបង្រៀនគ្រប់ថ្នាក់ បានចាត់ការប្រឡងល្បងវិជ្ជារបស់សិស្សផ្តាច់ឆ្នាំឡើងថ្នាក់តាមលំដាប់ថ្នាក់ គឺប្រឡងសិស្សថ្នាក់ឆ្នាំទី ១ ឡើងទៅថ្នាក់ឆ្នាំទីពីរ ។ ឡើងទៅថ្នាក់ឆ្នាំទីបី ។ ឡើងទៅថ្នាក់ឆ្នាំទី ៤ ។

ឯកាលដែលប្រឡងសិស្សថ្នាក់ឆ្នាំទី ៤ ចេញផុតទៅនោះ ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ បានទទួលបញ្ជីឈ្មោះអ្នកប្រឡងអំពីពាជការមកចំនួន ៣៩៨ រូបជាកូនសិស្សសាលាបាលីវត្តគ្រប់វត្តដែលសុំបុះឈ្មោះចូលប្រឡងរៀនក្នុងសាលាបាលីជាន់ខ្ពស់ ហើយបានចាត់របៀបរៀបចំចម្ងល់ឈ្មោះអ្នកប្រឡងទាំងនោះ លៃសង្កត់ឲ្យគ្រប់ចំនួនក្នុងដែលមានក្នុងកន្ទែងទាំង ៤ ថ្នាក់ ទឹងសាលារដ្ឋបាលផង គឺឲ្យដឹងចំនួន

កន្លងថ្នាក់ឆ្នាំមួយ ។ ត្រូវអគ្គិយបានអ្នកប្រឡងប៉ុន្មាននាក់ ហើយបានសារៈសោរឈ្មោះអ្នកប្រឡងជាក់កន្លងចញ្ជើយកទៅបិទភ្ជាប់ត្រង់កន្លែងមាត់ទ្វារដែលចូលទៅគ្រប់ថ្នាក់ទាំង ៤ ហើយនឹងកេងថែរក្សាសាលាចាស់ ដើម្បីឲ្យអ្នកប្រឡងសំគាល់ដឹងឈ្មោះរបស់ខ្លួនពីថ្ងៃមុនឲ្យហើយ កុំឲ្យពិបាកដល់ពេលចូលប្រឡង ។

លុះដល់ថ្ងៃចន្ទ ១១ កើត ខែមាឃ ឆ្នាំមមីចត្វាស័ក ត្រូវនឹងថ្ងៃ ១៥ ហ្វេវ្រៀយេ ឆ្នាំ ១៨៤៣, វេលាព្រឹកម៉ោង ៧ កន្លះ ពួកអ្នកប្រឡងចំនួន ៣៥៨ រូប ក៏បានមកជួបជុំគ្នាពេញត្រៀបត្រានៅមន្ទីរសាលាចាស់ ២ កន្លះ សាលារដ្ឋចាស់ ២ កន្លះ ហើយចូលទៅអង្គុយលើតុត្រៀមរង់ចាំលោកជាមេប្រយោគយកតួប្រយោគទៅឲ្យធ្វើការប្រឡងកន្លងពេលនោះ ។

ដល់វេលាម៉ោង ៨ ក្រុមសន្ធំចាតកុម្ម៉ង់ ចានអញ្ជើញចានឥមន្តមកជួបជុំធ្វើសេចក្តីដំនុំ នៅមន្ទីរសាលាចាស់ជាន់ខ្ពស់ ចំពោះមុខអ្នកប្រឡងកាលគ្នាដើម្បីនឹងពិនិត្យការប្រឡងចូលនេះ:

មានលោក អ្នកឧកញ៉ាអគ្គមហាសេនា អ៊ីង-អ៊ី, សេនាបតីក្រសួងព្រះបរមរាជវាំងព្រះហ្ស៊ាំង ឧត្តមធម្មការ ជាអធិបតីនៃក្រុមដំនុំ ។

លោកឌុយប៊ុងត៍, អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។

ព្រះតេជព្រះគុណ ព្រះអមរាភិរក្ខិតជុំ, ជំណាងព្រះសង្ឃនាយកគណធម្មយុត្តិ ។

១- ព្រះតេជព្រះគុណ ព្រះអរិយធម្មមុនី ប៉ុល, ដំណាងសម្តេចព្រះសង្ឃនាយកគណមហានិកាយ ។

២- ព្រះតេជព្រះគុណ ព្រះពុទ្ធយោសាចារ្យ ជួន-ណាត, ចាងហ្វាង សាលាចាស់ជាន់ខ្ពស់ ។

៣- ព្រះតេជព្រះគុណ ព្រះមហាព្រហ្មមុនី ខេព-អ៊ូ, ចាងហ្វាងរង សាលាចាស់ជាន់ខ្ពស់ ។

៤- ព្រះតេជព្រះគុណ ព្រះសាក្យវង្ស ហួត-តាត, គ្រូបង្រៀនសំស្កឹត សាលាចាស់ជាន់ខ្ពស់ ។

- លោកគ្រូ ព្រះអាចារ្យ ចែន-សុខ, គ្រូបង្រៀនថ្នាល់ សាលាចាស់ជាន់ខ្ពស់ ។

៥- លោកគ្រូ ព្រះអាចារ្យ ឈឹម - ស៊ុម គ្រូបង្រៀនថ្នាល់ សាលាចាស់ជាន់ខ្ពស់ ។

- ព្រះគ្រូ សុមេធមុនី ឋិតសីលោ, គ្រូបង្រៀនថ្នាល់ សាលាចាស់ជាន់ខ្ពស់ ។

- ព្រះគ្រូ ពោធិវង្សាចរិយាព្រឹទ្ធ ភជ - កឹង, គ្រូបង្រៀនថ្នាល់ សាលាចាស់ជាន់ខ្ពស់ ។

- លោកគ្រូ ព្រះអាចារ្យ គៅ - សឹម, ស្នៀនសាលាចាស់ជាន់ខ្ពស់ ។

ជាអ្នកជំនុំដែលមានអវត្តែរតេ លោកឡឺវេស៊ូដន៍សុបេរិយើរ លេខ ១៣៦ ចុះថ្ងៃ ១៤ ឃុំធំរិយេរ ឆ្នាំ ១៩៤៣ ដែលតាំងតាមអំណាចអវត្តែរតេ លោកគូវេរណើរហ្សូណាល់លេខ ៨៧៥១ ចុះថ្ងៃ ១ ដេសម្រ្ប ឆ្នាំ ១៩៤៦ ត្រង់ប្រការ ១៤ នឹងប្រការ ១៥ បើកនុតាសឲ្យតំនិត្យចំណេះវិជ្ជាឈ្មោះអ្នកដែលចូលប្រឡងយកទីជាសិស្សរៀនក្នុងសាលាជាលើជាន់ខ្ពស់ចំនួន ៣៥៨ រូប ដែលមានពាយចំនួនវត្តតាមលំដាប់តទៅខាងក្រោយនេះ

១—	វត្ត ទណ្ឌាលោម ភ្នំពេញ	១៣៨ រូប	១៨—	វត្ត មណីសាគរ ពណ្តាល	១ រូប
២—	" លង្កា "	៩៦ "	១៩—	" ក្បាលកោះអន្ទង់ចិន "	១ "
៣—	" បទុមវតី "	៩ "	២ —	" សុវណ្ណភារ "	១ "
៤—	" ស្វាយតែ "	៤ "	២១—	" ជន្លឹ "	១ "
៥—	" ប្រឡូវវង្ស "	៦ "	២២—	" រកាកោងក្នុង "	១ "
៦—	" ទួលមណីភម "	៤ "	២៣—	" ព្រៃកស្តី "	២ "
៧—	" កែវព្រែភ្លើង "	១៨ "	២៤—	" ចាក់អង្រែលើ "	១ "
៨—	" មហាមន្ត្តី "	២០ "	២៥—	" ព្រាង្គ កំពង់ស្តី	៥ "
៩—	" សំពៅមាស "	៩ "	២៦—	" ម្រ៉ី "	២ "
១០—	" ពិភទ្ធវង្សី "	២ "	២៧—	" ទន្លេយាទី ពាកែវ	១ "
១១—	" ស្រែបក "	១ "	២៨—	" អង្គមេត្រី "	៤ "
១២—	" ព្រះពុទ្ធមានបុណ្យ "	១២ "	២៩—	" វត្តែកប្លោស "	៩ "
១៣—	" ពោធិ៍ព្រឹក្ស ពណ្តាល	៤ "	៣០—	" ល្វា សៀមភាព	២ "
១៤—	" ស្វាកែត "	២ "	៣១—	" បុព្វទិសារាម "	២ "
១៥—	" មហាវេត្តវន "	១ "	៣២—	" សម្បូរមោស កំពង់ឆ្នាំង	១ "
១៦—	" តតីធំ "	៩ "	៣៣—	" ចាយ៉ាប ស្វាយរៀង	៣ "
១៧—	" ពោធបញ្ញាន់ "	១ "	៣៤—	" ព្រៃត្នាក់ "	១ "

កាលដែលក្រុមជំនុំបានពិនិត្យក្រែងអ្នកប្រឡងពាំងអម្បាលនេះ ឃើញមកអង្គុយគ្រប់ល្អែងកន្លែងពាំង ៤ ថ្នាក់ន័ងសាលារដ្ឋបាលសព្វគ្រប់ហើយ ទើបលោកអ្នកឧកញ៉ាអគ្គមហាសេនា យកគួរប្រយោគទី ១ សរសេរតាមសូត្រជាសេចក្តីតែងអំពីរឿងផ្សេង។ ដែលបានរើសសម្រាំងពុកតាំងពីថ្ងៃមុនមកបិទជាក់ក្នុងស្រោមសំបុត្របិទកាកល់ក្តី ចោះត្រាសង្កត់ព័ស៌ លើកឡើងបង្ហាញទៅមុខអ្នកប្រឡងសព្វគ្រប់ឲ្យដឹងថាជារបស់សុចរិតត្រឹមត្រូវដោយផ្លូវដ៏បរិសុទ្ធ ឥតមានចេតនាក្លែងក្លាយឡើយ ហើយយកកន្ត្រៃចៀរស្រោមសំបុត្រ ដែលបិទគួរប្រយោគសរសេរនោះ យកគួរប្រយោគពាំង ៨ មុខមកបត់ជាផ្នត់គួច។ ហើយដាក់ទៅក្នុងរង្វង់មួកលើកគ្រលុកចុះឡើង។ ទើបហៅអ្នកប្រឡង ១ រូប ឲ្យចូលមកចាប់គួរប្រយោគនោះ ផ្សងតាមព្រែងសំណាងរបស់ខ្លួន ចាប់បានប្រយោគណា ដែលមានសេចក្តីតែងរឿងអំពីវត្តអ្វី ក៏យកសេចក្តីរឿងនោះ មកឲ្យក្រុមមេប្រយោគជួយចម្លងសេចក្តីផ្សឹងផ្ទាត់ត្រឹមត្រូវតាមច្បាប់ដើមហើយ ក៏ចែកឲ្យមេប្រយោគកាន់យកសេចក្តីរឿងនោះទៅសូត្រ ឲ្យអ្នកប្រឡងសរសេរតាមសូត្រ គ្រប់ថ្នាក់គ្រប់កន្លែងពាំងនោះ; ក្នុងប្រយោគនីមួយៗមានវិធីធ្វើតទៅទៀតតាមរបៀបយ៉ែបនេះ ដាក់ជកបទាល់តែចប់គួរប្រយោគពាំង ៤ មុខ។

មុនដែលមេប្រយោគនឹងសូត្រសេចក្តីតែងរឿងប្រឡងនោះ ឲ្យអ្នកប្រឡងសរសេរតាមសូត្រ គឺបានសូត្រឲ្យស្តាប់ ១ ចប់គ្រប់ថ្នាក់ចាំងអស់សិន រួចហើយទើបសូត្រសម្រែចផ្តាច់ពេលតែម្តង តាំងពីវេលាព្រឹកម៉ោង ៩ ដល់ម៉ោង ១១ ទើបហើយស្រែចប្រយោគសរសេរតាមសូត្រ; វេលារសៀលពីម៉ោង ២ កន្លះដល់ម៉ោង ៦ ឲ្យប្រែបាលីលោកប្រយោគដែលស្រង់មកអំពីគម្ពីរព្រះធម្មបទដ្ឋកថា ។

ថ្ងៃអង្គារ ១៦ ហ្វេវ្រីយេរ, វេលាព្រឹកពីម៉ោង ៩ ដល់ម៉ោង ១១ ឲ្យអធិប្បាយគាថាដែលស្រង់មកអំពីគម្ពីរព្រះធម្មបទដ្ឋកថា; វេលារសៀលពីម៉ោង ២ កន្លះដល់ម៉ោង ៦ ឲ្យតែងរឿងជាគកក្នុងគម្ពីរព្រះធម្មបទដ្ឋកថា ។

កិច្ចដែលអ្នកប្រឡងប្រយោគសរសេរនៃមួយ ។ ចាំង ៤ មុខនេះចប់ស្រែចហើយ ក្រុមមេប្រយោគក៏បានប្រមូលសន្ទឹកក្រដាសសរសេរប្រឡងអំពីអ្នកប្រឡងនោះ ។ ពល់ ។ ថ្ងៃ ជូនទៅលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ហែកយកកក្សាលសន្ទឹកដែលអ្នកប្រឡងសរសេរឈ្មោះទីលំនៅរបស់ខ្លួននោះ ។ ចេញ ហើយក៏ឲ្យសន្ទឹកក្រដាសដែលសរសេរតែប្រយោគនោះ ។ មកវិញ ឲ្យមេប្រយោគពិនិត្យឲ្យពិន្ទុតាមចំណេះវិជ្ជាដែលអ្នកប្រឡងចេះដឹង ដោយត្រឹមត្រូវគ្រប់សន្ទឹកចាំងអស់, រួចហើយទើបយកកក្សាលសន្ទឹកក្រដាសដែលហែកចេញនោះ មកប្រជុំមេប្រយោគចាប់ផ្តើមកត្តាប់ទីឯសន្ទឹកក្រដាសដែលបានពិនិត្យរួចស្រែចគួ

ប្រយោគនីមួយៗ ហើយក៏ចាប់ផ្តើមប្រយោគស្រង់ពីខ្ទុំអំពីតួប្រយោគនីមួយៗ ចុះក្នុងបញ្ជីហើយបូកបញ្ចូលមេសម្រេចឲ្យដឹងថា អ្នកឆ្លងឈ្មោះណាដែលបានពីខ្ទុមួយមុខប៉ុន្មានៗ រួចរួមសម្រេចទៅឃើញឈ្មោះអ្នកឆ្លងជាប់ប្រយោគសរសេរចំនួន ១២២ រូប ដែលបានពីខ្ទុ ពី ១១០ ទៅ ១៧ ត្រូវបើកឧទាសឲ្យចូលឆ្លងប្រយោគសួរផ្តាល់មាត់តទៅទៀត ។

មុននឹងសួរប្រយោគផ្តាល់មាត់នោះ ពួកអ្នកឆ្លងជាប់ប្រយោគសរសេរចំនួន ១៦២ រូបនេះ ត្រូវផ្តិតទៅមាមដៃនឹងក្រដាស ១ សន្លឹក ចំនួនប្រវែង ១ តឹក ទុកជាសញ្ញាគ្រឿងសំគាល់តទៅមុខ ដើម្បីពិនិត្យសួរប្រយោគផ្តាល់មាត់កុំឲ្យគាត់ឆ្លងរួបអ្នកឆ្លងដែលមានគំនិតអាក្រក់ ។

ថ្ងៃពុធ-ព្រហស្បត៍-សុក្រ ២៤-២៥-២៦ ហ្វេវ្រីយេ, វេលាត្រឹក ព័រម៉ោង ៨ ដល់ម៉ោង ១១; វេលារសៀលពីម៉ោង ២ កន្លះដល់ម៉ោង ៦ ត្រង់ទាំង ៣ ថ្ងៃ ក្រុមមេប្រយោគពិនិត្យតួប្រយោគសួរផ្តាល់មាត់ដូចមានការយកដាក់ត្រាយនេះ :

១.- សួរមូលវេយ្យាករណ៍

២.- សួរឆ្នុះឬប្បវត្តិ

៣.- សួរវិន័យ

៤.- សួររឿងសាសនាព្រះពុទ្ធ ។

លុះសម្រេចតំបូរនេះហើយ ក្រុមមេប្រយោគប្រមូលយកពន្ធុប្រយោគសួរផ្ទាល់មាត់រៀងខ្លួនមកស្រង់ចុះក្នុងបញ្ជី ទើបបូកបញ្ចូលពន្ធុប្រយោគសរសេរនឹងប្រយោគសួរផ្ទាល់មាត់ផ្គាប់ចំសម្រេចឃើញថា អ្នកប្រឡងចាំង ១២២ រូបនោះ ឈ្មោះណាដែលប្រឡងបានពិន្ទុចន្លោះជាង ១៨០ ឡើងទៅ គ្រូវបានជាប់ជាសិស្សរៀនក្នុងសាលាបាលីជាន់ខ្ពស់ សម្រេចតាមប្រកាសលេខ ៦ ចុះថ្ងៃ ១៣ ឃុំធីរៈយោធ្នាំ ១៨៤៣ យកតែត្រឹម ៣៥ រូប គ្រូវចុកជាបានការក្នុងការដែលប្រឡងដណ្តើមយកទីជាសិស្សថ្មី គ្រូវចូលរៀនក្នុងសាលាបាលីជាន់ខ្ពស់ឆ្នាំ ១៨៤៣ នេះតទៅតាមបញ្ញត្តិត្រង់ប្រការ ១៤ ទំនឹង ១៥ នៃអាវ៉ែរតេលោកគ្រូវ៉ែរណើរហ្ស៊ូណោ-ក៉ាល់លេខ ៨៧៥១ ចុះថ្ងៃ ១ ដេសមប្រ៊ ១៨៤២ ។

ឯអ្នកប្រឡងចំនួន ៣៥ រូបដែលបានពិន្ទុពីត្រឹម ២៤២ ឡើងទៅដូចបានពយឈ្មោះនឹងវត្តតាមលំដាប់តទៅនេះ :

១-	កិ. ប៊ុន-សម្ភាជ	វត្ត	ខ្ណាលោម	ពិន្ទុ ៣០៤
២-	" អន-សារ៉ែយ	"	បទុមវតី	" ២៨៨
៣-	សា. មួង-ណុប	"	ខ្ណាលោម	" ២៧៨
៤-	" ផាម.លាង់ហា	"	"	" ២៧៤
៥-	" តាត់-ញ៉ិម	"	"	" ២៦៦
៦-	" ឡុង-ឱ្យ	"	លង្កា	" ២៦៦

ស៊ើតា

៧- សា. មៅ-ខាន់	វត្ត	ស្វាយពពែ	ពន្ធុសម្រែច	២៦៣	ស្មើគ្នា
៨- " នន់-ឆួក	"	ខ្នុនមណ្ឌិត	"	២៦៣	
៩- " នៅ-ជុន	"	ខ្ណាលោម	"	២៦១	ស្មើគ្នា
១០- " ជិន-កួង	"	"	"	២៦១	
១១- កំ. គង់-ស៊ុន	"	"	"	២៦១	
១២- " ខ្សែន-ឡាង	"	"	"	២៥៨	
១៣- " អួន-លី	"	បឹមរតី	"	២៥៨	
១៤- សា. ពុត-ផេង	"	ខ្ណាលោម	"	២៥៦	ស្មើគ្នា
១៥- កំ. អ៊ុង-ញឹម	"	ស្វាយពពែ	"	២៥៦	
១៦- " អួង-សុន	"	ខ្ណាលោម	"	២៥៥	ស្មើគ្នា
១៧- " ហ៊ាង-ខាត់	"	ស្វាយពពែ	"	២៥៥	
១៨- " អ៊ុន-តែម	"	លង្កា	"	២៥៤	
១៩- សា. ឃុត-ស៊ឹម	"	"	"	២៥៣	
២០- " រស់-ឡុង	"	ខ្ណាលោម	"	២៥២	ស្មើគ្នា
២១- " ថាប់-អួម	"	លង្កា	"	២៥២	
២២- " សំ-ជាម	"	ខ្ណាលោម	"	២៥១	
២៣- កំ. ប្រាក់-ភ័យ	"	"	"	២៤៧	

២៤-សា. កែ-លី	វត្ត ស្វាយពពែ	ពិន្ទុសម្រែច	២៤៦	ស៊ីគ្នា
២៥- " ថាច់-សឿង	" ទណ្ណាសោម	"	២៤៦	ស៊ីគ្នា
២៦-កំ. ចាប-ប៊ិន	" បទុមវតី	"	២៤៥	
២៧-សា. គួ-មេ	" ទួលមណីពាម	"	២៤៤	ស៊ីគ្នា
២៨-កំ. យស-យូរ	" បទុមវតី	"	២៤៤	ស៊ីគ្នា
២៩-សា. ញឹក-សុន	" ទណ្ណាសោម	"	២៤៤	ស៊ីគ្នា
៣០-កំ. យក់-ខ្លៅ	" "	"	២៤៤	ស៊ីគ្នា
៣១-សា. អ៊ូច-ឯក	" កែវព្រៃកក្តើង	"	២៤៣	
៣២-កំ. កឹម-ឆុក	" តោធិព្រឹក្ស	"	២៤២	ស៊ីគ្នា
៣៣- " វែម-សុន	" ទណ្ណាសោម	"	២៤២	ស៊ីគ្នា
៣៤-សា. ហៅ-ឆុច	" "	"	២៤២	ស៊ីគ្នា
៣៥-កំ. កឹម-សុខ	" "	"	២៤២	ស៊ីគ្នា

លុះដល់ថ្ងៃសៅរ៍ ២៧ ហ្មៃ ត្រីយោ វេលាព្រឹកមោង ៨ កន្លះ ពួកអ្នកប្រឡងជាប់ទាំងនេះ ក៏បានមកជួបជុំគ្នានៅរោងថែវនៃសាលាចាស់ជាន់ខ្ពស់ឈរចម្រុះធំចាំស្តាប់ក្រុមមេប្រយោគ, មានលោកអ្នកឧកញ៉ាអគ្គមហាសេនាជាអធិបតី កាន់បញ្ជីដែលបានចម្លងស្រង់ឈ្មោះរៀបរៀងតាមលំដាប់លេខសិស្សដែលប្រឡងជាប់ ចុះផ្ទៀងចំពោះមុខពួកសិស្សថ្មីទាំងនោះ ស្រួតហៅឈ្មោះតាមលំដាប់លេខជាត្រឿងសំគាល់ឲ្យដឹង

គ្រប់ៗគ្នា រួចហើយក៏លោកមានប្រសាសន៍ឲ្យពរសព្វសាធុការថា "ខ្ញុំព្រះករុណាមានសេចក្តីត្រេកអរនឹងអស់លោក ដែលប្រឡងជាប់នេះណាស់ ទំមន្តខំប្រឹងរៀបប្រឹងរៀនសូត្រឲ្យមែនទែន កុំធ្វេសប្រហែសឡើយ, សូមឲ្យបានប្រកបដោយសេចក្តីសុះចំរើនគ្រប់ប្រការ!" ។

ចំណែក- សិស្សដែលទើបប្រឡងជាប់ថ្មីៗ បានដឹងថាខ្លួនជាប់ជាសិស្សសាលាបាលីជាន់ខ្ពស់ហើយ ក៏មានសេចក្តីត្រេកអរសោមនស្សរីករាយខ្លាំងណាស់ ដោយអំណាចដែលខំប្រឹងប្រឡងយកបានជាកូនសិស្សបានដូចបំណងរបស់ខ្លួនពេញទី ហើយក៏ចំរើនពរលា, ថ្វាយបង្គំលាលោកគ្រូមេប្រយោគវិលត្រឡប់ទៅកាន់អាស្រមរបស់ខ្លួនវិញទៅ ។

នេះហើយ! ដែលហៅថា "ធ្វើសេចក្តីខ្នុកខ្នាន ដោយអំណាចនៃសេចក្តីព្យាយាម" ។

អំពីប្រឡងសិស្សចេញពីសាលាបាលីជាន់ខ្ពស់

ក្រុងភ្នំពេញ

កាលពីថ្ងៃអង្គារ ១៧ រោច ខែបុស្ស ឆ្នាំមមីចត្វាស័ក ត្រូវនឹងថ្ងៃ ៦ ហ្វេវ្រីយេរ ឆ្នាំ ១៩៤៣ វេលាព្រឹកម៉ោង ៧ កន្លះ កូនសិស្សចំនួន ៣១ រូប ថ្នាក់ឆ្នាំទី ៤ នៃសាលាបាលីជាន់ខ្ពស់ ដែលបានរៀនតាមសេចក្តីអនុញ្ញាតពីក្រសួងកំណត់ឆ្នាំជាគម្រប់ ៤ ហើយត្រូវប្រឡងចេញពីសាលាបាលី យកសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ (Diplôme) ក៏បាន

ទៅជួបជុំគ្នានៅមន្ទីរសាលាចាស់ជាន់ខ្ពស់ ហើយចូលទៅអង្គុយកន្លែងកន្លែងដែលជាប់ផ្ទាំងទី ១ និងទី ២ តាមលំដាប់ស្មាតែលបានសរសេរឈ្មោះនឹងលេខរៀងបន្ទាប់មកគ្រូបង្រៀនសំគាល់ឈ្មោះអ្នកប្រឡង រំដាំលោកជាមេប្រយោគយកតួប្រយោគណាមួយ មកឲ្យធ្វើការប្រឡងក្នុងពេលនោះ ។

លុះដល់វេលាម៉ោង ៨ ក្រុមសន្និបាតកុម្មិស្យុង បានអញ្ជើញនឹងនិមន្តមកជួបជុំធ្វើសេចក្តីដំនុំនៅមន្ទីរសាលាចាស់ជាន់ខ្ពស់ ចំពោះមុខកូនសិស្ស ដើម្បីនឹងពិនិត្យការប្រឡងនេះ:

មានលោកអ្នកឧកញ៉ាអគ្គមហាសេនា អ៊ឹង-អ៊ី, សេនាបតីក្រសួងព្រះបរមរាជវាំងព្រះឃ្លាំង ទំនងធម្មការ ជាអធិបតី នៃក្រុមជំនុំ ។

លោកឌុយប៉ុងត៍, អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ជំនួសឲ្យលោកចាងហ្វាងសាលាចាក់ឯកសែស នៅចុងបូព៌ាប្រទេស ក្រុងហាណូយ ។

លោកឡឺដេលេត (សាលីរេ) ឌុយប្លូតិកគូប៉ត៍នៅអមរាជការវៀរ ។

ព្រះគេជព្រះគុណ ព្រះពុទ្ធឃោសាចារ្យ ជួនណាត ចាងហ្វាងសាលាចាស់ជាន់ខ្ពស់ ។

១— ព្រះគេជព្រះគុណ ព្រះអមរកិរ្តិ ជុំ ដំណាងព្រះសង្ឃនាយកគណៈធម្មយុត្តិ

ព្រះតេជព្រះគុណ ព្រះអរិយធម្មមុនីប៉ុល, ជំណាងសម្តេចព្រះសង្ឃ-
នាយកគណៈមហានិកាយ

២- ព្រះតេជព្រះគុណ ព្រះមហា ពហ្មមុនី ទេព-អ៊ូ, ចាងហ្វាងវត
សាលាចាលីជាន់ខ្ពស់

៣- ព្រះតេជព្រះគុណ ព្រះសាក្យវង្ស ហួត-តាត, គ្រូបង្រៀនសំស្ក្រឹត
- - ព្រះគ្រូឧត្តមមុនី ម៉ឹង - វែស, ក្រុមជំនុំព្រះវិនៃបិដក
- - ព្រះមហា សោម - ឡូច, ក្រុមជំនុំព្រះវិនៃបិដក
ព្រះអាចារ្យ ប៉ែន-សុខ, គ្រូបង្រៀនសាលាចាលីជាន់ខ្ពស់
ព្រះគ្រូ សុមេធមុនី បិតសីលោ, គ្រូបង្រៀនសាលាចាលីជាន់ខ្ពស់
ព្រះគ្រូ គោធិវង្សាចរិយា ពឹទ្ធ កង - កឹង, គ្រូបង្រៀនសាលាចាលី
ជាន់ខ្ពស់
ព្រះអាចារ្យ ឈឹម - សុម, គ្រូបង្រៀនសាលាចាលីជាន់ខ្ពស់
អ្នកអាចារ្យ អ៊ុច - រស់, គ្រូបង្រៀនសាលាចាលីជាន់ខ្ពស់
ព្រះអាចារ្យ គៅ - សឹម, ស្មៀនសាលាចាលីជាន់ខ្ពស់

ជាអ្នកដំនុំដែលមានអវត្តមាន លោកឡើងស៊ីដង្គ័សុប៊ើរយើរ លេខ
១៣៤ ចុះថ្ងៃ១៤ ឃ្លាំងរំយោរ ឆ្នាំ ១៩៤៣ បែកទុកាសឲ្យពិន័ត្យចំណេះ
ដឹង ឈ្មោះសិស្សដែលប្រឡងចេញចំនួន ៣១ រូប ដែលបានកាយខាង
ក្រោយនេះ:

១ ស្វាយ-យន់	១២ ឈូត-ឆន	២២ ដាំង-ម៉ុច
២ ខន់-សែម	១៣ ហែន់-ឡឹក	២៣ ឯម-ន័ម
៣ លាន-កេង	១៤ សុខ-យ៉ែម	២៤ គល់-រ័ម
៤ អ័ង-ឈួន	១៥ គង់-ម៉ាលី	២៥ នន់-យង់
៥ សេង-ថាត់	១៦ ជា-ប៊ូ	២៦ ម៉ប់-កន
៦ អួក-នង	១៧ សួន-ឡាំង	២៧ ម៉ុក-ជា
៧ ច័ន-ស៊ុន	១៨ ក៉ន់-សិម	២៨ ឌួច-ប៊ុត
៨ ត្រែក-ស៊ាន	១៩ ហុង-ហួន(ភាន	២៩ រស់-ខុំ
៩ ច័ន-ឃាម	ប្រឡងត្រែះឈឺធ្ងន់)	៣០ ឌីង-ម៉ុច
១០ នៅ-លឹម	២០ តឹម-សុន	៣១ កុយ-វ៉ៃ
១១ សួស-គួ	២១ យឹន-ឈុត	

ត្រួមដំនុំបានពិនិត្យត្រួតសិស្សពាំងអម្បាលនេះ យើញមកគ្រប់ចំនួនហើយ ទើបលោកអ្នកឧកញ៉ាអគ្គមហាសេនា យកគួរប្រយោគទី ១ ប្រែតាសាចាលីជាភាសាខ្មែរ ដែលបានរៀសសម្រាំងខុកតាំងពីថ្ងៃមុនជាក់ក្តីនេះស្រាមសំបុត្រចិទភាកល់ក្តដិតចោះត្រាសង្កត់ព័លើ លើកឡើងបង្ហាញទៅមុខសិស្សសព្វគ្រប់ឲ្យដឹងថាជារបស់សុចរិតត្រឹមត្រូវ ដោយឆ្លងដ៏បរិសុទ្ធឥតមានក្លែងក្លាយឡើយ រួចហើយក៏យកតង្កៀបរៀបស្រាមសំបុត្រចិទគួរប្រយោគខាង យកគួរប្រយោគខាំង ៨ មកបន្តជាផ្នត់គួចៗ

ហើយដាក់ទៅក្នុងវង្វង់មួក លើកគ្រលុកចុះខ្សឹបៗ ទើបហៅកូនសិស្ស ១រូបឲ្យចូលមកចាប់គួរប្រយោគនោះ ផ្សងតាមត្រង់សំណាងរបស់ខ្លួន ចាប់បានគួរប្រយោគណា ក៏យកប្រយោគនោះមកសរសេរទំនិញក្តារតាំងបញ្ជូរទៅចំមុខសិស្ស ឲ្យធ្វើតាមចំណេះវិជ្ជាដែលខ្លួនរៀនចេះចាំមកចំនួន ២ ម៉ោងកន្លះទើបហើយប្រែភាសាចប់, ដល់ថ្ងៃរសៀលវេលាម៉ោង ១៥ លោកអ្នកឧកញ៉ាអគ្គមហាសេនា យកប្រយោគទី ២ ប្រែភាសាសំស្ក្រឹតជាភាសាខ្មែរមកឲ្យធ្វើ មានវិធីធ្វើរបៀបដូចកន្លងមកពីព្រលឹកនោះដែរ តែមានខ្លះតែបន្តិចបន្តួចទេ ។

ថ្ងៃពុធ ៣ ហ្វេវ្រិយេរ, វេលាព្រឹកម៉ោង ៨ ដល់ម៉ោង ១១ ឲ្យប្រែភាសាខ្មែរជាភាសាចាក់ដែសស, វេលារសៀលម៉ោង ១៥ ដល់ ១៧ ឲ្យអធិប្បាយសេចក្តីព្រះអភិធម្ម ។

ថ្ងៃព្រហស្បតិ៍ ៤ ហ្វេវ្រិយេរ, វេលាព្រឹកម៉ោង ៨ ដល់ម៉ោង ១១ ឲ្យអធិប្បាយសេចក្តីព្រះវិន័យ, វេលារសៀលម៉ោង ១៥ ដល់ម៉ោង ១៧ ឲ្យតែងសេចក្តីរឿងបឋមសម្ពោធិ ។

ក៏កិច្ចដែលសិស្សប្រឡងប្រយោគសរសេរតាំង ៦ មុខនេះចប់ស្រេចហើយ ក្រុមមេប្រយោគក៏ចាប់ផ្តើមសន្ទុះគ្រដាសសរសេរប្រឡងអំពីសិស្សតាំងនោះ ជូនទៅលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ

ហែកយកក្បាលសន្ធឹកត្រជាសដែលសិស្សសរសេរឈ្មោះ ទឹងខ្លាំងនៅ
លើសន្ធូរនោះ។ ចេញ ពុកនៅខ្លាំងប៉ុយរួបរស់លោក ហើយក៏ឲ្យ
សន្ធឹកត្រជាសដែលសរសេរតួប្រយោគ ប្រឡងចាំងនោះមកឲ្យមេប្រ-
យោគពិនិត្យឲ្យពិន្ទុតាមចំណេះវិជ្ជា ។ ដែលសិស្សចេះដឹងដោយត្រឹមត្រូវ
គប់សន្ធឹកចាំងអស់ រួចហើយទើបយកក្បាលសន្ធឹកត្រជាសដែលហែក
ចេញនោះ មកសិកក្លាប់ទឹងសន្ធឹកត្រជាសដែលបានពិនិត្យរួចស្រេច
តួប្រយោគប្រឡងខ្លាំងមួយ។ ហើយបានប្រជុំមេប្រយោគ ខានលោកអ្នក
ទេសាភិបាលមហាសេនា ជាអធិបតីស្រង់ពិន្ទុចុះតុដាប្រាប់ប្អូនប្រុសមេប
ឲ្យដឹងថា សិស្សណាបានពិន្ទុតាងមួយមុខប៉ុន្មាន។ ទើបត្រួតមេប្រយោគ
ចាំងនោះ ពិនិត្យប្រយោគសួរដាល់មាត់តទៅទៀត គឺឲ្យសិស្សមើល
ចាស់ អក្សរសៀម - ឡាតាំង ហើយឲ្យអធិប្បាយសេចក្តីជាភាសាខ្មែរ,
មើលសំស្តឹតជាអក្សរសៀម - ឡាតាំង ហើយឲ្យអធិប្បាយសេចក្តីជា
ភាសាខ្មែរ សួរឿងសាសនា ឧទាហរណ៍ពីបុរាណកថាក្នុងស្រុកខ្មែរ,
សួរអំពីរឿងពុទ្ធប្បញ្ញត្តិ, សួរពង្សាវតារឿងសាសនាព្រះពុទ្ធ, សួរអក្សរ-
សាស្ត្រខ្មែរ, សួរអំពីវិត្រកូមិ ទ្វីបអាស៊ីប៉ែកខាងកើត ទឹងប្រទេស
ឥណ្ឌាស៊ីនខាំងមួល និយាយភាសាជាកំងវែងរួចហើយក៏ប្រមូលយក
ពិន្ទុប្រយោគសួរដាល់មាត់នោះ មកស្រង់ចុះបញ្ជីទើបបូកប្រមូលពិន្ទុតួ

ប្រយោគសរសេរ ខ្ញុំឯងប្រយោគសួរផ្ទាល់មាត់ផ្តាច់សម្រេចយើញថា សិស្សចាំង ៣០ រូបនេះ ដែលប្រឡងបានពិន្ទុច្រើនជាង ២៩០ ឡើង ៧ ត្រូវខុកជាបានការក្នុងការប្រឡងចេញផ្តាច់ឆ្នាំជាគម្រប់ ៤ ត្រូវមានអំណាចបានសញ្ញាប័ត្រសាលាចាស់ជាន់ខ្ពស់ តាមបញ្ញត្តិក្នុងការគ្រងំប្រការ ២៤ នៃព្រះរាជប្រកាស ។

លុះដល់ថ្ងៃអង្គារ ៩ ហ្វ្រីយេរ, វេលាព្រឹកម៉ោង ៨ កន្លះ ពួកសិស្សដែលប្រឡងជាប់ចាំងនេះ ក៏បានមកជួបជុំនៅពេងថែវនៃសាលាចាស់ជាន់ខ្ពស់ ឈរចម្រុះរង់ចាំស្តាប់ក្រុមមេប្រយោគ មានលោកអ្នកឧកញ៉ាអគ្គមហាសេនា ជាអធិបតី កាន់បញ្ជីដែលបានកត់ស្រង់ឈ្មោះរៀងតាមលំដាប់លេខសិស្សដែលប្រឡងជាប់ចុះទៅឈរចំពោះមុខកូនសិស្សចាំងនោះសួគ្រហៅឈ្មោះតាមលំដាប់លេខជាគ្រឿងសញ្ញាឲ្យសិស្សដឹងគ្រប់ៗគ្នា រួចហើយក៏មានប្រសាសន៍ឲ្យពារសព្វសាធុការចំរើនដោយសិរីសួស្តីគ្រប់ៗ ព្រះអង្គដោយសេចក្តីសោមនស្សរីករាយជាកំរៃគាត, ចំណែកសិស្សចាំងនោះក៏មានទឹកមុខស្រស់ប្រឈ្យសប្បាយចិត្តគ្រប់ៗគ្នា ហើយក៏ចំរើនពរលោ-ថ្វាយបង្គំលោកក្រុមមេប្រយោគវិលត្រឡប់ទៅកាន់ភាពរៀងខ្លួនវិញទៅ ។